ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



◆ ការតាំងពិព័រណ៍របស់កម្ពុជានៅសារមន្ទីរ ហូឡូខសត៍

◆ កេរ្តិ៍ឈ្មោះអង្គការសហប្រជាជាតិជុំវិញបញ្ហានៅសាលាក្តីខ្មែរក្រហម

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១៨៥ ខែឧសភា ឆ្នាំ២០១៥

ស្វែងរកការពិត

លេខ១៨៥ ខែឧសភា ឆ្នាំ២០១៥

# ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា

◆ ការតាំងពិព័រណ៍របស់កម្ពុជានៅសារមន្ទីរហូឡូខសត៍ ..............................១

**ផ្នែកឯកសារ**

◆ ចម្លើយសារភាព ហែម មិ លេខាស្រុកភ្នំសំពៅ ..............................៤

◆ យកចិត្តទុកដាក់ បំពាក់បំប៉នបន្ថែមអំពីសីលធម៌ ..............................៩

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ គណៈស្រុកព្រះនេត្រព្រះ "ទុកជីវិតដើម្បីបម្រើ ..............................១៦

◆ រកឃើញឯកសារ តែនៅតែមិនអស់ចម្ងល់ ..............................១៩

◆ សង្គ្រាមបំផ្លាញការសិក្សារបស់ខ្ញុំ ..............................២២

◆ ចាប់ពីរបបខ្មែរក្រហមដល់ឧប្បត្តិហេតុ ហាំបាលី ..............................២៤

**ផ្នែកច្បាប់**

◆ កេរ្តិ៍ឈ្មោះអង្គការសហប្រជាជាតិជុំវិញបញ្ហានៅសាលាក្តី ..................៣៥

**វេទិកាពិភាក្សាសាធារណៈ**

◆ ប្រទេសកម្ពុជា ៖ ប្រវត្តិនៃអំពើហិង្សា ..............................៣៩

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ មានទោសព្រោះអ្វី? ..............................៤២

◆ ដំណើរភៀសខ្លួនឆ្លងដែនពីរបប ..............................៥០

◆ ដំណើរជីវិតឪពុកខ្ញុំចាប់ពីថ្ងៃទី១៧ ខែមេសា ..............................៥៨





ការសម្តែងសិល្បៈ នៅសារមន្ទីរប្រល័យពូជសាសន៍បឹងជើងឯក ក្នុងពិធីរំឭកខួបនៃការចងចាំ ថ្ងៃទី២០ ខែឧសភា

**សសរក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ពម.៩៩
ចុះថ្ងៃទី២ ខែសីហាឆ្នាំ១៩៩៩

រូបថតឯកសារៈមជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្មេរលេខនេះ ៖** សូ ហ្វារីណា, វេង សៀងហៃ, អេង កុកថាយ, ចន ឆរឆីអារី, សើបាស៊ីន ស្រ្តេងចូ, ជិន ដួងចន្ទ្រាកែវលក្ខីនារីរតន៍, ដូ សូភា, ដា សីហា, **អ្នកនិពន្ធនិងស្រាវជ្រាវ ៖** ទាវ សារៈមុនិន្ទ **អ្នកបកប្រែ ៖** សាយ សូលីដា និង សុភ័ក្ត្រ ភាណា **និពន្ធនាយកទូទៅ ៖** ឆាំង យុ **ជំនួយការនិពន្ធនាយក ៖** សោម ប៊ុនថន **ក្រាហ្វិកកុំព្យូទ័រ ៖** សោម ប៊ុនថន **គ្រប់គ្រងការចែកផ្សាយ ៖** ឆេង វើង និង សន ល័ក្ក Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org, www.truthcambodia.com

# ការតាំងពិព័រណ៍របស់កម្ពុជានៅសារមន្ទីរ ហូឡូខសត៍ ទីក្រុងវ៉ាស៊ីនតោនឌី.ស៊ី សហរដ្ឋអាមេរិក

នេះជាកិត្តិយសមួយសម្រាប់ការបើកសម្ពោធជាផ្លូវការនៃពិព័រណ៍កម្ពុជានៅសារមន្ទីរហូឡូខសត៍ សហរដ្ឋអាមេរិក ។ តាំងនាមឲ្យលោក ឆាំង យុ នាយកនៃមជ្ឈមណ្ឌលឯកសារកម្ពុជា មិត្តរួមការងាររបស់នាងខ្ញុំនៅមជ្ឈមណ្ឌលឯកសារកម្ពុជា អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងក្រុមគ្រួសាររបស់អ្នកទាំងនេះ នាងខ្ញុំសូមសម្តែងនូវអំណរគុណចំពោះការរៀបចំ និងការតាំងបង្ហាញនូវពិព័រណ៍នេះ ។

រឿងរ៉ាវដែលត្រូវបានបង្ហាញនៅទីនេះ គឺអាចមើលឃើញតាមរយៈរូបភាព និងតាមការស្តាប់ឧបករណ៍បំពងសំឡេង ដែលសុទ្ធសឹងជាសំឡេងផ្ទាល់របស់អ្នករស់រានមានជីវិតដែលរំឭកឡើងវិញពីការបាត់បង់អ្នកជាទីស្រលាញ់ ជាមួយរឿងរ៉ាវឈឺចាប់ ហើយក៏ជាវិធីសាស្ត្រដែលជនរងគ្រោះទាំងនេះប្រើប្រាស់សម្រាប់ដោះស្រាយបញ្ហាផ្លូវចិត្តផងដែរ ។ ទោះបីជាការដាក់តាំងបង្ហាញនេះអាចត្រឹមតែតំណាងឲ្យមួយភាគតូចនៃជនរងគ្រោះដែលរស់រានមានជីវិត និងបាត់បង់ជីវិតក្នុងរបបខ្មែរក្រហមក្តី ក៏ការតាំងពិព័រណ៍នេះបានបង្ហាញឲ្យយើងឃើញយ៉ាងជាក់ច្បាស់នូវបទពិសោធដែលនឹកស្មានមិនដល់ សម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ។ រឿងរ៉ាវរបស់អ្នកទាំងនេះ ក៏តំណាងឲ្យអ្នកដទៃទៀត ដោយរួមបញ្ចូលទាំងឪពុកម្តាយរបស់នាងខ្ញុំដែរ ។

***តើមូលហេតុអ្វីបានជារឿងរ៉ាវរបស់អ្នកទាំងនេះ ជាប់ទាក់ទងជាមួយយើងរាល់គ្នានៅពេលបច្ចុប្បន្ន?***

អំពើដ៏ឃោរឃៅរបស់ខ្មែរក្រហម ជាការបំពានសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរក្នុងប្រវត្តិសាស្ត្រនៃមនុស្សជាតិ ជាបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ និងការបំពានដ៏ធ្ងន់ធ្ងរលើសន្ធិសញ្ញាទីក្រុងវៀន ។ អំពើដ៏ព្រៃផ្សៃ ដែលបានកកើតឡើងនៅអំឡុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ នេះ បានកើតមានឡើងត្រឹមប៉ុន្មានទសវត្សរ៍បន្ទាប់ពីហូឡូខសត៍ប៉ុណ្ណោះ ។ បន្ទាប់ពីនោះមក យើងបានទទួលរងនូវបទពិសោធនៃអំពើឃោរឃៅទ្រង់ទ្រាយធំជាច្រើនទៀតនៅជុំវិញពិភពលោក ។ តើពេលណាទើបយើងរៀនសូត្រពីប្រវត្តិសាស្ត្រ? នៅពេលខ្មែរក្រហមកាន់កាប់ទីក្រុងភ្នំពេញនាថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ មនុស្សទាំងអស់ ដោយមិនគិតអំពីជាតិសាសន៍ ជនជាតិ និងសាសនា ត្រូវបានជម្លៀសចេញពីទីក្រុងទៅកាន់ទីជនបទ ។ បំពាក់ដោយគោលនយោបាយកុម្មុយនីស្តផ្តាច់ការ និងមហិច្ឆតាដែលឃ្លាតឆ្ងាយពីការពិតក្នុងការសម្រេចឲ្យបាននូវសង្គមគ្មានវណ្ណៈ ខ្មែរក្រហមបានលុបបំបាត់ចោលនូវសេរីភាព និងសេចក្តីថ្លៃថ្នូររបស់មនុស្ស ។ មនុស្សជាច្រើនដែលមានទ្រព្យធន សមត្ថភាព មុខតំណែង និងទំនាក់ទំនងជាមួយនឹងរដ្ឋាភិបាលសង្គមចាស់ គឺជាគោលដៅនៃការសម្លាប់ ។ បុរស ស្ត្រី ក្មេង និងចាស់ត្រូវបានបង្ខំឲ្យធ្វើការងារលើសពី១០ម៉ោងក្នុងមួយថ្ងៃ ហើយអ្នកទាំងនេះទទួលបានត្រឹមតែរបបអាហារតិចតួចប៉ុណ្ណោះ ។ មនុស្សមួយភាគធំបានប្រថុយជីវិតរបស់ខ្លួនទៅលួចអាហារដើម្បីបន្តជីវិត ។




កញ្ញា សូ ហ្វារីណា ថ្លែងសុន្ទរកថាទៅកាន់ភ្ញៀវ នៅសារមន្ទីរហូឡូខសត៍ ទីក្រុងវ៉ាស៊ីនតោនឌី.ស៊ី សហរដ្ឋអាមេរិក កាលពីថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៥

ប្រជាជនកម្ពុជាត្រូវបានបង្ខំឲ្យលះបង់ចោលនូវជំនឿសាសនា និងការអប់រំរបស់ខ្លួន។ ប្រសិនបើនរណាម្នាក់ត្រូវបានរកឃើញថា បានប្រណិប័តន៍នូវពិធីសាសនា អ្នកនោះនឹងត្រូវដាក់ទោសប្រហារជីវិត។ គ្រួសារនីមួយៗត្រូវបានបង្ខំឲ្យបែកគ្នាក្នុងរយៈពេលដ៏វែង ដើម្បីចេញទៅធ្វើការនៅទីកន្លែងឆ្ងាយៗ។ ជីវិតនៅអំឡុងរបបខ្មែរក្រហមគឺជា "នរកនៅលើភពផែនដី"។

ទោះបីជាខ្មែរក្រហមមានវិធីសាស្ត្រច្រើនក្នុងការសម្លាប់ជីវិតមនុស្សក្តី ក៏ខ្មែរក្រហមនៅតែមិនអាចរារាំងប្រជាជនពីការ






ងើបឡើងតស៊ូប្រឆាំងនឹងរបបខ្លួនដែរ។ ប្រជាជនជាច្រើនធ្វើការប្រឆាំងដោយបើកចំហ (ការបះបោរដោយបើកចំហ) ឬដោយសម្ងាត់ (ការតស៊ូប្រឆាំងជារៀងរាល់ថ្ងៃ) ដើម្បីទាមទារនូវភាពថ្លៃថ្នូររបស់មនុស្ស និងការរស់រានមានជីវិត។

ចំពោះអ្នកដែលនៅរស់រានមានជីវិត នៅបន្តរស់ដោយវិប្បដិសារី ព្រោះតែមិនអាចជួយសង្គ្រោះអ្នកជាទីស្រឡាញ់របស់ខ្លួនបាន។ បន្ទាប់ពីរបបនេះបានដួលរលំទៅនៅក្នុងឆ្នាំ១៩៧៩ អ្នករស់រានមានជីវិតបានខិតខំប្រឹងប្រែងដើម្បីកសាងជីវភាពនិងសហគមន៍ ព្រមទាំងធ្វើឲ្យសាសនារបស់ខ្លួនរស់ឡើងវិញ។ ដើម្បីសម្រេចបាននូវសកម្មភាពទាំងអស់នេះ អ្នកដែលរស់រានមានជីវិតត្រូវបង្ហាញចេញនូវការប្តេជ្ញា ដោយត្រូវប្រឈមទៅនឹងភាពលំបាកលំបិនពីអតីតកាលរបស់ខ្លួន។

ដោយជំរុញឲ្យប្រទេសក្រោយជម្លោះសម្រេចបាននូវយុត្តិធម៌ និងការផ្សះផ្សា ព្រមទាំងបន្តប្រឆាំងនឹងអំពើឃោរឃៅទ្រង់ទ្រាយធំដែលមានលក្ខណៈជាសកល មជ្ឈមណ្ឌលឯកសារកម្ពុជា និងសារមន្ទីរហូឡូខសត៍ បានធ្វើកិច្ចសហប្រតិបត្តិការរួមគ្នាដើម្បីបំផុសនូវការចងចាំអំពីប្រវត្តិសាស្ត្រ ការបាត់បង់អ្នកជាទីស្រឡាញ់ និងចែករំលែករឿងរ៉ាវរបស់ជនរងគ្រោះដែលនៅរស់រានមានជីវិត និងអប់រំមនុស្សជំនាន់បច្ចុប្បន្ននូវអំពើឃោរឃៅនេះ ព្រមទាំងរារាំងរាល់អំពើឃោរឃៅដែលប្រហាក់ប្រហែលនេះពីការកើតឡើងជុំវិញខ្លួនយើង។

ការតាំងពិព័រណ៍នេះ គឺជាការចាប់ផ្តើមនៃកិច្ចខិតខំប្រឹងប្រែងរយៈពេលវែងក្នុងការចែករំលែកនូវបទពិសោធ និងមេរៀនរបស់យើងទៅកាន់អ្នកដទៃទៀតនៅជុំវិញសកលលោក ក៏ដូចជា

ការរារាំងអំពើឃោរឃៅទ្រង់ទ្រាយធំកុំឲ្យកើតឡើងសាជាថ្មី ។ ដោយសារតែមជ្ឈមណ្ឌលឯកសារកម្ពុជាបាននឹងកំពុងបំប្លែងខ្លួនទៅជាមជ្ឈមណ្ឌលអចិន្ត្រៃយ៍ ដែលមានឈ្មោះថា “វិទ្យាស្ថានស្លឹករឹត” ដែលនឹងក្លាយជាអ្នកគ្រប់គ្រងសារមន្ទីនៃការចងចាំ មជ្ឈមណ្ឌលស្រាវជ្រាវ និងអប់រំ ដូច្នេះហើយយើងសង្ឃឹមថា នឹងអាចបន្តកសាងចំណងសហប្រតិបត្តិការរបស់យើងជាមួយនឹងសារមន្ទីរ ហូឡូខស្ត៍ ដើម្បីបម្រើដល់គោលដៅរួមរបស់យើង ។

តាំងនាមឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជា នាងខ្ញុំសូមសម្តែងនូវអំណរគុណចំពោះ សារមន្ទីរហូឡូខស្ត៍ ជាពិសេសគឺលោកក្រ្គីហ្គោរី ណាវ៉ានចូ និងក្រុមការងាររបស់លោកសម្រាប់ការធ្វើឲ្យលេចឡើងជារូបរាងនូវគម្រោងពិព័រណ៍នេះ ។ សូមអរគុណចំពោះក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ នៃព្រះរាជាណាចក្រកម្ពុជា លោកជំទាវ ភឿង សកុណា និងឯកឧត្តម ហាប់ ទូច ។ អរគុណចំពោះសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ជាពិសេសលោក ឆាយ វិសុទ្ធ ។ អរគុណចំពោះអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងក្រុមគ្រួសារ ព្រមទាំងបុគ្គលិកនៃមជ្ឈមណ្ឌល




ឯកសារកម្ពុជាទាំងអស់ ដែលបានខិតខំប្រឹងប្រែងដោយមិនខ្លាចនឿយហត់ក្នុងការចងក្រងជាឯកសារ បទពិសោធរបស់អ្នករស់រានមានជីវិត និងជួយដល់អ្នកទាំងនេះ ជាមួយក្រុមគ្រួសាររបស់គេឲ្យចងចាំ និងសះស្បើយ ។

មុននឹងបញ្ចប់ នាងខ្ញុំសូមលើកឡើងនូវពាក្យពេចន៍របស់លោក ឆាំង យុ នាយកមជ្ឈ មណ្ឌលឯកសារកម្ពុជា ៖ “មិនគិតថាជាស្ថានភាពរបស់បុគ្គល ឬជារួមទេ ការផ្សះផ្សាពិតជាមានសារសំខាន់ខ្លាំងណាស់ក្នុងការរស់នៅក្នុងជីវិតមួយដែលពេញលេញ ។ យើងមិនអាចគេចចេញពីប្រវត្តិសាស្ត្ររបស់យើងទេ ។ ប៉ុន្តែ យើងក៏មិនត្រូវធ្វើជាទាសកររបស់វាដែរ” ។ លោកបន្ថែមទៀតថា ៖ “ការផ្សះផ្សាផ្តល់ឲ្យយើងនូវច្រកចេញមួយ ។ ការផ្សះផ្សាផ្តល់ឲ្យយើងនូវច្រកមួយ ដោយអាចឲ្យយើងចូលរួមចំណែកដើម្បីទទួលបានភាពជោគជ័យជារួមសម្រាប់ជាតិរបស់យើង ដោយមិនចាំបាច់លះបង់នូវការខិតខំប្រឹងប្រែងរបស់យើងម្នាក់ៗទេ” ។ ***សូមអរគុណ!***

**ស៊ូ ហ្សារីណា**

# ចម្លើយសារភាពរបស់ ហែន មិ លេខាស្រុកភ្នំសំពៅក្រៅ តំបន់៣ ភូមិភាគពាយ័ព្យ

*ដកស្រង់ចេញពីឯកសារចម្លើយសារភាព D៥៨៩៦២*

ហែន មិ ភេទប្រុស អាយុ៤៥ឆ្នាំ ជាអតីតលេខាស្រុកភ្នំសំពៅក្រៅ តំបន់៣ ។ មិ មានស្រុកកំណើត នៅភូមិបឹងក្រសាល ឃុំស្ទឹង ស្រុកភ្នំសំពៅ តំបន់៣ ។ មិ ត្រូវបានអង្គការចាប់ខ្លួននៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៧៨ ពីបទបម្រើក្នុងសកម្មភាព សេ.អ៊ី.អា ក្បត់ប្រឆាំងនឹងបដិវត្តន៍ និងបានបញ្ជូនមកគុកទួលស្លែងដើម្បីសួរចម្លើយ ។ ខាងក្រោមនេះគឺជាសេចក្តីសង្ខេបចេញពីចម្លើយសារភាពរបស់ ហែន មិ ៖

ឆ្នាំ១៩៥៣ មិ បានចូលបម្រើក្នុងចលនាខ្មែរឥស្សរៈរយៈពេលមួយឆ្នាំក្រោមការដឹកនាំរបស់តាប៉ែត តា ប៉ែត (បច្ចុប្បន្នជាគណៈភូមិភាគពាយ័ព្យ) ។ លុះដល់ចុងឆ្នាំ១៩៥៤ ឈ្មោះ អេង អតីតចៅហ្វាយស្រុកចំឡងគួយ បានអប់រំ មិ ឲ្យចូលជាសមាជិក សេ.អ៊ី.អា ហើយបានប្រគល់ភារកិច្ចឲ្យអនុវត្ត គឺកសាងកម្លាំង សេ.អ៊ី.អា ឲ្យបានច្រើន ឃោសនាអប់រំប្រជាជនឲ្យស្រឡាញ់របបលោកសេរី និងបានភ្ជាប់ខ្សែរយៈជាមួយ តាប៉ែត ដែលជាខ្សែ សេ.អ៊ី.អា របស់ ស៊ីវ ហេង ។ ក្រោយពីភ្ជាប់ខ្សែហើយ តាប៉ែត បានណែនាំ មិ ឲ្យស្គាល់ខ្សែរយៈផ្សេងទៀតមាន ឈ្មោះ ឌី ហៅ វេង អនុលេខាតំបន់១, ឈ្មោះ ឃួប ហៅ ខ្វែង ប្រធានកងពលទី១ (បច្ចុប្បន្នអង្គការចាប់ហើយ), ឈ្មោះ រំ ហៅ រ៉ែន អតីតសមាជិកតំបន់១ (បច្ចុប្បន្នអង្គការចាប់ហើយ) ដើម្បីងាយស្រួលធ្វើសកម្មភាពប្រឆាំងនឹងអង្គការ ។ ក្រោយមក តាប៉ែត បានចាត់តាំង មិ ឲ្យទៅនៅភូមិក្រសាល និងភ្ជាប់ខ្សែជាមួយ តាគុំ អតីតលេខាតំបន់៣ (បច្ចុប្បន្នអង្គការចាប់ហើយ) ដើម្បីរៀបចំខ្សែបង្កប់តាមកន្លែងនីមួយៗ ។ បន្ទាប់មក តាគុំ បានណែនាំ មិ ឲ្យស្គាល់ខ្សែមួយចំនួនទៀត មានឈ្មោះ រ៉េន គណៈតំបន់៥ បច្ចុប្បន្នប្រធានចម្ការរបស់តំបន់៣, ឈ្មោះ ហឿង ប្រធានសហករណ៍ឃុំកូតឃ្មុំ ស្រុកបរវេល តំបន់៣, ឈ្មោះ ដូ អនុប្រធានសហករណ៍ ឃុំកូតឃ្មុំ ស្រុកបរវេល តំបន់៣, ឈ្មោះ ស៊ីប ប្រធានស្រុកបរវេល (បច្ចុប្បន្នអង្គការចាប់ខ្លួនហើយ), ឈ្មោះ យ៉ៃ ប្រធានទំនប់ទឹក តំបន់៣ តាចបកាប់ ហៅ សៀន អតីតគណៈស្រុកភ្នំសំពៅ ហើយបានដាក់ផែនការឲ្យអនុវត្តគឺ តាមដានចលនាខ្មែរក្រហមនៅតាមភូមិឃុំ ដើរឃោសនាប្រឆាំងខ្មែរក្រហម



កសិករនៅសហករណ៍ ស្រុកភ្នំសំពៅ ភូមិភាគពាយ័ព្យ កំពុងវាយសម្រុកដញ្ជូនបាយអ យ

កុំឲ្យប្រជាជនមានជំនឿលើខ្មែរក្រហមនៅតាមកន្លែងនីមួយៗ ត្រូវកសាងកម្លាំង សេ.អ៊ី.អា ឲ្យបានច្រើន ។

ឆ្នាំ១៩៦០ តាប៉ែត បាននិយាយប្រាប់ មិ ពីសភាពការណ៍បដិវត្តន៍ គឺកាន់តែមានសកម្មភាព និងសន្ទុះខ្លាំងក្លា ដូច្នេះធ្វើយ៉ាងណាឲ្យខ្សែរយៈរបស់យើងចុះឃោសនាកុំឲ្យប្រជាជនងាកទៅខាងខ្មែរក្រហមឲ្យសោះ ហើយធ្វើសកម្មភាពប្រឆាំងបដិវត្តន៍ឲ្យបានជាប់ជានិច្ច និងបានណែនាំ មិ ឲ្យស្គាល់ខ្សែ សេ.អ៊ី.អា របស់ខ្លួនចំនួនបួននាក់ទៀតមានឈ្មោះ គង់ អនុលេខាស្រុកភ្នំសំពៅ តំបន់៣, ឈ្មោះ វិន ប្រធានសហករណ៍ឃុំស្ទឹង តំបន់៣, ឈ្មោះ កឹង អនុប្រធានសហករណ៍ឃុំស្ទឹង ស្រុកភ្នំសំពៅ តំបន់៣, តាងឹន ហៅ ណៃ អតីតគណៈតំបន់៥ (បច្ចុប្បន្នអង្គការចាប់ខ្លួនហើយ) ។

ឆ្នាំ១៩៦៨ តាតុំ បានចាត់តាំង មិ ឲ្យភ្ជាប់ខ្សែជាមួយឈ្មោះ វើន ប្រធានស្រែប្រាំងរបស់ស្រុកអំពិល តំបន់៣, ឈ្មោះ សែន សមាជិកស្រុកភ្នំសំពៅក្រៅ តំបន់៣ និងឈ្មោះ ទៀប ប្រជាជននៅក្នុងសហករណ៍ជីរូក ស្រុកភ្នំសំពៅ ដែលជាខ្សែរបស់ខ្លួន ។ បន្ទាប់មក តាតុំ បានសម្រេចចាត់តាំង មិ និងតាទៀប ឲ្យធ្វើសកម្មភាពខាងក្រៅវិញ តាវើន តាប៉ែន និង ខួន (តាតុំ) រួមជាមួយអ្នកដែលធ្លាប់តស៊ូចាស់ៗមួយចំនួនទៀត ត្រូវចូលបង្កប់ខ្លួននៅក្នុងជួរបដិវត្តន៍ ។



...កទៅចាក់គ្រឹះទំនប់

ក្រោយរដ្ឋប្រហារ ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ តាតុំ បានចាត់តាំង មិ និងតាទៀប ឲ្យចូលបង្កប់ខ្លួនក្នុងជួរបដិវត្តន៍ជាមួយនឹងខ្លួនដែរ ហើយបានណែនាំឲ្យស្គាល់ខ្សែរយៈមួយចំនួនទៀតមានឈ្មោះ ស៊ី នីរសារ តាតុំ (ប្រធានយុទ្ធជនតំបន់៣) , ឈ្មោះ វ៉ុធ អនុប្រធានតំបន់៥ , ឈ្មោះ យុន មុនអង្គការចាប់ខ្លួនជាគណៈស្រុកអង្គរបុរី, ឈ្មោះ រុល ប្រធានរោងចក្របាត់ដំបង, ឈ្មោះ សាង ហៅ វន ប្រធានកងពលទី១ ភូមិភាគពាយ័ព្យ (បច្ចុប្បន្នអង្គការចាប់ខ្លួនហើយ) , ឈ្មោះ ហួយ អតីតជីទប់នៅព្រៃធំ បច្ចុប្បន្នជាប្រជាជននៅសហករណ៍ក្នុងស្រុកអំពិល ដើម្បីឲ្យសហការគ្នាធ្វើសកម្មភាពឃោសនាប្រជាជនឲ្យរត់ចូលទៅក្នុងតំបន់ខ្មាំងកាន់កាប់ និងធ្វើសកម្មភាពបង្អត់បាយប្រជាជន ។

ឆ្នាំ១៩៧១ តាតុំ បានចាត់តាំង មិ ឲ្យធ្វើជាអនុបញ្ជាការកងតូចយោធាតំបន់៣ ហើយបានឲ្យទាក់ទងខ្សែរយៈរបស់ខ្លួនមានឈ្មោះ លឿម ប្រធានគមនាគមន៍ភូមិភាគពាយ័ព្យ, ឈ្មោះ ម៉ឺក អតីតបញ្ជាការកងទ័ព តំបន់៣ (បច្ចុប្បន្នអង្គការចាប់ខ្លួនហើយ) , ឈ្មោះ នី អតីតប្រធានរោងម៉ាស៊ីនឈើភូមិភាគពាយ័ព្យ (បច្ចុប្បន្នអង្គការចាប់ខ្លួនហើយ) , ឈ្មោះ យ៉ុង អតីតគណៈវរសេនាធំរបស់ភូមិភាគពាយ័ព្យ (បច្ចុប្បន្នអង្គការចាប់ខ្លួនហើយ) ។ ក្រោយមកអង្គការបានដាក់ទិសឲ្យកងទ័ពទៅការពារប្រជាជន ។ ពេលនោះ មិ, លឿម, ម៉ឺក និង យ៉ុង បានរួមគ្នាធ្វើសកម្មភាពបំផុសកងទ័ពឲ្យរត់ចោលខ្សែត្រៀមពេលខ្មាំងវាយលុកចូល បណ្ដោយឲ្យខ្មាំងចូលធ្វើបាបប្រជាជន និងកៀរប្រជាជនយកទៅជាមួយអស់មួយចំនួន ។ បន្ទាប់មក មិ និង លឿម ធ្វើសកម្មភាព កសាងកម្លាំង សេ.អ៊ី.អា បានមួយចំនួនមានឈ្មោះ សុក ប្រធានយុទ្ធជនរបស់ស្រុកអង្គរបុរី តំបន់៣, ឈ្មោះ សាវើង ប្រធានកងធំនៅក្នុងកងពលទី១ ភូមិភាគពាយ័ព្យ, ឈ្មោះ ឈឿង បញ្ជាការកងវរសេនាតូច នៅក្នុងកងពល

ទី១ ភូមិភាគពាយ័ព្យ, ឈ្មោះ រឿន ប្រធានកងវរៈនៅក្នុងសហករណ៍បឹងក្រសាល ស្រុកភ្នំសំពៅ តំបន់៣, ឈ្មោះ យឿម ប្រធានជំទប់របស់សហករណ៍ស្ទឹង ស្រុកភ្នំសំពៅ, ឈ្មោះ ហាង ប្រធានសហករណ៍ស្រុកភ្នំសំពៅ តំបន់៣, ឈ្មោះ ឆយ ប្រធានកងធំនៅក្នុងសហករណ៍បឹងក្រសាល ស្រុកភ្នំសំពៅ តំបន់៣, ឈ្មោះ គៀម ប្រធានកងវរៈនៅក្នុងសហករណ៍បឹងប្រិយ ស្រុកភ្នំសំពៅ, ឈ្មោះ ឈឿន ប្រជាជននៅសហករណ៍កស្បៃក្រែង ស្រុកបវេល តំបន់៣ ។

ឆ្នាំ១៩៧២ គាគុំ បានចាត់តាំង មិ ឲ្យធ្វើជាគណៈយោធាស្រុកភ្នំសំពៅក្រៅ និងបានទាក់ទងជាមួយ តាទៀប និងតាសៀន ដែលជាខ្សែចាស់ជាប់រហូតមក ។ ក្រោយមក តាសៀន បានចាត់តាំង មិ, ង៉ា និង យូ ឲ្យធ្វើសកម្មភាព ពេលអង្គការឲ្យទិញអំបិល ទិញក្រណាត់ខោអាវ ចែកប្រជាជននោះ បក្ខពួក មិ មិនបានអនុវត្តតាមទិសដែលអង្គការដាក់ឲ្យទេ ថែមទាំងបំផុសប្រជាជនឲ្យរត់ទៅតំបន់ខ្មាំងអស់មួយចំនួនទៀត ។

ឆ្នាំ១៩៧៣ តាទៀប បានណែនាំ មិ ឲ្យទាក់ទងខ្សែរយៈរបស់ខ្លួនមួយចំនួនមានឈ្មោះ ចិ ប្រធានទំនប់សហករណ៍ភ្នំសំពៅ ស្រុកភ្នំសំពៅ, ឈ្មោះ អ៊ូច អនុប្រធានសហករណ៍ជីរូក ស្រុកភ្នំសំពៅក្រៅ តំបន់៣, ឈ្មោះ ឈឿម ប្រជាជននៅសហករណ៍បឹងក្រសាល ស្រុកភ្នំសំពៅក្រៅ ដើម្បីសហការគ្នាធ្វើសកម្មភាព ។

ដើមឆ្នាំ១៩៧៥ គាគុំ បានចាត់តាំង មិ ឲ្យធ្វើជាអនុប្រធានពាណិជ្ជកម្មប្រចាំនៅស្រុកភ្នំសំពៅក្រៅ ភូមិភាគពាយ័ព្យ និងបានណែនាំឲ្យទាក់ទងខ្សែរយៈឈ្មោះ ហឿន អតីតប្រធានរោងចក្រភូមិភាគពាយ័ព្យ (បច្ចុប្បន្នអង្គការចាប់ខ្លួនហើយ) និងឈ្មោះ ឆាំ អតីតប្រធានទំនប់ភូមិភាគពាយ័ព្យ (បច្ចុប្បន្នអង្គការចាប់ខ្លួនហើយ) ។ ក្រោយពីភ្ជាប់ខ្សែមក ឆាំ បានណែនាំ មិ ឲ្យស្គាល់ខ្សែរបស់ខ្លួនចំនួនបួននាក់ទៀត ។

ក្រោយរំដោះខែមេសា ឆ្នាំ១៩៧៥ អង្គការបានជម្លៀសប្រជាជនចេញពីទីក្រុងឲ្យទៅធ្វើស្រែនៅតាមជនបទ ។ ពេលនោះ គាគុំ បានចាត់តាំង មិ ឲ្យទៅទាក់ទងជាមួយ តាទៀប និងតាសៀន ដែលជាខ្សែរយៈចាស់ ដើម្បីរួមគ្នាធ្វើសកម្មភាពយកប្រជាជនទៅដាក់នៅទីនេះបន្តិចទីនោះបន្តិច ធ្វើឲ្យខាតពេលវេលារបស់ប្រជាជនក្នុងការធ្វើការងារស្រែចម្ការ ។ ឆ្លៀតពេលនោះដែរ មិ និង ឆាំ បានធ្វើសកម្មភាពកសាងកម្លាំងបានចំនួនបួននាក់ទៀត ហើយបានណែនាំកម្លាំងដែលទើបកសាងបានឲ្យធ្វើសកម្មភាពឃោសនាបំផុសប្រជាជនឲ្យប្រឆាំងនឹងបដិវត្តន៍ ប្រឆាំងរបបសមូហភាពរបស់បក្ស និងបំផ្លាញសម្ភារតាមកន្លែងនីមួយៗឲ្យរេចរឹល ពិសេសបំផ្លាញទំនប់ ប្រឡាយ ធ្វើយ៉ាងណាកុំឲ្យធ្វើស្រែសម្រេចតាមផែនការបីតោនក្នុងមួយហិកតារបស់បក្ស ។

ខែមីនា ឆ្នាំ១៩៧៦ តាញឹម បានចាត់តាំង មិ ឲ្យធ្វើជាប្រធានរោងចក្រក្រឡឹងភូមិភាគពាយ័ព្យ ហើយបានណែនាំ មិ ឲ្យខិតខំកសាងកម្លាំងឲ្យបានច្រើនថែមទៀត ទាំងក្នុងរោងចក្រទាំងក្រៅរោងចក្រ ។ ក្រោយមកឈ្មោះ ហឿន និង ឆាំ ដែលជាខ្សែចាស់ បានណែនាំឲ្យ មិ ស្គាល់ខ្សែរយៈជាងដប់នាក់ទៀតមាន ឈ្មោះ ម៉ឺន, ជៀត, តូច, ម៉ាប់, ហៀក, រ៉ាត់, ម៉ុម, យាន, វិត, ហេន, រិ និង លីប ដើម្បីត្រៀមរៀបចំធ្វើរដ្ឋប្រហារ ។ បន្ទាប់មក មិ និងបក្ខពួកបានធ្វើសកម្មភាពយកដែកមិនល្អទៅធ្វើខ្នៅខ្នងដើម្បីកុំឲ្យជាប់ប្រើការបានយូរ ទម្លាយទំនប់ឲ្យទឹកហូរចេញពីស្រែ ធ្វើឲ្យស្រូវអត់ទឹកងាប់អស់ជាច្រើនហិកតា បំផុសប្រជាជនឲ្យរត់ពីកន្លែងមួយទៅកន្លែងមួយទៀត ធ្វើឲ្យមានសភាពប្របូកប្របល់រាំងស្ទះដល់ផែនការធ្វើស្រែរបស់បក្ស និងកសាងកម្លាំងបានបួននាក់ថែមទៀត ។

ខែមករា ឆ្នាំ១៩៧៧ តាញឹម បានដក មិ ចេញពីរោងចក្រក្រឡឹង ឲ្យមកនៅតំបន់៣ ជាមួយ តាគុំគណៈតំបន់៣ ធ្វើជាសមាជិកស្រុក ហើយបានណែនាំខ្សែ សេ.អ៊ី.អា ឲ្យស្គាល់គ្នាងាយស្រួលទាក់ទងពេលធ្វើសកម្មភាពមានឈ្មោះ ហា, ឆាន, នួម, ស៊ឹម, ស៊ិន, និង អឿន ហៅគង់ ។ ក្រោយមកអង្គការបានដាក់ទិសឲ្យដឹកនាំប្រជាជនវាយសម្រុកធ្វើស្រែនៅលើដីខ្វាញ់ ។ ពេលនោះឈ្មោះ ហា បានចាត់តាំង មិ និង សឿន ឲ្យដឹកនាំឈ្មោះ ថន, តាត្រសក់ផ្អែម, ភឿង, សែន, ឈៃ, អ៊ូច, និង យ៉ាន់ ឲ្យធ្វើសកម្មភាពដឹកនាំប្រជាជនឲ្យទៅកាប់ព្រៃធ្វើស្រែនៅកន្លែងនេះបន្តិច កន្លែងនោះបន្តិច ធ្វើឲ្យការងារធ្វើស្រែត្រូវស្ទះ ទុកដីចោលឲ្យនៅទំនេរ មិនឲ្យប្រជាជនធ្វើស្រែ ហើយបែរជាដឹកនាំប្រជាជនឲ្យទៅដាំពោតនៅលើដីដែលមានស្មៅក្រាស់ ភ្ជួរមិនស្អាត ដែលជាហេតុធ្វើឲ្យពោតដុះមិនរួចខូចអស់គ្រាប់ពូជជាច្រើន ។ ចំណែកជីវភាពរបស់ប្រជាជនក៏ដោះស្រាយមិនបានល្អដែរ ។ ក្រោយមក ពេលដែល គាគុំ ចុះមកមន្ទីរស្រុកភ្នំសំពៅ

ក៏បានដក គាទៀប ចេញ ហើយបានចាត់តាំង មិ ឲ្យធ្វើជាអនុលេខាស្រុកភ្នំសំពៅចាប់ពីពេលនោះមក ។

នៅពាក់កណ្តាលឆ្នាំ១៩៧៧ តាញឹម បានហៅ តាគុំ និង មិ រួមជាមួយបក្ខពួកមួយចំនួនទៀតមាន ឈ្មោះ ជន់ លេខាស្រុកអំពិល តំបន់៣, ឆាន អនុលេខាស្រុកបវិល តំបន់៣, នួម កម្មករស្រុកបវិល តំបន់៣, ស៊ិន អនុលេខាស្រុកប៉ោយប៉ែត តំបន់៣, ស៊ឹម កម្មករស្រុកប៉ោយប៉ែត តំបន់៣, រឿ អនុលេខាស្រុកអន្លង់វ៉ែង តំបន់៣, ហា អនុលេខាស្រុកភ្នំសំពៅក្រៅ តំបន់៣ និង ឆាំ ប្រធានពាណិជ្ជកម្ម តំបន់៣ ឲ្យមកចូលរួមប្រជុំ ។ តាញឹម បាននិយាយថា ខ្មែរយ:របស់យើងត្រូវបានអង្គការចាប់ខ្លួនអស់មួយចំនួនហើយ តែយើងកុំភ័យ កុំជ្រួលច្របល់ឲ្យសោះ ត្រូវពង្រឹងស្មារតី និងគោលជំហរខ្មែរយ:របស់យើងនៅតាមកន្លែងនីមួយៗឲ្យបានល្អ ។ ម្យ៉ាងទៀតខ្មែរយ:របស់យើងនៅមិនទាន់អស់ទេ គឺនៅរាយគ្រប់ស្រុក គ្រប់តំបន់ គ្រប់ទីកន្លែងទាំងអស់ យើងត្រូវទាក់ទងគ្នាឲ្យជាប់ ហើយបន្តសកម្មភាពឲ្យខ្លាំងថែមទៀត តែចំណុចពិសេសត្រូវកសាងកម្លាំងរបស់យើងតាមកន្លែងនីមួយៗឲ្យបានច្រើនថែមទៀត ដើម្បីប្រឆាំងបក្សនៅថ្ងៃមុខ ។

ខែកក្កដា ឆ្នាំ១៩៧៧ តាគុំ បានហៅ មិ និង ហា មកជួបនៅមន្ទីរតំបន់៣ ហើយបានខទ្វេសនាមឲ្យស្គាល់ខ្មែរ សេ.អ៊ី.អា បួននាក់ទៀតមានឈ្មោះ ម៉ន, អុន, អឿម, និងសម័យដែលជាខ្មែររបស់តាញឹម នៅភូមិភាគបូព៌ា ព្រោះនៅខាងបូព៌ាគេរៀបចំកម្លាំងបានធំហើយ ដូច្នេះត្រូវទាក់ទងគ្នាឲ្យជាប់ក្នុងពេលធ្វើសកម្មភាព ។ ក្រោយមក តាគុំ បានបើកការប្រជុំមួយនៅថ្នកោលដែលអ្នកចូលរួមមានឈ្មោះ មិ, ហា, សម័យ, ម៉ន, ស៊ិន, ឆុន, ឆាន, នួម, រឿ, អឿម និង រឿន ។

ពេលនោះ តាគុំ បាននិយាយនៅក្នុងអង្គប្រជុំថា “តាមសេចក្តីសម្រេចចិត្តរបស់ភូមិភាគ គឺឲ្យយើងត្រៀមស្បៀងនៅតាមស្រុក តាមសហករណ៍នីមួយៗឲ្យបានច្រើនដើម្បីត្រៀមធ្វើរដ្ឋប្រហារ ។ ផ្នែកកងទ័ព តាញឹម បានរៀបចំរួចហើយ ចំណែកយើងនៅខាងក្រោយត្រូវត្រៀមស្បៀងឲ្យបានច្រើន ហើយចុះឃោសនាបំផុសឲ្យប្រជាជនប្រឆាំងជាមួយបក្ស” ។ ក្រោយពីដាក់ផែនការរួច មិ និង ហា បានចាត់តាំង អ៊ុច និង ហ៊ីង ឲ្យប្រមូលស្រូវលាក់ទុកក្នុងសហករណ៍ជីរូកបានចំនួន២០០ថាំង ។ ចំណែកនៅសហករណ៍បានដាក់ តាត្រសក់, ថន និង ភឿង ឲ្យប្រមូលស្រូវលាក់ទុកបានចំនួន ៥០០បាវ ។

នៅពាក់កណ្តាលខែវិច្ឆិកា ឆ្នាំ១៩៧៧ ហា បាននិយាយប្រាប់ មិ ថាបក្ខពួករបស់ខ្លួននៅតាមសហករណ៍ បានប្រមូលស្បៀងត្រៀមបានមួយចំនួនធំហើយ និងបានធ្វើសកម្មភាពជាបន្តបន្ទាប់ជាពិសេស សកម្មភាពបង្អត់បាយប្រជាជន ។ នៅពេលនោះដែរ ឈ្មោះ វ៉ាក់ ដែលជាខ្មែរចាស់បានមកជួប មិ និង ហា ហើយបានរាយការណ៍ថាខ្លួនបានកសាងកម្លាំង សេ.អ៊ី.អា បានចំនួនបួននាក់មានឈ្មោះ អាចារ្យតឹក, លឿត, ផ្លែក និង ឆម ហើយអ្នកទាំងបួននេះបានធ្វើសកម្មភាពបំផ្លាញដំណាំស្រូវ និងទម្លាយភ្លឺស្រែចោលជាបន្តបន្ទាប់ ។

ខែមករា ឆ្នាំ១៩៧៨ ហា លេខាស្រុកភ្នំសំពៅក្រៅត្រូវបានអង្គការចាប់ខ្លួន ។ បីថ្ងៃក្រោយមក តាគុំ បានមកជួប មិ ហើយបាននិយាយថា ទោះបីអង្គការចាប់ខ្លួនមិត្ត ហា ទៅហើយក្តី តែយើងត្រូវដឹកនាំខ្មែរយ:របស់យើងធ្វើសកម្មភាពបន្តទៀត សំខាន់ត្រូវចេះរក្សាការសម្ងាត់ឲ្យបានល្អ ។ ជាមួយគ្នានោះដែរ តាគុំ បានចាត់តាំង មិ ឲ្យធ្វើជាលេខាស្រុកភ្នំសំពៅក្រៅជំនួស ហា ហើយបានដកឈ្មោះ អាន ឲ្យមកធ្វើជាអនុលេខាស្រុកភ្នំសំពៅក្រៅ ឈ្មោះ សែន ជាសមាជិកស្រុកភ្នំសំពៅក្រៅ និងដកឈ្មោះ សៀន ឲ្យធ្វើជាប្រជាជនវិញ ។ ក្រោយពេលរៀបចំសមាសភាពដឹកនាំរួចហើយ ឈ្មោះ អាន និង សែន បានណែនាំ ខ្មែរ សេ.អ៊ី.អា របស់ខ្លួន ឲ្យ មិ បានស្គាល់មានឈ្មោះ គ្រប់ ប្រធានសហករណ៍តាង៉ែន ស្រុកភ្នំសំពៅក្រៅ តំបន់៣, ឈ្មោះ ញ៉ាន អនុប្រធានសហករណ៍ព្រៃធំ ស្រុកភ្នំសំពៅក្រៅ តំបន់៣, សារ៉ន ប្រធានកងឈ្លប ការពារសហករណ៍ព្រៃធំ ស្រុកភ្នំសំពៅក្រៅ តំបន់៣, កាយ ប្រធានកងអនុសេនាធំក្នុងសហករណ៍ព្រៃធំ ស្រុកភ្នំសំពៅក្រៅ តំបន់៣, ដួច អនុប្រធានកងធំក្នុងសហករណ៍ព្រៃធំ ។ ក្រៅពីនេះ មិ បានចាត់តាំង អ៊ុច ដែលជាខ្មែរចាស់ ឲ្យធ្វើសកម្មភាពលួចដុតផ្ទះឆេះអស់៥ខ្នង ក្នុងនោះមានក្រណាត់ខោអាវមួយចំនួនក៏ត្រូវបានដុតបំផ្លាញដែរ ។

ខែកុម្ភៈ ឆ្នាំ១៩៧៨ អង្គការបានដាក់ទិសឲ្យដឹកនាំប្រជាជន

វាយសម្រុកធ្វើស្រែប្រាំងក្នុងសហករណ៍មួយៗឲ្យបាន១០០ហិកតា ។ ពេលនោះ មិ បានចាត់តាំង អាន និង សែន ឲ្យធ្វើសកម្មភាពបំភ្លៃមាគ៌ារបស់បក្ស ដោយឲ្យសហករណ៍មួយៗធ្វើស្រែតែ៥០ហិកតាប៉ុណ្ណោះដើម្បីកុំឲ្យដោះស្រាយជីវភាពរបស់ប្រជាជនបានធូរធារ សម្បូរសប្បាយ ។ ក្រោយមក តាញឹម បានហៅ មិ, អាន, តាតុំ, អឿម, វឿន, ឆុន និង ឆាន ឲ្យមកប្រជុំគ្នានៅថ្នាក់គោល ។ ក្រោយពេលជួបជុំគ្នាហើយ តាញឹម បាននិយាយថា "ឥឡូវនេះអង្គការបានដាក់ទិសឲ្យយើងលើកទំនប់កំពីងពួយ និងជីកប្រឡាយស៊ីងតាហែនឲ្យបានសម្រេចតាមផែនការខែមីនា ឆ្នាំ១៩៧៨ខាងមុខ ។ ហេតុនេះ បក្ខពួករបស់យើងត្រូវធ្វើសកម្មភាពរារាំងផែនការនេះឲ្យបាន ព្រោះបើយើងរារាំងផែនការនេះបាន នោះវានឹងធ្វើឲ្យរាំងស្ទះដល់ផែនការធ្វើស្រែរបស់បក្ស ។ ហេតុនេះយើងម្នាក់ៗ ត្រូវខិតខំអនុវត្តរារាំងផែនការនេះ ឲ្យបានជោគជ័យ ហើយត្រូវចេះរក្សាការណ៍សម្ងាត់ឲ្យបានល្អ ទើបបក្ខពួករបស់យើងមានសុវត្ថិភាពល្អ និងធ្វើសកម្មភាពប្រឆាំងបដិវត្តន៍បានយូរអង្វែង ។ នៅពេលដែល តាញឹម ណែនាំចប់ យើងក៏បំបែកគ្នាទៅកន្លែងរៀងៗខ្លួន ។

ខែមីនា ឆ្នាំ១៩៧៨ មិ និង អាន បានដឹកនាំកម្លាំងប្រជាជននៅក្នុងស្រុកភ្នំសំពៅក្រៅទាំងអស់ ឲ្យទៅលើកទំនប់កំពីងពួយ ។ មិ, អាន និង គង់ បានចាត់តាំងឈ្មោះ ឆក, ហ៊ីង, កាយ, ទុយ, យ៉ាន់, តាត្រសក់, ហាន, ថន, ប៉ោង, ម៉ាប់ និង តែម ឲ្យធ្វើសកម្មភាពកាត់របបរបស់ប្រជាជនមិនឲ្យហូបចុកគ្រប់គ្រាន់ ហើយបើកសម្ភារ ចបបង្គី តិចតួចបំផុតឲ្យប្រជាជនដើម្បីធ្វើការងារលើកទំនប់នេះ ជាហេតុធ្វើឲ្យការងារនេះ ត្រូវកកស្ទះព្រោះមិនមានឧបករណ៍ប្រើប្រាស់គ្រប់គ្រាន់ ។ ចំណែកខោអាវដែលអង្គការរៀបចំទុកសម្រាប់ចែកជូនប្រជាជន បក្ខពួករបស់ មិ មិនបានបើកជូនប្រជាជនឲ្យបានគ្រប់គ្នាទេ ជាហេតុធ្វើឲ្យប្រជាជនមួយចំនួនដែលមិនបានទទួលរបបខោអាវ មានការថ្នាំងថ្នាក់ អាក់អន់ស្រពន់ចិត្តជាមួយបក្សជាបន្តបន្ទាប់ ។

ខែឧសភា ឆ្នាំ១៩៧៨ តាតុំ បានហៅ មិ និងខ្មែរមួយចំនួនទៀតមានឈ្មោះ សម័យ, ស៊ិន, ម៉ន, វឿ, អាន, វង់, ឆួយ, ឆុន, ឆ្នាំង ហៅ ជាល, និង វុធ ឲ្យមកជួបប្រជុំគ្នានៅថ្នាក់គោល ។ នៅពេលនោះ តាញឹម បាននិយាយណែនាំថា "នៅក្នុងភូមិភាគរបស់យើងឥឡូវនេះ បានរៀបចំខ្សែសង្វាក់បានរឹងមាំជាងមុន នៅតាមតំបន់ក៏ខ្លាំង នៅតាមស្រុកក៏អឺចឹងដែរ សំខាន់យើងត្រូវពង្រឹងខ្សែរយៈតាមកន្លែងនីមួយៗឲ្យខ្លាំងថែមទៀត ដើម្បីយើងត្រៀមធ្វើរដ្ឋប្រហារប្រឆាំងបក្សនៅថ្ងៃខាងមុខ ។ ចំណែកនៅតាមភូមិភាគផ្សេងៗទៀត ក៏គេបានរៀបចំខ្សែរបស់គេបានរួចហើយដែរ ។ ដូច្នេះនៅចំពោះមុខយើងត្រូវទាក់ទងគ្នាតាមកន្លែងនីមួយៗឲ្យជាប់ កុំឲ្យដាច់ឲ្យសោះ ហើយត្រូវអនុវត្តតាមផែនការឲ្យបានល្អ ម្យ៉ាងទៀតយើងត្រូវជួយលាក់ការណ៍ឲ្យបានជិតល្អដើម្បីការពារខ្សែរយៈ និងកម្លាំងរបស់យើងឲ្យបានយូរអង្វែងតទៅ ។

នៅដើមខែមិថុនា ឆ្នាំ១៩៧៨ តាតុំ បាននាំ មិ ទៅជួបជាមួយមិត្ត ខ នៅបាត់ដំបង ។ ពេលនោះមិត្ត ខ បាននិយាយប្រាប់ មិ និងតាតុំ ថា "តាមមើលសភាពការណ៍ឥឡូវនេះប្រហែលជាមិនស្លូវស្រួលទេ ព្រោះ តាញឹម ត្រូវបានអង្គការដកឲ្យទៅភ្នំពេញបាត់ហើយ មិនឃើញវិលត្រឡប់មកវិញទេ ។ ដូច្នេះយើងត្រូវខំពង្រឹងខ្សែរបស់យើងនៅតាមស្រុក និងនៅកន្លែងផ្សេងៗទៀត ឲ្យរក្សាការណ៍សម្ងាត់ឲ្យបានល្អ កុំឲ្យធ្វើសកម្មភាពចំហពេក ជាពិសេសកុំឲ្យមានសភាពជ្រួលច្របល់ឲ្យសោះ» ។ មិត្ត ខ បាននិយាយទៀតថា នៅតំបន់១ ខ្លួនក៏បានជម្រាបមិត្ត ប៉ែត រួចហើយដែរអំពីសភាពការណ៍នេះ ។ ពេលក្តាប់បានសភាពការណ៍បានហើយ មិ និងតាតុំ ក៏បាននាំគ្នាវិលត្រឡប់មកកន្លែងវិញ ។ លុះដល់ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៧៨ មិ រួមជាមួយតាតុំ, ម៉ន, អឿម, ឆុន, សម័យ ក៏ត្រូវអង្គការចាប់ខ្លួនតែម្តង ។

ចម្លើយសារភាពរបស់ មិ ត្រូវបានវាយអង្គុលីលេខមានចំនួន៤៩ទំព័រ ដែលនៅផ្នែកខាងក្រោយជាបញ្ជីរាយឈ្មោះរបស់មនុស្សចំនួន១១១នាក់ និងតួនាទី ដែលជាប់ពាក់ព័ន្ធធ្វើសកម្មភាពក្បត់របស់ខ្លួន ។ នៅចុងបញ្ចប់នៃចម្លើយសារភាព ផ្នែកខាងស្តាំមានស្នាមផ្តិតមេដៃ និងចុះហត្ថលេខារបស់ ហែន មិ ដែលជាអ្នកសារភាព ចុះកាលបរិច្ឆេទនៅថ្ងៃទី២៤ ខែសីហា ឆ្នាំ១៩៧៨ ។ នៅផ្នែកខាងឆ្វេង ក៏មានចុះហត្ថលេខារបស់អ្នកសួរចម្លើយ ឈ្មោះ អោក ហ៊ាង ដែរ ។

**ឆេង ខេង**

# យកចិត្តទុកដាក់ បំពាក់បំប៉នបន្ថែមអំពីសីលធម៌១២ប្រការរបស់ជនបដិវត្តន៍

*ដកស្រង់ចេញពីទស្សនាវដ្តីយុវជន និងយុវនារីបដិវត្តន៍លេខ១០ ចេញផ្សាយខែតុលា ឆ្នាំ១៩៧៨*

*សីលធម៌១២ប្រការរបស់ជនបដិវត្តន៍ ជាក្រឹត្យវិន័យរបស់បក្ស ដែលជនបដិវត្តន៍គ្រប់រូប ត្រូវតែគោរព អនុវត្តតាមគ្រប់ «ខ» ដោយជ្រួតជ្រាប និងភ្ជាក់រឭក ដើម្បីកសាងខ្លួនឲ្យទៅជាជនបដិវត្តន៍ល្អបរិសុទ្ធ ធូរធង់ អាចវាយសម្រុកសម្រេចភារកិច្ចបដិវត្តន៍តូចធំ ជាផលប្រយោជន៍ដល់ប្រទេសជាតិ ប្រជាជន បក្ស និងវណ្ណៈក្រីក្រយើង ។ សីលធម៌១២ប្រការរបស់ជនបដិវត្តន៍នេះ បានកកើតឡើងនៅឆ្នាំ១៩៦៨ ។ ឆ្នាំ១៩៦៨ ជាផ្លូវបត់ធំមួយ ក្នុងចលនាបដិវត្តន៍កម្ពុជាយើង គឺជាឆ្នាំដែលប្រជាជន កម្មករ កសិករក្រីក្រ ក្រោមការដឹកនាំដ៏ត្រឹមត្រូវ និងភ្លឺស្វាងនៃបក្សកុម្មុយនីស្តកម្ពុជាចាប់ផ្តើមផ្ទុះអាវុធ វាយកម្ទេចខ្មាំងសត្រូវ ជាខ្មាំងប្រជាជាតិ និងខ្មាំងវណ្ណៈ ដោយរួមផ្សំនឹងការតស៊ូនយោបាយផង ។ ឆ្នាំ១៩៦៨ ក៏ជាឆ្នាំលំបាកស្មុគស្មាញបំផុត តែក៏ជាឆ្នាំដែលបើកទំព័រប្រវត្តិសាស្ត្រថ្មីនៃចលនាតស៊ូបដិវត្តន៍របស់ប្រជាជនកម្ពុជា ក្រោមការដឹកនាំដ៏ត្រឹមត្រូវ និងភ្លឺស្វាងនៃបក្សកុម្មុយនីស្តកម្ពុជាយើង ។ ជាឆ្នាំភ្លឺស្វាង ដែលប្រជាជន និងកងទ័ពបដិវត្តន៍កម្ពុជាយើង ផ្អែកលើហិង្សាអាវុធ វាយកម្ទេចរដ្ឋអំណាចជិះជាន់ ឃោរឃៅ ហ្វាស៊ីសរបស់ពួកអាក្បត់ជាតិ និងវណ្ណៈសក្តិភូមិ នាយទុន ឲ្យរង្គោះរង្គើ រលំរលាយជាបន្តបន្ទាប់ រហូតដល់ត្រូវរលំរលាយទាំងស្រុងអស់ពីលើទឹកដីកម្ពុជាយើងនៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ។*

*ក្នុងឆ្នាំ១៩៦៨នេះ ខ្មាំងក៏បានបង្កើនការបង្ក្រាប រាតត្បាត ចាប់ចង កាប់សម្លាប់ជនបដិវត្តន៍ ជនស្នេហាជាតិ និងចម្រើន ហើយជាពិសេស គឺប្រជាជនក្រីក្រយើងនៅតាមជនបទចុងកាត់មាត់ញកយ៉ាងឃោរឃៅ ព្រៃផ្សៃ ហ្វាស៊ីសបំផុត ។ ខ្មាំងបានអនុវត្តយ៉ាងពេញទំហឹង និងដោយឥតញញើតដៃឡើយ នូវនយោបាយទុរគតភាវូបនីយកម្ម នយោបាយពាលាភាវូបនីយកម្ម និងនយោបាយហ្វាស៊ីសភាវូបនីយកម្មនៅគ្រប់ទិសទី តាំងពីទីក្រុងរហូតដល់ជនបទចុងកាត់មាត់ញក ហើយជាពិសេសគឺនៅតាមជនបទចុងកាត់មាត់ញក ។*

*ដើម្បីទប់ទល់ និងវាយកម្ទាត់នូវនយោបាយហ្វាស៊ីសទាំងបីខាងលើនេះរបស់ខ្មាំង ការពារ និងកសាងពង្រឹងពង្រីកកម្លាំងបដិវត្តន៍ឲ្យរីកចម្រើនខ្លាំងក្លាយ៉ាងឆាប់រហ័ស និងដើម្បីសម្រេចភារកិច្ចបដិវត្តន៍ប្រជាជាតិប្រជាធិបតេយ្យ ឲ្យកាន់តែមានប្រសិទ្ធភាពថែមទៀត បក្សកុម្មុយនីស្តកម្ពុជាយើង ដោយឈរលើមាគ៌ាជាយុទ្ធសាស្ត្រ និងមាគ៌ាជាយុទ្ធវិធីរបស់បក្ស និងដោយឈរលើសភាពការណ៍ជាក់ស្តែងនៃចលនាបដិវត្តន៍របស់យើងក្នុងរយៈកាលនោះ បានរៀបចំចងក្រងឡើងនូវឯកសារសីលធម៌១២ប្រការរបស់ជនបដិវត្តន៍នេះ ។ ដូច្នេះ ឯកសារ១២ប្រការរបស់ជនបដិវត្តន៍នេះ មិនមែនជាគម្ពីរ ឬជាទ្រឹស្តីដែលគាត់តែងឡើងដោយបុគ្គលណាម្នាក់ ឬក្រុមជនណាមួយឡើយ ។ តែគឺពិតជាចេញមកពីសាច់ស្រស់ ឈាមស្រស់របស់បុព្វបុរសបដិវត្តន៍យើង និងប្រជាជនយើង ក្នុងគ្រប់កាលសម័យតស៊ូបដិវត្តន៍ គឺពិតជាចេញមកពីចលនាបដិវត្តន៍ជាក់ស្តែងរបស់ប្រជាជនកម្មករ កសិករយើង ក្រោមការដឹកនាំដ៏ត្រឹមត្រូវ និងភ្លឺស្វាងនៃបក្សកុម្មុយនីស្តកម្ពុជា ជាបន្តបន្ទាប់មក ។ ដូច្នេះឯកសារសីលធម៌១២ប្រការនេះ គឺពិតជាក្រឹត្យវិន័យ ជាទស្សនៈគោលជំហរ និងជាសីលធម៌របស់បក្សកុម្មុយនីស្ត និងរបស់ប្រជាជនបដិវត្តន៍កម្ពុជាយើង ។*

*ដូច្នេះហើយ បានជាឯកសារនេះ ត្រូវបានផ្សព្វផ្សាយនៅក្នុងចំណោមយុទ្ធជន យុទ្ធនារី និងកម្មាភិបាលបដិវត្តន៍យើង នៅទូទាំងប្រទេស និងនៅក្នុងចំណោមប្រជាជន មហាជនបដិវត្តន៍នៅគ្រប់ទិសទី តាំងពីឆ្នាំ១៩៦៨មកម៉្លេះ ។ ប្រជាជន មហាជនបដិវត្តន៍នៅទូទាំងប្រទេស អបអរសាទរ រីករាយ ពេញចិត្តពេញថ្លើម ទទួលយក*

សីលធម៌បដិវត្តន៍១២ប្រការនេះ ទៅរៀនសូត្របំពាក់បំប៉នឲ្យខ្លួនជាប់ជានិច្ច ប្រែក្លាយទៅជាទស្សនៈគោលជំហរ និងជាសីលធម៌បដិវត្តន៍ប្រចាំជីវិតរបស់ខ្លួនក្នុងការអនុវត្តភារកិច្ចប្រចាំថ្ងៃជាបន្តបន្ទាប់មក ។ ដោយយុទ្ធជន យុទ្ធនារី និងកម្មាភិបាលបដិវត្តន៍គ្រប់ជាន់ថ្នាក់ជ្រួតជ្រាប និងអនុវត្តនូវសីលធម៌១២ប្រការនេះរបស់បក្សបានល្អត្រឹមត្រូវជានិច្ច បានជាប្រជាជនស្រឡាញ់ ពេញចិត្តពេញថ្លើម យុទ្ធជន យុទ្ធនារី និងកម្មាភិបាលបដិវត្តន៍ ហើយចាត់ទុកជនបដិវត្តន៍ជាសាច់ជាឈាមរបស់គេផ្ទាល់ ។ ដូច្នេះហើយបានជាបដិវត្តន៍យើង អាចចលនាប្រមូលកៀងគរកម្លាំងប្រជាជនគ្រប់ស្រទាប់វណ្ណៈ បានច្រើនកុះករ ហើយប្រយុទ្ធវាយកម្ទេចខ្មាំងសត្រូវគ្រប់ប្រភេទ ក៏បានខ្លាំងក្លាជាប់ជានិច្ច ទោះបីពេលនោះ យើងស្ថិតក្នុងសភាពក្រខ្សត់អត់ឃ្លាន ខ្វះសព្វខ្វះគ្រប់យ៉ាងណាក្តី ហើយទោះបីខ្មាំងសត្រូវវាឃោរឃៅ កាចសាហាវ និងហ្វាស៊ីសកម្រិតខ្ពស់យ៉ាងណាក្តី ។

ក្នុងរយៈកាលថ្មីនៃបដិវត្តន៍កម្ពុជាយើងបច្ចុប្បន្ននេះ សីលធម៌១២ប្រការរបស់ជនបដិវត្តន៍ នៅតែមានសារសំខាន់ និងមានអត្ថន័យជ្រាលជ្រៅចំពោះយើងជាជនបដិវត្តន៍ដដែល ។ បើដណ្តើមបានជ័យជម្នះហើយ យើងត្រឡប់ទៅជាបោះបង់ ឬបំភ្លេចចោលនូវគោលជំហរសីលធម៌១២ប្រការនេះ នោះចលនាបដិវត្តន៍សង្គមនិយមរបស់យើង និងជួបប្រទះនូវការលំបាករហូតដល់អាចទទួលបរាជ័យវិញក៏មានដែរ ។

◆ ព្រោះបើប្រាសចាកសីលធម៌បដិវត្តន៍១២ប្រការ យុទ្ធជន យុទ្ធនារី និងកម្មាភិបាលបដិវត្តន៍ យើងគ្រប់ថ្នាក់ អាចប្រែធាតុបដិវត្តន៍បន្តិចម្តងៗ ឬក៏ប្រែប្រួលលឿនឆាប់រហ័សជាងនេះទៀត ទៅជាសេរីនិយម នាម៉ឺននិយម អាជ្ញានិយម ហើយទោះចង់ ឬមិនចង់ វានឹងប្រែធាតុពីបដិវត្តន៍វណ្ណៈ អធនទៅជាអនុធនភាវូបនីយកម្ម នាយទុនភាវូបនីយកម្ម នាម៉ឺនភាវូបនីយកម្មពុំខានឡើយ ។

◆ បើយុទ្ធជន យុទ្ធនារី និងកម្មាភិបាលបដិវត្តន៍គ្រប់ថ្នាក់ប្រែធាតុបដិវត្តន៍ទៅជាយ៉ាងនេះហើយ នោះបដិវត្តន៍សង្គមនិយមរបស់យើង ពុំមែនឋិតនៅជាបដិវត្តន៍សង្គមនិយមរបស់វណ្ណៈអធន ដែលបម្រើផលប្រយោជន៍ប្រទេសជាតិ និងប្រជាជនកម្ពុជាជាទូទៅឡើយ ។ តែវាជាបដិវត្តន៍សង្គមនិយម តែសំបក តែស្លាក ឯខ្លឹមសារគឺជាបដិវត្តន៍នាយទុន ជាបដិវត្តន៍សេរីរី ដែលបម្រើតែផលប្រយោជន៍របស់វណ្ណៈកាន់អំណាចមួយក្តាប់តូចប៉ុណ្ណោះ ដូច្នោះពលិកម្មច្រើនឥតគណនារបស់បុព្វបុរសបដិវត្តន៍យើងរបស់យុទ្ធមិត្តយើង និងរបស់ប្រជាជន កម្មករ កសិករក្រីក្រយើង រាប់ជំនាន់មកហើយ នោះនឹងទៅជាអាសារឥតការ ។

◆ បើបដិវត្តន៍សង្គមនិយមយើង ប្រែក្លាយធាតុពិតយ៉ាងនេះហើយ នោះប្រទេសជាតិយើងប្រាកដជានឹងធ្លាក់ខ្លួនទៅជាខ្ញុំកញ្ជះគេវិញ អាប់ឱនទាបថោករកទីបំផុតគ្មាន ។ ប្រជាជនយើងពិតជានឹងធ្លាក់ខ្លួនទៅជាខ្ញុំគេ ហើយរងទុក្ខវេទនា ឈឺចាប់ខ្លោចផ្សាពុំដឹងពេលណាវិលខ្លួនរួចវិញឡើយ ហើយខ្ញុំគេលើកនេះ គឺខ្ញុំយួនឈ្លានពាន វាតទីលេបទឹកដីបំបាត់ពូជសាសន៍នេះឯង ។ ដូច្នេះ មហាថោកទាប មហារហេមរហាមយ៉ាងពិតប្រាកដ ។ នេះជាគ្រោះថ្នាក់ធំណាស់ចំពោះរូបយើងម្នាក់ៗដែលជាជនបដិវត្តន៍ ក៏ដូចជាចំពោះប្រទេសជាតិ ប្រជាជន និងចលនាបដិវត្តន៍យើងដែរ ។

ឃើញយ៉ាងនេះ យើងជាយុវជន យុវនារីបដិវត្តន៍គ្រប់រូប ក៏ដូចជាប្រជាជនកម្ពុជាទូទៅដែរ ចាំបាច់យកចិត្តទុកដាក់ បំពាក់បំប៉នបន្ថែម បន្ថែមហើយបន្ថែមទៀតជាប់ជានិច្ច អំពីសីលធម៌១២ប្រការរបស់ជនបដិវត្តន៍នេះជារៀងរហូតទៅ ។ យកសីលធម៌១២ប្រការរបស់ជនបដិវត្តន៍នេះ មកជាក្រឹត្យវិន័យសម្រាប់អនុវត្តជាប់ជាប្រចាំក្នុងជីវិតរបស់ខ្លួន មកជាកញ្ចក់សម្រាប់ឆ្លុះបញ្ចាំងមើលនូវការខុស និងការត្រូវរបស់ខ្លួនក្នុងការប្រព្រឹត្តជាក់ស្តែងប្រចាំថ្ងៃ ដើម្បីកែលម្អ និងកសាងខ្លួនយើងម្នាក់ៗ ក៏ដូចក្នុងការជួយកសាងសមមិត្តដទៃ ឲ្យបានរីកចម្រើនទៅជាជនបដិវត្តន៍ល្អបរិសុទ្ធ រឹងប៉ឹងខ្លាំងក្លាជាបន្តបន្ទាប់ និងជារៀងរហូត ។

**តទៅនេះ ជាសីលធម៌១២ប្រការរបស់ជនបដិវត្តន៍៖**

**១) ស្រឡាញ់ គោរព ហើយបម្រើប្រជាជន កម្មករ កសិករ ជាប់ជានិច្ច ៈ**

បើស្រឡាញ់ គោរពប្រជាជនហើយ យុវជន យុវនារីបដិវត្តន៍យើង គ្មានហេតុផលអ្វីទៅធ្វើអ្វីឲ្យប៉ះពាល់ដល់ប្រជាជនទេ ទោះបីប៉ះពាល់ជាពាក្យសម្តីក្តី ប៉ះពាល់ជាផលប្រយោជន៍របស់ប្រជាជនក្តី ។ បើស្រឡាញ់គោរពប្រជាជនហើយ មុខជានឹងបម្រើប្រជាជនដោយការប្រព្រឹត្តជាក់ស្តែង ឲ្យចេញទៅជាសាច់ការជាបន្តបន្ទាប់ ។

បម្រើប្រជាជននេះ គឺបំពេញភារកិច្ចបដិវត្តន៍របស់ខ្លួន ឲ្យបានល្អ ដោយខ្នះខ្នែង ដោះស្រាយគ្រប់បញ្ហាជូនប្រជាជនឲ្យបានល្អ ហើយយកចិត្តទុកដាក់អប់រំកសាងប្រជាជនក៏ឲ្យបានល្អ ធ្វើយ៉ាងណាឲ្យកម្លាំងប្រជាជនទាំងអស់ទៅជាកម្លាំងបដិវត្តន៍រឹងប៉ឹង ។ បើស្រឡាញ់គោរព ហើយបម្រើប្រជាជនយ៉ាងនេះហើយ ឃើញប្រជាជន មហាជនខុសឆ្គងអ្វីខ្លះៗ យើងមិនរឹងសម្បារ មិនប្រើអាជ្ញា ឬមិនប្រើវិធានការចាត់តាំងទៅលើប្រជាជន មហាជនទេ តែផ្ទុយទៅវិញ យើងឈឺឆ្អាល ខិតខំអប់រំ ណែនាំ និងពន្យល់ប្រជាជន មហាជន ឲ្យគេកាន់តែភ្ញាក់រលឹក ហើយបន្ថយការខុសឆ្គងរបស់គេជាអតិបរមារហូតដល់ប្រជាជន មហាជនភ្ញាក់រឭកបដិវត្តន៍ខ្ពស់ លែងធ្វើអ្វីខុសឆ្គងទៀត ។

នៅតាមមន្ទីរ ក្រសួង យុវជន យុវនារី និងកម្មាភិបាលបដិវត្តន៍យើង មិនបានទៅជាប់នឹងប្រជាជនក៏ពិតមែន តែក៏ត្រូវមានទស្សនៈគោលជំហរ គោរពស្រឡាញ់ប្រជាជនដោយអស់ពីចិត្តពីថ្លើមដែរ ហើយខិតខំបម្រើប្រជាជន តាមរយៈនៃការបំពេញភារកិច្ចស្នូលរបស់ខ្លួនឲ្យបានល្អ ដោយឈ្មុសឈ្មុល ឆ្នៃប្រឌិតគំនិតផ្តួចផ្តើមរស់រវើក និងសន្សំសំចៃខ្ពស់ជាប់ជានិច្ច ។

**២) នៅកន្លែងណា បម្រើប្រជាជននៅកន្លែងនោះ ឲ្យអស់ពីចិត្តពីថ្លើម ៖**

យើងជាជនបដិវត្តន៍ ដូច្នេះជាអ្នកបម្រើប្រជាជនក្នុងគ្រប់កាលៈទេសៈ ។ នៅកន្លែងណាក៏ត្រូវ បម្រើប្រជាជននៅកន្លែងនោះឲ្យបានល្អ ដោយខិតខំបំពេញភារកិច្ចបដិវត្តន៍របស់ខ្លួនឲ្យបានល្អ ឲ្យអស់ពីចិត្តពីថ្លើម ព្រោះនៅកន្លែងណាក៏ដោយ ការងារអ្វីក៏ដោយ សុទ្ធតែបម្រើប្រជាជនទាំងអស់ ។ គ្មានការងារណាថោកទាប គ្មានភារកិច្ចកន្លែងណាវាកិត្តិយសជាងកន្លែងណាទេ ។ ចំពោះយើងជាជនបដិវត្តន៍

បញ្ហាចោទតែត្រង់ថា បំពេញភារកិច្ចបម្រើប្រជាជនបានល្អ ឬមិនល្អតែប៉ុណ្ណោះ ។ ដូច្នេះសូម្បីតែយើងទៅកន្លែងណាម្តងៗ ទោះជារយៈពេលខ្លីក៏ដោយ ក៏ត្រូវតែឆ្លៀតឱកាសរួមធ្វើការងារជាមួយប្រជាជនគ្រប់ពេលវេលា រួមជំរុញការងារនៅកន្លែងនោះឲ្យបានខ្លាំងក្លា ។

**៣) មិនធ្វើអ្វីដែលប៉ះពាល់ដល់ប្រជាជនឲ្យសោះ ទោះជាម្ទេសមួយផ្លែ ឬសម្តីមួយមាត់ក្តី ៖**

នៅក្នុងប្រជាជន យើងច្រើនចាត់ទុកម្ទេសមួយផ្លែ ពីរផ្លែជារបស់តូចតាចបំផុត ។ ប្រជាជនយើងនិយមដាំតាមភូមិ តាមចម្ការ តាមក្បែររបង ក្បែរផ្លូវ សម្រាប់ចែកញាតិសន្តានក្នុងភូមិហូប ។ ដូច្នេះអ្នកណាក៏មកបេះហូបបានដែរ ។ ប៉ុន្តែចំពោះយើងជាជនបដិវត្តន៍ សូម្បីតែផ្លែម្ទេសមួយផ្លែ ដែលប្រជាជនយើងមិនជាចាប់អារម្មណ៍ផងក៏ដោយ ក៏យើងមិនត្រូវប៉ះពាល់ បេះបោចរបស់ប្រជាជន ជាដាច់ខាត ដោយគ្មានសុំអនុញ្ញាតពីម្ចាស់អ្នកដាំជាមុនឡើយ ។ ដូច្នេះជានិយអនុវត្តជាក់ស្តែង បើម្ទេសមួយផ្លែក៏មិនប៉ះពាល់ទៅហើយ បញ្ហាធំៗ ដែលសំខាន់ជាងម្ទេសមួយផ្លែនេះទៅទៀត គឺតាំងពីពាក្យសម្តី មនោសញ្ចេតនា រហូតដល់ផលប្រយោជន៍ធំៗរបស់ប្រជាជនទៀត នោះយើងជាជនបដិវត្តន៍ រឹតតែមិនត្រូវធ្វើ និងមិនប្រព្រឹត្តធ្វើឲ្យប៉ះពាល់ទៅលើប្រជាជនណាស់ទៅទៀត ។ ជានិយអនុវត្តជាក់ស្តែង មយ៉ាងទៀត គឺថា យុវជន យុវនារីបដិវត្តន៍យើងត្រូវប្រុងប្រយ័ត្ន តាំងពីពាក្យសម្តី អាកប្បកិរិយា របៀបរបបធ្វើការងារ រហូតដល់ទស្សនៈគោលជំហរ ធ្វើយ៉ាងណាកុំឲ្យទើសភ្នែក ទើសចិត្តប្រជាជនរហូតកុំឲ្យមានអីប៉ះពាល់ដល់មនោសញ្ចេតនារបស់ប្រជាជន ។

**៤) បើមានការខុសឆ្គងអំពីប្រជាជន ត្រូវសុំទោសប្រជាជន បើមានធ្វើអ្វីឲ្យខូចខាតដល់ប្រជាជន ត្រូវសងប្រជាជនវិញ ៖**

ឥឡូវនេះមិនមែនចោទបញ្ហាសងទេ ។ សំណួមពរសំខាន់របស់បក្ស គឺកុំឲ្យធ្វើអីខុសទៅលើប្រជាជន ។ បើឃើញថាមានខុសអី ទោះតិចតួចក្តី ជាសរសៃញាក់ គឺត្រូវកែប្រែភ្លាម ។ បើនៅជាមួយប្រជាជន ត្រូវធ្វើទិទៀន ស៊ុយតិទៀនចំពោះប្រជាជន ។ បើមិននៅជាមួយគ្នាទេ ក៏ត្រូវរកវិធីទាក់ទងជាមួយប្រជាជន ដើម្បីរកវិធីដោះស្រាយ ធ្វើយ៉ាងណាឲ្យប្រជាជនជ្រះស្រឡះខាងសតិអារម្មណ៍ ។ ជារួមប្រជាជនយើង អត់ទាមទារអ្វីពីយើងទេ ទាមទារតែកាយវិការ និងសីលធម៌បដិវត្តន៍ត្រឹមត្រូវរបស់យើងប៉ុណ្ណោះ ។ ទោះបីមានការលើសលោះធំក្តី តូចក្តី ឲ្យតែយើងបង្ហាញនូវសីលធម៌បដិវត្តន៍ត្រឹមត្រូវ ប្រជាជនអត់មានអីប្រកែកប្រកាន់នឹងយើងទៀតទេ ។

**៥) និយាយស្តី ដេកដើរ ឈរអង្គុយ ស៊ីចុក សៀកពាក់ លេងសើច តាមសភាពប្រជាជន ៖**

កាលពីឆ្នាំ១៩៦៨ ដែលបក្សផ្ញើឯកសារនេះ គឺយើងត្រូវការប្រជាជនណាស់ ព្រោះប្រជាជនទូទៅស្ថិតនៅក្នុងកណ្ដាប់ដៃខ្មាំងនៅឡើយ ។ ឯយើងពេលនោះ អត់ទាន់មានប្រជាជនទេ ។ យើងត្រូវការប្រាស្រ័យទាក់ទងជាមួយប្រជាជនណាស់ ។ ដូច្នេះ ក្នុងការរស់នៅប្រចាំថ្ងៃ ក៏ដូចក្នុងការធ្វើការងារ យុទ្ធជន យុទ្ធនារី និងកម្មាភិបាលបដិវត្តន៍គ្រប់ថ្នាក់ តែងសម្របខ្លួនតាមសភាពប្រជាជន ។ ទាំងក្នុងការនិយាយស្ដី ទាំងក្នុងការឈរអង្គុយ ស៊ីចុក ស្លៀកពាក់ រហូតដល់ការលេងសើចទៀត យើងប្រយ័ត្នប្រយែងណាស់ មិនធ្វើអ្វីឲ្យខុសពីសភាពប្រជាជន ពោលគឺមិនធ្វើអ្វីឲ្យទាស់ភ្នែក ឬប៉ះអារម្មណ៍ប្រជាជនឡើយ ។ ម្យ៉ាងដើម្បីបង្កប់ខ្លួននៅក្នុងប្រជាជន លាក់បំពួនខ្លួនពីភ្នែកខ្មាំងសត្រូវ ។ តែម្យ៉ាងទៀត ក៏ដើម្បីឲ្យប្រជាជនស្រឡាញ់ពេញចិត្តពេញថ្លើម ជឿទុកចិត្តលើបុគ្គលយើង ។ ហើយតាមរយៈនេះក៏ប្រជាជនស្រឡាញ់ជឿជាក់ ហើយខបត្ថម្ភគាំទ្រចលនាបដិវត្តន៍ និងចូលរួមប្រាស្រ័យ ធ្វើបដិវត្តន៍ ដោយមោះមុតដាច់ខាត ។

ចុះឥឡូវ យើងកាន់កាប់រដ្ឋអំណាចទូទាំងប្រទេសហើយ ប្រជាជននៅជាមួយយើងទាំងអស់ហើយ តែយើងត្រូវកែប្រែនូវទស្សនៈគោលជំហរ អាកប្បកិរិយារបស់យើងខាងលើនេះទេ?

◆ ប្រជាជននៅជាមួយបដិវត្តន៍ក៏ព្រោះតែស្រឡាញ់ ហើយជឿទុកចិត្ត និងកក់ក្ដៅលើបដិវត្តន៍ យល់ឃើញថា បដិវត្តន៍ល្អត្រឹមត្រូវ បដិវត្តន៍បម្រើ និងគាំពារផលប្រយោជន៍គេ ។ តែបើពេលណា យុទ្ធជន យុទ្ធនារី និងកម្មាភិបាលបដិវត្តន៍យើងគ្រប់ថ្នាក់ កែប្រែនូវអាកប្បកិរិយា ឬទស្សនៈគោលជំហរ ដែលជាសីលធម៌បដិវត្តន៍របស់យើងខាងលើនេះ ហើយនោះប្រជាជនមុខជាមិនពេញចិត្តនឹងយើងទេ ហើយរហូតដល់ខឹងសម្បារ ហើយស្អប់យើង មិនចង់ឲ្យចូលភូមិទៀតផង ។ ដូច្នេះ យើងដាច់ពីប្រជាជនតាមរយៈនេះ បដិវត្តន៍ និងដាច់ពីប្រជាជន គ្មានកម្លាំងប្រជាជនខបត្ថម្ភគាំទ្រ ។ ដូច្នេះធ្វើអ្វីក៏មិនខ្លាំងដែរ ការពារប្រទេសក៏មិនខ្លាំង កសាងប្រទេសក៏មិនលឿន ។ ការនេះបញ្ជាក់ឲ្យយើងឃើញច្បាស់ថា នៅក្នុងរយៈកាលថ្មីនៃបដិវត្តន៍កម្ពុជាបច្ចុប្បន្ននេះ យើងរឹតតែត្រូវការកម្លាំងប្រជាជនណាស់ទៅទៀត ដើម្បីការពារប្រទេសឲ្យបានខ្លាំងក្លា និងកសាងប្រទេសក៏ឲ្យបានខ្លាំងក្លា និងលឿនលោតផ្លោះ ។

**៦) កុំប្រព្រឹត្តអំពើអ្វីដែលល្មើសនឹងស្ត្រីភេទឲ្យសោះ ៖**

និយាយរួម គឺកុំប៉ះពាល់សីលធម៌នារី បុរសឲ្យសោះ ព្រោះបញ្ហានេះ វានាំឲ្យប៉ះពាល់កិត្តិយសយើង ឥទ្ធិពលយើងជាជនបដិវត្តន៍ នាំឲ្យប៉ះពាល់ដល់ប្រពៃណីស្អាតស្អំ ថ្លៃថ្នូររបស់ប្រជាជនយើង ។ ដូច្នេះ ប៉ះពាល់ដល់ប្រជាជនយើងនេះម្យ៉ាង ។ តែសំខាន់ម្យ៉ាងទៀត គឺបើយើងប៉ះពាល់ សីលធម៌នារី បុរស ដែលជាធាតុពិតពុករលួយស្អុយគគ្រុករបស់ខ្មាំងសត្រូវគ្រប់ប្រភេទនោះ និងនាំឲ្យខ្មាំងអូសទាញយើងបាន ។ ដូច្នេះ គ្រោះថ្នាក់ដល់ខ្លួន គ្រោះថ្នាក់ដល់ចលនាបដិវត្តន៍ ។

ចំពោះបញ្ហារៀបចំគ្រួសារបច្ចុប្បន្ននេះ គ្មានអ្វីជាខបសគ្គទេ ឲ្យតែឈរលើគោលការណ៍របស់បក្សទាំងពីរយ៉ាងគឺ៖

ទី១) សាមីខ្លួនទាំងសងខាងយល់ព្រម

ទី២) សមូហភាពយល់ព្រម ក៏ជាការស្រេចទៅហើយ ។ តើមានហេតុផលអីនាំឲ្យយើងប៉ះពាល់សីលធម៌នារីបុរស ។

**៧) កុំផឹកស៊ីអ្វី ដែលមានលក្ខណៈមិនបដិវត្តន៍ឲ្យសោះ ៖**

កាលពីសម័យមុនរំដោះ បញ្ហានេះវាមានពាសពេញសង្គមជាតិយើង ។ ដូច្នេះ ជនបដិវត្តន៍គ្រប់រូបត្រូវបង្ការលើបញ្ហានេះ តែឥឡូវនេះ អត់មានបញ្ហានេះទេ តែក៏ត្រូវអប់រំ កុំឲ្យផឹកស៊ីអ្វីដែលខុសពីជីវភាពរស់នៅរបស់ប្រជាជន ។ ពោលគឺយើងត្រូវរស់ឲ្យសមរម្យតាមមាគ៌ា តាមលក្ខការណ៍ និងតាមរបបបក្សកំណត់ ។ បើមានឃើញជនណា ទោះជាកម្មាភិបាលថ្នាក់ណាក្ដី ឬយុទ្ធជន យុទ្ធនារីក្ដី ឬក្នុងប្រជាជនក្ដី មានសភាពស៊ីផឹកនេះ យើងត្រូវចាប់អារម្មណ៍ អប់រំកសាង ឬពិនិត្យតាមដាន ក្រែងលោមានសមាសភាពខ្មាំងបង្កប់ វាបំផុសបញ្ហានេះឡើង ។

**៨) កុំលេងល្បែងស៊ីសងឲ្យសោះ ៖**

ឥឡូវនេះ គ្មានល្បែងស៊ីសងអីទៀតទេ ។ តែទោះជាយ៉ាងនេះក៏ដោយ ក៏ត្រូវអប់រំជាប់ ដើម្បីផ្ដាច់ឬសគល់វាឲ្យអស់ពីសង្គមជាតិយើង ។

**៩) កុំប៉ះពាល់ដល់លុយកាក់រួម ទ្រព្យសម្បត្តិរួម ទោះជាប្រាក់មួយរៀលក្ដី អង្ករមួយកំប៉ុង ឬថ្នាំមួយគ្រាប់ក្ដី ៖**

ឥឡូវយើងកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ជាសមូហភាពហើយ ។ តែក៏ត្រូវអប់រំ បំពាក់បំប៉នសីលធម៌បដិវត្តន៍ទី៩ នេះឲ្យបានជាប់ជាប្រចាំដែរ ។ កុំប៉ះពាល់ក្នុងនេះ គឺកុំយកប្រើប្រាស់ ខ្ជះខ្ជាយ រាយមាយ គឺត្រូវថែទាំ ទុកដាក់ហ្មត់ចត់ សម្រាប់ប្រើប្រាស់កសាង

ប្រទេស ការពារប្រទេសឲ្យបានយូរអង្វែង ។ គឺសន្សំសំចៃនូវរបស់របរសព្វសារពើឲ្យបានជាអតិបរមា កុំឲ្យខូចខាតចោលអាសារឥតការ ។ ជាន័យអនុវត្តមួយទៀត កុំប៉ះពាល់ទ្រព្យសម្បត្តិរួម គឺបើទុកដាក់សម្ភាររួម ត្រូវថែទាំឲ្យគត់មត់ កុំឲ្យខូចខាត ទោះបីបន្តិចបន្តួចក្តី ។ បើធ្វើការងារ ត្រូវបន្ថយការខូចខាត ការបាក់បែក ការបាត់បង់ឲ្យបានជាអតិបរមា ។ ដូច្នេះ ក្នុងការប្រជុំជីវភាព ត្រូវកសាងអំពីបញ្ហានេះឲ្យជាប់ ។

**១០) សុភាពរាបសារដាច់ខាតចំពោះប្រជាជន តែមានកំហឹងឆាបឆេះជានិច្ចចំពោះខ្មាំង ៖**

សីលធម៌របស់យើង គឺសុភាពរាបសារចំពោះប្រជាជន តែឆាបឆេះចំពោះខ្មាំង ។ បើឆាបឆេះចំពោះខ្មាំងហើយ យើងសកម្មប្រយុទ្ធហើយ ។ សកម្មប្រយុទ្ធ ទាំងនៅសមរភូមិមុខ សកម្មប្រយុទ្ធទាំងនៅសមរភូមិក្រោយ ។ ដូច្នេះ ត្រូវអប់រំរៀនសូត្រជាប់ ។ អប់រំហើយ ត្រូវចាត់តាំង ព្រោះបើធ្វើតែការងារនយោបាយ សតិអារម្មណ៍ មិនចាត់តាំងនោះ មិនអាចសកម្មប្រយុទ្ធទៅបានទេ ។

**១១) ស្រឡាញ់ ហើយធ្វើពលិកម្មជានិច្ច ៖**

ន័យពលិកម្មនេះ គឺការងារគ្រប់ផ្នែកដែលទទួលបន្ទុកចំពោះបក្ស ។ ត្រូវខិតខំបំពេញភារកិច្ច ដែលជាការងារស្នូលរបស់ខ្លួនដោយពេញចិត្តពេញថ្លើម និងហ្មត់ចត់ ។ ត្រូវចៀសវាងយ៉ាងណាកុំ ឲ្យខុស គឺឲ្យចេះតែចម្រើនទៅមុខជានិច្ច ។

ស្រឡាញ់ពលកម្មក្នុងន័យទី២ គឺពលកម្មបង្កបង្កើនផល ។ ក្រៅពីការងារស្នូល ត្រូវស្រឡាញ់ ពេញចិត្ត ពេញថ្លើម រួមកម្លាំងក្នុងកិច្ចការពលកម្មបង្កបង្កើនផល ឲ្យចេញជាបន្លែបន្ការ ជាឈើហូបផ្លែ និងជាដំណាំដំដុះសព្វមុខ ។ មួយថ្ងៃកើនបន្តិចៗ មន្ទីរក្រសួងមួយៗ ភូមិដ្ឋានមួយៗ វាទៅជាសួនដំណាំ ។ ម្យ៉ាងយើងចាត់ចែងធ្វើ ម្យ៉ាងទៀតត្រូវឆ្លៀតពេលរួមធ្វើជាមួយមហាជន ដោយស្រឡាញ់ ពេញចិត្តពេញថ្លើម ។

**១២) ប្រយុទ្ធនឹងខ្មាំង ប្រយុទ្ធនឹងឧបសគ្គដោយអង់អាចហើយហ៊ានធ្វើពលិកម្មគ្រប់បែបយ៉ាងជូនប្រជាជនកម្មករ កសិករ ជូនបក្ស ជូនបដិវត្តន៍ ដោយឥតលក្ខខណ្ឌ ក្នុងគ្រប់កាលៈទេសៈ ៖**

នេះជាសីលធម៌របស់ជនកុម្មុយនីស្តរបស់ជនបដិវត្តន៍ដែលចេញមកពីធាតុពិតរបស់វណ្ណៈអធន ដែលឈានមុខលះបង់អ្វីៗទាំងអស់ ។ ក្នុងការប្រយុទ្ធនឹងខ្មាំង ក៏ដូចប្រយុទ្ធនឹងឧបសគ្គនានាបច្ចុប្បន្ននេះ យើងមានលក្ខណៈងាយស្រួលច្រើនជាងមុនឆ្ងាយណាស់ ។ មិនដូចពីជំនាន់មុនទេ ដែលស្អីក៏ខ្វះ ស្អីក៏ខ្វះសព្វខ្វះគ្រប់ ។ បញ្ហាវាចោទតែលើសីលធម៌ប្រយុទ្ធធ្វើ ។ បើយើងមានសីលធម៌ប្រយុទ្ធស្រួចស្រាវ ពុះពារគ្រប់ឧបសគ្គបានហើយ ហើយមានការចាត់តាំងធ្វើ ឬប្រយុទ្ធជាសមូហភាពទៀត នោះគ្មានខ្មាំងសត្រូវណាមកធ្វើអីយើងបានទេ គ្មានឧបសគ្គណា មករាំងស្ទះដំណើរលោតផ្លោះរបស់យើងបានទេ ។ ប៉ុន្តែផ្ទុយទៅវិញ ទោះបីមានលក្ខណៈសម្បត្តិល្អយ៉ាងណា មានមធ្យោបាយច្រើនយ៉ាងណា តែបើគ្មានសីលធម៌ប្រយុទ្ធស្រួចស្រាវ មោះមុតពុះពារគ្រប់ឧបសគ្គ និងជម្នះការលំបាកសព្វបែបយ៉ាងទេ ក៏ពុំអាចធ្វើអ្វីកើតដែរ ឬបើទោះជាធ្វើបាន ក៏យឺតយ៉ាវ មិនខ្លាំងក្លា មិនលោតផ្លោះ តាមសំណូមពររបស់ចលនាបដិវត្តន៍ឡើយ ។ **ឆេង ទេង**

## រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទ ឬ សៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម ÷

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរស័ព្ទលេខៈ (៨៥៥) (១២) ៩៩៦ ៧៥០

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

Email: truthbunthorn.s@dccam.org

Home page: www.dccam.org

# ពិធីបើកសម្ពោធការតាំងពិព័រណ៍របស់កម្ពុជា រៀប
# ហូឡូខសត៍ ទីក្រុងវ៉ាស៊ីនតោនឌី.ស៊ី សហរដ្ឋ










# រចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា នៅសារមន្ទីរ អាមេរិក កាលពីថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៥










# គណៈស្រុកព្រះនេត្រព្រះ ៖ «ទុកជីវិតដើម្បីបម្រើការងារចាប់ចង»


ពុំ ខូ ហៅ តាខូ អតីតគណៈស្រុកព្រះនេត្រ ក្នុងរបបខ្មែរក្រហម

បន្ទាប់ពីខ្មែរក្រហមឡើងកាន់កាប់អំណាចនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ អង្គការខ្មែរក្រហមបានចាត់តាំងឲ្យកម្មាភិបាល ៤រូបឲ្យទទួលដឹកនាំស្រុកព្រះនេត្រព្រះ ។ ក្នុងនោះមាន អន មៅ៉ង ហៅ តាមៅ៉ង ទទួលជាលេខាស្រុក, សំអាត ហៅ តាសំអាត ជាអនុលេខា, តាពត និង ពុំ ខូ ហៅ តាខូ ទទួលជាសមាជិកគណៈកម្មាធិការស្រុក ។ តាខូ បានរួចផុតខ្លួនពីការចាប់ខ្លួន និងសម្លាប់ ដោយសារតែគណៈស្រុកព្រះនេត្រព្រះដែលផ្លាស់មកពីភូមិភាគនិរតីក្នុងឆ្នាំ១៩៧៧ ទុកសម្រាប់ជួយសម្រួលការងារចាប់ចង និងដឹកនាំប្រជាជនពីព្រោះពួកគេមិនស្គាល់ភូមិសាស្ត្រ និងកម្មាភិបាលដឹកនាំចាស់នៅតាមឃុំ តាមសហករណ៍ក្នុងស្រុកព្រះនេត្រព្រះ ។

ខូ មានស្រុកកំណើតនៅភូមិកំពង់ព្រះ ឃុំកំពង់ព្រះ ស្រុកសង្កែ ខេត្តបាត់ដំបង ។ ខូ ជាក្មេងកំព្រាឪពុកម្ដាយតាំងពីអាយុ ៥ឆ្នាំ ។ តាខូ មានបងប្អូនស្រីប្រុសចំនួន៧នាក់ ។ ខូ ជាកូនទី៥ក្នុងគ្រួសារ ។ កាលពីក្មេង ខូ មិនបានចូលសាលារៀនសូត្រឡើយ ព្រោះតែគ្រួសារមានជីវភាពក្រលំបាក រកព្រឹកខ្វះល្ងាច ។ តាខូ តែងតែជួយធ្វើស្រែចម្ការបងស្រី និងដើរស៊ីឈ្នួលគេដើម្បីបានលុយទិញអង្ករ ។ នៅឆ្នាំ១៩៧០ នៅពេលមានរដ្ឋប្រហារទម្លាក់សម្ដេចសីហនុ តំបន់ភាគច្រើននៅក្នុងខេត្តបាត់ដំបងបានក្លាយជាតំបន់រំដោះដែលគ្រប់គ្រងដោយខ្មែរក្រហម ។ ដោយមានការប្រកាសរបស់សម្ដេច សីហនុ ឲ្យកូនចៅឲ្យចូលព្រៃម៉ាគីដើម្បីរំដោះជាតិនោះ មានយុវជនយុវនារីជាច្រើនបានចូលរួមតស៊ូជាមួយពួកខ្មែរក្រហម ។ នៅឆ្នាំ១៩៧១ ខូ បានចាកចេញពីស្រុកកំណើតដើម្បីចូលព្រៃតស៊ូប្រឆាំងនឹងរបប លន់ នល់ ដោយដើរឃោសនាអប់រំប្រជាជនឲ្យយល់ដឹងពីមាគ៌ាបដិវត្តន៍របស់ខ្មែរក្រហម ។ បន្ទាប់មកអង្គការខ្មែរក្រហមបានបញ្ជូនឲ្យទៅស្រុកសូត្រនិគម ខេត្តសៀមរាម (តំបន់៣៥) ដើម្បីរៀនក្បួនយុទ្ធសាស្ត្រយោធា ដែលមានរយៈពេលបីខែ ។ ខណៈពេលនោះ ខូ និងយុវជនដ៏ទៃទៀតបានរៀនពីរបៀបលូនចូលក្នុងបន្ទាយដើម្បីស៊ើបការណ៍ រៀនរបៀបបោកគ្រាប់បែកដៃ និងរៀនសូត្រយុទ្ធសាស្ត្រច្រើនផ្សេងទៀត ។ បន្ទាប់ពីបញ្ចប់វគ្គរៀនសូត្រ ខូ ត្រូវបានអង្គការជ្រើសរើសឲ្យធ្វើជានីរសារជាអ្នករត់សំបុត្រ ។ អ្នករត់សំបុត្រពេលនោះមានគ្នាបីទៅបួននាក់រួមមាន ឈ្មោះ ឡាម ឈ្មោះ តុញ ឈ្មោះ វ៉ាង រត់សំបុត្រពីខេត្តសៀមរាប ទៅខេត្តបាត់ដំបង ជូនណាទៅស្វាយស៊ីសុផុន ។ នៅឆ្នាំ១៩៧២-៧៣ តំបន់ភាគច្រើនរបស់ខេត្តសៀមរាប រួមមានតំបន់ភ្នំក្រោម, អង្គរតូច, អង្គរធំ និងតំបន់ផ្សេងៗទៀត បានស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម ។ នៅពេលនោះ តាសុត ជាគណៈតំបន់សៀមរាប (តំបន់៣៥) ។

បន្ទាប់ពីខ្មែរក្រហមបានឡើងកាន់អំណាចទូទាំងប្រទេសនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខូ ត្រូវបានអង្គការបញ្ជូនមកខាងស្រុកព្រះនេត្រ និងទទួលនាទីជាសមាជិកស្រុក រួមជាមួយកម្មាភិបាល ៣រូបផ្សេងទៀត គឺ តាម៉ោង, តាសំអាត និង តាពត ។ នៅខណៈពេលនោះ តាម៉ោង គ្រប់គ្រងរួម ។ ចំណែក តាសំអាត, តាពត និង ខូ ទទួលខាងស្ថិតិ និងសេដ្ឋកិច្ច ។ នៅក្នុងឆ្នាំ១៩៧៥ នេះដែរ ខូ ត្រូវបានអង្គការរៀបចំឲ្យមានគ្រួសារ ។ ប្រពន្ធរបស់ ខូ

មានឈ្មោះ ស៊ុន និងមានស្រុកកំណើតនៅស្រុកក្រឡាញ់ ខេត្តសៀមរាប ។

ស្រុកព្រះនេត្រព្រះមានឃុំចំនួន៦ គឺឃុំព្រះនេត្រព្រះ ឃុំទានកម្ម ឃុំភ្នំលាភ ឃុំទឹកជោរ ឃុំប្រាសាទ និងឃុំរហាល ។ ទោះជាកាន់ខាងស្ថិតិ ប៉ុន្តែ ខូ មិនបានដឹងច្បាស់ថាប្រជាជនរស់នៅក្នុងស្រុកព្រះនេត្រព្រះមានចំនួនប៉ុន្មានម៉ឺន សែននាក់ឲ្យប្រាកដឡើយ គ្រាន់តែដឹងថាប្រជាជន១៧មេសា មានចំនួនច្រើនជាងប្រជាជនមូលដ្ឋាន ។ នៅក្នុងស្រុកព្រះនេត្រព្រះប្រជាជនភាគច្រើនស្លាប់ដោយសារអង្គការចាប់ខ្លួន និងអត់មានអាហារហូបចុកគ្រប់គ្រាន់ ព្រោះថ្នាក់ដឹកនាំស្រុកមិនបានធ្វើបញ្ជីឲ្យបានច្បាស់លាស់ថាមានប្រជាជនចំនួនប៉ុន្មានត្រូវការអង្ករប៉ុន្មានតោន ម្យ៉ាងទៀតខ្មែរក្រហមក៏មិនបានបែងចែកកម្លាំងឲ្យច្បាស់លាស់ដែរ ។

ខូ បានឲ្យដឹងទៀតថា ប្រជាជន១៧មេសាភាគច្រើនបានរាយការណ៍ពីគ្នាទៅវិញទៅមក ទើបខ្មែរក្រហមដឹងពីសមាសភាពថា នរណាជាមន្ត្រីរាជការ ឬជាទាហានរបស់របប លន់ នល់ ពាក់សក្តិប៉ុន្មានៗ ដែលជាមុខសញ្ញាត្រូវខ្មែរក្រហមចាប់បញ្ជូនពីថ្នាក់ឃុំទៅថ្នាក់ស្រុក និងបញ្ជូនបន្តទៅថ្នាក់តំបន់ទៀត ។

នៅក្នុងខែតុលា ឆ្នាំ១៩៧៥ ខូ ត្រូវបានអង្គការចោទថាខុសសីលធម៌ជាមួយបុគ្គលិកមន្ទីរពេទ្យ ពេលនោះត្រូវអង្គការចាប់ផ្តើមតាមដាន និងបញ្ឈរជើង ។ ខណៈពេលនោះ ខូ នៅមានតួនាទីតែមួយ គឺដើរមើលប្រជាជនធ្វើការងារ និងធ្វើស្រែនៅឃុំចំនួនបី គឺឃុំទឹកជោរ ឃុំភ្នំលាភ ឃុំប្រាសាទ ។

នៅឆ្នាំ១៩៧៧-៧៨ នៅភូមិភាគពាយ័ព្យមានការផ្លាស់ប្តូរកម្មាភិបាលខ្មែរក្រហមជាទ្រង់ទ្រាយធំ ដោយសារអង្គការខ្មែរក្រហមបានយកកម្មាភិបាលពីភូមិភាគនិរតី ដែលមានភក្តីភាពជាមួយ តាម៉ុក ឲ្យមកគ្រប់គ្រងជំនួសកម្មាភិបាលចាស់នៅភូមិភាគពាយ័ព្យដែលត្រូវចោទថាក្បត់ហើយត្រូវចាប់ខ្លួន និងសម្លាប់ចោល ។ បើតាម ខូ ដឹង គណៈភូមិភាគពាយ័ព្យឈ្មោះ រស់ ញឹម, គណៈតំបន់៥ ឈ្មោះ ហ៊ីង, ឈ្មោះ ជាល, គណៈស្រុកព្រះនេត្រព្រះ ឈ្មោះ ម៉ោង ឈ្មោះ សំអាត, និងគណៈ ឃុំក្នុងស្រុកព្រះនេត្រព្រះជាច្រើននាក់ផ្សេងទៀតត្រូវបានចាប់ខ្លួន និងបានបញ្ជូនទៅបាត់តែម្តង ។

ខូ មានសំណាងបានរួចផុតពីការចាប់ខ្លួន ពីព្រោះ ខូ មានកំហុសត្រូវបានកម្មាភិបាលចាស់បញ្ឈរជើងតាំងពីចុងឆ្នាំ១៩៧៥ ហើយម្យ៉ាងវិញទៀត កម្មាភិបាលខាងនិរតីត្រូវការអ្នកចាស់ៗដែលស្គាល់ភូមិសាស្ត្រ, ប្រជាជន និងកម្មាភិបាលខ្មែរក្រហមចាស់ៗដឹកនាំតាមថ្នាក់ឃុំ និងសហករណ៍ក្នុងស្រុកព្រះនេត្រព្រះទាំងមូល ។ ដូច្នេះ ខូ ត្រូវបានកម្មាភិបាលនិរតីប្រើប្រាស់ជាបណ្តោះអាសន្ន ដើម្បីងាយស្រួលធ្វើការជាមួយប្រជាជន និងការស្វែងរកចាប់កម្មាភិបាលចាស់ៗបន្តទៀត ។

បន្ទាប់ពីកម្មាភិបាលខាងនិរតីមកដឹកនាំស្រុកព្រះនេត្រព្រះ ខូ នៅតែទទួលការងារដើរមើលប្រជាជនធ្វើការងារ និងធ្វើស្រែនៅក្នុងឃុំទឹកជោរ ឃុំភ្នំលាភ ឃុំប្រាសាទដដែល ។ ផ្ទះរបស់ ខូ ស្ថិតនៅឃុំភ្នំលាភ គឺនៅជិតនឹងផ្ទះ យាយ ថែម ដែលជាគណៈស្រុកព្រះនេត្រព្រះមកពីខាងភូមិភាគនិរតី ។ យាយ ថែម ទៅធ្វើការនៅសាលាស្រុកនៅព្រះនេត្រព្រះដោយមាននីរសារជាអ្នកឌុបតាមម៉ូតូ សេ-អ៊ិល ។

ខូ បានដឹងថាឈ្មោះសមមិត្ត រៀម មាននាទីជាប្រធានយោធា និងសន្តិសុខតំបន់៥ មកពីភូមិភាគនិរតីបានបើករថយន្តមួយគ្រឿងដើរចាប់កម្មាភិបាលថ្នាក់ភូមិ ថ្នាក់ឃុំ ថ្នាក់ស្រុក និងថ្នាក់តំបន់៥ យកទៅដាក់មន្ទីរសន្តិសុខហើយ ខូ មិនដែលបានឃើញអ្នកទាំងនោះត្រឡប់មកវិញទេ ។ រៀម ជាប្រធានសន្តិសុខដែលមានចរិតកាចសាហាវឲ្យតែមានឈ្មោះនៅក្នុងបញ្ជីដែលត្រូវចាប់ខ្លួនហើយ គឺចាប់យកទាំងអស់គ្មានការលើកលែងម្នាក់ឡើយ ។ នៅពេលដែលចាប់ខ្លួនមេឃុំប្រាសាទ ឈ្មោះ គង់, ឈ្មោះ អឿន, មេឃុំភ្នំលាភ ឈ្មោះ ធាង និងឃុំទឹកជោរ ឈ្មោះ ឆាង និងឈ្មោះ សៅ គឺ ខូ បាននៅជាមួយ រៀម ដែរ ហើយមេឃុំទាំងនោះបានស្រែកអង្វរឲ្យ ខូ ជួយខ្លួនថែមទៀត ផង ។ ការស្រែកឲ្យជួយនេះបានធ្វើ ខូ មានអារម្មណ៍ភ័យខ្លាចតែ រៀម ចាប់ខ្លួនគាត់ទៀត ។

បន្ទាប់ពួកនិរតីមកគ្រប់គ្រងនៅស្រុកព្រះនេត្រព្រះ ពួកគេបានបង្កើតមន្ទីរលត់ដំមួយកន្លែងនៅភ្នំត្រយូង ។ អ្នកទោសដែលជាប់នៅភ្នំទ្រយោងនោះត្រូវបានខ្មែរក្រហមបង្ខំឲ្យវាយថ្ម ។

ចំពោះការអត់បាយខ្លាំងនៅចុងឆ្នាំ១៩៧៧នោះ មូលហេតុសំខាន់ គឺដោយសារតែកម្មាភិបាលមកពីភូមិភាគនិរតីមិនបាន

ពិភាក្សាជាមួយអ្នកមូលដ្ឋាននៅទីនេះ អំពីរបៀបធ្វើស្រែនៅកន្លែងណាមានទឹករាក់ត្រូវធ្វើយ៉ាងម៉េច ហើយកន្លែងមានទឹកជ្រៅត្រូវធ្វើយ៉ាងម៉េច គឺពួកគេបញ្ជាឲ្យប្រជាជន ធ្វើតាមចិត្តនឹកឃើញនៅរដូវវស្សា កន្លែងធ្វើស្រែភាគច្រើនមានទឹកជ្រៅ ហើយស្ទូវស្រូវតាមរបៀបអ្នកស្រុកនៅខាងភូមិភាគនិរតី ដល់ពេលទឹកជំនន់ឡើងមក គឺលិចខូចស្រូវអស់ អ៊ីចឹងបានជាប្រជាជនខ្វះខាត គ្មានអាហារហូបចុកគ្រប់គ្រាន់ធ្វើឲ្យកើតមានជំងឺឈឺហើមស្លាប់ច្រើន ។

នៅឆ្នាំ១៩៧៩ ខូ, រៀម, យាយ ចែម ព្រមទាំងកម្មាភិបាលភូមិភាគនិរតីទាំងអស់បាននាំគ្នារត់ចូលព្រៃព្រោះខ្លាចប្រជាជនសងសឹក ។ ខូ អះអាងថា ខ្លួនមិនបានធ្វើអាក្រក់ទៅលើប្រជាជននៅស្រុកព្រះនេត្រព្រះទេ តែ ខូ ខ្លាចប្រជាជនយល់ច្រឡំថាខ្លួនបានប្រព្រឹត្តអំពើឃោរឃៅដែរ ពីព្រោះកាលជំនាន់នោះ ខូ បានដើរជាមួយកម្មាភិបាលខ្មែរក្រហមដែលផ្លាស់មកពីភូមិភាគនិរតី ។

នៅក្នុងឆ្នាំ១៩៧៩នោះដែរ ខូ បាននាំប្រពន្ធកូនរត់ទៅរស់នៅជាប់ព្រំដែនថៃ នៅម្តុំភ្នំឆត្រ បន្ទាប់មកបានចូលបម្រើជាយោធាខ្មែរក្រហមបន្តទៀត ។ ខូ នៅកងពល៥១៩ ដែលមានប្រធានកងពលឈ្មោះ ឌុល សារឿន ។

នៅឆ្នាំ១៩៨២-៨៣ អង្គការបានបញ្ជូន ខូ ឲ្យមកវាយជាមួយទាហានវៀតណាមនិងទាហានខាងរបបសាធារណរដ្ឋប្រជាមានិតកម្ពុជានៅម្តុំបឹងទន្លេសាប ។ នៅឆ្នាំ១៩៨៥ ប្រពន្ធដើម ខូ ឈ្មោះ ស៊ុន ត្រូវខ្មែរក្រហមបញ្ជូនមករស់នៅស្រុកម៉ាឡៃ ។ បន្តិចក្រោយប្រពន្ធរបស់ ខូ មានជំងឺ និងបានស្លាប់នៅម៉ាឡៃ ។ នៅឆ្នាំ១៩៨៨ ខូ បានឡើងមកពីបឹងទន្លេសាបវិញ ហើយបានរៀបការប្រពន្ធថ្មីមួយផ្សេងទៀតឈ្មោះ វ៉ែត ។ នៅឆ្នាំ ១៩៩៣ ខូ បានផ្លាស់មករស់នៅក្នុងស្រុកថ្មពួកវិញ ។ ខូ បានដឹងថា យាយ ចែម សព្វថ្ងៃរស់នៅក្នុងស្រុកអន្លង់វែង ។ ចំណែកឈ្មោះ រៀម ប្រហែលរស់នៅខាងស្រុកម៉ាឡៃ និងភ្នំព្រឹក ។

**សុក ខណ្ណៈ**

# ដំណឹងស្វែងរកឪពុកមា

ខ្ញុំបាទឈ្មោះ ច័ន្ទ រិទ្ធី បច្ចុប្បន្នរស់នៅខណ្ឌសែនសុខ សង្កាត់ភ្នំពេញថ្មី ក្រុងភ្នំពេញ ។ ខ្ញុំបាទសូមប្រកាសរកឪពុកមា ឈ្មោះ សាប់ សំផន ដែលបានបាត់ខ្លួនក្នុងឆ្នាំ១៩៧៥ ក្រោយខ្មែរក្រហមរំដោះទីក្រុងភ្នំពេញ ។ លោកមា សាប់ សំផន មានស្រុកកំណើតនៅភូមិព្រៃលាភ ខេត្តកណ្តាល ។ គាត់មានឪពុកឈ្មោះ សាប់ ឈុន (ស្លាប់) និងម្តាយ ងួន វ៉ាន់ (រស់) និងមានបងប្អូនប្រុសស្រី៦នាក់រួមមាន ៖ ១) សាប់ សេរីឈុំ ភេទស្រី (ស្លាប់ក្នុងរបបខ្មែរក្រហម), ២) សាប់ សំផន ភេទប្រុស (បាត់ខ្លួនក្នុងរបបខ្មែរក្រហម), ៣) សាប់ ធីគន្ធ ភេទស្រី (ស្លាប់ក្នុងរបបខ្មែរក្រហម), ៤) សាប់ សុខារី ភេទស្រី, ៥) សាប់ វ៉ាន់នីន ភេទប្រុស, ៦) សាប់ ភូមិរិន្ទ ភេទស្រី ។

សូមបញ្ជាក់ថា ក្នុងរបបសាធារណរដ្ឋខ្មែរ លោកមា សាប់ សំផន ជាទាហាននៅបន្ទាយស្ទឹងមានជ័យ និងក្រោយមក ផ្លាស់ទៅធ្វើជាទាហានជើងទឹកនៅកំពង់សោម ខេត្តព្រះសីហនុ ។ ក្រោយថ្ងៃរំដោះ១៧មេសា ឆ្នាំ១៩៧៥ កូនទាហានម្នាក់បានជូនគាត់ឡើងគោកក្នុងគោលបំណងជូនលោកមាមករកក្រុមគ្រួសារ ហើយក៏បាត់ដំណឹងតាំងពីពេលនោះមក ។

អាស្រ័យហេតុនេះ បើបងប្អូនណាបានឃើញ និងស្គាល់លោកមារបស់ខ្ញុំឈ្មោះ សាប់ សំផន ដូចដែលបានរៀបរាប់ខាងលើ សូមទាក់ទងមកខ្ញុំបាទតាមទូរស័ព្ទលេខៈ ០១៦ ៨៧៩ ៣៩៨ ឬ ទំនាក់ទំនងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា ផ្ទះលេខ៦៦, មហាវិថីព្រះសីហនុ, រាជធានីភ្នំពេញ ឬ តាមរយៈទូរស័ព្ទ ០២៣ ២១១ ៨៧៥ ។

***សូមអរគុណ!***

# រកឃើញឯកសារ តែនៅមិនអស់ចម្ងល់

ថ្មីៗនេះ កូនរបស់ លឹម គឹមហួ បានរកឃើញឯកសារទាក់ទងឪពុកមាខ្លួនឈ្មោះ យូ ឈួន ម៉េងគា ដោយចៃដន្យតាមរយៈប្រព័ន្ធទិន្នន័យ ដេតាបេស (Database) នៃគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ កូនរបស់ គឹមហួ បានស្គាល់ឈ្មោះពូខ្លួនតាមរយៈការស្តាប់ម្តាយនិទានប្រាប់ជារឿយពីប្រវត្តិក្រុមគ្រួសារ រួចហើយបាននាំដំណឹងនេះទៅប្រាប់ម្តាយវិញ ។ ដើម្បីឲ្យដឹងច្បាស់ គឹមហួ បានពិនិត្យមើលឈ្មោះ និងឯកសារប្រវត្តិរូបដែលមានភ្ជាប់រូបថតជាមួយ ទើបដឹងថា ពិតជាប្អូនប្រុសរបស់គាត់ ។ ហេតុដូច្នេះហើយទើបធ្វើឲ្យគាត់កាន់តែចង់ដឹងពីដំណើរជីវិតរបស់ប្អូនប្រុសដែលបានបាត់ខ្លួន បែកគ្នាតាំងពីឆ្នាំ១៩៧៣ ។ ប៉ុន្តែ ដោយសារបច្ចុប្បន្ន គឹមហួ រស់នៅប្រទេសស្វីស មិនអាចមកជួបដោយផ្ទាល់ ទើបគាត់ទូរស័ព្ទឲ្យប្អូនប្រុសរបស់គាត់ម្នាក់ទៀតដែលរស់នៅសង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ឈ្មោះ ម៉េង ឡាយ (ក្រោយរំដោះឆ្នាំ១៩៧៩ ប្តូរឈ្មោះទៅជា អ៊ុន ស៊ីថា) មកស្វែងរកព័ត៌មានពីបងប្រុសដែលបានបាត់ខ្លួន ។

នៅវេលារសៀល ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៥ ម៉េង ឡាយ បានមកដល់ការិយាល័យព័ត៌មានសាធារណៈ និងត្រូវបានទទួលការស្វាគមន៍ពីរដ្ឋបាលរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ មុននឹងជួបខ្ញុំ ពូ ម៉េងឡាយ បានទទួលឯកសារប្រវត្តិរូបរបស់បងប្រុសគាត់ចំនួនពីរទំព័រ ពីក្រុមការងារផ្នែកឯកសារមជ្ឈមណ្ឌលឯកសារកម្ពុជា ។

ក្រោយពីពិភាក្សាគ្នាមួយរយៈខ្លី និងពិនិត្យលើឯកសាររូប






***សេចក្តីបកប្រែ*** ៖ នេះជារូបថត ដែលបានថតនៅក្នុងបន្ទប់របស់ខ្ញុំ នៅមូលដ្ឋានទ័ពអាកាស ឡាក់លែន រដ្ឋតិចសាស់ មុនពេលចាកចេញទៅកាន់ទីក្រុងសាន់ដេហ្គោ រដ្ឋកាលីហ្វ័រញ៉ា ។ ខ្ញុំថតរូបនេះដើម្បីទុកជាអនុស្សាវរីយ៍ ខែកុម្ភៈ ឆ្នាំ១៩៧៥ ហត្ថលេខា ម៉េងគា

ម៉េងឡាយ បានមានប្រសាសន៍ថា ការកត់ត្រាពីឈ្មោះឪពុកម្តាយ និងទីកន្លែងរស់នៅនៅក្នុងប្រវត្តិរូបបងរបស់គាត់ពិតជាត្រឹមត្រូវ ។ គាត់បានរៀបរាប់ថា គាត់មានឪពុកឈ្មោះ យូឈួន ធាម និងម្តាយ វ៉ាន់លី វ្លូចជ្រា និងមានបងប្អូនចំនួន៨នាក់ គឺ ទី១) លីម ទូ ភេទស្រី, ទី២) លីម គីមចេង (បច្ចុប្បន្ន លីម បូផល) ភេទស្រី, ទី៣) លីម ម៉េងគា (យូ ឈួន ម៉េងគា បាត់ខ្លួន) ភេទប្រុស, ទី៤) ម៉េង អារ៉ុង ភេទប្រុស, ទី៥) លីម កុសល ភេទប្រុស, ទី៦) គាត់ (ម៉េងឡាយ), ទី៧) លីម គីមហួ ភេទស្រី និងទី៨) លីម គីមម៉ី ភេទស្រី ។

គាត់បន្តថា ឪពុកម្តាយគាត់រស់នៅភូមិវាលវង្ស ឃុំវាលវង្ស ស្រុកកំពង់សៀម ខេត្តកំពង់ចាម ហើយក្នុងចំណោមបងប្អូនរបស់គាត់ គឺមានតែបងប្រុស យូ ឈួន ម៉េងគា ម្នាក់ប៉ុណ្ណោះ ដែលរៀនបានថ្នាក់ខ្ពស់ ។ បងប្រុសរបស់គាត់ បានប្រលងជាប់ឌុបជាប់នៅឆ្នាំ១៩៦៩ រួចហើយឡើងមករៀនបន្តនៅទីក្រុងភ្នំពេញផ្នែកឱសថសាស្ត្រ នៅសាលាពេទ្យ (បច្ចុប្បន្នសាកលវិទ្យាល័យសុខាភិបាល) ។ បងរបស់គាត់ បានមកស្នាក់នៅជាមួយបងប្អូន ។ បងរបស់គាត់តែងតែសរសេរសំបុត្រផ្ញើទៅសួរសុខទុក្ខឪពុកម្តាយ នៅផ្ទះ ហើយឪពុកម្តាយគាត់តែងតែផ្ញើលុយឲ្យបងប្រុសគាត់វិញ ។

ក្រោយរដ្ឋប្រហារ ឆ្នាំ១៩៧១ បងរបស់គាត់បានស្ម័គ្រចិត្តចូលធ្វើទាហានជើងទឹកដើម្បីរកប្រាក់កម្រៃបន្ថែមដោយមិនបានប្រាប់ឪពុកម្តាយឲ្យបានដឹងឡើយ ព្រោះពេលនោះផ្លូវពីភ្នំពេញទៅខេត្តកំពង់ចាម ត្រូវកងទ័ពរំដោះខ្មែរក្រហមកាន់កាប់មួយចំនួនហើយ ។ ហេតុដូច្នេះហើយ ទើបធ្វើឲ្យការទំនាក់ទំនងជួបការលំបាក ចំណែកឪពុកម្តាយគាត់ក៏ពិបាកក្នុងការផ្ញើលុយកាក់ទៅឲ្យបងប្រុសគាត់នៅភ្នំពេញដើម្បីចាយវាយ និងបង់ថ្លៃសាលាដែរ ។

ពេលចូលទាហានធ្វើដំបូង បងប្រុសរបស់គាត់ត្រូវនៅហាត់រៀននៅបន្ទាយម៉ុជ្រោយចង្វារ បន្ទាប់មកគាត់ត្រូវបានបញ្ជូនឲ្យទៅហ្វឹកហាត់នៅមូលដ្ឋានយោធារាម ខេត្តកំពង់សោម ថែមទៀត ។ ក្រោយពីចប់វគ្គបណ្តុះបណ្តាល បងប្រុសរបស់គាត់ត្រូវបានចាត់តាំងឲ្យធ្វើការ នៅក្នុងការិយាល័យទំនាក់ទំនងបរទេសផ្នែកយោធា ។

នៅឆ្នាំ១៩៧២ បងប្រុសរបស់គាត់មានភារកិច្ចទៅរើសទាហាននៅខេត្តកំពង់ចាម រួចហើយក៏ឆ្លៀតពេលទៅលេងឪពុកម្តាយ និងបងប្អូននៅផ្ទះ ។ នៅប្រហែលចុងឆ្នាំ១៩៧៣ បងប្រុសរបស់គាត់ ជាមួយនឹងកូនទាហានឈ្មោះ វើង បានទៅតាមរកក្រុមគ្រួសារនៅខេត្តកំពង់ចាម តាមម៉ារីនយោធាម្តងទៀត ក្នុងគោលបំណងនាំឪពុកម្តាយ និងបងប្អូនត្រឡប់មករស់នៅភ្នំពេញវិញ ព្រោះខ្មែរក្រហមបានកាត់ផ្តាច់ការធ្វើដំណើរតាមផ្លូវគោកទាំងស្រុងហើយ ។ ប៉ុន្តែគ្រួសារគាត់ លើកលែងតែបងស្រី លីម គីមចេង ម្នាក់ប៉ុណ្ណោះ ដែលត្រូវទៅធ្វើជាគ្រូបង្រៀននៅភ្នំពេញ ក្រោយពីនោះ ត្រូវបានខ្មែរក្រហមកៀរឲ្យទៅរស់នៅឃុំស្ពឺ ក្នុងស្រុកចម្ការលើទាំងអស់ តាំងពីពេលខ្មែរក្រហមវាយចូលក្នុងភូមិវាលវង្ស នៅខែសីហា ឆ្នាំ១៩៧៣ មកម្ល៉េះ ។ ចាប់តាំងពីពេលនោះ គាត់ និងគ្រួសារដែលជម្លៀសទៅស្រុកចម្ការ លែងបានជួបមុខបងប្រុសរហូត ។

ចំណែកបងប្រុសគាត់ ដែលមិនបានជួបនឹងគ្រួសារ នៅឆ្នាំ១៩៧៤ ក៏បានផ្តាំផ្ញើបងស្រី (លីម គីមចេង) នៅភ្នំពេញថា គាត់ត្រូវទៅរៀនបន្តទៅសហរដ្ឋអាមេរិករយៈពេលមួយឆ្នាំ ទើបត្រឡប់មកប្រទេសកម្ពុជា ។ បងប្រុសរបស់គាត់បានចាកចេញពីប្រទេសកម្ពុជា ទៅសហរដ្ឋអាមេរិក នៅថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៧៤ ។ នៅទីនោះ បងប្រុសគាត់បានជួបនឹងបងប្អូនជីដូនមួយឈ្មោះ អ៊ួយ ហ៊ាង និងប្តីឈ្មោះ សុខុម ធ្លាប់ធ្វើការងារនៅស្ថានទូតសហរដ្ឋអាមេរិកនៅទីក្រុងភ្នំពេញ ដែលបានចេញទៅរស់នៅសហរដ្ឋអាមេរិកមុន ។ ក្រោយពីរៀនចប់ នៅឆ្នាំ១៩៧៥ បងប្រុសរបស់គាត់បានដាក់ពាក្យស្នើសុំត្រឡប់មកស្រុកខ្មែរវិញ ។ ប៉ុន្តែពេលនោះ មិត្តភក្តិ និងបងប្អូនជីដូនមួយ បានឃាត់បងប្រុសគាត់ឲ្យរស់នៅអាមេរិកមួយរយៈសិន ព្រោះពេលនោះសភាពការណ៍នៅក្នុងស្រុកខ្មែរមានការប្រែប្រួល ។ ទោះបីជាយ៉ាងណា ដោយសារនឹកឪពុកម្តាយ និងស្រុកកំណើត បងរបស់គាត់ក៏បានសម្រេចចិត្តសរសេរពាក្យស្នើសុំត្រឡប់មកស្រុកកំណើតវិញ ។

ចាប់តាំងពីមកដល់ភ្នំពេញ បងប្រុសរបស់គាត់បានបាត់ដំណឹងរហូត ហើយគ្មាននរណាដឹង សូម្បីខ្មែរក្រហមយកបងប្រុសគាត់ទៅដាក់កន្លែងណា ។ ដូច្នេះហើយ ទើបបងប្អូននៅតែចង់ដឹងថា បងប្រុសគាត់ដែលមកដល់សព្វថ្ងៃមានអាយុ៦៥ឆ្នាំ នៅរស់ ឬស្លាប់ ហើយស្លាប់នៅកន្លែងណា? ម្យ៉ាងទៀត បងប្អូននៅតែសង្ស័យថា បងប្រុសរបស់គាត់អាចមិនត្រឡប់មកស្រុកខ្មែរវិញ ទោះឃើញមានឯកសារបញ្ជាក់ពីការស្នើសុំក៏ដោយ ។ **សោម ប៊ុនថន**






***សេចក្ដីបកប្រែ*** ៖ ដំណើរកម្សាន្ត នៅសាន់អង់តូនីញ៉ូ រដ្ឋតិចសាស់ នៅថ្ងៃចុងសប្ដាហ៍
យូ ឈួន ម៉េងគា សហរដ្ឋអាមេរិក

# សង្គ្រាមបំផ្លាញការសិក្សារបស់ខ្ញុំ

ឈិន វួច ជាជនរងគ្រោះមួយរូប ក្នុងចំណោមជនរងគ្រោះកម្ពុជារាប់ពាន់នាក់ដែលមានវាសនារួចរស់ជីវិតពីរបបយង់ឃ្នងខ្មែរក្រហម ។ មិនខុសពីអ្នកជាច្រើនឯទៀត វួច មិនបានសិក្សាឲ្យបានចប់ចុងចប់ដើមនោះទេ ដោយសារតែសង្គ្រាមដែលបានកើតឡើង ក្រោយថ្ងៃរដ្ឋប្រហារ១៨ មីនា ឆ្នាំ១៩៧០ រហូតដល់ពេលរបបខ្មែរក្រហមឡើងកាន់អំណាច ។

ជាកូនដែលកើតក្នុងគ្រួសារខ្មែរកាត់ចិន វួច មានក្តីសប្បាយរីករាយណាស់ ដែលបានកើតក្នុងគ្រួសារមួយ ដែលពោរពេញដោយក្តីស្រឡាញ់ពីឪពុកម្តាយ ជាមួយនឹងបងប្អូនប្រុសស្រីទាំង៧នាក់ ។ ឪពុករបស់គាត់ គឺជាមនុស្សម្នាក់ដែលស្រឡាញ់ និងឲ្យតម្លៃការសិក្សា ។ គាត់ខិតខំធ្វើការយ៉ាងមមាញឹក ដើម្បីរកប្រាក់ជួយផ្គត់ផ្គង់ដល់កូនៗរបស់គាត់ទាំងអស់ឲ្យបានរៀនសូត្រគ្រប់ៗគ្នា ។ ការខិតខំប្រឹងប្រែងរបស់ឪពុក វួច មិនបានធ្វើឲ្យគាត់ខកបំណងនោះទេ គឺកូនប្រុសច្បងរបស់បានក្លាយជាសាស្ត្រាចារ្យបង្រៀននៅវិទ្យាល័យសន្ធរម៉ុក និងកូនប្រុសពីរនាក់ទៀត នឹងក្លាយជាវេជ្ជបណ្ឌិតជួយសង្គ្រោះជីវិតប្រជាជន បន្ទាប់ពីអ្នកទាំងពីរបញ្ចប់ការសិក្សា ។

យ៉ាងណាមិញ សុភមង្គល និងសេចក្តីសប្បាយរីករាយក្នុងរបស់គ្រួសាររបស់ វួច បានរលាយបាត់បន្តិចម្តងៗ បន្ទាប់ពីរដ្ឋប្រហារទម្លាក់ព្រះនរោត្តម សីហនុ និងការចាប់ផ្តើមឡើងសង្គ្រាមស៊ីវិលនៅក្នុងប្រទេសកម្ពុជាដែលមានសភាពកាន់តែកាចសាហាវនិងឃោរឃៅឡើងៗ ។ ទន្ទឹមនឹងនោះដែរ វិស័យអប់រំរបស់ប្រទេសក៏ធ្លាក់ក្នុងស្ថានភាពក្រឡាប់ចាក់ ហើយសាលាមួយចំនួននៅតាមខេត្តនានា ត្រូវបានផ្អាកការបង្រៀនជាញឹកញាយ ដោយសារតែការទម្លាក់គ្រាប់បែកពីសំណាក់សហរដ្ឋអាមេរិក ។ វួច ក៏ដូចជាអ្នកដទៃទៀត ដែលស្ថិតក្នុងវ័យសិក្សា ត្រូវឃ្លាតឆ្ងាយពីសៀវភៅ ប៊ិច មិត្តរួមថ្នាក់ លោកគ្រូអ្នកគ្រូ និងសាលាជាទីស្រឡាញ់របស់ខ្លួន ។ វួច និងប្អូនៗត្រូវបង្ខំចិត្តឈប់រៀន ដើម្បីរត់គេចពីការទម្លាក់គ្រាប់បែក និងការវាយប្រយុទ្ធគ្នាពីសំណាក់ទាហាន លន់ នល់ និងខ្មែរក្រហម ។ វួច រៀនបានត្រឹមថ្នាក់ទី១០ សង្គមចាស់ប៉ុណ្ណោះ (ប្រហាក់ប្រហែលនឹងថ្នាក់ទី៣របស់កម្មវិធីសិក្សាថ្មី) ។ ក្រោយពីពេលដែលគាត់ត្រូវបង្ខំចិត្តឈប់រៀនមក គាត់ក៏ត្រូវបង្ខំចិត្តរស់នៅចាកឆ្ងាយពីក្រុមគ្រួសារឪពុកម្តាយរបស់គាត់ ដោយហេតុថា តំបន់ខ្លះទូទាំងប្រទេសកម្ពុជាត្រូវបានត្រួតត្រាដោយក្រុមខ្មែរក្រហម និងក្រុមលន់ នល់ ដូច្នេះធ្វើឲ្យគាត់មិនអាចធ្វើដំណើរទៅរកបងប្អូនគាត់បានទេ ។ កាលណោះ គាត់បានផ្លាស់មករស់នៅទីក្រុងភ្នំពេញជាមួយនឹងបងប្អូនរបស់គាត់ ហើយឪពុកម្តាយរបស់គាត់រស់នៅក្នុងភូមិកំណើតនៅក្នុងខេត្តកំពង់ធំ ។ អ្នកទាំងអស់គ្នាមិនអាចធ្វើការទាក់ទងគ្នាបានងាយស្រួលនោះទេ ។ តែទោះជាយ៉ាងណាក៏ដោយ វួច ចុងក្រោយបានជួបជុំនឹងឪពុកម្តាយរបស់គាត់នៅខេត្តកំពង់ធំវិញ ក្រោយពីគាត់បានធ្វើដំណើរពីភ្នំពេញវិញតាមយន្តហោះ ។

ស្ថានភាពសង្គ្រាមកាន់តែដុនដាបទៅៗ ភាពចលាចល ការកាប់សម្លាប់ និងការវាយប្រហារប្រដាប់អាវុធកើតឡើងស្ទើរតែរាល់ថ្ងៃ ដែលបានបន្សល់ទុកស្ត្រីមេម៉ាយ និងក្មេងកំព្រាជាច្រើន ។ ថ្ងៃមួយ វួច បានឃើញនូវរឿងរាវដ៏សាហាវមួយ នៅពេលដែលគាត់បានឃើញមនុស្សមួយចំនួនមកសម្លាប់ ហើយសាកសពត្រូវបានគេកាត់ក្បាល ហើយព្យួរលើកំណាត់ឈើ ដែលខ្លួនត្រូវបានគេកាត់ជាកង់ៗ ។ គាត់និយាយថា នោះជាអំពើសាហាវណាស់ដែលខ្មែរសម្លាប់ខ្មែរ ។ ពេលវេលាកាន់តែរំកិលទៅមុន ស្ថានភាពជម្លោះកាន់តែធ្ងន់ធ្ងរទៅៗ ។ ភាពភ័យខ្លាច និងអសន្តិសុខក៏នូវតែតាមលងបន្លាចក្រុមគ្រួសាររបស់គាត់ក៏ដូចជាប្រជាជនដទៃទៀតដែរ ។

នាថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ នៅទូទាំងប្រទេសកម្ពុជាត្រូវបានរំដោះ ។ ខ្មែរក្រហមចង់ឲ្យប្រជាជនទាំងអស់ក្លាយទៅជាកម្មករនិងកសិករតែប៉ុណ្ណោះ ព្រោះយល់ថា បញ្ញវន្តទាំងអស់គឺមិនអាចទុកចិត្តបាន ។ ដូចច្នេះ វួច នឹងគ្មានឱកាសទទួលយកការអប់រំទៀតទេ និងជារៀងរហូត ។ ខុសប្លែកពីប្រជាជនកម្ពុជាផ្សេងៗទៀត ដែលអាពាហ៍ពិពាហ៍របស់អ្នកទាំងនោះ ត្រូវបានរៀបចំឡើងដោយ

អង្គការតែ វួច បែរជាមានសំណាងមែនទែន ដែលគាត់អាចរៀបការត្រឹមត្រូវដែលគោរពទៅតាមបែបបទប្រពៃណីខ្មែរ ដោយហេតុថាពេលនោះ ខ្មែរក្រហមមិនទាន់រឹតត្បិតខ្លាំងពេលកាន់កាប់ដំបូង ។ កាលណោះ មានអាចារ្យរៀបចំពិធីមង្គលការរបស់គាត់ និងមានការចូលរួមពីភ្ញៀវកិត្តិយសទៀតផង ។

អាពាហ៍ពិពាហ៍នេះកើតឡើងមិនត្រូវពេលមែនពិត តែនោះគឺជាការផ្សំផ្គុំដ៏ល្អ ដោយសារតែគាត់ទាំងពីរមិនដែលទុកឲ្យគ្នាភ័យខ្លាចអ្វីទេ ក៏ប៉ុន្តែ គាត់តែងតែជួយគ្នាដើម្បីឲ្យរួចចេញពីសេចក្តីស្លាប់ក្នុងរបបនោះ ។ ក្រោយមកគាត់ទាំងពីរទទួលបានចំណងដៃគឺកូនប្រុសមួយ ដែលកាលណោះ មានឆ្មបស្រីវៀតណាមមួយនៅជិតផ្ទះគាត់ជួយបង្កើតកូនឲ្យ ។ កូនប្រុសដំបូងរបស់គាត់ចាប់កំណើតចំពេលដែលប្រទេសកម្ពុជាកំពុងតែស្ថិតក្នុងសុបិន្តដ៏អាក្រក់ មិនមានការថែទាំគ្រប់គ្រាន់ មិនមានអាហារហូបគ្រប់គ្រាន់ មិនទទួលបានការអប់រំគ្រប់គ្រាន់ តែគាត់នៅតែខំប្រឹងត្រដររស់ចាកចេញពីរបបនោះ ។ ក្រោយមក ស្ថានការណ៍កាន់តែវិវត្តកាន់តែអាក្រក់ទៅៗ ក្នុងពេលដែលមានការធ្វើបន្សុទ្ធកម្មលើសត្រូវផ្ទៃក្នុង និងសត្រូវខាងក្រៅ កាន់តែព្រៃផ្សៃទៅៗ ដែលធ្វើឲ្យប្រជាជនជាច្រើនមានការសង្ស័យលើគ្នាទៅវិញទៅមក ។

ដើម្បីជួយអង្គការធ្វើបន្សុទ្ធកម្មលើសត្រូវទាំងនោះ ដែលភាគច្រើន គឺជាអតីតទាហាន លន់ នល់ និងបញ្ញាជនមូលធននិយម ប្រជាជនតែងតែចោទប្រកាន់គ្នាទៅវិញទៅមកថា មានជំនាក់ទំនងជាមួយ លន់ នល់ ជាក្រុមប្រឆាំងនឹងអង្គការ ។ កាលណោះ បងប្រុសទាំងពីររបស់ វួច ដែលជាអតីតសាស្ត្រាចារ្យ ត្រូវអង្គការយកទៅសម្លាប់ ដោយដឹកតាមឡានមួយគ្រឿងចេញទៅ ដោយមិនដឹងថាយកទៅណានោះទេ ហើយក៏បាត់ដំណឹងរហូត ។

ដោយឡែក ចំពោះជីវភាពរបស់គ្រួសាររបស់ វួច ក៏មិនខុសពីប្រជាជនខ្មែរដទៃទៀតដែរ ក្នុងរយៈពេល ៣ឆ្នាំ ៨ខែ និង២០ថ្ងៃនេះ គាត់និងប្តីរបស់គាត់ត្រូវតែធ្វើការយ៉ាងធ្ងន់ ដើម្បីប្តូរយករបបអាហារយ៉ាងតិចតួចបំផុតដើម្បីហូប ។ ទោះជាយ៉ាងណាក៏ដោយ គ្រួសាររបស់គាត់នៅតែខិតខំតស៊ូត្រដររស់ ។ គ្រួសាររបស់គាត់ស្ទើរតែត្រូវអង្គការយកទៅកម្ទេចទៅហើយ ដោយអង្គការបានប្រាប់ ឲ្យទៅរៀននៅដីថ្មី ហើយគាត់មិនបានដឹងថាជាផែនការកម្ទេចរបស់អង្គការនោះទេ ផ្ទុយទៅវិញ គាត់បានរៀបចំនូវប្រដាប់ប្រដារកសិកម្មមួយចំនួន ដោយគាត់យល់ថា អង្គការបញ្ជូនឲ្យទៅធ្វើកសិកម្មនៅកន្លែងផ្សេង ។ ជាភ័ព្វសំណាង ដោយមានកម្មាភិបាលខ្មែរក្រហមម្នាក់ដែលស្រឡាញ់រាប់អានប្តីរបស់ វួច បានប្រាប់ និងបដិសេធមិនឲ្យគ្រួសាររបស់ វួច ឡើងឡានទៅជាមួយគេ ។ តាំងពីពេលនោះមក គ្រួសាររបស់គាត់បានរួចផុតពីការសម្លាប់រហូតរបបកម្ពុជាប្រជាធិបតេយ្យត្រូវផ្តួលរំលំ ដោយកងទ័ពស្ម័គ្រចិត្តវៀតណាម និងរណសិរ្សសង្គ្រោះជាតិកម្ពុជា នៅថ្ងៃទី៦ មករា ឆ្នាំ ១៩៧៩ ។

បន្ទាប់ពីរបបខ្មែរក្រហមត្រូវបានបញ្ចប់ គ្រួសាររបស់ វួច បានស្គាល់នូវភាពរីករាយឡើងវិញ ហើយក៏មានសមាជិកថ្មីក្នុងគ្រួសារបន្ថែមទៀត ដោយគាត់មានកូនប្រុសចំនួន៦នាក់ ។ ប្តីរបស់ វួច ក៏មានមុខមាត់នៅក្នុងសង្គមមួយរូបដែរ គឺគាត់បានធ្វើជាអភិបាលស្រុកបារាយណ៍ ក្នុងខេត្តកំពង់ធំ ។ ប្តីរបស់ វួច គឺជាមនុស្សម្នាក់ដែលទទួលការស្រឡាញ់ គោរពរាប់អានពីសាធារណជនទូទៅ តែរឿងអកុសលមួយបានកើតឡើងចំពោះគាត់គឺ នៅឆ្នាំ១៩៩២ មុនពេលបោះឆ្នោតដែលរៀបចំដោយ អ៊ុនតាក់ ប្តីរបស់ វួច ត្រូវខ្មាន់កាំភ្លើងបាញ់សម្លាប់នៅឯផ្ទះរបស់គាត់ នៅភូមិកាតាយ ឃុំសូយោង ស្រុកបារាយណ៍ ខេត្តកំពង់ធំ ។ ក្រោយពីបាត់បង់នូវបង្គោលក្នុងគ្រួសារ វួច ត្រូវទទួលយកអម្រែកមួយយ៉ាងធ្ងន់ ក្នុងការគ្រប់គ្រងថែទាំគ្រួសារទាំងមូល ។ វួច ត្រូវធ្វើជាឪពុកផង និងជាម្តាយផង ។ គាត់ខិតខំធ្វើការរកប្រាក់ឧបត្ថម្ភកូនៗ ដើម្បីឲ្យកូនៗបានរៀនសូត្រខ្ពង់ខ្ពស់គ្រប់ៗគ្នា ។ វួច យល់ថា ការសិក្សាពិតជាសំខាន់ណាស់សម្រាប់កូនៗរបស់គាត់ និងដើម្បីអនាគតរបស់កូនទាំងអស់គ្នា ។ វួច មិនចង់ឲ្យកូនលំបាកដូចជាគាត់នោះទេ ដោយសារគាត់គ្មានឱកាសនឹងរៀនសូត្រ ព្រោះតែសង្គ្រាម ។ ជាលទ្ធផលដែលគាត់ទទួលបានក្រោយពីការខិតខំរបស់គាត់ គឺ កូនប្រុសបីនាក់ បានប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ហើយម្នាក់ក្នុងចំណោមអ្នកទាំងបីបានទទួលការអប់រំដល់ថ្នាក់ឧត្តមសិក្សាទៀតផង ។ ទោះបីជាមិនមែនជាលទ្ធផលធំសម្បើមយ៉ាងណាក៏ដោយ តែអ្វីដែល វួច លះបង់ទាំងអម្បាលមាណ គឺគ្រប់គ្រាន់ណាស់ហើយសម្រាប់គាត់ គាត់ពេញចិត្តណាស់ចំពោះលទ្ធផលនេះ ដោយកូនៗទាំងអស់របស់គាត់ បានសិក្សាគ្រប់ៗគ្នា និងមានមុខរបរ ជីវភាពសមរម្យគ្រប់គ្នា ។ **ខេង សៀងហៃ**

# ចាប់ពីរបបខ្មែរក្រហម ដល់ឧប្បត្តិហេតុ ហាំបាលី៖ អត្តសញ្ញាណជនជាតិចាម នៅក្នុងយុគសម័យសកលភាវូបនីយកម្ម

*(តពីលេខមុន)*

## *៦) ជនជាតិចាមនៅដើមសតវត្សរ៍ទី២០*

*គិតត្រឹមដើមសតវត្សរ៍ទី២០ ជនជាតិចាមបានបង្កើតខ្លួនជាក្រុមជាតិពន្ធុ-សាសនាភាគតិចមួយ រស់នៅជាមួយខ្មែរដែលជាអ្នកកាន់សាសនាព្រះពុទ្ធភាគច្រើន ។ ពួកគេរស់នៅផ្នែកផ្សេងៗនៃប្រទេស ប៉ុន្តែផ្តុំគ្នានៅខេត្តកំពង់ចាម ចំណែកជនជាតិជ្វាផ្តុំគ្នានៅតាមតំបន់ទំនាបកណ្តាល ។ នៅក្នុងឆ្នាំ១៩៤១ ម៉ាសែល នើ (Marcel Ner) បានរកឃើញថា មានក្រុមអ្នកកាន់សាសនាអ៊ីស្លាមសំខាន់បី ដែលបែងចែកពីគ្នាដោយប្រភពនៃឥទ្ធិពលមកលើពួកគេ ។ ក្រុមមួយទទួលឥទ្ធិពលពីវប្បធម៌ និងភាសាម៉ាឡេ ក្រុមមួយទៀតទទួលឥទ្ធិពលពីអក្សរអារ៉ាប់ និងការបកប្រែសាសនា ចំណែកក្រុមទី៣ទទួលឥទ្ធិពលពីការអភិរក្សបំណែកសេសសល់នៃអរិយធម៌របស់ចម្ប៉ាតាមរយៈភាសាចាម ។ ក្រុមទាំងនេះសព្វថ្ងៃជាក្រុមជ្វា ក្រុមអ្នកកាន់សាសនាអ៊ីស្លាមស៊ុននីកម្ពុជា និងក្រុមអ្នកកាន់សាសនាអ៊ីស្លាមអ៊ីម៉ាមសាន់ ។*

*នៅកំពង់ចាម នៅភូមិទ្រា ស្វាយឃ្លាំង និងប៉ឹស នៅក្នុងស្រុកក្រូចឆ្មារ គឺជាមជ្ឈមណ្ឌលវប្បធម៌ និងសាសនារបស់ជនជាតិចាម ។ នៅលើទីតាំងភ្នំភ្លើងចាស់ និងស្របតាមទំនាបលិចទឹករបស់ទន្លេមេគង្គ*



*ប្រជាជនចាមនៅឃុំស្វាយឃ្លាំង ស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ ចូលរួមស្តាប់សវនាការកាត់ទោសមេដឹកនាំខ្មែរក្រហម ដែលរៀបចំផ្សាយបន្តដោយក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា*

ភូមិទាំងនេះ ស្ថិតនៅក្នុងចំណោមភូមិដែលមានចំនួនប្រជាជនច្រើនបំផុត និងដីមានជីជាតិបំផុតនៅកម្ពុជា ។ ខេត្តកំពង់ចាមជាខេត្តធំមួយ ។ សព្វថ្ងៃនេះ ខេត្តនេះមានចំនួនប្រជាជន១លាន៧សែននាក់ ។ ប្រហែលជានៅក្នុងរជ្ជកាលរបស់ព្រះបាទនរោត្តម (១៨៦០-១៩០៤) ចាមមួយចំនួនតូចបានចេញមុខ ចេញមាត់ ដែលមានដូចជា បូតេស, ស្មោង ម៉ាន និងដង្កោ ម៉ាត់ ដែលអ្នកទាំងអស់នេះមកពីភូមិស្វាយឃ្លាំង ។

បូតេស ត្រូវបានតែងតាំងដោយព្រះបាទនរោត្តម ជាទីប្រឹក្សាពិសេសទទួលបន្ទុកកិច្ចការចាម ។ ចាស់ទុំក្នុងភូមិស្វាយឃ្លាំងដែលនៅរស់បាននិយាយថា ព្រះបាទនរោត្តម យាងតាមកប៉ាល់ធំមួយតាមទន្លេមេគង្គទៅកាន់ស្វាយឃ្លាំង ដើម្បីប្រគល់តំណែងនេះជូនគាត់ ។ បូតេស និងដង្កោ ម៉ាត់ជាពាណិជ្ជករស្តុកស្តម្ភ ដែលបានដឹកជញ្ជូនឈើតាមទន្លេមេគង្គទៅកូសាំងស៊ីន ។ ពួកគេបានសាងសង់ផ្ទះពីឈើប្រណិត ។ ផ្ទះមួយចំនួនតូចបានរួចផុតពីការបំផ្លិចបំផ្លាញដោយខ្មែរក្រហម ។ ផ្ទះរបស់ បូតេស ដែលគាត់បានសាងសង់សម្រាប់ប្រពន្ធជនជាតិវៀតណាមរបស់គាត់ នៅសល់នៅឡើយ ។ គាត់ក៏បានសាងសង់សឺន និងព្រះវិហារអ៊ីស្លាម នៅកណ្តាលភូមិនៅមុនពេលគាត់ទទួលអនិច្ចកម្មដែលប្រហែលជានៅឆ្នាំ១៩៤០ ។ ដោយមានទ្រព្យសម្បត្តិជនជាតិចាមទាំងបីនាក់នេះ ម្នាក់ៗមានប្រពន្ធបួនប្រាំ ។ បូតេស មានប្រពន្ធបី ស្មោង ម៉ាន មានប្រពន្ធ៧ ។ សព្វថ្ងៃនេះ ចៅ និងចៅទួតរបស់ពួកគេនៅបន្តរស់នៅស្វាយឃ្លាំង និងនៅក្នុងភូមិប៉ឹសនៅក្បែរនោះ ។ ពួកគេខ្លះបានផ្លាស់ទៅរស់នៅម៉ាឡេស៊ី សហរដ្ឋអាមេរិក និងប្រទេសផ្សេងៗទៀត ។ អ្នកទាំងបីនេះ ត្រូវបានកប់នៅក្នុងកន្លែងបញ្ចុះសពមួយក្នុងចំណោមកន្លែងបញ្ចុះសពចំនួន៧នៅក្នុងភូមិ ។

នៅក្នុងរជ្ជកាលរបស់ព្រះបាទមុនីវង្ស អ្នកភូមិស្វាយឃ្លាំងម្នាក់ទៀតឈ្មោះ តា បូរ៉ាត់ ត្រូវបានតែងតាំងជាអ្នកតំណាងឲ្យជនជាតិកម្ពុជា ។ តា បូរ៉ាត់ ក៏ត្រូវបានគេស្គាល់ថា ជាមិត្តភក្តិជិតស្និទ្ធរបស់ព្រះបាទមុនីវង្ស ។ នៅក្នុងរបបសង្គមរាស្ត្រនិយម ជនជាតិចាមដែលមានចំណេះដឹងមានឥទ្ធិពលម្នាក់ឈ្មោះ លី មូសា បានសាងសង់សាលាសាសនាអ៊ីស្លាមនៅស្វាយឃ្លាំងដែលគិតត្រឹមពេលនោះមានចាមប្រមាណជា១២៨២គ្រួសាររស់នៅជាប់ៗគ្នា ដែលមានប្រជាជនសរុបប្រមាណជា៥ ទៅ៦ពាន់នាក់ ។

ជនជាតិចាមពីតំបន់នេះ មានទំនាក់ទំនងតាមប្រពៃណីជាមួយម៉ាឡេស៊ី ។ ពីម៉ាឡេស៊ី ពួកគេបន្តធ្វើទំនាក់ទំនងជាមួយឥណ្ឌា និងមជ្ឈិមបូព៌ា ស្វែងរកការអប់រំ និងចំណេះដឹងពីប្រទេសទាំងនេះ ។ សព្វថ្ងៃនេះ ជនជាតិចាមក្មេងៗជាច្រើនស្វែងរកការងារពលកម្ម និងការសិក្សានៅប្រទេសម៉ាឡេស៊ី និងប្រទេសថៃភាគខាងត្បូង ។ លី មូសា បានចំណាយពេលសិក្សាសាសនាអ៊ីស្លាមនៅម៉ាឡេស៊ី មុនពេលត្រឡប់មកកាន់កម្ពុជាក្នុងនាមជាគ្រូសាសនាអ៊ីស្លាមល្បីសុះសាយម្នាក់ ។

## សម័យអាណានិគម

នៅដើមសម័យអាណានិគម ជនជាតិចាមកម្ពុជាខ្លះបានធ្វើដំណើរទៅវៀតណាមដើម្បីផ្លាស់ប្តូរចាមនៅទីនោះឲ្យប្រតិបត្តិសាសនាអ៊ីស្លាមធម្មតា ប៉ុន្តែការព្យាយាមនេះមិនទទួលបានផលទាំងស្រុងទេ ដោយសារជនជាតិចាមនៅវៀតណាមនៅបន្តគោរពបុព្វបុរសប៉ូយ៉ាង (Po Yang) តាមប្រពៃណី ។ ប៉ុន្តែ អាយម៉ូនីញេ បានរាយការណ៍ថា ការខិតខំប្រឹងប្រែងខ្លះក្នុងចំណោមនេះទទួលបានជោគជ័យ ៖ “ពីរបីឆ្នាំកន្លងទៅ ភូមិមហាម៉ាត់ចំនួនបីនៅប៉ារីក (Parik) ក្លាមៗ បានឈប់គោរពប៉ូយ៉ាងរបស់ចាម បន្ទាប់ពី “អ្នកធម្មយាត្រា” ហាជីបរទេសម្នាក់បានធ្វើដំណើរកាត់ ដែលបានថ្កោលទោសចំពោះការប្រតិបត្តិតាមប្រពៃណីនេះ” ។

នៅចុងសតវត្សរ៍ទី១៩ នៅវៀតណាម បារាំងបានព្យាយាមលុបចោលនូវយុទ្ធនាការបញ្ចូលវប្បធម៌ដែលព្រះចៅវៀតណាម មិញ ម៉ាង (Minh Mang) បានអនុវត្តកាលពីប៉ុន្មានទសវត្សរ៍មុន ដែលមានរួមទាំង ការបង្ខំជនជាតិចាមមកពីអតីតប៉ាន់ឌូរាំងហ្គាឲ្យស្លៀកសម្លៀកបំពាក់វៀតណាម និយាយភាសាវៀតណាម ប្រើឈ្មោះវៀតណាម និងប្រារព្ធពិធីបុណ្យផ្សេងៗរបស់វៀតណាម ។ បារាំងបានការពារកម្មសិទ្ធិបញ្ញារបស់ចាម និងបានធ្វើឲ្យរស់ឡើងវិញនូវទំនៀមទម្លាប់ចាម ។ ភាសា និងអក្សរចាម ត្រូវបានធ្វើឲ្យរស់ឡើងវិញ និងបានលើកទឹកចិត្តឲ្យប្រើប្រាស់ សូម្បីតែជាមធ្យោបាយសម្រាប់ទំនាក់ទំនងជាមួយរដ្ឋាភិបាលអាណានិគម ។

នៅដើមសតវត្សរ៍ទី២០ ឋានៈតាមផ្លូវច្បាប់របស់ចាមនៅកម្ពុជា ត្រូវបានយកមកពិភាក្សា ។ សេវាយុត្តិធម៌អាណានិគម

(Colonial Judiciary Service) ពិចារណាដាក់ជនជាតិភាគតិចចាមឲ្យនៅក្រោមរដ្ឋបាលបារាំងផ្ទាល់ក្នុងនាមជា "ជនបរទេស" ដែលអាចត្រូវបានគំរាមកំហែងពីជនជាតិខ្មែរ ។ មានអំណះអំណាងប្រឆាំង "ភាពជាបរទេស" នេះដែលរួមមាន ១) ជនបរទេសតែមួយគត់នៅក្នុងចំណោមចាម គឺជាជនជាតិម៉ាឡេមួយចំនួនដ៏តូចដែលកើតនៅបរទេស និង ២) ចាម និងម៉ាឡេ ក៏បានកាន់តំណែងជាមន្ត្រីនៅក្នុងរដ្ឋាភិបាលកម្ពុជា ដូចជានៅត្បូងឃ្មុំ ស្ទឹងត្រង់ និងពញាឮមានអភិបាល ជាអ្នកកាន់សាសនាអ៊ីស្លាម ។ អំណះអំណាងអំពី "ភាពជាបរទេស" នេះ មិនទទួលបានជ័យជម្នះទេ ។ ដូច្នេះ នៅក្នុងច្បាប់របស់អាណានិគមចាម និងម៉ាឡេ ត្រូវបានចាត់បញ្ចូលជាក្រុមជនភាគតិច ប៉ុន្តែមិនមែនជាជនបរទេសទេ ។

ក្នុងបរិបទនៃជាតិនិយម ការត្រូវបានចាត់ថ្នាក់ជាក្រុមជនជាតិភាគតិច គឺជាការរួមបញ្ចូលគ្នាគួរសមដែរ ។ នេះគឺជាជំហានមួយនៃជំហានដំបូងឆ្ពោះទៅរកការទទួលបានសញ្ជាតិសម្រាប់ជនជាតិចាម នៅក្នុងរដ្ឋកម្ពុជាទំនើប បន្ទាប់ពីបាត់បង់ទឹកដីទាំងអស់ទៅវៀតណាម ។ ប៉ុន្តែជនជាតិចាមនៅតែនិយាយភាសាដើម និងភាសាបរទេសដូចជា ម៉ាឡេ និង អារ៉ាប់ ។ ជំនាញនិយាយភាសាខ្មែររបស់ពួកគេ គឺខ្សោយ ។ ការនេះបាននាំទៅដល់ការនិយាយលេងសើចដោយជនជាតិខ្មែរជាច្រើន អំពីការនិយាយភាសាខ្មែរមិនច្បាស់ និងបានរិះគន់ចំពោះការខ្វះការធ្វើសមាហរណកម្ម ។ ដូច្នេះ ការបង្កើតអត្តសញ្ញាណសើៗរបស់ជនជាតិចាម ដែលជាកម្ពុជាដោយឡែកនោះ គឺមានដែនកំណត់ ។ វាខុសឆ្ងាយពីកម្រិតនៃសមាហរណកម្មដែលគេឃើញនៅពេលបច្ចុប្បន្ន ។

ប៉ុន្តែ ជនជាតិចាមមិនព្រមបញ្ជូនកូនចៅរបស់ពួកគេទៅសាលាបារាំង ដែលនៅទីនោះពួកគេភ័យខ្លាចថា វប្បធម៌ និងប្រពៃណីដែលពួកគេប្រកាន់ខ្ជាប់ជាយូរមកហើយ អាចបាត់បង់នៅពេលក្រោយ ។ ជាក់ស្តែង កម្មវិធីរបស់វៀតណាមក្នុងការបញ្ចូលជនជាតិចាមទៅក្នុងសង្គមរបស់ពួកគេនៅដើមសតវត្សរ៍ទី១៩ បានបង្ខំឲ្យចាមជាច្រើនផ្លាស់ប្តូរទីលំនៅមកកម្ពុជា ។ ដោយគ្មានសញ្ញាបត្រពីសាលាទាំងនោះ ចាមមិនអាចស្វែងរកការងារវិជ្ជាជីវៈនៅក្នុងរដ្ឋបាល



សិស្សស្រីជនចាមនៅក្នុងស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ កំពុងរៀនថែមម៉ោងសម្រាប់មុខវិជ្ជាចំណេះដឹងទូទៅ នៅសាលាឯកជន

អាណានិគមបានទេ ។ ការនេះ បាននាំទៅដល់តួនាទីខ្សត់ខ្សោយជាងមុនសម្រាប់ពួកគេនៅក្នុងរដ្ឋាភិបាល និងសង្គមកម្ពុជាទាំងមូល ហើយក៏មានជីវភាពខ្សត់ខ្សោយជាងដែរ ។

ការខ្វះខាតការសិក្សានៅក្នុងប្រព័ន្ធសាលាបារាំងបានបណ្ដាលឲ្យជនជាតិចាមផ្ដោតកម្លាំងរបស់ពួកគេនៅក្នុងវិស័យពាណិជ្ជកម្ម និងការសិក្សាសាសនាអ៊ីស្លាមយ៉ាងផុសផុល ។ នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៣០ នើ បានអង្កេតការសិក្សាបែបនេះនៅភូមិត្រា ដែលមានសាលាសាសនាពីរដឹកនាំដោយគ្រូហ្ស៊ីកហ្ស៊ីននៅម៉ិកកា (Mecca) និងខេឡានតាន (Kelantan) ។ នើ ក៏បានអង្កេតឃើញការអនុវត្តបែបនេះដែរនៅស្វាយឃ្លាំង និងប៊ឺស ដែលមានលក្ខណៈខុសពីធម្មតា បើពិនិត្យមើលអំពីចំនួនអ្នកបញ្ចប់ការសិក្សាផ្នែកសាសនាកម្រិតខ្ពស់នៅក្រៅប្រទេស ។

គេអាចត្រឹមតែស្រមៃមើលអំពីមូលហេតុនៅពីក្រោយការដែលជនជាតិចាមជ្រើសរើសយកការអប់រំសាសនា ជាជាងការអប់រំដែលមិនទាក់ទងនឹងសាសនា ។ ក្ដីសង្ឃឹមចម្បងរបស់ពួកគេអំពីជីវភាពល្អជាងនេះដោយគ្មានការអប់រំមិនទាក់ទងនឹងសាសនា អាចរួមមានការរីកចម្រើនរបស់សាសនាអ៊ីស្លាមនៅកម្ពុជាទៅដល់កម្រិតខ្ពស់មួយតាមដែលអាចធ្វើទៅបាន និងទំនាក់ទំនងជាមួយសហគមន៍អ៊ីស្លាមសកលលោកតាមរយៈពាណិជ្ជកម្ម និងការអប់រំ ។ ជាមួយនេះ ជនជាតិចាមមានតម្រូវការចាំបាច់តិចតួចណាស់ក្នុងការធ្វើទំនាក់ទំនងជាមួយសហគមន៍ក្នុងស្រុក សូម្បីតែនៅពេលដែលពួកគេពុំមានការអប់រំ និងទំនាក់ទំនងសាសនាសមរម្យ ។ ផ្ទុយទៅវិញ ពួកគេបានស្វះស្វែងចូលជាមួយរដ្ឋាភិបាលពាក់ព័ន្ធនឹងការគ្រប់គ្រង និងការចាត់ចែងសាសនាអ៊ីស្លាម ធ្វើឲ្យមានភាពប្លែកនូវសាសនា និងជាតិពន្ធុនៅកម្ពុជា និងបង្កើតជាដៃគូក្នុងការជំរុញឲ្យមានគំនិតប្រឆាំងនឹងវៀតណាម និងជម្នះលើការវាតទីនិយមរបស់ប្រទេសនេះ ។

## កម្មវិធីខេមរភាវូបនីយកម្មរបស់ព្រះនរោត្តម សីហនុ

នៅក្នុងទសវត្សរ៍៦០ ព្រះអង្គម្ចាស់នរោត្តមសីហនុ បានបង្កើតពាក្យមួយចំនួនសម្រាប់ក្រុមនយោបាយ ជាតិពន្ធុ និងសាសនានៅកម្ពុជា ដោយផ្អែកលើពាក្យខ្មែរ ។ នេះគឺជាការព្យាយាមរបស់អ្នកដឹកនាំរូបនេះដើម្បីធ្វើសមាហរណកម្ម (យ៉ាងហោចណាស់តែផ្នែកខាងក្រៅ) ក្រុមទាំងនេះនៅក្នុងខ្មែរជាតិនិយមដែលស្អិតរមួតជាមួយគ្នា ។ ពាក្យដែលបានបង្កើតឡើងទាំងនោះរួមមានៈ ខ្មែរស ខ្មែរក្រហម ខ្មែរខៀវ (បៃតង) ខ្មែរអ៊ីស្លាម ខ្មែរកុម្មុយនីស្ត ខ្មែរលើ ខ្មែរក្រោម ខ្មែរដើម និងខ្មែរឥស្សរៈ ។ គេក៏ឮសូរការប្រើពាក្យថា ខ្មែរពុទ្ធសាសនាដែរ ។ “ខ្មែរ” ទាំងអស់នេះ ត្រូវបានចាត់ទុកថាជាកូនចៅរបស់ព្រះនរោត្តម សីហនុ ។ ព្រះអង្គបានប្រើប្រាស់សភាពសណ្ឋានដី និងទស្សនៈនយោបាយដើម្បីដាក់ឈ្មោះឲ្យក្រុមទាំងនេះ ។ ជាក់ស្ដែង ខ្មែរលើ និងខ្មែរក្រោម សំដៅទៅជនជាតិដើមរស់នៅតាមតំបន់ភ្នំ និងជនជាតិខ្មែររស់នៅលើដីសណ្ដទន្លេមេគង្គផ្នែកខាងក្រោម ។ កម្ពុជាតែងតែបែងចែកតាមសភាពសណ្ឋានដី ។

នៅក្នុងយុគសម័យមុនអង្គរ ប្រទេសនេះត្រូវបានបែងចែកជាចេនឡាខ្ពស់ និងទាប ។ នេះប្រហែលជាដោយសារតែនៅដែនដីកណ្ដាលប្រទេសនេះ មានដែនដីទំនាបលិចទឹកធំមួយ នៅជុំវិញទន្លេសាប និងប្រព័ន្ធទន្លេមេគង្គ ។ សណ្ឋានដីបែបនេះបានបង្កើតនូវអត្ថន័យមួយ នៅក្នុងចំណោមប្រជាជនកម្ពុជាក្នុងការកំណត់ប្រទេសរបស់ពួកគេជាពីរផ្នែកៈ ផ្នែកខាងក្រោមដែលសើម និងផ្នែកខ្ពស់ដែលខ្ពស់ ហើយស្ងួត ។ ពាក្យខ្មែរ ខ្មែរស ឬ (ខ្មែរសេរី), ខ្មែរក្រហម, ខ្មែរកុម្មុយនីស្ត និងខ្មែរឥស្សរ (ខ្មែររំដោះ) ត្រូវបានប្រើដើម្បីសម្គាល់ក្រុមនយោបាយផ្សេងៗ ។ ពេលខ្លះ នេះគឺត្រូវតាមការកំណត់សម្គាល់តាមនយោបាយសកលលោក ។ ជាក់ស្ដែង ខ្មែរក្រហមមានន័យថា ជាខ្មែរ ពណ៌ក្រហម ។

ដែលចំណាប់អារម្មណ៍ពិសេស គឺការកំណត់អ្នកកាន់សាសនាអ៊ីស្លាមនៅកម្ពុជាថាជាខ្មែរអ៊ីស្លាម ។ វាគួរឲ្យឆ្ងល់ដែលថា ពាក្យថា “អ្នកកាន់សាសនាអ៊ីស្លាម” មិនត្រូវបានប្រើប្រាស់នៅក្នុងភាសាខ្មែរដើម្បីនិយាយសំដៅទៅអ្នកប្រតិបត្តិសាសនាអ៊ីស្លាម ប៉ុន្តែពាក្យ “អ៊ីស្លាម” ត្រូវបានប្រើប្រាស់ដើម្បីនិយាយសំដៅទៅទាំងសាសនា និងអ្នកគោរពសាសនានេះ ។ ដូច្នេះ ប្រជាជនខ្មែរសព្វថ្ងៃនេះ តែងតែហៅអ្នកកាន់សាសនាអ៊ីស្លាមដែលជាជនជាតិចាមថាជា “បងប្អូនអ៊ីស្លាម” ។ ព្រះអង្គម្ចាស់សីហនុជាអ្នកនយោបាយដែលមានលក្ខណៈការទូត និងដែលនិយាយឥតសំចៃ ។ ការដាក់ឈ្មោះអ្នកកាន់សាសនាអ៊ីស្លាមនៅកម្ពុជាថា ជាខ្មែរដែលមានសាសនាផ្សេង បានបង្ហាញឲ្យឃើញអំពីការទទួលយកយ៉ាងកក់ក្ដៅរបស់

ព្រះអង្គនូវជនជាតិទាំងនេះ បើទោះបីជាពួកគេមានជាតិពន្ធុផ្សេងក៏ដោយ ។ ព្រះអង្គម្ចាស់ សីហនុ ក៏បានដើរតួនាទីជាអ្នកនយោបាយផ្សះផ្សាមួយរូបដែរ ដែលបានទទួលយកគ្រប់សាសនា និងគ្រប់ក្រុមជាតិពន្ធុទាំងអស់នៅក្នុងសង្គមមួយដែលបែងចែកដោយប្រវត្តិជាតិពន្ធុ និងសេដ្ឋកិច្ច ។

ការបែងចែករវាងអ្នកមាន និងអ្នកក្រ និងអ្នកជនបទ និងទីក្រុង បានធ្វើឲ្យកើតឡើងនូវការតស៊ូខ្មែរក្រហម ។ ជនជាតិខ្មែរធ្វើចម្ការ និងកាន់តំណែងរដ្ឋាភិបាល ។ ជនជាតិចិន និងវៀតណាមកាន់កាប់ជំនួញនៅទីក្រុង ។ អ្នកកាន់សាសនាអ៊ីស្លាមជាអ្នកនេសាទ អ្នកសម្លាប់សត្វយកសាច់លក់ និងអ្នកជំនួញត្រាច់ចរ ។ ការទទួលយកនូវភាពស្មើគ្នាដោយព្រះនរោត្តម សីហនុ បានធ្វើឲ្យរំជួលចិត្តដល់ជនជាតិចាម ដែលប្រវត្តិ និងសាសនាខុសប្លែករបស់ពួកគេមិនបានជួយបង្កើនឋានៈរបស់ពួកគេនៅកម្ពុជា បើពិនិត្យមើលអំពីទស្សនៈរបស់ជនជាតិខ្មែរ ។

ប៉ុន្តែ នៅក្នុងការបង្កើតខ្មែរអ៊ីស្លាម ព្រះនរោត្តមសីហនុ បានផ្អែកការបែងចែករបស់ព្រះអង្គ លើគំនិតច្បាស់លាស់ ។ ដូចដែលបានកត់សម្គាល់ខាងលើអ្នកកាន់សាសនាអ៊ីស្លាមនៅកម្ពុជារួមមាន ជនជាតិចាម ជ្វា និងខ្មែរដែលប្តូរសាសនា ។ ជនជាតិជ្វានិយាយភាសាខ្មែរញឹកញាប់ដូចនិយាយភាសាម៉ាឡេដែរ ។ សព្វថ្ងៃនេះ ក្រៅពីកាន់សាសនាអ៊ីស្លាម ជនជាតិជ្វាមិនមានលក្ខណៈអ្វីផ្សេងខុសប្លែកពីជនជាតិខ្មែរដែលនិយាយភាសាខ្មែរទេ ។ ដូច្នេះ ពាក្យខ្មែរអ៊ីស្លាម ប្រើជាមួយជនជាតិជ្វាត្រឹមត្រូវជាង ជាមួយជនជាតិចាម ។

រយៈពេលកន្លងមក ជាតិពន្ធុចាមមួយបានចាប់ផ្តើមបង្ហាញអំពីទំនាក់ទំនងច្រើនជាមួយវប្បធម៌ខ្មែរ ច្រើនជាងក្រុមចាមផ្សេងទៀត ។ នេះគឺក្រុមអ៊ីម៉ាមសាន់ ដែលថ្វាយបង្គំតែមួយដងក្នុងមួយសប្តាហ៍ ។ នៅក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីភ្ជាប់ទៅនឹងវប្បធម៌ចាមចំណាស់ ដែលប្រហែលជាត្រូវបានបង្កើតឡើងនៅក្នុងរដ្ឋដែលទទួលឥទ្ធិពលឥណ្ឌារបស់ចម្ប៉ាមុនពេលកាន់សាសនាអ៊ីស្លាម អ៊ីម៉ាមសាន់ងាកទៅក្បែរវប្បធម៌ខ្មែរនៅក្នុងរបៀបមួយចំនួនដែលរួមមានជំនឿបែបចម្រុះ សម្លៀកបំពាក់ អាហារ និយាយភាសាខ្មែរច្បាស់ និងការប្រារព្ធពិធីផ្សេងៗ ។

## ជម្លោះ និងការផ្លាស់ប្តូរនៅក្នុងសាសនា

នៅក្នុងអំឡុងពេលនៃពាក់កណ្តាលទី១នៃសតវត្សរ៍ទី២០ ដែលគិតត្រឹមពេលនោះ ភាគច្រើននៃជនជាតិចាម បានក្លាយជាសាហ្វី (Shafiis) និងអ្នកដើរតាមទស្សនៈបែបម៉ាឡេនៃសាសនាអ៊ីស្លាម ពួកគេទទួលរងនូវជម្លោះយ៉ាងខ្លាំងក្លារវាងក្រុមថ្មី និងក្រុមចាស់ នៅក្នុងពិភពឥណ្ឌូ-ម៉ាឡេ ។ ក្រុមថ្មី បានលេចមុខ លេចមាត់ក្នុងរយៈពេលមិនយូរប៉ុន្មាន នៅក្នុងក្រុមហ៊ុន Dutch East Indies និងនៅក្នុងការតាំងទីលំនៅ នៅច្រកសមុទ្រម៉ាឡេស៊ី ។

ទំនើបនិយមអ៊ីស្លាមដែលបានជំរុញចិត្តក្រុមថ្មី មានប្រភពចេញពីឥណ្ឌា និងប៉ាគីស្ថាន ជាមួយ មហាម៉ាត់ អាប់ឌូ (Mohammad Abduh) (១៨៤៩-១៩០៥) និង រ៉ាស៊ីដ រីដា (Rashid Rida) (១៨៦៥-១៩៣៥) ។ ក្រុមថ្មីបានធ្វើការវាយប្រហារកន្លែងសាសនានៅម៉ាឡេស៊ី និងបាន អំពាវនាវឲ្យធ្វើការបន្សុទ្ធកម្មនូវទ្រឹស្តី និងការប្រតិបត្តិចាស់ៗ ។ ការប្រតិបត្តិចាស់ៗដែលពួកគេបម្រុងនឹងលុបបំបាត់រួមមានៈ **១)** ការធ្វើធម្មយាត្រាទៅផ្នូររបស់គ្រូសាសនាអ៊ីស្លាម, **២)** ជំនឿលើមន្តអាគម, **៣)** ពិធីកប់សពពិធីរៀបការ និងពិធីកំណើតដែលខ្វះការពន្យល់ខាងសាសនាអ៊ីស្លាម ។ ជម្លោះមួយទៀតរវាងក្រុមថ្មីនិងក្រុមចាស់គឺនៅលើការបញ្ជាក់ ឬការសូត្រអំពីគោលបំណងរបស់នរណាម្នាក់ពេលចាប់ផ្តើមថ្វាយបង្គំ ។

ការមិនរីកចម្រើននៅក្នុងផ្នែកអក្សរសាស្ត្រ និងអសមត្ថភាពក្នុងការសម្របខ្លួនទៅតាមបញ្ហាប្រឈមរបស់ពិភពទំនើប ត្រូវបានបន្ទោសទៅលើការប្រតិបត្តិតាមមហាម៉ាត់យ៉ាងតឹងតែង និងរបៀបបង្រៀនតាមប្រពៃណី ដែលសិស្សរៀនដោយការទន្ទេញចាំ ។ ផ្ទុយទៅវិញ ក្រុមថ្មីបានណែនាំនូវប្រព័ន្ធថ្នាក់រៀនមួយដែលមិនសូវផ្តោតលើការទន្ទេញចាំលើកទឹកចិត្តឲ្យមានភាពស្មើភាពគ្នាផ្នែកការអប់រំ រវាងក្មេងប្រុស និងក្មេងស្រី និងបានបញ្ចូលប្រធានបទមិនទាក់ទងនឹងសាសនាទៅក្នុងកម្មវិធីសិក្សា ។

ក្រុមថ្មី ប្រហែលជាបានជ្រៀបចូលមកក្នុងប្រទេសកម្ពុជាដំបូងនៅក្នុងទសវត្សរ៍១៩១០ នៅពេលភូមិទ្រាមានសាលារៀនល្បីឈ្មោះចំនួនពីរ ដែលមួយក្នុងចំណោមនេះមានកម្មវិធីសិក្សាបែបទំនើបមិនទាក់ទងនឹងសាសនា ។ ជម្លោះធ្ងន់ធ្ងរបានកើតឡើងនៅក្នុងទសវត្សរ៍១៩៥០ តាមរយៈការផ្សព្វផ្សាយគំនិតថ្មីរបស់គាត់បន្ទាប់ពីបានវិលត្រឡប់ទៅកាន់ខេត្តកំពង់ចាម បន្ទាប់ពីចំណាយ

ពេលសិក្សាជាច្រើនឆ្នាំនៅខេឡានតាន (Kelantan) ។ ពិធីបញ្ចុះសពដែលត្រឹមត្រូវ ជាប្រធានបទពិភាក្សាគ្នាយ៉ាងក្តៅគគុក ។ ក្រុមថ្មីក៏បានអះអាងអំពីភាពល្អជាងដោយសារជំនាញខាងភាសាអារ៉ាប់ ចំណែកក្រុមចាស់ ដែលសិក្សាតាមប្រព័ន្ធហាឡាកា (Halaqah) នៅតែផ្អែកទាំងស្រុងទៅលើអក្សរសាស្ត្រម៉ាឡេនៅឡើយ ។ ទាំងក្រុមចាស់ និងក្រុមថ្មីផ្អែកការសិក្សារបស់ពួកគេលើពិភពអ្នកកាន់សាសនាអ៊ីស្លាម ម៉ាឡេ ដូច្នេះជម្លោះរវាងក្រុមទាំងពីរនេះ ក៏ឆ្លុះបញ្ចាំងអំពីជម្លោះនៅពិភពម៉ាឡេដែរ ។

អ៊ីម៉ាម អាម៉ាត់ ក្រោយមកបានចូលរួមជាមួយក្រុមថ្មីរបស់ លី មូសា ។ គាត់បានត្រឡប់មកពីសិក្សានៅឥណ្ឌា ហើយប្រហែលជាទទួលឥទ្ធិពលពីចលនាកំណែទម្រង់មួយរបស់ឥណ្ឌា ដែលទំនងជា ឌីអូបាន់ឌីស (Deobandis) ឬ ណាវ៉ាត់ អាល់-អ៊ូឡាម៉ា (Nadwat al-Ulama) ។ ជម្លោះរវាងក្រុមចាស់ និងក្រុមថ្មីបានបណ្តាលឲ្យមានការបែកបាក់ក្រុមគ្រួសារ ការបែកបាក់ភូមិ និងជម្លោះហិង្សា ។ នៅចុងបញ្ចប់ វាទំនងជាថា ក្រុមថ្មីបានចាញ់ ។ នៅក្នុងឆ្នាំ១៩៦០ រដ្ឋាភិបាលកម្ពុជាបានជម្លៀសអ៊ីម៉ាមទាំងពីរទៅប្រទេសថៃ ។ ប្រហែលជាកត់សម្គាល់ឃើញអំពីភាពចាំបាច់ឲ្យមាននូវការដឹកនាំមជ្ឈការដែលច្បាស់ និងច្រើនជាងនេះ នៅក្នុងចំណោមអ្នកកាន់សាសនាអ៊ីស្លាម នៅក្នុងឆ្នាំ១៩៦០ ព្រះនរោត្តម សីហនុ បានតែងតាំងរាជាធិបតី រេះ ឡា ជាម៉ូវទីដំបូងនៅកម្ពុជា ដើម្បីដឹកនាំសហគមន៍ជនជាតិចាម និង ជ្វា ។ គាត់កាន់តំណែងនេះអស់មួយជីវិត ។ រេះ ឡា (Res Lah) បានរិះគន់ចលនាកំណែទម្រង់នេះ ដែលបានបង្កើតឲ្យមានការបាក់បែកនៅក្នុងសហគមន៍អ្នកកាន់សាសនាអ៊ីស្លាមតូចមួយនៅកម្ពុជា ។ ប៉ុន្តែ សព្វថ្ងៃនេះ អ្នកកាន់សាសនាអ៊ីស្លាម មិនសូវជាចម្រុះដូចកាលពីមុនទេ ។ អ្នកទេសនាសាលាហ៊ីបានសរសើរថា នេះជាស្នាដៃរបស់ លី មូសា និងក្រុមថ្មីរបស់គាត់ ។

### ជនជាតិចាមនៅក្រោមរបប លន់ នល់

នៅក្នុងរបបលន់ នល់ សហគមអ៊ីស្លាមនៅកម្ពុជាត្រូវបានដឹកនាំដោយហាជី អាប់ឌុលឡា ប៊ីន អ៊ីដ្រេះ (Abdoullah bin Idres) ដែលគេស្គាល់ផងដែរថាជា ហាជី រេះ ឡា ។ ហាជី រេះ ឡា បានរៀបចំកិច្ចប្រជុំប្រចាំឆ្នាំរវាងហាគីម និងទូន ពីសហគមន៍អ៊ីស្លាមនៅកម្ពុជា ។ អង្គការចាមពីរផ្សេងទៀតក៏ត្រូវបានរៀបចំឡើងនៅក្នុងសម័យសាធារណរដ្ឋខ្មែរ ដើម្បីបម្រើឲ្យសហគមន៍ ។ សមាគមន៍អ៊ីស្លាមមជ្ឈិម (Central Islamic Association) ដឹកនាំដោយ ហាជី មហាម៉ាត់ អាលី ហារូន (Haji Mohammad Aly Haroun) ។ សមាគមយុវជនខ្មែរអ៊ីស្លាម (Association of Khmer Islamic Youth) ដឹកនាំដោយ អាប់ឌុល រ៉ាឆេដ ប៊ីន អ៊ីដ្រេះ (Abdul Rached bin Idres) ។ ជនជាតិចាមនៅតាមតំបន់កុម្មុយនីស្តដែលយើងនឹងបានឃើញនៅក្នុងជំពូកបន្ទាប់ ក៏បានបង្កើតក្រុមផ្សេងៗ ដោយមានថ្នាក់ដឹកនាំថ្នាក់ឃុំ ដោយផ្អែកលើមនោគមវិជ្ជាកុម្មុយនីស្ត ។

នៅក្នុងឆ្នាំ១៩៧០ ជាលើកដំបូង ជនជាតិចាមត្រូវបានបំបែករវាងក្រុមដែលស្ថិតនៅក្រោមការគ្រប់គ្រងដោយខ្មែរក្រហមកុម្មុយនីស្ត និងអ្នកដែលស្ថិតនៅក្រោមរបបសាធារណរដ្ឋខ្មែរ ដែលប្រកាន់ទស្សនៈបែបសេរីលោកខាងលិច ប្រឆាំងកុម្មុយនីស្ត ប្រឆាំងវៀតណាម ដឹកនាំដោយសេនាប្រមុខ លន់ នល់ ។ ការបំបែកសហគមន៍ចាមនេះមិនមែនធ្វើឡើងដោយស្ម័គ្រចិត្តទេ ព្រោះនេះគឺជារឿងមិនធម្មតាសម្រាប់សហគមន៍មួយដែលតែងតែនៅជាមួយគ្នាជាដរាបនៅកម្ពុជា ។ ដូចខ្មែរជាច្រើនទៀតដែរ ចាមបានប្រយុទ្ធប្រឆាំងគ្នាចាប់ពីឆ្នាំ១៩៧០ ដល់១៩៧៥ ។ ជួនកាលបងប្អូនប្រុសត្រូវប្រយុទ្ធគ្នានៅក្នុងសមរភូមិ ។ ម្ខាងជឿជាក់លើភាពស្មើភាពគ្នា និងយុត្តិធម៌សង្គម ចំណែកម្ខាងទៀត ជឿជាក់លើសេរីភាពសាសនា និងអនាគតរបស់អ៊ីស្លាម ដែលអាចមានគ្រោះថ្នាក់ដោយសារការកើនឡើងនូវលទ្ធិកុម្មុយនីស្ត ។ គួរឲ្យកត់សម្គាល់ មានមន្ត្រីចាមនៅក្នុងរបបសាធារណរដ្ឋខ្មែរច្រើនជាង នៅក្នុងរបបព្រះនរោត្តម សីហនុ ។ មានអ្នកកាន់សាសនាអ៊ីស្លាមច្រើនដែរនៅក្នុងជួរកងទ័ព ។ បើយោងតាម កែវ អ៊ីប្រាហ៊ីម ពួកគេស្ម័គ្រចិត្តចូលរួម ដោយសារពួកគេជឿថា ខ្មែរកុម្មុយនីស្តនឹងមិនអនុញ្ញាតឲ្យពួកគេប្រតិបត្តិសាសនាអ៊ីស្លាមទេ នៅពេលពួកគេឡើងកាន់អំណាច ។ ជំនឿនេះប្រហែលជាបានពង្រឹងបន្ថែមដោយព័ត៌មានអំពីការបោសសម្អាតមេដឹកនាំសហគមអ្នកកាន់សាសនាអ៊ីស្លាមនៅខេត្តកំពង់ចាម និងតំបន់ផ្សេងទៀតដែលគ្រប់គ្រងដោយខ្មែរក្រហម ។ ប៉ុន្តែ ការបង្ខំឲ្យចូលទាហាន ក៏មានកើតឡើងដែរនៅក្នុងរបប លន់ នល់ ដោយរដ្ឋាភិបាលសាធារណរដ្ឋខ្មែរ ។

នៅក្នុងរបបសាធារណរដ្ឋខ្មែរ ជនជាតិចាមម្នាក់ឈ្មោះ

ឡេះ កូសេម បានលេចមុខលេចមាត់នៅក្នុងសង្គ្រាម ក៏ដូចជានៅក្នុងនយោបាយជាតិពន្ធុ ។ នយោបាយជាតិពន្ធុ និងប្រឆាំងវៀតណាមនៃរបបសាធារណរដ្ឋខ្មែរ ត្រូវបានសម្រេចឡើងដោយផ្នែកដោយ ឡេះ កូសេម និងក្រុមនយោបាយ ចម្រុះមួយឈ្មោះថា ហ្វុលរ៉ូ (FULRO) ។ ដោយប្រឆាំងនឹងវៀតណាម លន់ នល់ បានប្រើប្រាស់ក្តីសង្ឃឹមរបស់ជនជាតិចាមក្នុងការដណ្តើមយកចម្ប៉ាមកវិញ ជាមធ្យោបាយដើម្បីទទួលបានការគាំទ្រប្រឆាំងនឹងវៀតណាមកុម្មុយនីស្ត ។ នៅក្នុងទស្សនៈទូលាយជាងនេះរបស់គាត់ លន់ នល់ ចង់បង្រួបបង្រួមជនជាតិមននៅភូមា និងប្រទេសថៃ ខ្មែរនៅកម្ពុជា និងកម្ពុជាក្រោម ផ្នែកមួយរបស់កម្ពុជាដែលត្រូវបានភ្ជាប់ទៅវៀតណាមក្នុងឆ្នាំ១៩៤៩ ជនជាតិចាមនៅកម្ពុជា និងវៀតណាម និងកុលសម្ព័ន្ធភ្នំ ។

ក្នុងនាមជាអ្នកដឹកនាំជាតិពន្ធុមួយរូប ឡេះ កូសេម ចង់បង្រួបបង្រួមចាម កុលសម្ព័ន្ធភ្នំជនជាតិដើម និងខ្មែរកម្ពុជាក្រោម ដើម្បីដណ្តើមយកទឹកដីដែលត្រូវបានភ្ជាប់ដោយវៀតណាម ។ ឡេះ កូសេម បានសិក្សាជាមួយ លន់ នល់ នៅវិទ្យាល័យស៊ីសុវត្ថិ ។ ក្រោយមក គាត់បានក្លាយជាទីប្រឹក្សាយ៉ាងជិតស្និទ្ធរបស់ លន់ នល់ ស្តីអំពីបញ្ហាជនជាតិចាម និងត្រូវបានតែងតាំងជាមេទ័ពរបស់កងទ័ពសាធារណរដ្ឋខ្មែរ ។ ឡេះ កូសេម ទទួលបានការអនុញ្ញាតឲ្យបង្កើតជាកងវរសេនាតូចនៅក្នុងកងកម្លាំងសន្តិសុខកម្ពុជា ។ កងកម្លាំងនេះ មានឈ្មោះល្បីខាងស្មារតីប្រឆាំងកុម្មុយនីស្ត បំផ្លាញ និងកម្ទេចជនកុម្មុយនីស្តនៅក្នុងភូមិដែលគ្រប់គ្រងដោយខ្មែរក្រហម ។ ប៉ុន្តែ ក្រោយមក កងកម្លាំងនេះត្រូវបំបែកដោយកងកម្លាំងសន្តិសុខកម្ពុជា ដោយសារភាពសាហាវឃោរឃៅជ្រុលរបស់ក្រុមនេះ ។

ជាតិពន្ធុនិយម បានងើបមុខឡើងនៅក្នុងទសវត្សរ៍១៩៥០ ។ វាបានជំរុញឲ្យមាននូវសម្ព័ន្ធមិត្ត មួយរវាងក្រុមកុលសម្ព័ន្ធភ្នំ នៅតាមតំបន់ភ្នំរវាងប្រទេសកម្ពុជា និងវៀតណាម ។ ក្នុងឆ្នាំ១៩៦៤ ឡេះ កូសេម បានរៀបចំកិច្ចប្រជុំជាមួយចលនាបាចារ៉ាកា (Baja raka) នៅតំបន់ភ្នំភាគកណ្តាលប្រទេសវៀតណាម ដើម្បីបញ្ចុះបញ្ចូលពួកគេឲ្យចូលរួមជាមួយចលនារបស់គាត់ ដែលមានឈ្មោះថា រណសិរ្សរំដោះកម្ពុជាភាគខត្តរ និងរណសិរ្សរំដោះចម្ប៉ា ។ បាចារ៉ាកា សកម្មនៅតំបន់ភ្នំភាគកណ្តាលរបស់វៀតណាម ព្យាយាមស្វែងរកស្វ័យតភាព និងសិទ្ធិសម្រាប់កុលសម្ព័ន្ធភ្នំដែលបានបាត់បង់ដីទៅ ចំនួនជនអន្តោប្រវេសន៍វៀតណាមដែលចេះតែកើនឡើងមកកាន់តំបន់ប្រវត្តិសាស្ត្ររបស់គេ ។ អង្គការទាំងបីនឹងត្រូវរួមបញ្ចូលជាមួយអង្គការដឹសណ្តទន្លេមេគង្គខាងក្រោម មានឈ្មោះថារណសិរ្សតស៊ូខ្មែរកម្ពុជាក្រោម ដែលអ្នកគាំទ្រជាតិពន្ធុខ្មែរ ក៏ត្រូវបានគ្រប់គ្រងដោយវៀតណាមនៅលើដីប្រវត្តិសាស្ត្ររបស់ពួកគេ ។ អង្គការទាំងបួននេះបានរួមបញ្ចូលគ្នាបង្កើតជា FULRO ដែលនៅតែជា អង្គការយោធា និងនយោបាយរហូតដល់ដើមទសវត្សរ៍១៩៩០ នៅពេលត្រូវរំសាយចោលដោយ អ៊ុនតាក់ ។

ឯកសារមួយសរសេរដោយ អ៊ី បាម អ៊ីណូល (Y Bham Enoul) ដែលជាសមាជិកសំខាន់មួយ និងក្រោយមកជាប្រធានរបស់ FULRO បានសង្កត់ធ្ងន់អំពីមនោគមវិជ្ជារបស់ FULRO ៖

ចាប់តាំងពីឆ្នាំ១៩៥៥ ប្រទេសទាំងអស់របស់ឥណ្ឌូចិន ទទួលបានឯករាជ្យ ។ ប៉ុន្តែ ប្រជាជាតិ និងប្រជាជនចាម នៅតែទទួលរងការឈឺចាប់ និងបានក្លាយជាអ្វីដែលហៅថា ជាជនជាតិភាគតិចនៅលើទឹកដីរបស់ខ្លួន ។ ការប្រើប្រាស់ពាក្យនេះគឺជាការមាក់ងាយសម្រាប់ក្រុមមួយដែលជាម្ចាស់ទឹកដីពិតប្រាកដ ។ ព្រោះពាក្យនេះមានន័យថា មនុស្សតូច ។ ដូច្នេះ ពួកគេមិនមានសិទ្ធិគ្រប់គ្រងប្រទេសខ្លួន និងប្រជាជនជាតិដោយខ្លួន ពួកគេផ្ទាល់ ឬពួកគេមិនត្រូវបានអនុញ្ញាតឲ្យធ្វើដូច្នេះ ។ ដូច្នេះ អត្តសញ្ញាណជាតិរបស់ពួកគេត្រូវបាត់បង់ ហើយពួកគេត្រូវតែរស់នៅជាទាសកររបស់ប្រជាជាតិដែលខ្លាំងជាង និងឆ្លាតជាង ដូចជា យួន ឲ្យពាក្យមើលងាយមួយប្រើសំដៅទៅជនជាតិវៀតណាម ព្រោះគ្រោះថ្នាក់នៅពេលអនាគតគឺធំធេងណាស់សម្រាប់ប្រជាជនចាម ដូច្នេះ ចាមត្រូវភ្ញាក់រឭកឡើង តស៊ូ និងប្រយុទ្ធដើម្បីបម្រើប្រជាជាតិខ្លួនឯង ។

ត្រាក់ផ្សព្វផ្សាយរបស់សាធារណរដ្ឋខ្មែរក្នុងឆ្នាំ១៩៧៤ បានបញ្ជាក់ថា "អ្នកកាន់សាសនាអ៊ីស្លាមខ្មែរយើងមិនដែលភ្លេចថា បុព្វបុរសរបស់ជនជាតិវៀតណាមសព្វថ្ងៃនេះបានកាន់កាប់ចម្ប៉ារបស់ពួកគេដោយមិនស្របច្បាប់ ដែលកាលពីមុនមានទីតាំងនៅលើអ្វីដែលជាវៀតណាមកណ្តាលឥឡូវនេះ" ។ ត្រាក់នោះក៏បានចោទប្រកាន់វៀតណាមថាបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិចាម ៖

ចម្ប៉ាត្រូវបានភ្ជាប់យកដោយវៀតណាម ។ ជនជាតិចាមដែលនៅសេសសល់បានក្លាយជាអ្នកកាន់សាសនាអ៊ីស្លាម នៅក្នុងការផ្លាស់ប្តូរសាសនាជាប្រវត្តិសាស្ត្រក្នុងទ្រង់ទ្រាយធំ ។ ជនជាតិចាមសព្វថ្ងៃនេះកំពុងជួបគ្រោះថ្នាក់រលាយបាត់បង់ ។ គោលនយោបាយរបស់វៀតកុង គឺដើម្បីលុបបំបាត់ពួកគេឲ្យបានច្រើនតាមដែលអាចធ្វើទៅបាន និងធ្វើវៀតណាមរូបនីយកម្មលើអ្នកដែលនៅសេសសល់ ។ ផែនការរបស់វៀតកុង មានបីដំណាក់កាលៈ ប្រល័យពូជសាសន៍ ធ្វើឲ្យលែងកាន់សាសនាអ៊ីស្លាម និងការផ្លាស់ប្តូរយ៉ាងធ្ងន់ធ្ងរទៅកុម្មុយនីស្ត ។

ឡេះ កូសេម បានដឹកនាំគណៈប្រតិភូអ្នកកាន់សាសនាអ៊ីស្លាមជនជាតិចាមទៅចូលរួមនៅក្នុងសមាជលើកដំបូងរបស់អង្គការអ៊ីស្លាមអាស៊ី-អាហ្វ្រិក *(Afro-Asian Islamic Organization)* នៅទីក្រុងបានឌុង ប្រទេសឥណ្ឌូនេស៊ី ក្នុងខែតុលា ឆ្នាំ១៩៧០ ។ មេទ័ព ឡេះ កូសេម ក៏បានរៀបចំទស្សនៈកិច្ចប្រចាំឆ្នាំសម្រាប់គណៈប្រតិភូខ្មែរ និងអ្នកកាន់សាសនាអ៊ីស្លាមទៅកាន់ប្រទេសជាច្រើន ដើម្បីយុទ្ធនាការរកការគាំទ្រសម្រាប់សាធារណរដ្ឋខ្មែរ ក៏ដូចជាដើម្បីផ្សព្វផ្សាយអំពីអ្នកកាន់សាសនាអ៊ីស្លាមនៅកម្ពុជា និងទុក្ខលំបាករបស់ពួកគេនៅក្នុងសង្គ្រាម ។ អតីតមន្ត្រីភស្តុភាររបបលន់ នល់ ម្នាក់ឈ្មោះ កែវ អ៊ីប្រាហ៊ីម *(Keo Ibrohim)* បាននិយាយថា ក្នុងឆ្នាំ១៩៧៣ គាត់ជាផ្នែកមួយនៃគណៈប្រតិភូមួយទៅកាន់ប្រទេសនិយាយភាសាបារាំង ដូចជាប្រទេសបារាំង និងអេត្យូពី ដើម្បីពន្យល់អំពីមូលហេតុដែលប្រទេសកម្ពុជា ដែលជាប្រទេសអព្យាក្រឹត្យធ្លាក់ទៅក្នុងសង្គ្រាមឥណ្ឌូចិនលើកទី២ ។

ក្នុងឆ្នាំ១៩៧៤ ឡេះ កូសេម និងអ្នកគាំទ្ររបស់គាត់ បានសរសេរអត្ថបទមួយមានចំណងជើងថា «ការបូជារបស់ខ្មែរកាន់សាសនាអ៊ីស្លាម» ។ អត្ថបទនេះបានវាយប្រហារសម្តេច សីហនុ ដែលបានចូលដៃជាមួយកងកម្លាំងកុម្មុយនីស្តប្រឆាំងសាសនា នៅក្នុងព្រៃ ។ អត្ថបទនេះក៏បានចោទប្រកាន់ខ្មែរក្រហមអំពីការសម្លាប់ខ្មែរកាន់សាសនាអ៊ីស្លាមដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ពួកគេ និងជនកុម្មុយនីស្តអំពីអំពើប្រល័យពូជសាសន៍ប្រឆាំងនឹងខ្មែរកាន់សាសនាអ៊ីស្លាម ។ ដើម្បីគាំទ្រការចោទប្រកាន់របស់ពួកគេ អត្ថបទនេះបានចុះបញ្ជីឈ្មោះហាកឹម ទូន និងមេដឹកនាំសហគមន៍ដែលត្រូវបានសម្លាប់ដោយខ្មែរក្រហម ។ អត្ថបទនេះក៏ចុះបញ្ជីព្រះវិហារសាសនាអ៊ីស្លាមដែលត្រូវបានបំផ្លាញផងដែរ ។ អត្ថបទនេះមិនបានកំណត់ក្រុមកុម្មុយនីស្តខ្មែរក្រហមថាជាកងកម្លាំងឯករាជ្យទេ ។ អត្ថបទនេះបានបញ្ចូលក្រុមនេះជាមួយក្រុមកុម្មុយនីស្តឥណ្ឌូចិនដឹកនាំដោយវៀតណាមខាងជើង ។ ការធ្វើបែបនេះបានធ្វើឲ្យពួកគេអាចភ្ជាប់ទុក្ខលំបាករបស់ចាមនៅចម្ប៉ាជាមួយនឹងជនជាតិចាមកាន់សាសនាអ៊ីស្លាមនៅកម្ពុជា ។ ក្រុមទាំងពីរនេះជាជនរងគ្រោះនៃសត្រូវកុម្មុយនីស្តតែមួយដែលដឹកនាំដោយកុម្មុយនីស្តវៀតណាម ដែលបុព្វបុរសរបស់ពួកគេបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិចាម កាលពី៥សតវត្សរ៍មុន ។

គិតត្រឹមឆ្នាំ១៩៧៥ កម្ពុជាមានព្រះវិហារសាសនាអ៊ីស្លាមចំនួន១១៨ ដឹកនាំដោយហាកឹមមួយ និងអនុប្រធានហាកឹមពីររូប ។ គិតត្រឹមពេលនោះ កម្ពុជាមានអ៊ីម៉ាមពី៦ ទៅ១០នាក់ និងហាជីជាងមួយពាន់នាក់ ។ ជនជាតិចាមចំនួន២៥នាក់ ត្រូវគេដឹងថាបានរៀនចប់ពីមជ្ឈមណ្ឌលពិភពលោកនៃការសិក្សាអំពីសាសនាអ៊ីស្លាម ។ ៩នាក់បានបញ្ចប់ការសិក្សារយៈពេល៦ឆ្នាំនៅសកលវិទ្យាល័យអាល់-អាហ្សា *(Al-Azhar University)* នៅទីក្រុងកៃរ៉ូ ។ បុគ្គលជាច្រើននៃបុគ្គលទាំងនេះ ត្រូវខ្មែរក្រហមបានសម្លាប់ក្នុងរយៈពេលបីឆ្នាំ ប្រាំបីខែ និងម្ភៃថ្ងៃ បន្ទាប់ពីនោះនៃគោលនយោបាយឥតត្រាប្រណីរបស់របបខ្មែរក្រហមក្នុងការធ្វើបរិសុទ្ធកម្មសង្គម ដែលជាលទ្ធផល បណ្តាលឲ្យមានអំពើប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិចាម ។ **(តទៅលេខក្រោយ)**

**អេង កុកថាយ**


## អានទស្សនាវដ្តីតាមគេហទំព័រ

ទស្សនាវដ្តីស្វែងរកការពិតទាំងអស់ត្រូវបានផ្សព្វផ្សាយតាមគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ្នកអានអាចរកបានតាមៈ http://d.dccam.org/Projects/Magazines/Magazine_Searching.htm . ព័ត៌មានបន្ថែម សូមទាក់ទង សោម ប៊ុនថន ទូរស័ព្ទលេខ ០១២ ៩៩៦ ៧៥០ ឬ ០២៣ ២១១ ៨៧៥ ។

# ថ្នាក់រៀននៅទួលស្លែង

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតថ្នាក់រៀនសាធារណៈមួយនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ។ ថ្នាក់រៀននេះត្រូវបានបង្កើតឡើងក្នុងខែវិច្ឆិកា ឆ្នាំ២០១១ ដោយមានកិច្ចសហការរវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។ សារមន្ទីរទួលស្លែងគឺជាអតីតសាលារៀនដ៏ទំនើបមួយដែលបានសង់ឡើងជាលើកដំបូងនៅក្នុងឆ្នាំ១៩៦២ ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្មែរក្រហមបានប្រែក្លាយសាលារៀននេះទៅជាគុកដ៏សម្ងាត់បំផុតមួយក្នុងចំណោមគុកចំនួន១៩៦ទូទាំងប្រទេស ។ អ្នកទោសភាគច្រើនដែលត្រូវបញ្ជូនទៅទួលស្លែង គឺជាកម្មាភិបាលខ្មែរក្រហមដែលត្រូវបានចោទប្រកាន់ពីបទប្រព្រឹត្តអំពើក្បត់ជាតិ ដូចជា ការសហការជាមួយរដ្ឋាភិបាលបរទេស ឬធ្វើជាអ្នកស៊ើបការណ៍ឲ្យសេ.អ៊ី.អា ឬ កា.ហ្សេ.បេ ជាដើម ។



ចាប់តាំងពីការប្រែក្លាយពីកន្លែងរៀនសូត្រមួយទៅជាកន្លែងដ៏គួរឲ្យរន្ធត់ និងមហន្តរាយមួយ ទួលស្លែងមិនដែលទទួលបានមុខងាររបស់ខ្លួនដូចកាលពីដើមវិញឡើយ ។ ទោះបីជាយ៉ាងនេះក្តី នៅពេលអនាគត ដើម្បីទាមទារមកវិញនូវកេរដំណែលអប់រំដែលមានលក្ខណៈវិជ្ជមានរបស់ទួលស្លែង និងដើម្បីបន្ថែមសមាសភាពអប់រំមួយទៅក្នុងសារមន្ទីរនេះ ថ្នាក់រៀននេះ ត្រូវបានបង្កើតឡើងដើម្បីផ្តល់ការបង្រៀន និងការពិភាក្សាដោយឥតគិតថ្លៃអំពីប្រវត្តិសាស្ត្ររបបខ្មែរក្រហម និងប្រធានបទដែលជាប់ទាក់ទង ដូចជា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ថ្នាក់រៀននេះ ក៏ជាវេទិកាសាធារណៈមួយសម្រាប់ឲ្យអ្នកមកទស្សនា និងអ្នកដែលនៅរស់រានមានជីវិតចែករំលែកព័ត៌មានគ្នាក្នុងការថែរក្សារយៈកាលនៃប្រវត្តិសាស្ត្រកម្ពុជាដ៏មានសារសំខាន់មួយទុកឲ្យអ្នកជំនាន់ក្រោយបានរៀនសូត្រ ។

បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ដែលមានសញ្ញាបត្រមកពីបរទេស និងបានទទួលវិញ្ញាបនបត្រពីក្រសួងអប់រំ យុវជន និងកីឡា ផ្នែកការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩) ព្រមទាំងមានការចូលរួមពីអ្នកជំនាញជាតិ និងអន្តរជាតិដែលមានជំនាញលើប្រវត្តិសាស្ត្រប្រទេសកម្ពុជា និងអ្នកដែលនៅរស់រានមានជីវិតពីមន្ទីរស-២១ នឹងបង្រៀននៅថ្នាក់រៀននេះ ។ ព័ត៌មានទាក់ទងនឹងថ្នាក់រៀននេះ សូមទាក់ទង ម៉ែន ពិចិត្រ តាមរយៈទូរស័ព្ទលេខៈ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែលៈ truthpechet@dccam.org ។

**◆ ទីកន្លែង ៖ អគារ "ក" ជាន់លើ ◆ ពេលវេលា ៖ ច័ន្ទ ២-៣រសៀល, ពុធ ៩-១០ព្រឹក, សុក្រ ២-៣រសៀល**

# ការិយាល័យព័ត៌មានសាធារណៈ

“ការិយាល័យព័ត៌មានសាធារណៈ” របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍វិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ ។ ប្រភេទឯកសារទីពីរគឺជាបទសម្ភាសដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសជាមួយជនរងគ្រោះនិងអតីតកម្មាភិបាលខ្មែរក្រហម ។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម ។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្ងាប់របស់ខ្មែរក្រហម និងឯកសារប្រភេទទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត ។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននឹងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារខ្លះទៀតរួមមាន ៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លង ព័ត៌មានដែលបានមកពីការសម្ភាសជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ថនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ជា ផល្លា តាមរយៈ ទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល truthphalla.c@dccam.org ។





















# គេហទំព័រទស្សនាវដ្ដីស្វែងរកការពិតជាភាសាខ្មែរ

## www.truthcambodia.com

ទស្សនាវដ្ដីស្វែងរកការពិត បង្កើតគេហទំព័រ www.truthcambodia.com ក្នុងគោលបំណងផ្សព្វផ្សាយ និងអប់រំឲ្យបានកាន់តែទូលំទូលាយអំពីរបបកម្ពុជាប្រជាធិបតេយ្យ (របបខ្មែរក្រហម) ដើម្បីសម្រេចឲ្យបាននូវការចងចាំ យុត្តិធម៌ និងការផ្សះផ្សាជាតិក្នុងសង្គមដែលទទួលរងនូវការបែកបាក់ និង សង្គ្រាមជាច្រើនទសវត្សរ៍ ។

គេហទំព័រ www.truthcambodia.com ក៏នឹងដើរតួនាទីដ៏សំខាន់ផងដែរក្នុងការចែករំលែកព័ត៌មានអំពីដំណើរការសវនាការកាត់ទោសមេដឹកនាំខ្មែរក្រហមជាមួយសាធារណជន និងជួយសាលាក្ដីក្នុងការរំឡែកព័ត៌មានទាក់ទងប្រវត្តិសាស្ត្រខ្មែរក្រហម នៅខណៈពេលអត្ថបទមួយចំនួននៅក្នុងគេហទំព័រនេះត្រូវបានយកទៅប្រើប្រាស់ជាភស្តុតាងដើម្បីដាក់បន្ទុកមេដឹកនាំខ្មែរក្រហម ។

គេហទំព័រ www.truthcambodia.com បែងចែកជា៥ ផ្នែកសំខាន់ គឺ១) ផ្នែកឯកសារ ២) ផ្នែកប្រវត្តិ សាស្ត្រ ៣) ផ្នែកច្បាប់ ៤) ផ្នែកវេទិកាពិភាក្សាជាសាធារណៈ និង ៥) ផ្នែកស្រាវជ្រាវស្វែងរកក្រុម គ្រួសារដែលបានស្លាប់ ឬបាត់ខ្លួនក្នុងរបបខ្មែរក្រហម ។ នៅក្នុងគេទំព័រ www.truthcambodia.com ក៏មានផ្ទុកនូវឯកសារជាវីដេអូ, សំឡេង, រូបថត និងឯកសារដើមរបស់ខ្មែរក្រហមដែរ ។

អត្ថបទសម្រាប់ផ្នែកទី១) នឹងរៀបរៀងឡើង ដោយស្មេរមជ្ឈមណ្ឌលឯកសារកម្ពុជា ដោយផ្អែកលើឯកសារដើមទាំងស្រុង ។ សរសេរឲ្យស្រួលអាន គឺការសង្ខេបចេញពីឯកសារដើមមកជាអត្ថបទ ។ គោលបំណងនៃផ្នែកនេះ គឺចង់ជម្រាបជូនសាធារណជនថា តើមានឯកសារអ្វីខ្លះដែលតម្កល់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ផ្នែកទី២) គឺជាអត្ថបទវិភាគលើប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហម ។ អត្ថបទផ្នែកនេះគឺជាអត្ថបទចូលរួមមកពីអ្នកជំនាញជាន់ខ្ពស់លើប្រវត្តិសាស្ត្រខ្មែរក្រហម ហើយមានទិសដៅសម្រិតសម្រាំងប្រវត្តិសាស្ត្រនេះឲ្យមានភាពកាន់តែសុក្រិតឡើងទៀត ។ ផ្នែកទី៣) គឺជាផ្នែកច្បាប់ដែលធ្វើការវិភាគដោយមេធាវី ឬចៅក្រម ឬអ្នកជំនាញការច្បាប់អន្តរជាតិ ។ ការវិភាគនេះនឹងជួយជាគំនិតលើផ្នែកច្បាប់ថា តើឧក្រិដ្ឋកម្មអ្វីខ្លះដែលបានកើតឡើងក្នុងរបបខ្មែរក្រហម ហើយថា តើឧក្រិដ្ឋកម្មនីមួយៗត្រូវតែដោះស្រាយតាមនីតិវិធីបែបណា ដើម្បីរកឲ្យបាននូវយុត្តិធម៌ពិតប្រាកដមួយដល់ជនរងគ្រោះ ។ ផ្នែកទី៤) គឺជាវេទិកាពិភាក្សា និង ផ្ដល់គំនិតនានាលើបញ្ហាខ្មែរក្រហម ។ អត្ថបទទីនេះ គឺជាវិភាគទានចូលរួមពីសំណាក់អង្គការក្រៅរដ្ឋាភិបាលនានា សមាជិករាជរដ្ឋាភិបាល គ្រូ សិស្ស និស្សិត ជាដើម ។ល ។ ផ្នែកទី៥) គឺជាទំព័រស្រាវ ជ្រាវស្វែងរកក្រុមគ្រួសារដែលបានស្លាប់ ឬ បាត់ខ្លួនក្នុងរបបខ្មែរក្រហម ឬការសាកសួររកព័ត៌មានអំពីមិត្តភក្ដិ សាច់សារលោហិតដែលបានស្លាប់ដោយសាររបបខ្មែរក្រហម ។ ជាទំព័រឈឺចាប់ អាណោចអធម ប៉ុន្តែក៏ជាទំព័ររម្ងាប់ការមន្ទិលសង្ស័យដើម្បីសេចក្ដីសុខក្នុងខ្លួនជាអមតៈ ។

សរុបសេចក្ដីទៅផ្នែកទាំង៥ ខាងលើនៃគេហទំព័រ www.truthcambodia.com នឹងបើកចំហជូនដល់ការចូលរួមស្វែងរកការពិតពីសាធារណជនគ្រប់ស្រទាប់ ជាន់ថ្នាក់ ដោយមិនប្រកាន់ពណ៌សម្បុរ ភេទ អាយុ ឬនិន្នាការនយោបាយណាមួយឡើយ ។ គេហទំព័រ www.truthcambodia.com នឹងបម្រើដល់សាធារណជន និងដើម្បីជួយជ្រោមជ្រែងស្វែងរកយុត្តិធម៌ជូនដល់ប្រជាជនកម្ពុជាគ្រប់រូប ។ គ្រប់ លិខិត ឬអត្ថបទ ដែលផ្ញើមកកាន់គេហទំព័រ www.truthcambodia.com សូមដាក់ឈ្មោះ មុខងារ អាសយដ្ឋាន និងលេខទូរស័ព្ទសម្រាប់ផ្ញើសេចក្ដីបញ្ជាក់លើខ្លឹមសារនៃលិខិត ឬអត្ថបទមុនការចេញផ្សាយ ។

គេហទំព័រ www.truthcambodia.com សូមរក្សាសិទ្ធិក្នុងការកែលម្អពាក្យពេចន៍នៃលិខិតទាំងឡាយ ក្នុងន័យថែរក្សានូវអត្ថន័យដើមទាំងស្រុង ។ ប៉ុន្តែ គេទំព័រ www.truthcambodia.com នឹងចុះផ្សាយទាំងស្រុងចំពោះអត្ថបទចូលរួមទាំងឡាយ ។

# កេរ្តិ៍ឈ្មោះរបស់អង្គការសហប្រជាជាតិជុំវិញបញ្ហា នៅសាលាក្តីខ្មែរក្រហម

*តុលាការកូនកាត់របស់អង្គការសហប្រជាជាតិស្ថិតនៅក្នុងគ្រោះថ្នាក់ដោយមិនដឹងខ្លួន*

*នៅពេលដែលប្រទេសម្ចាស់ជំនួយបានមើលរំលងនូវការជ្រៀតជ្រែករបស់រដ្ឋាភិបាលកម្ពុជា*



និមិត្តសញ្ញារបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ទីក្រុង អាន អាប៊ីរ រដ្ឋមីឈីហ្កែន ៖ អង្គការសហប្រជាជាតិ ប្រឈមនឹងការសាកល្បងយ៉ាងលំបាកចំពោះទំនុកចិត្ត ។ ប្រមាណជាងមួយទសវត្សកន្លងមក អង្គការសហប្រជាជាតិបានធ្វើការគាំទ្រ ចំពោះ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬហៅកាត់ថា (អ.វ.ត.ក) ដែលជាសាលាក្តីកូនកាត់បង្កើតឡើងដោយមានការចូលរួមពីភាគីជាតិ និង អន្តរជាតិ ដើម្បីធ្វើការកាត់ទោស “មេដឹកនាំជាន់ខ្ពស់” និងអ្នកដទៃទៀតដែល “ទទួលខុសត្រូវខ្ពស់បំផុត” ចំពោះអំពើឃោរឃៅនៅក្នុងរបប ប៉ុល ពត ដែលមានការគាំទ្រពីប្រទេសចិន ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឆ្លុះបញ្ចាំងឲ្យឃើញនូវការរួមបញ្ចូលគ្នារវាងប្រទេសមហាអំណាចលោកខាងលិចដែលជ្រោមជ្រែង ជំរុញឲ្យមានយុត្តិធម៌ ដឹកនាំដោយអង្គការសហប្រជាជាតិ ជាមួយនឹងរដ្ឋាភិបាលកម្ពុជាដែលគាំទ្រដោយទីក្រុងប៉េកាំងដែលជាអ្នកគ្រប់គ្រងដ៏ធំ ។ រដ្ឋាភិបាលកម្ពុជាបានធ្វើការសាកល្បងលើការតាំងចិត្តរបស់អង្គការសហប្រជាជាតិម្តងហើយម្តងទៀត ដោយបានធ្វើការជ្រៀតជ្រែកលើកិច្ចការងារតុលាការ និងធ្វើការពន្យារពេលសវនាការទាំងឡាយណាដែលខ្លួនមិនចង់ឲ្យកើតមានឡើង ។ អង្គការសហប្រជាជាតិ និងមន្ត្រីនៃប្រទេសផ្តល់ជំនួយតែងតែបញ្ចៀសនូវរាល់បញ្ហាទាំងនេះ ហើយចង់ឃើញសំណុំរឿងដំបូងនៃករណីទាំងពីររបស់សាលាក្តីបានបញ្ចប់ និងការពារនូវកេរដំណែលរបស់ខ្លួននៅក្នុងតុលាការ និងប្រទេសកម្ពុជា ។ ទោះបីជាយ៉ាងណាការរួមបញ្ចូលគ្នារវាងអង្គការសហប្រជាជាតិ និងកម្ពុជាដែលស្ទើរតែប្រេះឆាទៅហើយនោះ ក៏ដោយសារតែលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ធ្វើការច្រានចោលនូវដីកាឃាត់ខ្លួនដែលចេញដោយចៅក្រមដែលតែងតាំងដោយអង្គការសហប្រជាជាតិ ។ ការបដិសេធរបស់លោក ហ៊ុន សែន ដែលមានការជំរុញពីចិន និងការឆ្លើយតបដោយស្ទាក់ស្ទើរពីប្រទេសលោកខាងលិចបានចោទជាបញ្ហាប្រឈមដ៏ធ្ងន់ធ្ងរទៅលើតួនាទីរបស់អង្គការសហប្រជាជាតិ ។ ជំនួយទន់ខ្សោយលើបទដ្ឋានច្បាប់នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ពីសំណាក់សមាជិករដ្ឋសំខាន់ៗ អាចនឹងកាត់បន្ថយនូវសមត្ថភាពរបស់អង្គការសហប្រជាជាតិក្នុងការដាក់ចេញនូវបទដ្ឋានការងាររបស់ខ្លួនដែរ ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវបានបង្កើតឡើងបន្ទាប់ពីការចរចាគ្នាអស់រយៈពេលជាច្រើនឆ្នាំ គិតចាប់ពីឆ្នាំ១៩៩៩ ។ រដ្ឋាភិបាលអាមេរិកបានលើកឡើងនូវគំនិតបង្កើតតុលាការអន្តរជាតិ ដូចជា តុលាការអន្តរជាតិសម្រាប់អតីត

ប្រទេសយូហ្គោស្លាវី និងរ៉ាន់ដា ក៏ប៉ុន្តែសំណើសុំនេះមានសភាពរអាក់រអួល ។ ប្រទេសជាច្រើនបានធ្វើការជំទាស់ចំពោះសាលាក្តីអន្តរជាតិ ហើយសិទ្ធិវេតូរបស់ចិនបានជំទាស់ជាមួយនឹងការសម្រេចណាមួយរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិដែលបង្ខំឲ្យលោក ហ៊ុន សែន ប្រគល់ឲ្យប្រទេសលោកខាងលិចដឹកនាំនូវសវនាការ ដែលជាប់ទាក់ទងជាមួយអតីតខ្មែរក្រហមដែលជាសម្ព័ន្ធភាពរបស់ចិន ។

ដូច្នេះហើយ មន្ត្រីអាមេរិកក៏បានផ្តួចផ្តើមឡើងនូវគំនិតនៃការបង្កើតតុលាការកូនកាត់ ជាគំនិតមួយដែលលោក ហ៊ុន សែន គាំទ្រពីព្រោះជាមធ្យោបាយមួយសម្រាប់ទាក់ទាញនូវជំនួយអន្តរជាតិ និងមានលក្ខណៈសមស្រប ដោយមិនចាំបាច់បាត់បង់នូវអំណាចលើដំណើរការសាលាក្តី ។ អង្គការសហប្រជាជាតិ និងភាគីកម្ពុជាមានការខ្វែងគំនិតគ្នាអំពីថា តើភាគីណាមួយដែលនឹងត្រូវមានសិទ្ធិតែងតាំងចៅក្រមក្នុងចំណោមចៅក្រមទាំងអស់ និងអ្នកដែលទទួលនាទីសំខាន់ៗផ្សេងទៀត ។ លោក ហ៊ុន សែន បានប្រឆាំង ហើយជាចុងក្រោយប្រទេសម្ចាស់ជំនួយមួយចំនួន រួមបញ្ចូលទាំង ជប៉ុន បារាំង អូស្ត្រាលី និងសហរដ្ឋអាមេរិក បានដាក់សម្ពាធលើអគ្គលេខាធិការអង្គការសហប្រជាជាតិ លោក កូហ្វី អាណាន់ និងអ្នកច្បាប់របស់គាត់ឲ្យសម្រុះសម្រួល ។ មន្ត្រីមួយចំនួន ជាពិសេសនៅទីក្រុងវ៉ាស៊ីនតោនបានធ្វើការផ្តោតលើការធ្វើឲ្យប្រសើរឡើងចំពោះការស្វែងរកយុត្តិ


នួន ជា (រូបថត : អ.វ.ត.ក)


ខៀវ សំផន (រូបថត : អ.វ.ត.ក)


អៀង ធីរិទ្ធ (រូបថត : អ.វ.ត.ក)


មាស មុត (រូបថត : អ.វ.ត.ក)


អ៊ឹម ចែម (រូបថត : អ.វ.ត.ក)


អោ អាន (រូបថត : អ.វ.ត.ក)

ធម៌ និងសម្លឹងឃើញថា ការរួមបញ្ចូលនៃអង្គការសហប្រជាជាតិ គឺជាផ្លូវឆ្ពោះទៅមុខតែមួយប៉ុណ្ណោះ ។ អ្នកដទៃទៀតរំពៃឃើញថា ការគាំទ្រដំណើរការដែលដឹកនាំដោយកម្ពុជា គឺជាផ្លូវតែមួយក្នុងការកសាង ឬរក្សានូវឥទ្ធិពលនៅក្នុងទីក្រុងភ្នំពេញ និងប្រឆាំងនឹងការកើនឡើងនៃអំណាចរបស់ចិន ។

លទ្ធផលបានបង្ហាញថា តុលាការកម្ពុជា គឺងាយនឹងទទួលរងឥទ្ធិពលពីការជ្រៀតជ្រែកផ្នែកនយោបាយនៅក្នុងស្រុក ។ អ្នកដែលត្រូវបានចាត់តាំងដោយអង្គការសហប្រជាជាតិ និងកម្ពុជាបានព្រមព្រៀងលើករណីពីរនៃសំណុំរឿងលើកដំបូងរបស់តុលាការ ។ ករណីទីមួយបានលើកឡើងអំពី ឌុច អតីតប្រធានមន្ទីរសន្តិសុខស-២១ ដ៏ព្រៃផ្សៃនៅគុកទួលស្លែង ដែលត្រូវបានចោទប្រកាន់នៅក្នុងឆ្នាំ ២០១០ ពីបទបានប្រព្រឹត្តឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ ករណីទីពីរ គឺជាប់ទាក់ទងទៅនឹងមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមដែលនៅរស់រានមានជីវិតចំនួនពីររូប គឺ នួន ជា និង ខៀវ សំផន ដែលត្រូវបានចោទប្រកាន់នៅក្នុងឆ្នាំ២០១៤ ពីបទបានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ហើយបាននឹងកំពុងត្រូវជំនុំជម្រះពីធាតុផ្សំបទល្មើសបន្ថែមទៀត ។ ទោះបីជាមានបញ្ហាជាច្រើនត្រូវបានលើកឡើងទាក់ទងនឹងករណី ដូចជាការចោទប្រកាន់អំពីបញ្ហាពុករលួយនៅក្នុងការិយាល័យរដ្ឋបាល និងការបដិសេធក្នុងការកោះមន្ត្រីរដ្ឋាភិបាលកម្ពុជាមួយចំនួនឲ្យចូលបង្ហាញខ្លួនក៏ដោយ ក៏ភាគីជាតិ មិនបានព្យាយាមទប់ស្កាត់ករណីទាំងនេះឡើយ រហូតដល់អង្គជំនុំជម្រះបានចេញសាលក្រម ។ ការបដិសេធរបស់លោក ហ៊ុន សែន ដែលបង្កជាបញ្ហាប្រឈមដល់ដំណើរការក្តី បានដាក់កំហិតដល់ការកាត់ទោសនៅថ្ងៃខាងមុខ ។

រយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ព្រះរាជអាជ្ញាដែលតែងតាំងដោយអង្គការសហប្រជាជាតិបានជំរុញឲ្យមានការចោទប្រកាន់ជនសង្ស័យរហូតដល់៦រូបបន្ថែមទៀត ដើម្បីនាំមកកាត់ទោស ក៏ប៉ុន្តែ លោក ហ៊ុន សែន បានច្រានចោល ។ លោកបានលើកឡើងថា សំណុំរឿងបន្ថែមនេះ អាចបង្កទៅជាជម្លោះ ។ លោក ហ៊ុន សែន មានប្រសាសន៍ធ្ងន់ៗទៅកាន់ឯកឧត្តមអគ្គលេខាធិការអង្គការសហប្រជាជាតិ បាន គីមូន កាលពីឆ្នាំ២០១០ថា នឹងមិនមានសវនាការបន្ថែមទៀតទេ ។ មន្ត្រីតុលាការភាគីកម្ពុជាដែលនៅក្រោមបង្គាប់បានអនុវត្តតាមការណែនាំពីរដ្ឋាភិបាល ។ មន្ត្រីទាំងនោះបានលើកឡើងថា ជនសង្ស័យទាំងនោះ មិនត្រូវបានចាត់ចូលជាអ្នកដែល “ទទួលខុសត្រូវខ្ពស់បំផុត” ចំពោះឧក្រិដ្ឋកម្មក្នុងរបបខ្មែរក្រហមទេ បើទោះជាអ្នកទាំងនេះត្រូវបានចោទពីបទបានប្រព្រឹត្តអំពើឃោរឃៅលើជនរងគ្រោះរាប់ពាន់នាក់ក៏ដោយ ។

មន្ត្រីដែលចាត់តាំងដោយភាគីកម្ពុជា ក៏បានបង្កជាភាពស្មុគស្មាញដល់ការស៊ើបអង្កេត ដែលជាហេតុបណ្តាលឲ្យចៅក្រមអន្តរជាតិ និងបុគ្គលិកមួយចំនួនលាឈប់ពីតំណែង ដើម្បីសម្តែងការប្រឆាំង ។ អ្នកនាំពាក្យរបស់រដ្ឋាភិបាលបានថ្លែងថា មន្ត្រីអង្គការសហប្រជាជាតិអាច “ខ្ចប់អីវ៉ាន់ត្រឡប់ទៅវិញ” ប្រសិនបើអ្នកទាំងនេះមិនយល់ស្របនឹងជំហររបស់រដ្ឋាភិបាល ។ នៅខែមីនា ឆ្នាំ២០១៥ បន្ទាប់ពីចៅក្រមដែលចាត់តាំងដោយអង្គការសហប្រជាជាតិបានចោទលើជនសង្ស័យបីរូបបន្ថែមទៀត លោក ហ៊ុន សែន បានព្រមានថា តុលាការបានធ្វើ “ស្ទើរតែលើសពីការអត់ធ្មត់របស់គាត់” ។ រដ្ឋាភិបាលបានច្រានចោលនូវដីកាឃាត់ខ្លួន ។ នៅខែកុម្ភៈ លោក ហ៊ុន សែន បានលើកឡើងជាថ្មីម្តងទៀតថា សំណុំរឿងបន្ថែមអាចជំរុញឲ្យមនុស្សមួយចំនួន “វិលចូលព្រៃវិញ” ហើយបានចោទជាសំណួរថា “តើនឹងមានមនុស្សប៉ុន្មាននាក់នឹងស្លាប់ប្រសិនបើមានសង្គ្រាមកើតឡើងជាថ្មី?” ទោះបីជាយ៉ាងណា មានភ័ស្តុតាងជាមូលដ្ឋានតិចតួចណាស់ចំពោះការភ័យខ្លាចនេះ ។ ខ្មែរក្រហមដែលជាកងកម្លាំងប្រយុទ្ធបានរលាយទៅហើយ ទន្ទឹមនឹងនេះ សវនាការរបស់អង្គជំនុំជម្រះវិសាមញ្ញ ក៏មិនបានបំពានដល់សន្តិភាពដែរ ។ កម្លាំងចលករជាក់ស្តែង សម្រាប់ដោះស្រាយនូវបញ្ហារបស់កម្ពុជា គឺពង្រឹងនូវនយោបាយដែលគ្រប់គ្រងលើដំណើរការនេះ ។ រដ្ឋាភិបាលបច្ចុប្បន្នដែលដឹកនាំដោយគណបក្សប្រជាជនកម្ពុជារបស់លោក ហ៊ុន សែន មានរួមបញ្ចូលនូវអតីតសមាជិកខ្មែរក្រហម ដែលកាន់មុខតំណែងខ្ពស់ ។ លោក ហ៊ុន សែន ផ្ទាល់ក៏ជាកម្មាភិបាលខ្មែរក្រហមថ្នាក់ទាបដែរ នៅមុនពេលដែលលោករត់ភៀសខ្លួនទៅប្រទេសវៀតណាម និងជួយរៀបចំចលនាតស៊ូទម្លាក់ខ្មែរក្រហមពីអំណាច កាលពីឆ្នាំ១៩៧៩ ។ សមាជិកដទៃទៀត ក្រោយមកក៏ទទួលបាននូវមុខតំណែងផ្លូវការសំខាន់ៗ ដើម្បីជាថ្នូរដល់អ្នកទាំងនោះក្នុងការចាកចេញពីរបបខ្មែរក្រហម ដែលខ្លួនបានចូលរួមនៅក្នុងអំឡុងទសវត្សទី៨០ និង៩០ ។

ហេតុដូច្នេះ ទំហំនៃកាត់ទោសដែលបើកទូលាយ អាចក្លាយទៅជាការគំរាមកំហែងមួយដល់គណបក្សប្រជាជនកម្ពុជា ។ សវនាការក៏អាចបង្កជាភាពអាម៉ាស់ដល់ប្រទេសចិន ដែលជាអ្នកគាំទ្រដ៏សំខាន់ដល់របប ប៉ុល ពត ព្រមទាំងជាអ្នកគាំទ្ររបស់គណបក្សប្រជាជនកម្ពុជានាពេលបច្ចុប្បន្នដែរ ។ ជំនួយផ្នែកហិរញ្ញវត្ថុ និងការគាំទ្រផ្នែកនយោបាយរបស់ចិន បានជួយទ្រទ្រង់ដល់ស្ថិរភាពរដ្ឋាភិបាលរបស់លោក ហ៊ុន សែន ដែលជាហេតុបង្កឲ្យអ្នកដឹកនាំគណបក្សប្រជាជនកម្ពុជាកាន់តែមិន យល់ព្រមចំពោះទង្វើទាំងឡាយណាដែលបំពានដល់ទីក្រុងប៉េកាំង និងសមត្ថភាពក្នុងការបំពាននូវអំណាចរបស់អ្នកដទៃ ។

ទោះបីជាការចូលរួមរបស់អង្គការសហប្រជាជាតិ នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺដើម្បីជួយធានាឲ្យបាននូវបទដ្ឋានអន្តរជាតិក៏ដោយ ក៏ប្រទេសម្ចាស់ជំនួយដែលជាសមាជិកអង្គការសហប្រជាជាតិបានធ្វើការឆ្លើយតបយ៉ាងសោះអង្គើយចំពោះការជ្រៀតជ្រែករបស់កម្ពុជាម្តងហើយម្តងទៀត ។ មន្ត្រីអង្គការសហប្រជាជាតិ បានចេញនូវសេចក្តីថ្លែងការណ៍អំពី «ការព្រួយបារម្ភយ៉ាងខ្លាំង» ក៏ប៉ុន្តែពួកគេបានលើកឡើងច្រើនដងថា ពួកគេនឹងមិនធ្វើការស៊ើបអង្កេតលើការចោទប្រកាន់ទាំងឡាយណាដែលមិនមានភស្តុតាងទាក់ទងជាមួយនឹងការជ្រៀតជ្រែកផ្នែកនយោបាយទេ ។ ការបដិសេធបច្ចុប្បន្នរបស់រដ្ឋាភិបាលចំពោះដីកាឃាត់ខ្លួន បានបង្កើតទៅជាការលេចឡើងនៃការរិះគន់ពីសំណាក់សង្គមស៊ីវិល ជាមួយគ្នានោះ អង្គការគម្រោងយុត្តិធម៌សង្គម បានលើកឡើងអំពីបរាជ័យរបស់អង្គការសហប្រជាជាតិដើម្បីដោះស្រាយនូវបញ្ហា «តែបែរជាបង្កនូវភាពតានតឹងបន្ថែម» ជាងខបសគ្គដោយសាររដ្ឋាភិបាលទៅទៀត ។ ទោះបីជាយ៉ាងណាក្តី ម្ចាស់ជំនួយរួមមាន សហរដ្ឋអាមេរិក បារាំង និង អង់គ្លេស បានធ្វើការបញ្ជាក់ជាថ្មីម្តងទៀតចំពោះការគាំទ្រតុលាការ ។ ជប៉ុននៅតែបន្តផ្តត់ផ្គង់នូវជំនួយហិរញ្ញវត្ថុទាំងស្រុងដោយអមជាមួយនឹងសំណួរ ហើយអគ្គរាជទូតជប៉ុន បានថ្លែងថា «នៅពេលដែលការជ្រៀតជ្រែកផ្នែកនយោបាយមកលើដំណើរការប្រព្រឹត្តទៅរបស់តុលាការ មិនទាន់រកឃើញការដកចេញនូវការគាំទ្រចំពោះតុលាការ គឺជាសញ្ញាណដែលខុសឆ្គង» ។

ដំបូងឡើយ ប្រទេសសំខាន់ៗដែលជំរុញឲ្យអង្គការសហប្រជាជាតិចូលរួមសម្ព័ន្ធភាពដ៏យ៉ាប់យ៉ឺនជាមួយនឹងរដ្ឋាភិបាលកម្ពុជា បានបរាជ័យក្នុងការដាក់ចេញនូវគោលការណ៍រឹងមាំដើម្បីការពារនូវតម្លាភាព និងឯករាជភាពរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ផ្នែកនេះបានឆ្លុះបញ្ចាំងមួយភាគពីភាពភ័យខ្លាចដោយសារការបង្ខិតបង្ខំអាចបង្កជាបញ្ហាដល់ករណីទាំងពីរនៃសំណុំរឿងដំបូងរបស់តុលាការ ជាពិសេសសំណុំរឿងដែលប្រឆាំងទៅនឹងមេដឹកនាំជាន់ខ្ពស់ នួន ជា និង ខៀវ សំផន ។ ការព្រួយបារម្ភនេះ សម្តែងឲ្យឃើញពីទម្ងន់តិចតួចដោយសារតែបច្ចុប្បន្ន មេដឹកនាំជាន់ខ្ពស់ត្រូវបានកាត់ទោសត្រឹមត្រូវតាមច្បាប់ ។ ហេតុផលបង្កប់នៃភាពអសកម្មរបស់ម្ចាស់ជំនួយ គឺការមិនព្រមជំទាស់នឹងរដ្ឋាភិបាលរបស់លោក ហ៊ុន សែន និងការបណ្តែតបណ្តោយឲ្យធ្លាក់នៅក្រោមឥទ្ធិពលរបស់ចិនកាន់តែខ្លាំងឡើង ។ ហេតុដូច្នេះ ករណីនៅប្រទេសកម្ពុជាបានរំលេចឡើងនូវបញ្ហាប្រឈម ជាពិសេស ទាក់ទងនឹងកំណើននៃប្រសិទ្ធភាពការងាររបស់អង្គការសហប្រជាជាតិ ដោយសារតែអំណាចរបស់ប្រទេសចិនបានជំរុញឲ្យប្រទេសលោកខាងលិច និងជប៉ុន សម្រេចចិត្តបង្កើនការប្រុងប្រយ័ត្នចំពោះដៃគូរដ្ឋាភិបាលដែលមានសភាពយ៉ាប់យ៉ឺន ។

អង្គការសហប្រជាជាតិ និងប្រទេសម្ចាស់ជំនួយសំខាន់ៗរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវបង្ហាញពីគោលជំហររឹងមាំដើម្បីប្រឆាំងនឹងការជ្រៀតជ្រែកផ្នែកនយោបាយដែលកើតឡើងនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដោយបញ្ជាក់ឲ្យបានច្បាស់ថាក្នុងករណីដែលមិនមានការកែតម្រូវភ្លាមៗ មូលនិធិដែលផ្តល់ដល់តុលាការនឹងត្រូវបញ្ឈប់ ហើយរដ្ឋាភិបាលរបស់លោក ហ៊ុន សែន នឹងជាអ្នកទទួលបន្ទុកនេះ ។ ជំហរបែបនេះ នឹងធ្វើឲ្យការសង្ស័យទាំងប៉ុន្មានបង្ហាញឲ្យកាន់តែច្បាស់នៅទីក្រុងទីក្រុងភ្នំពេញ ហើយអាចនាំទៅដល់ការពិភាក្សាដ៏មានខ្លឹមសារ ប៉ុន្តែ មធ្យោបាយទាំងនេះអាចជាហានិភ័យ ។ ប្រសិនបើជំហរនេះមិនបានជោគជ័យ មិនត្រឹមតែបង្កឲ្យមានការពន្យារដល់ការស្វែងរកយុត្តិធម៌ដល់ប្រជាជនកម្ពុជា និងកេរ្តិ៍ឈ្មោះរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាប៉ុណ្ណោះទេ គឺវាអាចប៉ះពាល់ដល់ជំនឿទុកចិត្តលើអង្គការសហប្រជាជាតិក្នុងការប្រកាន់ខ្ជាប់នូវបទដ្ឋានអន្តរជាតិទៀតផង ។

**ចន ឆរឆីអារី**

# ប្រទេសកម្ពុជា : ប្រវត្តិនៃអំពើហិង្សា

**(តចប់)**

ប៉ុន្តែលទ្ធផលចុងក្រោយពិបាកនឹងស្មានទុកមុនណាស់ ។ ចាប់តាំងពីកងទ័ពវៀតណាមបណ្តេញខ្មែរក្រហម ចេញពីអំណាច នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ការយល់ដឹងពីរបបខ្មែរក្រហម ត្រូវបានជាប់ជំពាក់ដ៏គួរឲ្យអស់សង្ឃឹមជាមួយនឹងនយោបាយរបស់ប្រទេសកម្ពុជា ។ ពេញមួយទសវត្សរ៍ឆ្នាំ១៩៨០ សាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលលើកបន្តុបដោយកងទ័ពវៀតណាម បានប្រយុទ្ធប្រឆាំងនឹងក្រុមចលនាតស៊ូចម្រុះ ដែលរួមមានក្រុមខ្មែរក្រហម គាំទ្រដោយបស្ចិមប្រទេស និងប្រទេសចិន ។ ជាមួយនឹងសង្គ្រាមស៊ីវិលរ៉ាំរ៉ៃ សាធារណរដ្ឋប្រជាមានិតកម្ពុជាបានកសាងភាពស្របច្បាប់របស់ខ្លួន ដោយឈរលើមូលដ្ឋានថាខ្លួនជាអ្នកផ្តួលរំលំរបប ប៉ុល ពត ។ នៅដើមទសវត្សរ៍ឆ្នាំ១៩៨០ សាធារណរដ្ឋប្រជាមានិតកម្ពុជា បានសាងសង់ស្តូបរំរំឭកវិញ្ញាណក្ខន្ធនៅតាមតំបន់មួយចំនួន ដូចជាវត្តស្ទួនពេជ្រ ដើម្បីធ្វើឲ្យការប៉ះទង្គិចផ្លូវចិត្តរបស់អ្នករស់រានមានជីវិតក្លាយទៅជារឿងនយោបាយ ។ អ្នករស់រានមានជីវិតត្រូវបានជំរុញឲ្យយល់ឃើញថា ៧មករា គឺជាថ្ងៃដែលធ្វើឲ្យរដ្ឋកម្ពុជានៅឋិតថេរ និងជាថ្ងៃកំណើតទីពីរនៃប្រទេសនេះ ។

នៅក្នុងផែនការនេះ ការឡើងកាន់អំណាចរបស់ខ្មែរក្រហមកាលពីបួនទសវត្សរ៍មុនត្រូវបានចាត់ទុកថាជាជំហានអន្តរការរវាងភាពរីករវរកាលពីអតីតកាល និងសមិទ្ធផលពិតប្រាកដនាពេលបច្ចុប្បន្ន ។ នៅវត្តស្ទួនពេជ្រ ខ្ញុំបានជួបលោក ទេព គី អាយុ ៦០ ឆ្នាំ ដែលមានមាឌល្អិត ពាក់អាវស ដៃខ្លី ខោខ្មៅ និងស្បែកជើងផ្ទាត់ ។ ក្នុងនាមជាអ្នកដឹកកិច្ចការច្រើនក្នុងមូលដ្ឋាន លោក ទេព គី មានតួនាទីជាប្រធានសន្តិសុខភូមិ សមាជិកគណបក្សប្រជាជនកម្ពុជា សមាជិកគណៈកម្មការវត្ត និងជាឆ្មាំស្តូបរំឭកវិញ្ញាណក្ខន្ធ ។ លោក



អំពើហិង្សានៅប្រទេសកម្ពុជា ដែលបានកើតឡើងនៅក្នុងទសវត្សរ៍ឆ្នាំ១៩៩០

ទេព គឺ បាននិយាយថា ១៧ មេសា ជាថ្ងៃដ៏សំខាន់ ។ ថ្ងៃនេះ ដូចជាដើមកំណើតដូចជាការចាប់ផ្តើមនៃថ្ងៃ៧មករា ។ ប្រសិនបើពួកយើងមិនមាន ១៧ មេសា នោះទេ យើងក៏មិនមាន ៧មករា ដែរ ។

ចាប់តាំងពីពេលនោះមក របបខ្មែរក្រហមគឺជាប្រធានបទដ៏សំខាន់ក្នុងកិច្ចពិភាក្សារបស់លោក ហ៊ុន សែន ។ គាត់បានកេងយកចំនេញពីការចង់បានសន្តិភាពយ៉ាងខ្លាំងរបស់អ្នករស់រានមានជីវិត ដោយអះអាងថា គណបក្សប្រជាជនគឺជាតួអង្គតែមួយគត់ដែលស្ថិតនៅចន្លោះកម្ពុជានិងការវិលត្រឡប់ទៅរកស្ថានភាពដ៏គ្រោះថ្នាក់ ។ រាជរដ្ឋាភិបាលបានប្រើប្រាស់របបខ្មែរក្រហមជាចំនុចគោលសម្រាប់សមិទ្ធផលរបស់ខ្លួន និងក៏ជាលេសដោះសារនូវរាល់បញ្ហាទាំងឡាយនាពេលបច្ចុប្បន្នរួមមានដូចជាអំពើពុករលួយ អំពើហិង្សានយោបាយ និងការខូចខាតប្រព័ន្ធបរិបាលកិច្ចនយោបាយ ។ បើនិយាយពីនយោបាយយុទ្ធសាស្ត្រនេះពិតជាមានភាពជោគជ័យដ៏គួរឲ្យកត់សម្គាល់ ។ ប៉ុន្តែ យុទ្ធសាស្ត្រនេះក៏បានរារាំងមិនឲ្យមានការបកស្រាយត្រឹមត្រូវពីភាពភ័យខ្លាចនៃអតីតកាល ឬបញ្ហាប្រឈមមុនជាច្រើននាពេលបច្ចុប្បន្ន ។ លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលសិក្សាស្រាវជ្រាវពីឧក្រិដ្ឋកម្មនៃរបបកម្ពុជាប្រជាធិបតេយ្យ បាននិយាយថា «កិច្ចខិតខំប្រឹងប្រែងណាក៏អស្ចារ្យរុងរឿងដែរ បើប្រៀបធៀបជាមួយរបបខ្មែរក្រហម ពីព្រោះរបបខ្មែរក្រហមមានភាពងងឹតសូន្យឈឹង ។ អ្នកអាចមានត្រឹមតែទៀនតូចមួយដើម តែទៀននោះអាចក្លាយទៅជាកាំជ្រួច» ។

លោក ខាលម៉ៃយើល យល់ស្របថា «រាជរដ្ឋាភិបាលនេះបានគ្រប់គ្រងប្រទេសអស់រយៈពេល៣០ឆ្នាំមកហើយ ។ ប្រសិនបើរាជរដ្ឋាភិបានចង់បានភាពទទួលខុសត្រូវខ្លួនអាចទទួលបាន ។ ប្រសិនបើខ្លួនចង់បានប្រព័ន្ធតុលាការត្រឹមត្រូវមួយ ក៏អាចទទួលបានដែរ ។ គ្រាន់តែរាជរដ្ឋាភិបានជ្រើសជំរើស មិនចង់បានតែប៉ុណ្ណោះ»

សព្វថ្ងៃ ៧មករា នៅតែជាខ្សែបន្ទាត់ដ៏សំខាន់នៅក្នុងនយោបាយប្រទេសកម្ពុជា ដែលបែងចែកយ៉ាងច្បាស់លាស់រវាងអ្នកជំទាស់ និងអ្នកគាំទ្រគណបក្សប្រជាជនកម្ពុជា ដែលកាន់អំណាចអស់រយៈពេលយូរ ។ ថ្ងៃ៧មករា គឺជាថ្ងៃរំដោះដោយឈរលើទស្សនៈមួយ រីឯទស្សនៈមួយផ្សេងទៀត ព្រឹត្តិការណ៍នេះគឺជាការឈ្លានពានពីសំណាក់ប្រទេសវៀតណាមដែលជាសត្រូវប្រវត្តិសាស្ត្រ ។ គ្មានមូលដ្ឋានកណ្តាលទេសម្រាប់ភាគីទាំងពីរនេះ ។ នៅក្នុងសេចក្តីថ្លែងសុន្ទរកថាមុនពិធីរំលឹកខួប ៧ មករា ឆ្នាំនេះ លោក ហ៊ុន សែន និយាយថា នរណាដែលជំទាស់នឹងរាជរដ្ឋាភិបាលរបស់គាត់គឺជាអ្នកគាំទ្រខ្មែរក្រហម ។ គាត់បានមានប្រសាសន៍ថា «អ្នកឯងស្អប់ ប៉ុល ពត ប៉ុន្តែអ្នកឯងប្រឆាំងនឹងអ្នកផ្តួលរលំ ប៉ុល ពត ។ តើនេះមានន័យថាយ៉ាងម៉េច? វាមានន័យថាអ្នកឯងជាសម្ព័ន្ធមិត្តនៃរបបខ្មែរក្រហម» ។

នេះសបញ្ជាក់ឲ្យឃើញថា ប្រជាជនកម្ពុជាសព្វថ្ងៃអាចពិភាក្សាអំពីរបបខ្មែរក្រហមដោយតុល្យភាពនៅមានកម្រិតតិចតួចនៅឡើយ ។ ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យមិនត្រូវបានបង្រៀនឲ្យបានត្រឹមត្រូវទេនៅតាមសាលាក្នុងប្រទេសកម្ពុជា រហូតដល់ឆ្នាំ ២០១០ ។ មួយភាគធំនៃបញ្ហានេះបណ្តាលមកពីភាគីនយោបាយដែលប្រកួតប្រជែងនឹងគ្នាមិនយល់ស្របថាតើត្រូវបង្រៀនប្រវត្តិសាស្ត្រនេះយ៉ាងដូចម្តេច ។ ចំនុចដ៏រសើបនៃបញ្ហានេះក៏ធ្វើឲ្យមានការប៉ះពាល់ដល់កិច្ចខិតខំប្រឹងប្រែងដើម្បីនាំយកមេដឹកនាំខ្មែរក្រហមនៅរស់រានមានជីវិតមកកាត់ទោស ។

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានកាត់ទោសប្រកបដោយជោគជ័យចំនួនបីដង ចាប់តាំងពីបានបង្កើតនៅឆ្នាំ២០០៦ ក៏ប៉ុន្តែរាជរដ្ឋាភិបាលបានព្យាយាមយ៉ាងខ្លាំង ដើម្បីកំណត់ការកាត់ទោសនេះឲ្យនៅត្រឹមក្រុមតូចមួយនៃអតីតមេដឹកនាំ ដែលត្រូវបានជ្រើសរើសរួចហើយ ។ មន្ត្រីគណបក្សប្រជាជនកម្ពុជាជាច្រើនសព្វថ្ងៃនេះ ធ្លាប់ជាកម្មាភិបាលខ្មែរក្រហមថ្នាក់ក្រោម និងកណ្តាល ។ ដូច្នេះ យើងអាចសន្មតបានថា អ្នកទាំងនោះ មានការភ័យខ្លាចនូវអ្វីដែលកិច្ចដំណើរការជំនុំជម្រះដែលមិនកំហិតដោយច្បាប់ អាចនឹងត្រូវលាតត្រដាង ។ លោក ឆាំង យុ មានប្រសាសន៍ថា «ដោយសារតែខ្មែរក្រហមបានប៉ះពាល់មកលើមនុស្សគ្រប់រូប បញ្ហាខ្មែរក្រហមក្លាយទៅជារឿងបុគ្គលម្នាក់ៗ»

អស់រយៈពេលប៉ុន្មានសប្តាហ៍កាលពីខែតុលា និងវិច្ឆិកា បាតុករមួយរូបដែលមានឈ្មោះ រឿន កុសល បានធ្វើការតវ៉ាតែម្នាក់ឯងគត់នៅទីលានប្រជាធិបតេយ្យក្នុងទីក្រុងភ្នំពេញ ។ កុសល ដែលមានអាយុទើបតែ៥ឆ្នាំ នៅពេលបាត់បង់ឪពុកម្តាយរបស់គាត់ក្នុង

អំឡុងពេលជម្លៀសចេញពីទីក្រុងភ្នំពេញ កាលពីថ្ងៃទី១៧ ខែមេសា បានឈរ និងដៃកាន់ឆ័ត្រ ដើម្បីការពារពីពន្លឺព្រះអាទិត្យ ។ បដាសរសេរដោយដៃបានដាក់នៅលើឥដ្ឋ ។ បដាទាំងនោះបង្ហាញពីគោលបំណងតវ៉ារបស់គាត់យ៉ាងច្បាស់ គឺថាអតីតមេដឹកនាំខ្មែរក្រហម នួន ជា និង ខៀវ សំផន ដែលត្រូវបាននាំមកកាត់ទោសនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គ្រាន់តែជា ឃាតករសិប្បនិម្មិតតែប៉ុណ្ណោះ ជាការពិតទៅ វៀតណាម និងកងទ័ពវៀតកុងនោះទេ ដែលជាអ្នកទទួលខុសត្រូវពិតប្រាកដចំពោះឧក្រិដ្ឋកម្មខ្មែរក្រហម ។ គាត់បានពន្យល់ប្រាប់ ខេមបូឌា ដេលី ថា «គោលបំណងសំខាន់របស់ខ្ញុំ គឺពន្យល់ប្រាប់សហគមន៍ជាតិ និងអន្តរជាតិថា ខៀវ សុផន និង នួន ជា មិនមែនជាជនដៃដល់ពិតប្រាកដនោះទេ»

នៅក្នុងប្រទេសកម្ពុជា រឿងរ៉ាវជាផ្លូវការដ៏ច្រើនលើសលប់អំពីរបបខ្មែរក្រហមបានបង្កើតសាច់រឿងប្រវត្តិសាស្ត្រផ្ទុយស្រឡះមួយទៀត ដែលឧក្រិដ្ឋកម្មខ្មែរក្រហមមិនមែនជាឧក្រិដ្ឋកម្មប្រព្រឹត្តដោយជនជាតិខ្មែរនោះទេ ប៉ុន្តែគឺជាឧក្រិដ្ឋកម្មដែលប្រព្រឹត្តដោយវៀតណាមទៅវិញទេ ។ ការយល់ឃើញបែបនេះក្លាយទៅជារឿងទូទៅមួយដ៏គួរឲ្យបារម្ភ ។ នៅពាក់កណ្ដាលឆ្នាំ២០១៣ លោក កឹម សុខា អនុប្រធានគណបក្សសង្គ្រោះជាតិ បង្កឲ្យមានការតវ៉ាប្រឆាំងយ៉ាងខ្លាំង បន្ទាប់ពីលោកអះអាងថាមន្ទីរស-២១ ដែលជាគុកធ្វើទារុណកម្មដ៏ឃោរឃៅមួយរបស់ខ្មែរក្រហម ស្ថិតនៅក្នុងសាលាមួយ នៅខាងត្បូងជាយទីក្រុងភ្នំពេញ គឺជាគុកសិប្បនិម្មិតដែលបង្កើត ឡើងដោយជនជាតិវៀតណាម ។ ម្ចាស់ហាងកាហ្វេម្នាក់នៅក្បែររបងវត្តស្ទូនពេជ្រ ដែលមិនព្រមប្រាប់ឈ្មោះរបស់គាត់ ដោយសារតែភាពរសើបនៃបញ្ហានេះ បាននិយាយដូចគ្នាថា គាត់មិនជឿលើការបកស្រាយជាផ្លូវការអំពីប្រវត្តិសាស្ត្រខ្មែរក្រហមនោះទេ ។ តាមគំនិតរបស់គាត់ «អ្វីៗទាំងអស់បណ្ដាលមកពីវៀតណាម» ដោយសារតែគ្មានប្រវត្តិសាស្ត្រត្រឹមត្រូវសម្រាប់ជាគោល ភាពមន្ទិលសង្ស័យផ្នែកប្រវត្តិសាស្ត្រតែងតែកើតមានជានិច្ច ។

ប៉ុន្តែ ក្ដីសង្ឃឹមមួយចំនួនអាចនឹងកើតឡើង ដោយសារតែប្រទេសកម្ពុជាកំពុងតែផ្លាស់ប្ដូរ ។ ច្រើនឆ្នាំកន្លងផុតទៅ អតីតកាលចាប់ផ្ដើមសាបរលត់បន្តិចម្ដងៗ ។ ស្ទើរតែពីរភាគបីនៃប្រជាជនកម្ពុជាសព្វថ្ងៃមានអាយុតិចជាង៣០ឆ្នាំ ដូច្នេះសុបិន្តអាក្រក់ពីអតីតកាលមិនបន្តយាយីដូចពីមុននោះទេ ។ ការមិនបន្តយាយីរបស់អតីតកាលបានឃើញកាន់តែច្បាស់ នៅក្នុងការបោះឆ្នោតជាតិនៅខែកក្កដា ឆ្នាំ២០១៣ ។ នៅពេលនោះ គណបក្សប្រជាជនកម្ពុជាទទួលរងនូវការបរាជ័យក្នុងការបោះឆ្នោតយ៉ាងធ្ងន់ធ្ងរមិនធ្លាប់មានចាប់តាំងពីឆ្នាំ១៩៩៨ ដោយសារតែមានគណបក្សសង្គ្រោះជាតិ ដែលទើបបង្កើតឡើងថ្មី ។ នៅជួរខាងមុខនៃអ្នកប្រឆាំងនឹងលោក ហ៊ុន សែន គឺយុវវ័យរាប់លាននាក់ ដែលកើតក្នុងទសវត្សរ៍ឆ្នាំ១៩៩០ និងសម្រាប់អ្នកទាំងនោះ របបខ្មែរក្រហមមានទំនាក់ទំនងផ្នែកនយោបាយតិចតួចណាស់ជាមួយបញ្ហា ដូចជាការងារ អំពើពុករលួយ និងការអប់រំ ។

លោក ឆាំង យុ បានមានប្រសាសន៍ថា «ដោយសារតែអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមជាច្រើនមានវ័យជាង៦០ ឬ៧០ឆ្នាំទៅហើយ មនុស្សដែលកើតក្នុងសម័យនេះគឺជាជំនាន់ទីមួយ ដែលពិតជាអាចរំដោះពីប្រវត្តិសាស្ត្រ និងនាំប្រទេសកម្ពុជាចេញពីស្រមោលខ្មែរក្រហម»

លោក ឆាំង យុ បាននិយាយថា «ឥឡូវនេះ មនុស្សដែលមានវ័យ៣៥ឆ្នាំ គឺស្ថិតនៅចន្លោះនៃការចាប់ផ្ដើម និងទីបញ្ចប់ ។ ខ្ញុំពណ៌នាអ្នកទាំងនោះថាជាជំនាន់អន្តរកាល ។ រយៈពេល១០ឆ្នាំខាងមុខទៀត ប្រទេសកម្ពុជានឹងស្ថិតនៅក្នុងដំណើរអន្តរកាល ដែលជាការផ្លាស់ប្ដូរពិតប្រាកដមួយឆ្ពោះទៅរកអ្វីផ្សេងទៀត» ប៉ុន្តែ លោក ឆាំង យុ បានបន្ថែមថា «ប្រសិនបើគ្មានការអប់រំក្មេងជំនាន់ក្រោយ ឲ្យបានត្រឹមត្រូវពីរបបខ្មែរក្រហមនោះទេ ព្រឹត្តិការណ៍ដ៏ខ្មៅងងឹតមួយនៃប្រវត្តិសាស្ត្រកម្ពុជានឹងស្ថិតនៅក្រោមនីមនយោបាយ ហើយប្រជាជនកម្ពុជាមិនអាចរំដោះខ្លួនពីអតីតកាលបានឡើយ» ។

ដោយដកស្រង់ចេញពីឃ្លាដ៏ល្បីមួយ នៅក្នុងសៀវភៅរបស់លោក វីលៀម ហ្វកណឺ ដែលមានចំណងជើងថា *Requiem for a Nun* លោក ឆាំង យុ បាននិយាយថា «អតីតកាលមិនដែលផុតរលត់ទេ ហើយអតីតកាលក៏មិនមែនជារឿងអតីតកាលដែរ» ។ គាត់បន្ថែមថា «ប៉ុន្តែអ្នកមិនត្រូវឲ្យអតីតកាលរារាំងអ្នកនោះទេ ។ អ្នកមិនគួរក្លាយទៅជាទាសករអតីតកាល» ។ **សើបាស្ទីន ស្ត្រេនចូ**

# មានទោសព្រោះអ្វី?

**(តចប់)**

នៅប្រមាណម៉ោងប្រាំបីព្រឹក សន្តិសុខពីរនាក់ បានមកឈរបង្ហាញខ្លួននៅពីមុខបន្ទប់ខ្ញុំ ។

- ឯណាខ្សែដែលអញឲ្យឯងវេញនោះ?

ខ្ញុំងាកខ្លួនស្រវាយកខ្សែដែលដាក់នៅលើក្បាលដំណេក

អ្នកទាំងពីរទទួលយកពីខ្ញុំ និងចងគន្លាក់ដៃខ្ញុំទាំងពីរទៅក្រោយខ្នង ហើយដោះខ្នោះចេញពីជើង រួចក៏បញ្ជាឲ្យចុះទៅដី ។ ខ្ញុំចុះមកឈរនៅពីមុខរោងសន្តិសុខម្នាក់ដែលឈរចាំនៅដី បានទាញក្រណាត់ខ្មៅពីក្នុងហោប៉ៅខោ មកចងរុំមុខខ្ញុំហើយកាន់ចំណងខ្សែរុញខ្នងខ្ញុំដើរទៅមុខ ។

ខ្ញុំមានអារម្មណ៍រន្ធត់ខ្លាំងណាស់ តែចិត្តមួយគិតថាទោះជាខ្ញុំភ័យរន្ធត់យ៉ាងណាក៏មិនអាចជៀសផុតបានដែរ ព្រោះទាំងសាច់ទាំងឈាមរបស់ខ្ញុំស្ថិតនៅក្នុងកណ្ដាប់ដៃខ្រិដ្ឋរបស់អ្នកទាំងនេះហើយ ។ ខ្ញុំខំតាំងចិត្តប្រមូលអារម្មណ៍ដែលភ័យខ្លាចរបស់ខ្ញុំដែលកំពុង តែហោះហើរចេញទៅឆ្ងាយ ឲ្យវិលត្រឡប់មកគស៊ូជាមួយឆន្ទៈយុវជនរបស់ខ្ញុំវិញ ហើយទាំងស្មារតីឲ្យបានមាំមួន ដើម្បីតទល់នឹងស្ថានការណ៍ដែលនឹងកើតមាននៅពេលខាងមុខនេះ ។ បេះដូងខ្ញុំដែលពីពេលមុនលោតស្ទើរតែធ្លាយដើមទ្រូង ឥឡូវវាកំពុងសម្រួលមកត្រឹមសភាពដើមវិញ ។

- អាឯងអង្គុយចុះ!

នេះគឺបញ្ជាប្រកបដោយភាពកាចសាហាវ និងគ្មានវិចារណញ្ញាណ ។

ខ្ញុំដាក់គូថអង្គុយយឺតៗ ដោយតឹងនឹងខ្សែចំណង គូថខ្ញុំក៏បានប៉ះនឹងកៅអីឈើគ្មានបង្អែក ខ្ញុំខំទ្រេតខ្នងទៅក្រោយបន្តិចក្រែងមានជញ្ជាំង តែគ្មានប៉ះអ្វីសោះ ។ សន្តិសុខម្នាក់បានស្រែកសួរមក ខ្ញុំដោយ គំហកសំឡុតស្មារតីខ្ញុំថាៈ

- អាឯងមកទីនេះមានភ័យខ្លាចទេ?

- ខ្ញុំអត់ភ័យខ្លាចទេ ព្រោះខ្ញុំគ្មានកំហុសអ្វីផង!

- នែ៎ ពួកអាឆ្កែអាមេរិក! កន្លែងនេះ មិនដែលចាប់មនុស្សគ្មានទោសយកមកទេ ។

វានិយាយផង វាទះកំភ្លៀងខ្ញុំមួយដៃយ៉ាងខ្លាំង ធ្វើឲ្យខ្ញុំបែកអំពិលអំពែកពេញភ្នែកដែលចងបិទ ដូចមនុស្សខ្វាក់ មិនអាចមើលមុខពួកគេបាន ។

- បាទ! ខ្ញុំយល់តែខ្លាចបងចាប់មនុស្សច្រឡំ

- យើស! អាឯងថាអញច្រឡំផង

សន្តិសុខនោះនិយាយចប់ភ្លាម កណ្ដាប់ដៃដ៏រឹងណែនបានដាល់ចំកញ្ចប់មាត់ខ្ញុំមួយដៃពេញទំហឹង ធ្វើឲ្យខ្ញុំដួលធ្លាក់ពីលើជើងម៉ា ។ ស្នាមម្រាមដៃទះកំភ្លៀងមិនទាន់ទាំងបាត់ឈឺក្រហាយផង ឥឡូវត្រូវដាល់មួយដៃថែមទៀត ខ្ញុំប្រឹងងើបអង្គុយលើជើងម៉ាវិញ

- អាឯងអង្គុយហ្នឹងដីបានហើយ!

ខ្ញុំអង្គុយចោងហោង ហើយយកចង្កាដាក់លើក្បាលជង្គង់ ។ ខ្ញុំដឹងថាមានឈាមហូរចេញពីមាត់មកហើយ ព្រោះរាងក្ដៅខណ្ឌៗ និងប្រៃលែមៗ ។ សន្តិសុខនោះបន្តដោយសម្ដីអសុរសមកខ្ញុំទៀតថាៈ

- អាឯងដឹងទេ? អង្គការយើងមានភ្នែកដូចម្នាស់ ចង់អាឯងធ្វើអី នៅកន្លែងណា ក៏អង្គការយើងដឹងទាំងអស់ អាឯងមិនបាច់លាក់ហើយប្រាប់ឲ្យត្រង់មក បើមិនចង់ឈឺខ្លួន!

- ពេលនេះ បើបងៗធ្វើទារុណកម្មខ្ញុំដល់ស្លាប់ក៏ខ្ញុំមិនដឹងពីទោសកំហុសខ្ញុំដដែល ។

- អាឯងរត់ពីស្រុកនេះទៅធ្វើទាហានអាណុលមែនទេ?

សំណួរមួយឃ្លានេះធ្វើឲ្យខ្ញុំអស់ជំនឿទៅលើអង្គការភ្នែកម្នាស់របស់អ្នកទាំងអស់នេះ ។

- ខ្ញុំទៅរៀនបន្តទេ ខ្ញុំអត់បានធ្វើទាហានអ្វីទេ!

- ឯងរៀនដល់ថ្នាក់ណា?

- បាទ! ខ្ញុំរៀនបានត្រឹមថ្នាក់ទីប្រាំបីទេ ព្រោះជីវភាពរបស់ខ្ញុំក្រីក្រពេក ។

- ហ្នឹងហើយ ពេលអាឯងឈប់រៀន អង្គការដឹងថាឯងធ្វើ

ទាហាន ។

-អត់ទេបង! ខ្ញុំឈប់រៀន ខ្ញុំធ្វើជាកម្មករដាំងកំបោរ និងធាក់ស៊ីក្លូ ។

-ចុះអាឯងធ្វើអីខ្លះក្នុងការរោងដាំងកំបោរ?

សំណួរនេះ ខ្ញុំដឹងថាអ្នកសួរចម្លើយចង់បញ្ជាក់ ថាខ្ញុំនិយាយនេះពិតឬមិនពិតតែប៉ុណ្ណោះ ។

-បាទ! ខ្ញុំ គេប្រើឲ្យតែជញ្ជូនឥដ្ឋ និងកំបោរឲ្យជាង ។ គេធ្វើតែប៉ុណ្ណោះ ចំណែកកិច្ចការសាងសង់នៅលើមេជាងជាអ្នកធ្វើ ។

-តែអង្គការដឹងថាឯងធ្វើទាហានអាណុល!

-ខ្ញុំអត់ទេបង! បើខ្ញុំធ្វើមែនខ្ញុំប្រាប់បងហើយមិនបាច់ឈឺខ្លួនទេ ។

-អាឯងមាត់រឹងណាស់!

ស្នូររំពាត់ បានវាត់មកសំដៅខ្នងខ្ញុំខ្ទាប់ៗ ខ្ញុំឈឺផ្សាក្រហាយណាស់ តែខ្ញុំខាំមាត់សង្កត់ចិត្ត មិនស្រែកថ្ងូរឡើយ ។

បន្ទាប់មកសំឡេងមនុស្សម្នាក់ផ្សេងទៀត និយាយព្រមទាំងដៃទះតុតិចៗ

-មិត្តឯងយកវាទៅកន្លែងសិនទៅ ចាំល្ងាចសួរវាទៀត!

សំឡេងបញ្ជានេះ ប្រហែលជាមេរបស់ក្រុមសន្តិសុខហើយ បានជាអ្នកទាំងអស់នោះ ឆ្លើយថា បាទបងៗ ព្រមៗគ្នា ។ ពេលនោះអ្នកយាមចាប់រុញខ្នងខ្ញុំឲ្យក្រោកឈរហើយនាំដើរចេញមកក្រៅ ស្នាមរបួសនៅលើខ្លួន ខ្ញុំកំពុងតែឈឺផ្សាដោយដំណក់ញើសហូរកាត់ ។ មកដល់មុខរោង អ្នកយាមស្រាយមុខចេញហើយឲ្យខ្ញុំឡើងទៅកាន់បន្ទប់ បន្ទាប់ពីដាក់ខ្នោះជើងខ្ញុំរួចហើយ ទើបបញ្ជាឲ្យពូនៅក្បែរខ្ញុំស្រាយចំណងចេញ ។ ខ្ញុំអង្គុយឈ្ងោកមុខ ព្រោះឈឺចាប់នឹងអំពើព្រៃផ្សៃមកលើខ្ញុំ ។ ស្នាមរបួសលើ ខ្លួនខ្ញុំវាឈឺមិនស្មើនឹងមុខរបួសលើទឹកចិត្តដ៏បរិសុទ្ធរបស់ខ្ញុំដែលត្រូវទទួលរងនូវអំពើអយុត្តិធម៌នេះឡើយ ។ ពូនៅជាប់ខ្ញុំសួរឡើងៈ

-អង្គការចោទក្មួយរឿងអីដែរ?

-អង្គការចោទថាខ្ញុំធ្វើទាហានលន់-នល់ ។

គាត់ដកដង្ហើមធំយ៉ាងវែង

-ហ៊ឺ...គឺលំនាំតែមួយ ឲ្យតែអង្គការចាប់យកមកទីនេះ គឺសុទ្ធសឹងជាអ្នកក្បត់អង្គការ សុទ្ធតែ ទាហាន ជាប៉ូលីស ឬក៏ចារកម្ម *C-I-A* ឬ *K-G-B* ទាំងអស់ ទោះជាយើងខំប្រឹងប្រកែកការពារខ្លួនយ៉ាងណា ក៏សន្តិសុខនៅតែបង្ខំឲ្យយើងទទួលយកដដែល ចិត្តដែលប្រឹងតស៊ូដើម្បីយុត្តិធម៌របស់ខ្លួនបានឡើយ ។ ដូច្នេះយើងត្រូវតែទទួលយក ដើម្បីរក្សាខ្លួនយើងកុំឲ្យទទួលរងនូវការវាយដំប្រំធាក់តទៅទៀត ។ បងថា គាត់ដោះអាវខ្ញុំចេញ ហើយពោលថាៈ

-ពុទ្ធោ ទើបតែសួរចម្លើយលើកទីមួយសោះ ឯងត្រូវទទួលទណ្ឌកម្មខ្លាំងម៉្លេះ? មើលចុះស្នាមរំពាត់វាយឯងឡើងខ្មៅចស្បែកចេញឈាមទៅហើយឯងបែរខ្នងមកបងស្អំឲ្យ ។

បងថា គាត់ស្អំខាងខ្នង ចំណែកពូគាត់ស្អំត្រង់មាត់ដែលបែកកំពុងហូរឈាមរីមៗ នៅឡើយ ។

-ពូ! តើត្រូវសួរចម្លើយយើងប៉ុន្មានដងទើបឈប់?

-មិនទៀងទេ សួរ និងធ្វើបាបយើងទាល់តែយល់ព្រមទទួលយកនូវអ្វីដែលអង្គការកំណត់ឲ្យយើង ទើបឈប់ណ៎ ។

-ខ្ញុំសម្ងំដេក ព្រោះហេវហត់ទ្រាំទ្រនូវទារុណកម្មរបស់អង្គការ ។

ពេលហូបបបរក៏មកដល់អ្នកទោសដែលអង្គការមិនឲ្យចេញទៅធ្វើការ នាំគ្នាហុតបបររួចជាស្រេច ។ បងថា បង្ខំខ្ញុំឲ្យហូបបបរៈ

-ឯងហូបទៅកុំឲ្យហេវ បើឯងមិនហូបទេប្រយ័ត្នបាក់កម្លាំងក្លាយទៅជាមានជំងឺទៀតនោះ គឺវិវរហើយព្រោះនៅទីនោះគ្មានអ្នកព្យាបាលទេ ។

ខ្ញុំដួសបបរមួយស្លាបព្រាដាក់ចូលក្នុងមាត់ តែត្រូវខ្ជាក់ចេញមកវិញ ព្រោះវាឈឺផ្សាមុខរបួសនៅក្នុងមាត់យ៉ាងខ្លាំង ។ ខ្ញុំលើកចានបបរហុចទៅឲ្យបងថាៈ

-ណេះបង! យកទៅចែកគ្នាពិសាចុះ ខ្ញុំហូបមិនកើតទេ ខ្ញុំឈឺមាត់ខ្លាំងណាស់ ។

-ទេ! បងមិនយកទេ ឯងទុកទៅក្រែងបាត់ឈឺមាត់ឯងនឹងឃ្លានវិញ ។

-ទោះជាឃ្លានក៏ខ្ញុំហូបមិនកើតដែរ បងយកចែកគ្នាយើងហូបចុះ ចាំល្ងាចក្រែងខ្ញុំហូបបានវិញ

គាត់ទាំងអស់គ្នាសម្លឹងមកខ្ញុំដោយក្តីអាណិតអាសូរ ។

-ពូ! យកចែកគ្នាយើងហូបចុះ ខ្ញុំដឹងថា យើងទាំងអស់គ្នាកំពុងតែឃ្លានរបបខ្ញុំប៉ុណ្ណឹងទោះជា ពូ បងហូបម្នាក់ឯងក៏មិនឆ្អែតដែរ

តែបើខ្ញុំទុកចោលបន្តិចទៀតនឹងមានប្រមូលបាន ហើយនឹងចាក់ចោលក៏ជាការមួយគួរឲ្យស្តាយណាស់ ព្រោះយើងកំពុងតែត្រូវការវា តើមែនទេ? ដូច្នេះសូមពូទទួលយកទៅចែកគ្នាចុះ ។ ខ្ញុំមិនទាន់ស្លាប់នឹងអត់អាហារមួយពេលនេះទេ ។

ពួកគាត់ទទួលយកហូបតែមួយឬពីរស្លាបម្នាក់ រួចហើយហុចបន្តចែកគ្រប់ៗគ្នា ។ ពូនៅជាប់ខ្ញុំ និយាយថាៈ

-ក្មួយ ដេកទៅ! ចាំពូដុំក្រមាស្អំមាត់ឲ្យក្មួយ ក្រែងល្វាចវាបាត់ឈឺ ។

-មិនបាច់ទេពូ! ខ្ញុំគិតថាចាប់ពីពេលនេះតទៅ ខ្លួនខ្ញុំនឹងត្រូវជាំឬក៏ស្នាមរំពាត់បែកឈាមច្រើនជាងនេះទៅទៀត ។ ដូច្នេះ បើស្អំពេលនេះវាបាត់ឈឺតែមួយពេលប៉ុណ្ណោះ តែវានឹងត្រូវហើយឡើងនៅពេលបន្តិចទៀតនេះវិញមិនខាន ។

-តែទោះជាយ៉ាងណាក៏ដោយ ក៏ពូត្រូវតែធ្វើក្នុងនាមជាអ្នកទោសម្នាក់ដែលត្រូវជួយគ្នាទៅវិញទៅមក លាក់បាំងអីពូបានឃើញក្មួយតាំងពីថ្ងៃដំបូង ពូនឹកឃើញកូនប្រុសពូ បើសិនជាវានៅរស់ម៉្លេះ មានអាយុ និងរូបរាងធំប៉ុនក្មួយឯងហើយ ។

-ចុះកូនពូស្លាប់ដោយសារអ្វីដែរទៅ?

-គឺវាធ្វើយោធារបស់អង្គការ ហើយវាស្លាប់នៅសមរភូមិ អ្នកលឿង នឹកឃើញរឿងនេះពូហាក់ដូចពើតផ្សាក្នុងចិត្តខ្លាំងណាស់ កូនប្រុសពូបានបូជាជីវិតដ៏ក្មេងខ្ចីរបស់វាដើម្បីបុព្វហេតុបដិវត្តន៍ ដើម្បីរំដោះប្រទេសឲ្យរួចផុតពីសង្គ្រាម ដើម្បីសេចក្តីសុខរបស់ពូក៏ដូចជាប្រជាជនទូទៅ ។ តែទីបំផុត ឪពុករបស់វាក្លាយជាអ្នកទោសបដិវត្តន៍ទៅវិញ គឺខ្លួនពូត្រូវអង្គការចោទប្រកាន់ថា បានប្រែចិត្តប្រែពណ៌ ទាំងខ្លួនពូមិនបានលាបមិនបានដាត់ពណ៌សោះឡើយ ។ នេះហើយជាពានរង្វាន់របស់អង្គការដែលបានប្រទានមកឲ្យពូ ដែលខំលះបង់កូនជាទីស្រឡាញ់ដើម្បីជ័យជម្នះរបស់បដិវត្តន៍ ។

អ្នកទោសទាំងអស់ដេកលក់ខ្លះ ឯខ្លះទៀតរសាប់រសល់ដេកមិនលក់ ព្រោះក្តីស្រេកឃ្លាន ។ ខ្ញុំដេកលក់មួយភាំងស្រាប់តែថ្ងៃរាងជ្រេរបន្តិចទៅហើយ ។ សន្តិសុខបានមកយកខ្ញុំទៅសួរទៀត និងបានចោទសួរខ្ញុំដូចពីព្រឹកមិញ ។ ខ្ញុំព្យាយាមឆ្លើយ ទៅវិញមិនឲ្យខុសចម្លើយពីព្រឹកមិញដែរ ។ អ្នកសួរចម្លើយ ក៏ដាក់សំណួរថ្មីមួយទៀតមកសួរខ្ញុំ ។

-អាឯងចេញពីភ្នំពេញ អង្គការយើងដឹងថាអាឯងបានជួបនឹងឈ្មោះ ថាច់ ច័ន្ទ និង អ៊ិត ថន ហើយវាទាំងពីរនាក់នេះបានចាត់តាំងឲ្យអាឯងធ្វើជា *C.I.A* និង *K.G.B* ទៀតផងមែនទេ?

-ខ្ញុំមិនដែលស្គាល់អ្នកទាំងពីរនោះថាជាអ្នកណាឬក៏ធ្វើអ្វីនោះទេ ហើយតាំងតែពីចេញពីភ្នំពេញ រហូតឥឡូវខ្ញុំគ្មានបានទៅទាក់ទងអ្នកណាបានម្តងឡើយ ព្រោះខ្ញុំមិនដែលគេចវេសចោលកន្លែងរស់នៅប្រមូលផ្តុំរបស់ខ្ញុំគ្មានការអនុញ្ញាតបានមួយថ្ងៃឡើយ ។

-យើស! មេរបស់អាឯងហើយ ឯងមិនស្គាល់ទៀតឬ?

អ្នកសួរនោះ ធាក់ខ្ញុំមួយជើងចំថ្ងាស ធ្វើឲ្យដាច់ផ្ងារទៅក្រោយធ្លាក់ពីលើជើងម៉ា បោកក្បាលនឹងជញ្ជាំង រួចទាត់មួយជើងចំឆ្អឹងជំនីខ្ញុំម្ខាងទៀត ខ្ញុំចុកណែនពេញទ្រូងនិយាយលែងរួច ខ្ញុំមិនប្រឹងក្រោកវិញទេ បណ្តោយឲ្យអ្នកទាំងនោះធ្វើបាបឲ្យអស់ចិត្តចុះ អ្នកយាមចាប់បោចសក់ក្បាលទាញខ្ញុំឲ្យក្រោកអង្គុយវិញ ។

-អាឯងឆាប់សារភាពឲ្យត្រង់ ហើយប្រាប់ឈ្មោះក្រុមអាឯងឲ្យអស់មកទើបរួចខ្លួន បើមិនដូច្នោះទេ អាឯងនឹងត្រូវដាច់បំពង់កឥឡូវហើយ ។

អ្នកសួរបានបោចសក់ខ្ញុំផ្ងារទៅក្រោយ និងយកកាំបិតមកអូសឆូតត្រង់កខ្ញុំតិចៗ ក្នុងបំណងកំញើញខ្ញុំឲ្យភ័យខ្លាច ។

-ឆាប់និយាយមកកពួកអាឯងអាប៉ុន្មាននាក់ ហើយឈ្មោះអីខ្លះ?

-បង! ខ្ញុំមិនដឹងឆ្លើយប្រាប់ថាម៉េចទេ ព្រោះខ្ញុំគ្មានបក្សពួកដូចបងចោទសោះ ។

-អាឯងលាក់ មិនព្រមប្រាប់ឬ?

អ្នកសួរនោះទាត់ខ្ញុំមួយជើងចំសៀតដ្កា ដួលទៅជីម្តងទៀត ហើយវាយខ្ញុំជាច្រើនរំពាត់ថែមទៀត ពេលអស់ចិត្ត ក៏ទាញកអាវខ្ញុំឲ្យក្រោកអង្គុយលុតជង្គង់វិញ ។

-ម៉េចអាឯងឆ្លើយឬមិនឆ្លើយ ថាក្រុមឯងមានប៉ុន្មាននាក់?

-ខ្ញុំគ្មានពួក គ្មានក្នាឯណាទេបង ខ្ញុំជីកព្រែករាល់ថ្ងៃ ពេលចេញពីធ្វើការ ខ្ញុំនៅតែអង្គភាពកងចល័ត សូម្បីតែផ្ទះខ្ញុំមិនដែលបានទៅមើលឪពុកម្តាយខ្ញុំដែលចាស់ជរាផង តើខ្ញុំមានពេលឯណាទៅបង្កើតឲ្យមានពួក មានក្រុមកើតទៅ?

-អាឯងមាត់រឹងគ្រាន់បើផង!

ចប់សម្តីភ្លាម សួរវាំពាត់បានវាត់វាយខ្ញុំគ្មានសំចៃដៃ ។ ខ្ញុំដឹងថាអ្នកដែលវាយដែលទាត់ដែលធាក់ខ្ញុំមានគ្នាពីរនាក់ ព្រោះសួរវាំពាត់បានវាយទាំងសងខាងពីក្រោយខ្នងខ្ញុំ ខ្ញុំឈឺណាស់ ឈឺរកពាក្យអ្វីមកថ្លាថ្លែងឲ្យសមបានឡើយ ។ បន្ទាប់មកសំឡេងអ្នកសួរដដែលបានចាប់ផ្តើមទៀត

ចុះមិត្តភក្តិជិតស្និទ្ធរបស់អាឯងនៅក្នុងកងចល័តហ្នឹងមានប៉ុន្មាននាក់ដែរ?

សំណួរនេះខ្ញុំនឹកឃើញទៅដល់មិត្តភក្តិរួមការងាររក្នុងការដ្ឋានពេលនេះបើខ្ញុំប្រាប់អង្គការនឹងចាប់យកមកទីនេះទៀត ដែលអ្នកទាំងនោះមិនទាំងដឹងរឿងអ្វី សោះដូចតែខ្ញុំដែរហ្នឹង ។ ខ្ញុំគ្មានមិត្តភក្តិជិតស្និទ្ធទេ គឺមានតែមិត្តបំពេញការងាររការកិច្ចជូនអង្គការទូទាំងកងចល័តតែប៉ុណ្ណោះ ។

- បើអាឯងគ្មានមិត្តភក្តិទេ ម៉េចក៏អាខ្មាំងយួន ដប់នាក់ដែលវាចូលមកស៊ើបការណ៍ ហើយត្រូវអង្គការយើងចាប់បាន វាឆ្លើយថាអាឯងជាអ្នកដឹកនាំក្រុមវាមកលាក់ ហើយបានផ្តល់ស្បៀងផ្តល់អាវុធ និងគូសដែនទីឲ្យវា ហើយថាអាឯងហ្នឹងជាមេរបស់វា និងពាក់ស័ក្តិពីរទៀត ។

ចប់សំណួរនេះភ្លាម ខ្ញុំនឹកឃើញពាក្យពូដែលនៅជាប់ខ្នោះជាមួយខ្ញុំថា អ្នកណាក៏ដោយឲ្យតែមកដល់ទីនេះគឺសុទ្ធតែក្បត់អង្គការ សុទ្ធតែប៉ូលីស ទាហាន ស័ក្តិមួយ-ពីរ-បី-តែទាំងអស់ទោះជា យើងមិនបានធ្វើ ក៏អង្គការបង្ខំឲ្យយើងទទួលយកតាមការកំណត់ឲ្យដែរ ។ ខ្ញុំកំពុងតែគិតនឹងសំណួរដែលហួសចិត្តនេះ ស្រាប់តែមានចរន្តអគ្គីសនីមកប៉ះត្រង់កខ្ញុំព្រួចៗ ភ្នែករបស់ខ្ញុំចេញភ្លើងដូចផ្លេកបន្ទោរនៅពេលភ្លៀងអឺចឹង ខ្លួនខ្ញុំញ័ររចំប្រប់មួយរំពេច ។

- យ៉ាងម៉េចឯងឆ្លើយឬមិនឆ្លើយ អម្បាញ់មិញនេះអញគ្រាន់តែបង្ហាញឲ្យឯងដឹងពីឥទ្ធិពលម៉ាញ៉េតូ២ របស់យើងតែបន្តិចទេ បើឯងមិនឆ្លើយនឹងត្រូវបានទទួលច្រើនជាងនេះមិនខាន ។

- បង! ខ្ញុំមិនដែលស្គាល់ឬក៏បានទាក់ទងជាមួយអ្នកអស់ហ្នឹងទេ ហេតុអីវាធ្វើដាក់ខ្ញុំទៅកើត ខ្ញុំធ្វើការរាល់ថ្ងៃរបបខ្ញុំមានតែនៅក្នុងកសិការតែប៉ុណ្ណោះ ខ្ញុំមានស្បៀងឯណាបម្រុងទុកសម្រាប់ពួកនោះ ហើយអាវុធរបស់ខ្ញុំមានតែចបកាប់ បង្គី ដងរែក ។ តើខ្ញុំមានឃ្លាំងឯណាសម្រាប់ស្តុកស្បៀងស្តុកអាវុធនោះ បើខ្ញុំរស់នៅតែក្នុងអគ្គភាពកងចល័ត ហើយមានតែបន្ទេចតូចមួយជាកម្មសិទ្ធិនោះ ។

- បើអាឯងមិនទាក់ទិនជាមួយវាទេ ហេតុអីបានជាវាឆ្លើយថា ឯងជាមេរបស់ក្រុមវា?

- ខ្ញុំមិនដឹងទេ ហើយក៏មិនជឿថាអ្នកទាំងនោះស្គាល់ខ្ញុំដែរ នេះជាការភ័ន្តច្រឡំតែប៉ុណ្ណោះ ។

- យើស! អាឯងមានចេតនាចង់លាក់បាំងពីសកម្មភាពរបស់ឯង បានជាធ្វើមិនដឹងមិនស្គាល់?

ចប់សម្តីយមរាជភ្លាម សំឡេងទារុណកម្មមកលើខ្លួនខ្ញុំខ្ទប់ៗជាប់ៗ ដូចព្យុះសង្ឃរា បោកបក់ថ្ម ទម្លាក់ពីលើភ្នំអ៊ីចឹង ។ ម្តងនេះលែងប្រើរំពាត់ទៀតហើយ គឺប្រើកូនឈើប្រហែលប៉ុនមេជើងវាយខ្ញុំ វាយទាត់ធាក់ខ្ញុំយ៉ាងវក់វី ននៀលនឹងដី ស្រាប់តែមានដំបងមួយភ្ជាត់មកត្រូវក្បាលខ្ញុំចំពីក្រោយ ខ្ញុំងងឹតមុខឈឺងលែងដឹងអ្វីទាំងអស់ ។ នៅពេលខ្ញុំដឹងខ្លួនឡើងវិញ គឺស្ថិតនៅក្នុងបន្ទប់ឃុំឃាំងអាវខ្ញុំត្រូវទទឹកជោគ រីឯជើងខ្ញុំជាប់ខ្នោះរួចជាស្រេចទៅហើយ ។ ខ្ញុំឃើញពូ និងបងថា កំពុងផ្ញុំក្រមាស្អំកន្ទែង ដែលហើមដាំនៅលើខ្លួនខ្ញុំ ។ ទារុណកម្មមកលើខ្ញុំកាន់តែខ្លាំងឡើងគ្មានទីបញ្ចប់ ហើយបើមានថ្ងៃបញ្ចប់គឺ ប្រហែលជាថ្ងៃដែលខ្ញុំត្រូវលាចាកទីបលោកដ៏គំរក់នេះហើយក៏មិនដឹង ។

ខ្ញុំឈឺសព្វកន្លែងស្ទើរកម្រើកខ្លួនមិនរួច ។ ពូ និងបងថា គាត់ជួយលើកខ្ញុំឲ្យក្រោកអង្គុយ ដើម្បីដោះអាវដែលសើមសំដិលឲ្យស្ងួត និងជូតសម្អាតដីដែលប្រឡាក់ចេញពីខ្លួនខ្ញុំ អ្នកទោសនៅក្នុងបន្ទប់ ដែលជាប់ខ្នោះជាមួយគ្នាហើយនៅឃ្លាតឆ្ងាយពីខ្ញុំ អ្នកខ្លះឲ្យអាវខ្ញុំយកមកពាក់ ហើយខ្លះដែលនៅឆ្ងាយពីខ្ញុំ អ្នកទាំងអស់គ្នាមិនអាចជួយអ្វីខ្ញុំបានឡើយ គឺគ្រាន់តែក្រវីក្បាលសម្តែងក្តីអាណិតមកខ្ញុំរកពាក្យអ្វីមកសារស័ព្ទពុំបានឡើយ ។

- ពូ! បង! តើខ្ញុំមកដល់បន្ទប់យើងនេះរបៀបណាទៅ?

- គឺសន្តិសុខឲ្យពូ ប្អូនថា ហើយអ្នកទោសពីរនាក់ទៀតទៅយកក្លួយឯងមក ព្រោះនៅពេលសន្ទប់ អ្នកយាមយកក្លួយមកទុកពេលក្រោមដើមស្វាយ ខាងមុខមន្ទីរសួរចម្លើយ ហើយមកហៅយើងឲ្យទៅ យកឯងមកទីនេះវិញ ហើយយើងក៏ជួយរឹតច្របាច់ទើបក្លួយដឹងខ្លួនវិញ ។

–ក្មួយ! កុំរីករួសនឹងអង្គការអី ក្មួយចាំបាច់ត្រូវតែឆ្លើយស្របតាមការដែលអង្គការគ្រោងទុកទៅ បើមិនដូច្នេះទេពូប្អូនថា ហើយនឹងអ្នករួមខ្នោះឯងទៀត នៅតែឃើញភាពវេទនារបស់ក្មួយជារហូត ។

–ខ្ញុំមិនអាចក្បត់នឹងឆន្ទៈខ្ញុំបានទេពូ ហើយពូក៏យល់ដែរថា តើយុវជនយើងសព្វថ្ងៃចង់បានអ្វី?

–ពូដឹង! តែជីវិតយើងវាស្ថិតនៅក្នុងកណ្ដាប់ដៃរបស់អង្គការ បើអង្គការចង់ប្រាប់យើងឲ្យទៅជាអ្វី ពេលណាក៏បានដែរណាក្មួយ ដូច្នេះក្មួយត្រូវគិតពីទុក្ខវេទនារបស់ខ្លួនឯងខ្លះទើបបាន ។

ក្មួយសាកគិតមើលថា ប្រជាជនយើងខ្លះស្អប់ខ្ពើមបំផុតនូវអំពើលួចឆក់ ហើយសច្ចាថាក្នុងមួយជីវិតនេះ នឹងមិនប្រព្រឹត្តអំពើដ៏ថោកទាបនេះឡើយ តែឥឡូវ ដោយសារតែជីវិតបេះតែទាមទាររកអាហារដើម្បីបង្គ្រប់នូវការស្រេកឃ្លាន អ្នកទាំងនោះសុខចិត្តក្បត់ឧត្តមគតិរបស់ខ្លួនទៅលួចចេក ពោត ដំឡូងមកបរិភោគដើម្បីសង្គ្រោះជីវិតអោយរួចផុតពីការហត់ហេវខ្សោះកម្លាំងមួយគ្រាៗដែរ ។

–តែខ្ញុំគ្មានជម្រើសទេពូ ព្រោះខ្ញុំជាប្រជាជនថ្មី ហើយត្រូវអង្គការចោទប្រកាន់ជាទាហានហើយ ពាក់ស័ក្តិពីរទៅទៀត តើខ្ញុំមានសង្ឃឹមរស់ទេពូ? បើខ្ញុំឆ្លើយសារភាពតាមនោះខ្ញុំនឹងត្រូវស្លាប់ភ្លាម តែបើខ្ញុំមិនសារភាពតាមនោះទេ ខ្ញុំត្រូវទទួលទណ្ឌកម្មយ៉ាងធ្ងន់រហូតដល់ស្លាប់ ។ ដូច្នេះផ្លូវទាំងពីរនៃការសម្រេចចិត្តរបស់ខ្ញុំ វានឹងទៅជួបគ្នាជាផ្លូវតែមួយគឺស្លាប់ដដែល ។ ដូច្នេះខ្ញុំត្រូវតាំងចិត្តពង្រឹងស្មារតី ជាយុវជនក្នុងការការពារយុត្តិធម៌សម្រាប់ខ្លួនឯងនៅពេលដែលខ្ញុំត្រូវស្លាប់ដោយក្ដីអយុត្តិធម៌នេះឲ្យបាន ។

–តែពូមិនអាចទប់ចិត្តមិនអាណិតក្មួយនៅក្នុងសភាពបែបនេះបានទេណាក្មួយ!

–ខ្ញុំសូមអរគុណនូវសន្ដានចិត្តដ៏ល្អប្រពៃរបស់ពូ និងបងថាខ្លាំងណាស់ តែពូត្រូវតែកាត់ចិត្តហើយ ចាត់ទុកថាទាំងនេះជាសកម្មភាពទណ្ឌកម្មនៅឋាននរកនៃយើងនេះហើយ ។

–ពូ! បង! យើងនិយាយនេះ គិចនាំមកនូវទណ្ឌកម្មដល់យើងទៀតទៅ ។

–មិនអីទេក្មួយ! ព្រោះនៅពេលថ្ងៃអ៊ីចឹង អ្នកយាមមិនសូវជាចាប់អារម្មណ៍ប៉ុន្មានទេ ហើយយើងដែលនៅជាប់ខ្នោះជាមួយគ្នានេះក៏មានចិត្តស្រឡាញ់គ្នាដែរ គឺមិនយកគាប់យកគួរឲ្យអ្នកយាមមកធ្វើបាបគ្នាឯងនោះដែរ ។

ក្រោយពេលហូបបបរល្វាចរួចមក ទិដ្ឋភាពនៅក្នុងដែនមច្ចុរាជនេះមានសភាពស្ងាត់ឈឹងរួមផ្សំ និងមេឃចង់ធ្លាប់ភ្លៀងផងនោះធ្វើឲ្យទីកន្លែងនេះរឹតតែងងឹតមួយកម្រិតទៀត ។ យប់នេះខ្ញុំស្រមៃឃើញរូប អាប៉ក់ នៅស្រស់ៗនឹងភ្នែកខ្ញុំ ។ ពាក្យបណ្ដាំរបស់វា ខ្ញុំនៅចាំគ្រប់ម៉ាត់តាមទាំងអស់ ខ្ញុំនឹកស្ញើចដល់ទឹកចិត្តជាយុវជនរបស់វាខ្លាំងណាស់ ទោះជាឈឺមានការហេវហត់លំបាកយ៉ាប់យឺននៅក្នុងខ្លួនវាប៉ុណ្ណា ក៏វាមិនដែលត្អូញថ្ងូរ វានៅតែញញឹមលើកទឹកចិត្តខ្ញុំទាំងអស់គ្នាមិនឲ្យអស់សង្ឃឹមដោយសារវាស៊ូទ្រាំជម្នះក្នុងការឈឺចាប់តែខ្លួនវារហូតដល់ដង្ហើមចុងក្រោយរបស់វា ។ ខ្លួនវានៅតែមានជំនឿយ៉ាងមុតមាំថា នឹងមានថ្ងៃវិញត្រឡប់មកវិញនូវសេរីភាព អធិបតេយ្យភាព យុត្តិធម៌ មិនខានឡើយ នោះហើយជាក្ដីសង្ឃឹមនិងជាថ្ងៃដែលរង់ចាំ ។ តែពេលនេះ ថ្ងៃដែលពោរពេញដោយក្ដីសប្បាយរីករាយ និងសុភមង្គលរបស់វាមិនទាន់វិលត្រឡប់មកវិញផង វាក៏បានលាកចាកលោកនេះទៅបាត់ហើយ ។ ចំណែកខ្ញុំតើអាចទៅដល់ថ្ងៃដែលយុវជនទាំងអស់សង្ឃឹមនោះបានដែរឬអត់? អង្គការដាក់គុកខ្ញុំមែន បានត្រឹមតែរូបកាយប៉ុណ្ណោះ តែឆន្ទៈជាយុវជនដែលស្រឡាញ់សេរីភាព និងយុត្តិធម៌របស់ខ្ញុំ អង្គការមិនអាចឃុំឃាំងបានឡើយ ។ ពេលនេះកម្លាំងកាយខ្ញុំត្រូវចុះខ្សោយទ្រុឌទ្រោមក៏ពិតមែន តែសតិសម្បជញ្ញៈរបស់ខ្ញុំនៅតែរឹងប៉ឹង មិនបណ្ដោយទន់ជ្រាយទៅតាមទម្ងន់ទណ្ឌកម្មដ៏សាហាវរបស់ពួកបិសាចនេះ ជាដាច់ខាត ទោះជាត្រូវស្លាប់ក៏ខ្ញុំនៅតែតស៊ូដើម្បីសម្រេចចិត្តមិនសារភាពតាមអង្គការនេះ ហើយដែលខ្ញុំគិតថាតើមានវាសនាទៅដល់ថ្ងៃដែលរង់ចាំនោះបានដែរឬទេ? ហើយខ្លួនខ្ញុំមិនដឹងថាត្រូវកាត់ព្យុះភ្លៀងរន្ទះដល់ពេលណានោះឡើយ ។ ភ្លាមនោះ ស្រាប់តែសំឡេងផ្អើលឆោឡោនៅខាងបន្ទប់ដែលនៅជាប់ជញ្ជាំងខ្ញុំឡើង ។

–ពួកអាឯងឡូឡាស្អី? ចង់ងាប់ទាំងអស់ហ្នឹងឬ?

នេះជាសម្ដីសន្តិសុខដែលនៅយាមនៅជិតនោះ ។ អ្នកទោសនៅក្នុងបន្ទប់នោះឆ្លើយតបវិញ

– បាទបង! អ្នកទោសឈ្មោះ គួន ដាច់ខ្យល់ស្លាប់ហើយ!

អ្នកយាមពីរនាក់ឡើងមកឆ្លុលពិលពិនិត្យមើល ហើយប្រាប់វិញថា ៖

-អើ! បើវាងាប់ទៅហើយ ពួកឯងចាំបាច់ឡូឡាធ្វើស្អី នាំគ្នាដេកអោយស្ងៀមវិញទៅ ចាំព្រឹក ចាំយកទៅកប់ ។

អ្នកយាមទាំងនោះក៏ដើរចុះទៅវិញ ។ ខ្ញុំសួរពូតិចៗ

-ពូ! តើពូ គួន នេះជាប់ទោសយូរហើយឬ? ហើយស្រុកគាត់នៅឯណាដែរ?

-គាត់ជាប់គុកនេះប្រហែលប្រាំមួយខែហើយ ហើយគាត់នៅភូមិធ្នូក សង្កាត់ស្លូងនេះឯង ។

យប់ថ្ងៃៗ ចេះតែរំកិលទៅមុខគ្មានកន្លល់ពីទុក្ខខ្លោចផ្សារបស់មនុស្សសត្វឡើយ ។ ខ្ញុំត្រូវអង្គការសួរចម្លើយព្រឹកល្ងាចៗ ជារៀងរាល់ថ្ងៃ ចំណែកទារុណកម្មក៏នៅតែមានលើរូបខ្ញុំជាដរាប ប៉ុន្តែនៅថ្ងៃខ្លះ មានសំណាងក៏ត្រូវទទួលទារុណកម្មតិចដែរទៅ ថ្ងៃខ្លះស៊យក៏ត្រូវរាងច្រើនទៅ ។

ចំណែក តាវ៉ាត គាត់មានអាយុហុកសិបឆ្នាំ សក់គាត់ស្កូវអស់ទៅហើយ ហើយត្រូវអង្គការចាប់មកទីនេះក្រោយខ្ញុំប្រហែលមួយអាទិត្យ ។ អ្នកយាមដាក់ខ្នោះនៅក្នុងបន្ទប់ជាមួយខ្ញុំដែរ តែនៅទល់មុខបងថា គាត់នៅភូមិខ្នាចក្រសាំង ឃុំជីគរ ។ អង្គការចោទគាត់ពីបទមានជាប់ពាក់ព័ន្ធនឹងពួកយួនស៊ើបការណ៍ដប់នាក់ ដូចខ្ញុំដែរ អង្គការសួរចម្លើយគាត់តែបីដងសោះ គាត់បានផ្តិតមេដៃទទួលយកកំហុសក្លាម ព្រោះគាត់មិនអាចស៊ូទ្រាំនឹងទម្ងន់ទារុណកម្មមកលើរូបគាត់បាន ទោះជាគាត់មិនបានធ្វើក៏ត្រូវតែទទួល យកទាំងចុកចាប់ក្នុងចិត្តជាទីបំផុត ។

ចំណែកអ្នកទោសដែលត្រូវដល់វេនស្លាប់ ក៏មានជាបន្តបន្ទាប់ស្ទើររាល់ថ្ងៃ អ្នកទាំងនោះស្លាប់ ដោយសារកង្វះអាហារ និងជំងឺផ្សេងៗ ដូចជា ពូឌី និងស៊ីដឿន នៅភូមិស្លូងតាស្រាំងក៏នៅភូមិស្លូងដែរ គាត់ពីរនាក់នេះស្លាប់ដោយជំងឺចុះរាក និងអ្នកទោសជាច្រើនទៀតដែលពេលនេះខ្ញុំភ្លេចឈ្មោះអស់ហើយ ។ ខ្ញុំនឹកឃើញល្ងាចមួយដែលអ្នកយាមបញ្ចេញអ្នកទោសទៅងូតទឹក ហើយខ្ញុំឈឺពោះផងខ្ញុំដើរក្នុងជួរជាមួយអ្នកទោសនៅក្នុងបន្ទប់ខ្ញុំ កាត់មុខកងសន្តិសុខដែលឈរយាមចាំមើលសកម្មភាពអ្នកទោស ។ ខ្ញុំស្គាល់ឈ្មោះក្រុមបិសាចម្នាក់ច្បាស់ណាស់ ព្រោះវាជាអតីតកូនសិស្សសាលាវត្តជ្រៃបិទមាស ជាមួយខ្ញុំកាលនៅពីក្មេងៗ ហើយអង្គុយរៀននៅជាប់ខ្ញុំតែម្តង វាឈ្មោះ អាន ។ ដោយការឈឺពោះ និងរាកតិចៗផងខ្ញុំឈោងដៃបេះក្តិបត្របែកបានបួនផ្លែ ដោយមិនបានសុំអនុញ្ញាតពីអ្នកយាម ពេលនោះឈ្មោះ អាន ដែលឈរយាមនៅជិតនោះឃើញ វាបានវាយខ្ញុំបីរំពាត់ហើយព្រមានថាៈ

-អាឯងសេរីដើរបេះបោចគ្មានសុំអ្នកណាអីចឹង?

ខ្ញុំងាកមើលមុខរបស់វាហើយនិយាយតបថាៈ

-ខ្ញុំឈឺពោះពេកណាបង ខ្ញុំបេះក្តិបត្របែកនេះទៅធ្វើជាថ្នាំទេ ដោយមិនបានសុំអនុញ្ញាតពីបង សូមបងអភ័យទោសខ្ញុំផងចុះ! វាមិនស្តីមកខ្ញុំវិញទេ ហើយលើករំពាត់ដែលកាន់នៅដៃក្រវីធ្វើជាសញ្ញាឲ្យខ្ញុំដើរចេញពីវា ចំណែកក្តិបត្របែកក៏វាមិនយកពីខ្ញុំទៅបោះចោលដែរ ។ យប់នេះខ្ញុំមានអារម្មណ៍ខុសប្លែកពីធម្មតា ខ្ញុំនឹកឃើញព្រឹត្តិការណ៍នៅល្ងាចមិញដែល អាអាន ជាអតីតមិត្តភ័ក្តិនឹងគ្នាសោះ វាដាច់ចិត្តលើកដៃវាយខ្ញុំ ដោយសារតែក្តិបត្របែកតែបួនផ្លែ ខ្ញុំស្រមៃឃើញកាលនៅពីក្មេងធ្លាប់អង្គុយរៀនតុជាមួយគ្នានឹកឃើញលោកគ្រូវាយទាំងពីរនាក់ដោយសារប្រលែងគ្នា នឹកឃើញធ្លាប់កាច់នំអន្សមអាំងចែកគ្នាស៊ី ធ្លាប់លេងគប់វង់ជាមួយគ្នា ។ អាអាន កាលនៅពីក្មេងវាមានចរិតស្លូតបូតណាស់ ចុះឥឡូវចិត្តវាខុសពីមុនខ្លាំងម្ល៉េះ ឬមួយវាមិនស្គាល់ខ្ញុំ? ទេមិនអាចទេ ព្រោះខ្ញុំនៅចាំវាច្បាស់ណាស់ ហើយវាក៏ជាក្មេងម្នាក់ដែលនៅជិតខ្ញុំ ដើរឃ្វាលគោជាមួយខ្ញុំច្រើនទៀតផង ដូច្នេះវាមិនអាចភ្លេចខ្ញុំទៅរួចទេ តែពេលនេះ តើមានអ្វីមកបាំងភ្នែក និងជំរុញចិត្តវាឲ្យបំភ្លេចកំណាប់អនុស្សាវរីយ៍កាលនៅពីក្មេងអស់រលីញអីចឹង ។ មែន សង្គ្រាមវាមិនបង្កតែភាពវិនាសកម្មតែមួយមុខនោះទេ វាបានកាឡៃចរិតមនុស្សពីស្លូតទៅជាកាច ពីមានសីលធម៌ទៅជាអសីលធម៌ដែរ ហើយក៏ប្រហែលមកពីកត្តាដូច បងប៉េង និយាយប្រាប់ខ្ញុំដែរហើយ ព្រោះការសាបព្រួសមនោគមន៍មានឥទ្ធិពលខ្លាំងណាស់ វាធ្វើឲ្យមនុស្សវង្វេងភ្លេចគិតពីមិត្ត និងសត្រូវ ព្រោះមានជំនឿយ៉ាងមុតមាំថា អ្នកណាក៏ដោយឲ្យតែនៅជាមួយរបបលន់ នល់ គឺសុទ្ធតែសត្រូវនឹងបដិវត្តន៍ទាំងអស់ សូម្បីតែឪពុកខ្លួនឯងក៏ដោយ ។ ដូច្នេះចិត្តគំនិតរបស់វាត្រូវអង្គការបំពាក់អប់រំឲ្យដាច់ខាតជាមួយសត្រូវធ្វើចិត្តអោយកាចសាហាវ គ្មានមេត្តា គ្មានមនោសញ្ចេតនាអ្វីទាំងអស់ ។ ទារុណកម្មមកលើរូបខ្ញុំជាងមួយខែកន្លងមកនេះ ខ្ញុំមិនដែលអង្វរសុំ ឬក៏ស្រក់ទឹកភ្នែក ចំពោះការឈឺចាប់នេះម្តងណាឡើយ តែពេលនេះ

ទឹកភ្នែកខ្ញុំហូរមកដោយឯកឯងព្រោះស្នាមអនុស្សាវរីយ៍កាលនៅពីក្មេងរវាងខ្ញុំ និងអាអាន កំពុងតែសើចចំអកដល់រូបខ្ញុំ ហើយវាកំពុងតែរំលឹក និងលាតត្រដាងពីសកម្មភាពអតីតកាលពេញអារម្មណ៍ខ្ញុំ ។ ទឹកភ្នែកខ្ញុំនេះ មិនមែនជាទឹកភ្នែកសងសឹកនោះទេ គឺជាទឹកភ្នែកដែលសោកស្តាយពីចរិតរបស់មនុស្សដែលធ្លាប់តែស្លូតបូតធ្លាប់អត់ឱនអធ្យាស្រ័យគ្នា ប្រែមកជាកាចសាហាវគ្មានមេត្តាទៅវិញ ។ ថ្ងៃរះផុតចុងឈើ គឺជាថ្ងៃទីសែសិបដែលខ្ញុំត្រូវជាប់ឃុំឃាំងនៅក្នុងជុំរំបិសាច ហើយក៏ជាថ្ងៃដែលពួកវាត្រូវហុតឈាមខ្ញុំផងក៏មិនដឹង ។

ខ្ញុំត្រូវសួរចម្លើយនៅកន្លែងថ្មីនេះ អស់រយៈពេលដប់ពីរថ្ងៃទៀត តែមានថ្ងៃខ្លះ សួរខ្ញុំតែមួយពេលទេ ហើយខ្ញុំមានថ្ងៃដែលត្រូវមានសំណាងខ្លះដូចនៅកន្លែងសួរចម្លើយពីពេលមុននោះទេ ។ ចាប់ពីថ្ងៃនោះមក សន្តិសុខឈប់ហៅខ្ញុំទៅសួរចម្លើយទៀតហើយ ខ្ញុំបានធូរស្រាលឡើងវិញ តែរាងកាយខ្ញុំស្គមកំប្រឹង ស្លេកស្លាំងគ្មានកម្លាំងនៅក្នុងខ្លួនទេ គឺមានតែកម្លាំងឆន្ទៈស្មោះត្រង់ និងយុវភាពរបស់ខ្លួនតែប៉ុណ្ណោះ ។ បីថ្ងៃក្រោយមក គឺមានចំនួនថ្ងៃទីហាសិបប្រាំ ទើបអង្គការមកនាំខ្ញុំទៅសួរម្តងទៀត អ្នកយាមបានចងដៃចងមុខ ខ្ញុំដដែល តែមិននាំខ្ញុំទៅបន្ទប់សួរចម្លើយទេ គឺនាំខ្ញុំទៅកន្លែងមួយដែលមានក្រាលឥដ្ឋការ៉ូ ហើយមានកៅអីបង្អែកឲ្យខ្ញុំអង្គុយ ហើយក៏អត់មានធ្វើទារុណកម្មខ្ញុំទេ ហើយប្រាប់ខ្ញុំថា “ឥឡូវនេះអង្គការបានសម្រេចដោះលែងឯងវិញហើយ ព្រោះកន្ទងមកអង្គការភ័ន្តច្រឡំនឹងឯង តែឯងត្រូវធ្វើកិច្ចសន្យាចំនួនបី“ខ”ក្នុងចំណោមកិច្ចសន្យាទាំងបីខនេះខ្ញុំនៅចាំតែមួយ “ខ” ទេគឺ “លាក់ការសម្ងាត់ឲ្យបានខ្ពស់ជូនអង្គការ” គឺមិនដឹងមិនឮ មិនឃើញអ្វីទាំងអស់ ព្រោះពេលដែលខ្ញុំចេញមកច្បាស់ជាមានញាតិមិត្ត បងប្អូនអ្នកទោសដែលនៅជាប់គុក មកសួរពីសុខទុក្ខបងប្អូនរបស់ខ្លួនហើយ ចម្លើយរបស់ខ្ញុំ គឺមិនដឹងមិនឃើញ ។ សន្តិសុខនោះ សូត្រកិច្ចសន្យានេះឲ្យខ្ញុំស្តាប់រួចហើយ ទាញដៃខ្ញុំទាំងជាប់ចំណងទៅផ្តិតមេដៃលើឯកសារនោះ ហើយនិយាយបន្ថែមទៀតថា “ឯងត្រូវតែធ្វើឲ្យបាននូវកិច្ចសន្យាទាំងបី“ខ”នេះ បើមិនដូច្នេះទេ ឯងនឹងត្រូវចាប់ខ្លួនម្តងទៀត ។ ឯងនេះជាមនុស្សមានសំណាងតែមួយក្នុងមួយពាន់សំណាង ព្រោះឯងជាប្រជាជនថ្មីដែលចូលមកដល់ទីនេះហើយ អាចមានសំណាងចេញទៅវិញបាន ។ ដូច្នេះឯង ត្រូវគោរពកិច្ចសន្យានេះឲ្យបាន” ។

សន្តិសុខបាននាំខ្ញុំមកកន្លែងវិញ ហើយពូ និងបងថា គាត់មានទឹកមុខស្រស់ស្រាយជាងមុនបន្តិច ព្រោះខ្ញុំមកវិញលើកនេះគឺមានមុខមាត់ សាច់ ស្បែក នៅល្អដូចដើម គាត់ទាំងពីរសួរខ្ញុំថាៈ

-ថ្ងៃនេះ សន្តិសុខហៅឯងសួរពីអ្វីទៀត?

-សន្តិសុខថា អង្គការភ័ន្តច្រឡំ ហើយដោះលែងខ្ញុំវិញហើយ!

-ពូ! ត្រេកអរណាស់ ហើយពូក៏សូមសរសើរនូវទឹកចិត្តដ៏ក្លាហាន និងមុតមាំរបស់ក្មួយឯង ។ តែពូដូចជាមិនសូវកក់ក្តៅប៉ុន្មានទេ បើគេមិន......ក៏ត្រូវបញ្ជូនទៅមន្ទីរសន្តិសុខតំបន់២១ទៀតហើយ ព្រោះ នៅទីនោះឯងអត់ទទួលទោសផងនោះ ។

-ខ្ញុំក៏មានជំនឿអីចឹងដែរពូ! តែណ្ហើយចុះពូកុំខ្វល់ចំពោះខ្ញុំអីព្រោះខ្ញុំនៅក្មេង គ្មានប្រពន្ធ គ្មានកូន ដែលត្រូវទួញយំសោកស្តាយនោះទេ ។ ដូច្នេះ សូមពូគិតពីខ្លួនពូឲ្យបានច្រើនល្អជាង ព្រោះពូនៅមានប្រពន្ធមានកូនដែលនៅទន្ទឹងរង់ចាំពូ ។ នៅថ្ងៃនេះខ្ញុំគ្មានទុក្ខកង្វល់អ្វីទេ ព្រោះផ្លូវពីរដែលខ្ញុំត្រូវសម្រេចចិត្តនោះឥឡូវវាបានមកផ្លូវរួមចូលគ្នាតែមួយហើយ ។

នៅថ្ងៃទី២៧ ខែមិថុនា១៩៧៧ ហើយជាថ្ងៃគម្រប់៥៨ថ្ងៃប្រហែលម៉ោង៧ព្រឹក សន្តិសុខពីរនាក់ក្នុងឯកសណ្ឋានពណ៌ខ្មៅប្រដាប់ដោយកាំភ្លើងគ្រប់គ្នា មកឲ្យខ្ញុំរៀបអីវ៉ាន់ ខ្ញុំគ្មានរបស់អ្វីក្រៅពីខោអាវដែលស្លៀកជាប់នឹងខ្លួនរហែករហ៊ែអស់ហើយ និងក្រមាមួយតែប៉ុណ្ណោះ ។ អ្នកយាមដោះខ្នោះ ចេញពីជើងខ្ញុំ ខ្ញុំក្រោកឈរហើយលាពូ បងថា និងអ្នកទោសដែលនៅជាមួយជាចុងក្រោយបង្អស់ ។ ពូងើបសម្លឹងមកមើលមុខខ្ញុំ ចំណែកបងថា និងអ្នកទោសខ្លះទៀតមានទឹកភ្នែករលីងរលោងដោយក្តីអាណិតមកខ្ញុំថា មិនដឹងជាអង្គការយកទៅណាទៀតទេ ។

ខ្ញុំចុះមកដល់ដី ក្រោមមេឃភ្លៀងរលឹមស្រិចៗ អ្នកយាមចងដៃខ្ញុំដដែល តែអត់យកក្រណាត់ខ្មៅមកចងមុខខ្ញុំទេ គឺយកក្រមាខ្ញុំមកចងមុខខ្ញុំវិញ ហើយដឹកដៃខ្ញុំដើរកាត់ដំណក់ភ្លៀងយ៉ាងយូរខ្ញុំមិន ដឹងថានាំខ្ញុំទៅទិសណាទេ ។ ខ្ញុំគិតថាបន្តិចទៀតនេះ ខ្ញុំនឹងត្រូវលាចាកលោកនេះហើយខ្ញុំសូមទោសម្តាយ ឪពុកខ្ញុំ ដែលនៅជាតិនេះខ្ញុំមិនបានសងគុណគាត់ចាំជាតិក្រោយខ្ញុំនឹងសងគុណលោកទាំងពីរវិញ ខ្ញុំឲ្យព្រលឹង អាប៉ក់ មករង់ចាំទទួលខ្ញុំផង ព្រោះបន្តិចទៀតយើងនឹងនាំគ្នាទៅឲ្យឆ្ងាយពីដែនដីដ៏កំណាចនេះ ទៅនៅភពមួយ

ដែលមានសិទ្ធិសេរីភាពពេញលេញទាំងពីរនាក់ ។ សន្តិសុខលែងដៃខ្ញុំ ហើយឲ្យឈប់នៅស្ងៀម ខ្ញុំគិតថា ដល់មាត់រណ្ដៅហើយ ខ្ញុំលួចយកជើងរាវទៅខាងមុខរកមាត់រណ្ដៅតែដីរាបដដែល ខ្ញុំដកជើងមកវិញ ។ ខ្ញុំឮសំរឹបជើងដើរពីក្រោយសំដៅមករកខ្ញុំ ខ្ញុំហាក់ដូចជារសើបស្រៀវក្បាលខ្លាំងណាស់ សំរិបជើងក៏បាត់ឮសូរ ខ្ញុំរាប់តែក្នុងចិត្តថា១-២-៣ ស្រាប់តែដៃរបស់ម្ចាស់សំរឹបជើងនោះ ស្រាយក្រមាដែលចងមុខខ្ញុំចេញ តែដៃខ្ញុំសន្តិសុខនោះអត់ស្រាយចំណងចេញនោះទេ ។ ខ្ញុំឃើញរទេះសេះដែលមានក្រុមសន្តិសុខជិះនៅលើរទេះចំនួនពីរនាក់ នៅឈប់ពីមុខខ្ញុំប្រហែល១៥ម៉ែត្រ អ្នកដែលនាំខ្ញុំចេញមកគេបញ្ជារខ្ញុំអោយដើរទៅជិះរទេះសេះនោះ សន្តិសុខម្នាក់ត្រឡប់ទៅកន្លែងវិញម្នាក់ទៀត មកជិះរទេះសេះជាមួយខ្ញុំដែរ ម្នាក់នោះគ្រៀកខ្ញុំឡើងលើរទេះសេះរួច យកក្រមាខ្ញុំមកគ្របខ្លួនខ្ញុំមិនឲ្យអ្នកដទៃឃើញចំណង ទើបឡើងជិះតាមក្រោយ ។

សេះក៏ចាប់ផ្ដើមអូសរទេះឲ្យទៅមុខដោយផ្ទុកមនុស្សចំនួនបួននាក់ទាំងរូបខ្ញុំ ខ្ញុំមិនដឹងថាអ្នកទាំងនោះនាំខ្ញុំទៅណាទេ ព្រោះអម្បាញ់មិញគឺចងមុខខ្ញុំជិត ហើយនាំដើរបត់បែនចុះឡើងៗវង្វេងទិសអស់ហើយ ហើយត្រូវពេលនោះមេឃស្រទុំមានភ្លៀងរលឹមតិចៗផង ខ្ញុំមើលថ្ងៃមិនឃើញឡើយ ។ ខ្ញុំនៅតែគិតថា សន្តិសុខទាំងនេះនាំខ្ញុំទៅកាន់មន្ទីរសន្តិសុខតំបន់២១ទៀតហើយ អង្គការមិនដោះលែងខ្ញុំនោះទេ ព្រោះដៃខ្ញុំនៅជាប់ចំណងនៅឡើយ តែប្លែកត្រង់មិនចងមុខខ្ញុំ ។ រទេះសេះបានមកដល់ផ្លូវមុខវិទ្យាល័យសួងដែលត្រូវអង្គការយកធ្វើជាមន្ទីរពេទ្យស្រុកត្បូងឃ្មុំ ទើបខ្ញុំបាត់វង្វេងហើយស្គាល់ទិសឡើងវិញ រទេះសេះបានបត់ក្បាលទៅទិសខាងលិចសំដៅទៅផ្សារសួង ហើយបត់តាមផ្លូវជាតិមកទិសខាងលិចទៀតប្រហែល៧០០ម៉ែត្រ ទើបមកដល់មន្ទីរ «ឃ» កងចល័ត ហើយជាកន្លែងដែលអង្គការចាប់ខ្ញុំ ។ សេះបានឈប់បោលនៅមុខមន្ទីរកងចល័ត ហើយគ្នាពីរនាក់ចុះដើរចូលទៅខាងក្នុង មួយសន្ទុះទើបត្រឡប់មកវិញ ហើយបានបញ្ជាឲ្យខ្ញុំចុះពីលើរទេះសេះដោយមានគ្នាពីរនាក់ជួយទប់ខ្លាចក្រែងខ្ញុំដួល ទើបបានស្រាយចំណងដៃខ្ញុំចេញហើយនិយាយថា «សូមប្រគល់សិទ្ធិឲ្យមិត្តឯងវិញ» ពាក្យមួយឃ្លានេះខ្ញុំនៅចាំគ្រប់ម៉ាត់រហូតដល់ពេលនេះ ។

ពេលនេះខ្ញុំមានជីវិតរស់ឡើងវិញហើយ តែរស់នៅក្នុងសភាពគ្មានសិទ្ធិ គ្មានសេរីភាព និងការចងចាំ រាងកាយធ្លាប់តែមាំមួនក្លៀវក្លាស្វាហាប់ ឥឡូវក្លាយជាមានជំងឺរ៉ាំរ៉ៃរហូតបច្ចុប្បន្ន ។ ខ្ញុំចេះតែនឹកគិតរហូតដល់ឥឡូវថា «តើខ្ញុំមានទោសព្រោះអ្វី? » ។

**ឌី សុភា**



ប្រជាជនកម្ពុជានាំក្រុមគ្រួសារធ្វើដំណើរត្រឡប់មកភូមិកំណើតវិញ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំ នៅឆ្នាំ១៩៧៩

# ដំណើរភៀសខ្លួនឆ្លងដែនពីរបបកម្ពុជាប្រជាធិបតេយ្យ

***រឿងពិតរបស់ ជា សីហា***

***(តពីលេខមុន)***

*យុវជនទាំងនេះសម្តែងភាពស្និទ្ធស្នាលជាមួយខ្ញុំ ហើយហៅខ្ញុំថា "ពុក" ជំនួសពាក្យ "ឪពុក" ដែលសម័យខ្មែរក្រហមតម្រូវឲ្យក្មេងៗហៅមនុស្សចាស់ដែលមានអាយុប្រហាក់ប្រហែលនឹងឪពុកម្តាយរបស់ខ្លួនថា ពុក ឬម៉ែ ។ ពេលនោះ ខ្ញុំមានអាកប្បកិរិយាអេះអុះ ព្រោះនឹកមិនឃើញអត្តសញ្ញាណរបស់យុវជនទាំងនោះទេ ។ យុវជនម្នាក់មុននោះបានយល់ពីអធ្យាស្រ័យរបស់ខ្ញុំក៏បញ្ជាក់ជាថ្មីប្រាប់ខ្ញុំថា "ពួកខ្ញុំជាសមាជិកកងចល័តស្លួលកោងដែលពុកធ្លាប់ផ្តល់ថ្នាំសម្រាប់ព្យាបាលភ្នែកឲ្យរាល់ពេលដែលពួកខ្ញុំចេញដំណើរទៅធ្វើការឆ្ងាយ" ។ ខ្ញុំសូមអភ័យទោសចំពោះពួក គេដែលខ្ញុំនឹករកអត្តសញ្ញាណរបស់ពួកគេមិនឃើញភ្លាមៗ ពីព្រោះពួកកងចល័តស្លួលកោងមានចំនួនច្រើន ខ្ញុំពុំអាចចាំបានទាំងអស់ទេ ។ យុវជនម្នាក់នោះបានខ្សឹបប្រាប់ខ្ញុំថា "បុរសម្ចាស់បន្ទប់នេះឈ្មោះ រឿង មានកូនឈ្មោះ លី ជាបុគ្គលមានចរិតប្រឡើសបើសមិនដែលរាប់រកនរណាឡើយ ។ អ្នកទោសក្នុងមន្ទីរឃុំឃាំងទាំងអស់មានការក្រែងវែងចំពោះបុគ្គលម្នាក់នោះណាស់ ។ ដូច្នេះសូមពុកអញ្ជើញទៅនៅជាមួយពួកខ្ញុំឯហ្នឹងម្ខាងនោះ ពួកខ្ញុំនឹងបម្រើពុកឲ្យបានជិតដល់ជាទីបំផុត" ។ ខ្ញុំមានចិត្តកន្ទះរាអល់អែកចំពោះការអញ្ជើញ ដោយទទួចរបស់យុវជនដែលមានចិត្តស្មោះចំពោះខ្ញុំ ព្រោះម្យ៉ាង បុរសឈ្មោះ រឿង បានទៅលុតជង្គង់អញ្ជើញខ្ញុំដោយគោរពមុនគេ ហើយម្យ៉ាងទៀតខ្លួនខ្ញុំបានទទួលការបម្រើដោយផ្ចិតផ្ចង់ពីបុរសនោះរួចមកហើយ ។ ខ្ញុំឆ្លើយប្រាប់ទៅយុវជនទាំងនោះថា "ខ្ញុំនៅជាមួយបុរសឈ្មោះ រឿង នេះមួយរយៈពេលសិនបើមិនស្រួល ទើបខ្ញុំទៅនៅជាមួយពួកកូនៗវិញ" ។ យុវជនទាំងនោះយល់ព្រមតាមការសម្រេចចិត្តរបស់ខ្ញុំ ។ បុរសឈ្មោះ រឿង បានវិលមកពីបោកគក់កំណាត់មុងរបស់ខ្ញុំហើយហៅខ្ញុំទៅមុជទឹកជម្រះខ្លួន ។ គេបណ្តើរខ្ញុំសំដៅទៅអាងទឹក ។ គេដូតទឹកឲ្យខ្ញុំ គេជួយដុសក្អែលជម្រះកាយខ្ញុំដោយយកចិត្តទុកដាក់ ។ ខ្ញុំសង្កេតមើលអាកប្បកិរិយារបស់បុរសនេះ ពុំដូចអ្វីដែលពួកយុវជនបានប្រាប់ខ្ញុំនោះឡើយ ។ យើងវិលមកពីកន្លែងងូតទឹកទាំងអស់គ្នា ។ គេយកក្រមាមកជូតខ្លួនខ្ញុំ ហើយយកអាវមកពាក់ឲ្យខ្ញុំហាក់ដូចខ្ញុំនេះជាអ្នកមានគុណរបស់គេ ។ រួចរាល់ហើយ ខ្ញុំអង្គុយលើកន្ទេលដើម្បីសំណេះសំណាលឲ្យស្គាល់គ្នា ស្រាប់តែបុរសនោះលុតជង្គង់ថ្វាយបង្គំខ្ញុំបីដង ហើយនិយាយមករកខ្ញុំថា "ចាប់ពីពេលនេះតទៅខ្ញុំសុំបង ធ្វើជាបងធម៌របស់ខ្ញុំ" ខ្ញុំក៏បានយល់ព្រមតាមសេចក្តីសុំនេះ ។ ដូច្នេះយើងជាបងប្អូនធម៌នឹងគ្នាក្នុងគ្រាកម្សត់ ខ្ញុំរស់នៅដោយសុខសាន្តជាមួយប្អូន រឿង និងកូនធម៌ឈ្មោះ លី ។ ពួកយុវជនអតីតសមាជិកកងចល័តស្លួលកោងបានយកចិត្តទុកដាក់រាប់អានខ្ញុំដូចឪពុករបស់គេ ។ មន្ទីរឃុំឃាំងបូរីរាំកាលពីមុននេះបន្តិចគឺជាពន្ធនាគាររបស់ខេត្តបូរីរាំ ។ ដោយសារចំនួនអ្នកភៀសខ្លួនខ្មែរដែលមកជាប់ឃុំនៅទីនេះកើនច្រើនឡើងជាលំដាប់ ទើបរដ្ឋបាលខេត្តសម្រេចធ្វើគុកថ្មី សម្រាប់ដាក់អ្នកទោសសៀមដោយឡែក ។ ដូច្នេះមន្ទីរឃុំឃាំងនេះ ត្រូវបានគេហៅថា គុកចាស់ ។ របបហូបចុក និងការឃុំគ្រងរក្សាឲ្យនៅដដែល លើកលែងតែពុំមានខ្នោះឃ្នាងដូចកាលពីមុននោះឡើយ ។ របបអាហាររបស់អ្នកទោសគឺមួយថ្ងៃឲ្យបរិភោគពីរពេល គឺថ្ងៃត្រង់ និងល្ងាច ។ ក្នុងមួយពេលៗ គេផ្តល់អាហារឲ្យតែមួយបែបដដែលៗជារៀងរាល់ថ្ងៃ គឺទឹកប្រហុករាវៗមួយកូនចានជម និងគ្រាប់ស្រូយប្រាំមួយផ្លែ ។ ចំណែកបាយវិញក៏មានចំនួនតិចតួចពុំគ្រប់គ្រាន់ដែរ គឺមួយចានទាបចំទើរស្មើនឹងមួយវែកក្រឡុម ។ ពួកយុវជនបានរំលែកបាយរបស់គេបន្ថែមមកឲ្យខ្ញុំ ម្នាក់កន្ទះស្លាបព្រាបាយ ដូច្នេះ ចំនួនបាយរបស់ខ្ញុំកើនឡើងល្មមឲ្យខ្ញុំបរិភោគបានឆ្អែត ។ ខ្លួនខ្ញុំចាប់ផ្តើមមានសាច់ឈាមឡើងវិញបន្តិចម្តងៗ ។ មានពេលមួយសរសៃអំបោះមួយបានចេញពីមុខរបួសជើងរបស់ខ្ញុំដោយខ្លួនឯង ខ្ញុំទាញវាបន្តិចម្តងៗចេញពីដំបៅទាល់តែផុតចុង ។ សរសៃអំបោះនេះមានប្រវែងប្រមាណ*

ពីរតឹក ។ ខ្ញុំនឹកឃើញថា សរសៃអំបោះនេះរបូតចេញពីកំណាត់ស្បៃ ដែលពេទ្យទាហានស្រុកអារញ្ញយកមកជូតសម្អាតមុខរបួសឲ្យខ្ញុំ កាលខ្ញុំនៅជាប់ក្នុងមន្ទីរឃុំឃាំងតម្រួតយោធាដើមស្ពលមកម្ល៉េះ ។ សរសៃអំបោះនេះហើយជាមូលហេតុដែលធ្វើឲ្យដំបៅនៅជើងរបស់ខ្ញុំមិនព្រមសះស្បើយ ។ គ្រាន់តែខ្ញុំដកសរសៃអំបោះចេញពីដំបៅភ្លាម ដំបៅនោះក៏ជិតមុខសះជាពីពេលនោះមក ។

ពេលវេលាកន្លងទៅយ៉ាងយឺតៗបំផុត ។ ខ្ញុំ និងអ្នកភៀសខ្លួនដទៃទៀតតែងជួបគ្នាថ្ងៃពីរបីដងក្នុងរៀងៗខ្លួន ។ យើងនឹកស្រុក នឹកប្រពន្ធកូន ។ យើងចង់ទៅច្បាំងដើម្បីរំដោះប្រទេសយើងពីកណ្ដាប់ដៃ ពួកព្រៃផ្សៃដែលគេដាក់ឈ្មោះឲ្យខ្លួនគេថា «កម្ពុជាប្រជាធិបតេយ្យ» ។ កាលណោះ នៅមុនឆ្នាំ១៩៧០ សម្ដេចព្រះ នរោត្តម សីហនុ មានព្រះឋានៈជាព្រះប្រមុខរដ្ឋ ។ ព្រះអង្គដាក់ឈ្មោះឲ្យពួកទាំងនោះថា «ខ្មែរក្រហម» ព្រោះ ពួកអ្នកទាំងនោះមាននិន្នាការទៅខាងលទ្ធិកុម្មុយនីស្ត ។ ចំនួនខ្មែរភៀសខ្លួននៅក្នុងមន្ទីរឃុំឃាំងបូរីរ៉ាំ បានកើនឡើងដល់ជិតប្រាំរយនាក់ ។ យើងតែងសាកសួរគ្នាពីព័ត៌មានថ្មីៗដែលអ្នកភៀសខ្លួនទើបមកដល់បានរៀបរាប់ ។ យើងដឹងអំពីការរឹតបន្តឹងរបស់ខ្មែរក្រហមមកលើប្រជាជន ការសម្លាប់ប្រជាជនកាន់តែច្រើនឡើង ការសម្លាប់គ្នាគេក្នុងជួរកម្មាភិបាលខ្មែរក្រហម ពួកខ្មែរក្រហមពីភូមិភាគនិរតីមកបោសសម្អាតពួកភូមិភាគផ្សេងៗ ពួកកម្មាភិបាលជំនាន់ចាស់បានខ្ចាត់ខ្ចាយអស់ហើយ គឺគេយកទៅរៀនសូត្រ! ។ ប្រជាជនបានរត់ភៀសខ្លួនចេញពីសហករណ៍នីមួយៗកាន់តែច្រើនឡើង ។ ពួកយោធាខ្មែរក្រហមបណ្ដឹងការយាមកាមទ្វេដង ។ ពួកវាតាមប្រមាញ់អ្នកភៀសខ្លួនមិនឲ្យរត់រួចឡើយ ។ អ្នកភៀសខ្លួនដែលរត់មកជាពួកមានចំនួនច្រើនរងហានិភ័យ ច្រើនជាងអ្នកភៀសខ្លួនមានចំនួនតិច ។ ខ្មែរក្រហមតាមប្រមាញ់មុនមកដល់ព្រំដែន នៅសេសសល់ប៉ុន្មានទាហានសៀមបាញ់សម្លាប់នៅពេលឆ្លងចូលមកដល់ដីសៀម ។ ក្រុមខ្លះមានចំនួនដល់ជាងមួយរយនាក់ អ្នករស់រានមានជីវិតនៅសល់មិនដល់ដប់នាក់ផងទេ ។ ខ្ញុំនឹកថា តើអ្នកភៀសខ្លួនដែលត្រូវគេសម្លាប់ទាំងអស់ដោយគ្មានដំណឹង តើមានប៉ុន្មាននាក់ទៅ? ។ ខ្មែរអើយ! យកជីវិតមកបោលទទេ តាមព្រំដែនគ្នាអ្នកដឹងពុំ ។ នេះហើយជាលទ្ធផលនៃការដណ្ដើមអំណាចគ្នារវាងខ្មែរ និងខ្មែរ ។ ខ្មែរបាត់បង់ទឹកដីស្ទើរតែអស់ក៏ព្រោះតែរឿងហ្នឹង ម្ដេចក៏ខ្មែរមិនរាង? ។ ពួកយើងជាជនភៀសខ្លួនមក នៅឆ្ងាយពីស្រុកឆ្ងាយពីគ្រួសារ មកពឹងពាក់បរទេសទើបភ្ញាក់ខ្លួនហើយចេះស្រឡាញ់ស្រុកទេសរបស់ឯង ។ យើងត្រៀមខ្លួននឹងយកជីវិតទៅប្ដូរយកសេរីភាពឲ្យប្រជាជនខ្មែរវិញ ។ យើងបានរៀបចំពួកយើងដោយស្ងាត់ៗជាពួក ជាក្រុមជាកងរួចស្រេចបាច់ ហើយមានមេ មានកើយត្រឹមត្រូវ ។ យើងរៀបបាន១៦កងអនុសេនាតូច ។ នៅពេលយើងរកអាវុធបាន ឬមានការគាបសង្កត់ខ្លាំងពីពួកសៀម យើងនឹងចេញពីជំរុំឃុំឃាំងភ្លាម យើងទៅច្បាំង ។ យើងម្នាក់ៗអន្ទះសាររង់ចាំឱកាសនោះមកដល់ ។ នៅពេលក្រោយមកទៀត ក្នុងឱកាសដែលអង្គការអន្តរជាតិបានទទួលការអនុញ្ញាតឲ្យចូលទៅក្នុងមន្ទីរឃុំឃាំងបាន ខ្ញុំបានទាក់ទងភ្នាក់ងារសេ.អ៊ី.អា មេរិកាំងតាមរយៈមិត្តម្នាក់ដែលជាវេជ្ជបណ្ឌិតសញ្ជាតិកាណាដា ។ ភ្នាក់ងារសេ.អ៊ី.អាដ៏សំខាន់ម្នាក់មកជួបខ្ញុំ ។ ខ្ញុំរៀបរាប់អំពីមនោសញ្ចេតនារបស់ខ្ញុំចំពោះសហរដ្ឋអាមេរិក អំពីការជួយរំដោះភ្នាក់ងារ សេ.អ៊ី.អា ម្នាក់ពីប៉ោយប៉ែតឆ្លងដែនទៅអារញ្ញ តាមការពឹងពាក់របស់ចៅហ្វាយនាយរបស់ខ្ញុំ នៅពេលខ្មែរក្រហមហៀបនឹងចូលមកដល់ប៉ោយប៉ែត ។ ខ្ញុំពន្យល់ប្រាប់គេអំពីមូលហេតុនៃការសុំជំនួយជាអាវុធពីសហរដ្ឋអាមេរិក និងអំពីស្ថានការណ៍ថ្មីៗនៅក្នុងប្រទេសកម្ពុជា ។ ភ្នាក់ងារនោះឆ្លើយមកខ្ញុំវិញតាមរបៀបមើលងាយមើលថោកថា៖ «ពួកលន់ នល់ មានដល់ទៅរថក្រោះយន្តហោះ វាយខ្មែរក្រហមមិនឈ្នះផង ចុះអ្នកឯងចង់បានកាំភ្លើងតែប្រាំរយដើមធ្វើម្ដេចទៅប៉ះជាមួយខ្មែរក្រហមបាន» ។ ខ្ញុំខំពន្យល់គេថា «ស្ថានភាពស្រុកទេសមិនដូចគ្នាទេ កាលជំនាន់លន់ នល់ ប្រជាជនគាំទ្រខ្មែរក្រហម ប៉ុន្តែឥឡូវប្រជាជនស្អប់ខ្មែរក្រហមរង់ចាំតែមានខ្នងបង្អែកគេនឹងបះបោរភ្លាម» ។ បន្ទាប់មកគេប្រាប់ខ្ញុំថា ចាំគេយកសំណើនេះ ទៅគិតមើលសិន ។ ខ្ញុំបានបន្ថែមប្រាប់ភ្នាក់ងារនោះថា «បើមិនបានកាំភ្លើងប្រាំរយដើម ក៏សុំតែពីររយដើមសិនក៏បានដែរ» ។ សំណើរបស់ខ្ញុំ ទាំងប៉ុន្មាននោះមិនមានចម្លើយជារៀងរហូត ។ នៅពេលដែលខ្ញុំបានទៅរស់នៅប្រទេសបារាំង ទើបដឹងថា អាមេរិកាំង និងសៀមគាំទ្រពួកខ្មែរក្រហមឲ្យប្រឆាំងនឹងយួន ។ ដូច្នេះ ហើយបានជារណសិរ្សទាំងអស់របស់ខ្មែរស (ពួកប្រឆាំងខ្មែរក្រហម) កាលជំនាន់ខ្មែរក្រហមកាន់អំណាច ពុំអាចងើបមុខរួចឡើយ ។

មិនយូរប៉ុន្មានក្រោយមក ពួកតម្រួតនៃមន្ទីរឃុំឃាំងបូរីរាំ ដឹងពីវត្ថុបំណងដ៏ខ្លាំងក្លាកើនឡើងពីមួយថ្ងៃទៅមួយថ្ងៃរបស់ពួកយើងថា ចង់ទៅតស៊ូជាមួយខ្មែរក្រហម ។ ដើម្បីបន្ធូរបរិយាកាសនៃការផ្សារជ្រួលជ្រើមរបស់ពួកខ្មែរភៀសខ្លួននៅក្នុងជំរុំឃុំឃាំងបូរីរាំ អាជ្ញាធរសៀមបានហាមពួកតម្រួតឲ្យឈប់និយាយពាក្យគំរាមគំហែងថា ចង់បញ្ជូនពួកអ្នកភៀសខ្លួនទៅប្រគល់ឲ្យខ្មែរក្រហមវិញ ហើយម្យ៉ាងទៀតគេបញ្ជូនខ្មែរម្នាក់ឈ្មោះ សៅ សេនា មកការិយាល័យតម្រួតនៅមន្ទីរឃុំឃាំង ហើយតម្រួតហៅខ្ញុំឲ្យទៅជួបបុរសនោះ ។ បុរសនោះមានមាឌមធ្យមសម្បុរជ្រះមានអាយុប្រមាណជាង៥សិបឆ្នាំ រាងសង្ហា សម្តី សំដៅសុភាពឥតរដឹន សមជាអ្នកភ្នំពេញ ។ ខ្ញុំឃើញស្លាកស្នាមរបួសជាច្រើនកន្លែងនៅនឹងស្បែកក្បាលរបស់គាត់ ។ ពេលជួបគ្នាភ្លាម ខ្ញុំសម្គាល់ឃើញមនោសញ្ចេតនាដ៏ជ្រាលជ្រៅរបស់គាត់មកលើរូបខ្ញុំដែលជាជនរួមជាតិរបស់គាត់ ។ គាត់និយាយមកកាន់ខ្ញុំដូចជាបងម្នាក់ដែលមានមេត្តាធម៌ និយាយមករកប្អូនដោយសេចក្តីនឹករព្ញក ។ ខ្ញុំក៏មានសមានចិត្តចំពោះគាត់វិញដែរ ។ ន័យដែលបង្កប់ក្នុងសម្តីរបស់គាត់ធ្វើឲ្យខ្ញុំយល់បានថា គាត់ពុំអាចនិយាយដោយស្មោះត្រង់បានទេ ព្រោះគាត់ខ្លាចតម្រួតសៀម ។ គាត់គ្រាន់តែនិយាយមកកាន់ខ្ញុំថា «យើងកំពុងតែរកកន្ទ័ពនៅតាមជាយដែន យើងខ្វះខាតសព្វគ្រប់ ចាំមើលបន្តិចទៀតសិន» ។ គាត់បានហុចប្រាក់មកឲ្យខ្ញុំ ៥០បាត ហើយយើងបែកគ្នាត្រឹមនោះ ។ ខ្ញុំនឹកគាត់ នឹកពិចារណាសម្តីរបស់គាត់ ។ ខ្ញុំយល់ឃើញថា គាត់ជាភ្នាក់ងារម្នាក់ដែលជាប់ក្នុងក្រញាំជើងសៀម ។ ឱខ្មែរអ្នកស្នេហាជាតិអើយ! ទទួលវាសនាមិនខុសគ្នាឡើយ រត់រួចពីក្រញាំខ្មែរគ្នាឯងទៅជាប់ក្នុងក្រញាំបរទេស ។ គេប្រើយើងរហូតដល់ថ្ងៃយើងស្លាប់ ។ យើងជាទាសៈដាច់ថ្លៃរបស់គេ ។ សេចក្តីនឹកស្រុក នឹកគ្រួសារក្លាយជាជំងឺមកយាយីខួនប្រាណខ្ញុំ ។ ខ្ញុំឈឺ ឈឺចាប់ខ្លាំងឡើងៗឥតស្រាក ។ ភ្ញាក់ពីដំណេកក៏ឈឺ ពេលហូបក៏ឈឺ ពេលល្ងាចក៏ឈឺ ពេលដេកក៏ឈឺ ឈឺគ្មានអ្វីប្រៀបគ្មាន ឈឺរហូតដល់លែងខ្លាចស្លាប់ ។ នេះហើយជាជំងឺរបស់អ្នករត់ចោលស្រុក ។ បរិយាកាសនៅក្នុងមន្ទីរឃុំឃាំងកាន់តែតានតឹងឡើង ។

ថ្ងៃ១៥ រោច ខែភទ្របទ ជាថ្ងៃបុណ្យភ្ជុំបិណ្ឌ ។ ភ្ជុំបិណ្ឌជាបុណ្យទានតាមប្រពៃណីជាតិខ្មែរ ជាបុណ្យដ៏ធំសំខាន់ដែលជនជាតិខ្មែរជាពុទ្ធសាសនិកបានប្រារព្ធពិធីនេះតាំងពីថ្ងៃ១ រោច ខែភទ្របទ ដល់ថ្ងៃ១៤ រោច ខែដដែល ហៅថា ពិធីបុណ្យកាន់បិណ្ឌ ឬដាក់បិណ្ឌ ដល់ថ្ងៃ១៥ រោចជាថ្ងៃដាច់ខែភទ្របទជាថ្ងៃបុណ្យភ្ជុំបិណ្ឌ ។ ពិធីបុណ្យនេះធ្វើសម្រាប់ឧទ្ទិសកុសលជូនទៅវិញ្ញាណក្ខន្ធនៃបុព្វការីរបស់ខ្លួនដែលបានធ្វើមរណកាលទៅហើយ ។ មន្ត្រី ឬនិយោជិតនៃគ្រឹះស្ថានរាជការ ឬឯកជនត្រូវបានឈប់សម្រាកពីការងារ៣ថ្ងៃគឺ ថ្ងៃ ១៤ រោច ១៥ រោច ខែភទ្របទ និងថ្ងៃ១ កើត (ខែអស្សុជ) ។ ពួកយើងជាអ្នកជាប់ឃុំក្នុងជំរុំឃុំឃាំងបុរីរាំ ពុំបានដឹងអំពីថ្ងៃបុណ្យដ៏សំខាន់នោះទេ ពីព្រោះម្យ៉ាងគ្មានប្រក្រតិទិនមើល ហើយម្យ៉ាងទៀតពួកយើងពុំបានយកចិត្តទុកដាក់នឹងពេលវេលាតាំងពីខ្មែរក្រហមចូលមកគ្រប់គ្រងប្រទេស ។ ដល់យូរៗទៅពួកយើងបាត់បង់ទម្លាប់នៃការយល់ដឹងអំពីពេលវេលា ។ ស្រាប់តែមានប្រជាជនសៀមដែលមានដើមកំណើតជាខ្មែរប្រមាណបួនប្រាំនាក់នាំនំអន្សមនំគមជានំធ្វើសម្រាប់ពិធីបុណ្យនោះ ជាច្រើនចូលមកចែកចាយឲ្យពួកយើងទើបយើងដឹងតាមអ្នកម្ចាស់ទាននោះថា ថ្ងៃបុណ្យភ្ជុំបិណ្ឌបានកន្លងផុតទៅហើយ ។ ភ្ញៀវដ៏ឧត្តមរបស់យើងមានសមានចិត្តដ៏ជ្រាលជ្រៅចំពោះពួកយើង ។ ពួកគាត់ថែមទាំងមកសម្តែងរបាំគែនដ៏ពិរោះធ្វើឲ្យពួកយើងលន្លោចចិត្ត ហើយទស្សនាអស់រយៈពេលយ៉ាងយូរ ។ ក្រោយពីការសម្តែងរបាំគែនចប់សព្វគ្រប់ទៅភ្ញៀវរបស់យើងនៅសំណេះសំណាលជាមួយពួកយើងរហូតដល់តម្រួតមកហៅគាត់ឲ្យចេញពីជំរំ ។ ខ្លឹមសារនៃការសំណេះសំណាលនោះ សំដៅទៅដល់ការចង់រត់ការ ដើម្បីដោះពួកយើងខ្លះឲ្យរួចពីការឃុំឃាំង ហើយឲ្យទៅប្រកបការងារជាអ្នកជានៅតាមភូមិស្រុកជាធម្មតា ។ លើសពីនោះទៅទៀតពួកគាត់ខ្លះមានកូនក្រមុំដែលមានរូបរាងស្រស់សោភា ដែលអាចរៀបចំផ្សំផ្គុំឲ្យបានជាប្រពន្ធរបស់កម្លោះខ្មែរខ្លះបានទៀតផង មិនតែប៉ុណ្ណោះសោត គាត់នឹងចែកទ្រព្យសម្បត្តិឲ្យជាដីស្រែ ជាគោ ជាច្រើនហិចតាគោជាច្រើនទឹមទៀត ។ ប៉ុន្តែ ពុំមែនជារឿងងាយស្រួលទេ គឺត្រូវទៅរត់ការសុំច្បាប់ពីក្រសួងមហាតថៃ(មហាផ្ទៃ) ទើបបាន ។ ប្រមាណមួយអាទិត្យក្រោយមក ភ្ញៀវដ៏ឧត្តមរបស់យើងបានវិលមករកពួកយើងវិញ ទាំងទឹកភ្នែក ព្រោះឈឺចិត្តនឹងសម្តីរបស់មន្ត្រីដែលជាអាជ្ញាធរខាងមហាតថៃថា «បើហងចង់ឲ្យកូនទៅខ្មេន (ខ្មែរ) ឲ្យទៅផ្តែវិញប្រសើរជាង» ។ នេះជាពាក្យមើលងាយមើលថោក

របស់ពួកអាជ្ញាធរសៀមមកលើជនជាតិខ្មែរ បើពិតជាពួកអាជ្ញាធរសៀមពោលដូច្នេះមែន ។

ជនជាតិ ឬប្រទេសនីមួយៗ បើមានការបែកបាក់សាមគ្គីគ្នា ហើយគេនឹងមើលងាយមើលថោកជនជាតិនោះ ប្រទេសនោះពុំខាន ឡើយ ។ យើងជាប្រជារាស្ត្រស្លូតត្រង់ យើងមានមុខនាទីត្រឹមតែប្រកបរបរចិញ្ចឹមជីវិតដោយសុចរិត ។ កាលបើស្រុកកើតកលិយុគ យើងក៏មានទុក្ខ បើស្រុកបានសុខ យើងក៏សប្បាយ ។ “សូមកុំយកនយោបាយធ្វើជាល្បែងលេងសើច ព្រោះលោក អ៊ិន តាំ អ្នកនយោបាយខ្មែរសម័យសាធារណរដ្ឋ មានប្រសាសន៍ថា កាំភ្លើងបាញ់ចេញមួយគ្រាប់អាចសម្លាប់បានមនុស្សម្នាក់ ប៉ុន្តែ សម្តីអ្នកនយោបាយមួយម៉ាត់អាចសម្លាប់មនុស្សអស់រាប់រយរាប់ពាន់នាក់” ។

មានព្រឹកមួយ អ្នកភៀសខ្លួនមួយក្រុមបានសុំអនុញ្ញាតពីតម្រួតទៅមើលទីផ្សារបុរីរាំ ។ ខ្ញុំសុំទៅផ្សារ ដោយសារតែគេដែរ ។ ខ្ញុំដើរមើលផ្សារមួយជុំ ខ្ញុំឃើញស្ត្រីម្នាក់មានថ្នាំបាញ់កន្ទះកូនល្អី ដាក់លក់តែឯងដាច់ពីគេ ។ ខ្ញុំសូមចែកថ្នាំជក់ពីគាត់មួយបាញ់ដោយសួរអំពីតម្លៃថ្នាំនោះ ។ គាត់ឲ្យខ្ញុំត្រដាងជាយក្រមា ។ ខ្ញុំប្រកែក ព្រោះខ្ញុំត្រូវទិញថ្នាំជក់តែមួយបាញ់ទេ ។ ស្ត្រីនោះបង្ខំខ្ញុំឲ្យធ្វើតាមគាត់ ។ ខ្ញុំលាតជាយក្រមាបន្តិច ស្រាប់តែគាត់ចាក់ថ្នាំជក់កន្ទះល្អីនោះមកលើជាយក្រមារបស់ខ្ញុំ ។ ខ្ញុំភ្ញាក់នឹងកាយវិការរបស់គាត់ទើបដៃខ្ញុំលាតត្រដាងជាយក្រមាទាំងអស់ ព្រោះខ្លាចធ្វើឲ្យបាញ់ថ្នាំធ្លាក់ទៅលើដី ។ គាត់ទាញជាយក្រមារេចថ្នាំនោះឲ្យខ្ញុំ ហើយប្រាប់ថាយកទៅ! យើងជាខ្មែរដូចគ្នា កាលបើខ្មែរក្រោមមានទុក្ខ ពួកយើងខ្មែរលើត្រូវតែជួយ ។ ខ្ញុំថ្លែងអំណរគុណចំពោះស្ត្រីនោះទាំងទឹកភ្នែក ព្រោះម្យ៉ាងខ្ញុំនឹកថា ស្ត្រីនោះមានសភាពជាអ្នកក្រីក្រនៅជនបទ គាត់ឲ្យថ្នាំជក់ទាំងអស់មកខ្ញុំ តើគាត់បានប្រាក់ឯណាយកទៅផ្ទះវិញ? ម្យ៉ាងទៀតកាយវិការរបស់គាត់ ធ្វើឲ្យខ្ញុំរំភើបក្រៃលែងចំពោះទឹកចិត្តស្នេហាជាតិរបស់គាត់ ។ តើមានខ្មែរប៉ុន្មាននាក់ទៀតដែលស្រឡាញ់ជាតិ ដោយស្មោះដូចស្ត្រីរូបនោះ? ខ្ញុំសូមឧទ្ទិសសេចក្តីគោរពរបស់ខ្ញុំជូនទៅស្ត្រីដែលមានចិត្តស្មោះ ចំពោះជាតិរបស់ខ្លួននោះ ទោះខ្មែរលើ ខ្មែរកណ្តាល ខ្មែរក្រោមក្តី ។

មានថ្ងៃមួយ តុលាការសៀមបានឲ្យយកឧបករណ៍ភ្លេងជាច្រើនយ៉ាងមករក្សាទុកក្នុងមន្ទីរឃុំឃាំង ព្រោះកើតមានក្តីក្តាំងគ្នាអំពីឧបករណ៍ភ្លេងនោះ ។ យើងជាអ្នកជាប់ឃុំ ជាអ្នកមានពេលទំនេរច្រើនរមែងអផ្សុក ។ ដល់ពេលឃើញមានឧបករណ៍ភ្លេងទំនើបជាច្រើនបែបមកនៅចំពោះមុខដែលយើងខានឃើញយូរមកហើយ ក៏តាំងនាំគ្នាពាក់ពូនមកមើលវត្ថុចម្លែក ។ ដោយឃើញសភាពកុះករនៃអ្នកភៀសខ្លួននៅមុខឧបករណ៍ភ្លេង តម្រួតមន្ទីរឃុំឃាំងបានចេញមកមើលការខុសត្រូវ ។ មានមេតម្រួតម្នាក់សួរពួកយើងថា “ពួកឯងដែលស្គាល់ឧបករណ៍ទាំងអស់នេះឬទេ? មានមិត្តយើងម្នាក់ឆ្លើយថា “ស្គាល់” ។ “តើពួកឯងចេះលេងឬទេ? តម្រួតសួរបន្តទៀត ហើយមិត្តម្នាក់នោះឆ្លើយថា “ចេះ” ។ “តើឯងចង់លេងឬទេ? ចម្លើយថា “ចង់” ។ តម្រួតនោះ បានអនុញ្ញាតឲ្យអ្នកចេះលេងតន្ត្រីចូលសាកល្បងមើល ។ លេងភ្លេងបទទំនើបខ្មែរបានពីរបីបទក៏ត្រូវតម្រួតឲ្យឈប់លេងសិន ព្រោះមិនទាន់បានសុំការអនុញ្ញាតពីថ្នាក់លើ ។ ក្រោយមកបានពីរបីថ្ងៃ លោកភូឈួយខេត្ត អភិបាលរងខេត្តទីពីរ ដែលអ្នកទទួលខុសត្រូវលើពន្ធនាគារ និងមន្ទីរឃុំឃាំងរបស់ខេត្តបានអញ្ជើញមកដល់មន្ទីរឃុំឃាំងដែលពួកយើងស្នាក់នៅ ។ មានគេប្រាប់ខ្ញុំថា លោកភូឈួយមានដើមកំណើតជាខ្មែរបុរីរាំ ។ ខ្ញុំត្រេកអរណាស់ ព្រោះនឹកថា លោកភូឈួយ ដែលមានដើមកំណើតជាខ្មែរមុខនឹងជួយសម្រាលទុក្ខទោសឲ្យយើងជាពុំខាន ។ ខ្ញុំប្រញាប់ទៅសម្តែងការគោរពដឹងគុណចំពោះរូបលោកដែលអញ្ជើញមកសំណេះសំណាលជាមួយពួកយើង ។ គាត់ចេះនិយាយភាសាខ្មែរច្បាស់ ។ គាត់សួរអំពីសុខទុក្ខរបស់យើង យើងក៏និយាយសារទុក្ខជូនគាត់ស្តាប់អំពីទុក្ខលំបាកខាងផ្លូវចិត្តរបស់យើង ព្រោះនឹកស្រុក នឹកគ្រួសារដែលពុំអាចទៅមកបាន ។ ម្យ៉ាងទៀត យើងក៏បានជម្រាបគាត់ថាពួកយើង ឥតរត់លួនទៅណាទៀតទេ សូមឲ្យគាត់បន្ធូរបន្ថយការរឹតត្បិតមកលើពួកយើង ។ ដោយមកអំពីរោគអផ្សុក ដែលត្រូវឃុំឃាំងជាប់មិនអាចចេញទៅណាបានធ្វើឲ្យអ្នកភៀសខ្លួនខ្មែរម្នាក់កើតទុក្ខរហូតដល់ស្លាប់ ។

ក្រោយពីបានស្តាប់ពាក្យសារសព្វរបស់ពួកយើង លោកភូឈួយខេត្តក៏បានបន្ធូរបន្ថយការរឹតត្បិត ដោយអនុញ្ញាតឲ្យពួកយើងមានសិទ្ធិសុំច្បាប់ចេញទៅក្រៅមន្ទីរឃុំឃាំងបានអាចឲ្យពួកយើងប្រជុំគ្នាហាត់ប្រាណ ឬលេងកីឡាបាននៅទីធ្លាក្នុងមន្ទីរឃុំឃាំង ។ សេចក្តីអនុញ្ញាតចុងក្រោយ គឺឲ្យពួកយើងប្រគុំតន្ត្រីនៅល្ងាចថ្ងៃណា

មួយ គាត់នឹងអញ្ជើញមកជាអធិបតី ។ យើងសម្តែងអំណរគុណជាអនេក ជូនចំពោះករុណាធម៌របស់គាត់ ។

ថ្ងៃដែលយើងរង់ចាំបានមកដល់ គឺរាត្រីសមោលសប្រឡងចម្រៀងខ្មែររបស់ខ្មែរអពយពក្រោមអធិបតីភាពរបស់លោកភូឈួយខេត្តបុរីរាំ និងមានអ្នកមុខអ្នកការ មានមន្ត្រីមានតម្រួតចូលរួមផង ។ នៅថ្ងៃនោះ យើងមានមោទកភាពដ៏ក្រៃលែងនៅចំពោះមុខភ្ញៀវដែលមានបណ្តាស័ក្តិ ។ យើងជ្រើសរើសមេប្រយោគក្នុងចំណោមពួកយើង ។ បេក្ខជនប្រឡងក៏នៅក្នុងចំណោមយើងដែរ ។ ពិធីនេះ ប្រារព្ធនៅកន្លែងទទួលទានអាហារពេលថ្ងៃត្រង់របស់ពួកយើង ។ យើងយកតុអាហារមកតម្រៀបធ្វើវេទិកាប្រឡង ។ ភ្ញៀវកិត្តិយសអង្គុយលើកៅអីជួរខាងមុខ ។ ពួកមេប្រយោគអង្គុយលើកៅអីជួរខាងចំហៀង ឯពួកយើងអ្នកភៀសខ្លួនសាមញ្ញអង្គុយលើកៅអីជួរខាងក្រោយ ។ ភ្លេងបន្ទឺឡើងជាកិច្ចចាប់ផ្តើមកម្មវិធីប្រឡង ។ មេប្រយោគហៅឈ្មោះបេក្ខជនឡើងច្រៀងម្នាក់ម្តងៗ ។ បទចម្រៀងសុទ្ធសឹងជាបទមនោសញ្ចេតនាជ្រាលជ្រៅ ជាបទកម្សត់ ។ បេក្ខជនភាគច្រើនបានច្រៀងដល់ទីបញ្ចប់ ទោះបីជាមានសភាពអាក់រអួលខ្លះក្តី ។ មានមួយភាគទៀត ច្រៀងត្រឹមតែពាក់កណ្តាល ក៏អួលដើមកច្រៀងទៅទៀតពុំរួច ។ ក្នុងចំណោមអ្នកអួលដើមកទាំងនោះ មានអ្នកស្រែកទ្រហោយំក្រោបទចម្រៀងរបស់ខ្លួនខ្លះដែរ ។ មានបេក្ខជនម្នាក់នោះឈ្មោះ ឃ្លីន ស្រែកចម្រៀងពីដំបូងយ៉ាងពិរោះដល់ត្រង់ឃ្លាថា "បើកមុខមើលកូន" កាយវិការរបស់អ្នកចម្រៀងគឺលុតជង្គង់ម្ខាងទៅលើក្តារ ដៃលើកធ្វើជាសើយមុងឡើង ហើយឱនក្បាលចុះទាបធ្វើហាក់ដូចជាកំពុងមើលកូនដែលដេកលើកន្ទេលផ្ទាល់ដី ស្រាប់តែដួលស្រប៉ាបទៅលើក្តារ ។ ពួកមេប្រយោគកេះគ្នាថា កាយវិការធម្មជាតិដែលកម្ររកបាន ។ ភ្លេងលេងហួសវគ្គនេះហើយ បេក្ខជនក្រាបនៅស្ងៀមឥតកម្រើក ។ មេប្រយោគចាត់គ្នាឲ្យឡើងទៅមើលដល់លើវេទិកា ស្រាប់តែបេក្ខជនផ្ទារស្រទាងឡើងទធាក់ជើង ហើយស្រែកទ្រហោយំចង់ធ្វើអត្តឃាត ។ ពួកមេប្រយោគស្ទុះឡើងទៅសែងអភ័ព្វជនចុះពីលើវេទិកា ។ ឧប្បត្តិហេតុនេះ ធ្វើឲ្យទស្សនិកជនភាគច្រើនទប់ទឹកភ្នែកមិនបាន ។

រាត្រីសមោលសរបស់ខ្មែរអពយពបានបញ្ចប់ទៅទាំងទឹកភ្នែក ។ អនុស្សាវរីយ៍នៃរាត្រីនេះ ដិតដាមក្នុងដួងចិត្តនៃទស្សនិកជនគ្រប់គ្នា ។ ស្អែកឡើង កើតមានភាពជ្រួលជ្រើមរបស់ប្រជាជនដែលនៅជិតមន្ទីរឃុំឃាំង ។ គេលើកគ្នាមកសុំមេតម្រួតនៃមន្ទីរឃុំឃាំងឲ្យគេបានចូលទស្សនារាត្រីសមោលសរបស់ខ្មែរអពយពផង ។ មេតម្រួតឆ្លើយថា "គេសម្តែងឲ្យបាត់អផ្សុកតែប៉ុណ្ណោះ មិនឲ្យអ្នកក្រៅចូលមកមើលទេ" ។ អ្នកស្រុកមិនព្រមក៏ឡើងទៅតវ៉ាដល់សាលាខេត្ត ។ លោកភូឈួយខេត្តចង់រំងាប់ភាពជ្រួលជ្រើមនេះ បានបញ្ជាឲ្យពួកយើងធ្វើរាត្រីសមោលសម្តងទៀត ។ ម្តងនេះ ពួកយើងគិតថា លេងជាល្ខោនម្តង ។ លេងល្ខោនត្រូវការហាត់ក្នុងរយៈពេលយូរ ។ តម្រួតទុកពេលឲ្យយើង១០ថ្ងៃសម្រាប់ហាត់ ។ យើងហាត់ទាំងថ្ងៃទាំងយប់ ។ យើងចង់បានរបាំត្រឡោកមួយទៀតសម្រាប់បើកឆាក ។ ក្នុងចំណោមពួកយើងគ្មានអ្នកជំនាញខាងរបាំសោះ ឯល្ខោនវិញ យើងអាចលេងរឿងងាយៗទៅបាន ។ ខ្ញុំទទួលភារៈសរសេររឿងល្ខោន ។ មានយុវជនពីរបីនាក់គិតគូរពីរបាំត្រឡោក ។ មួយអាទិត្យក្រោយមក របាំត្រឡោក ឬរបាំកណ្តូបសេះរបស់អ្នកស្វាយរៀង ត្រូវបានយុវជនខ្មែរជាអ្នកភៀសខ្លួន នៅជំរំឃុំឃាំងបុរីរាំលៃលកប្រឌិតបានប្រហាក់ប្រហែលនឹងរបាំត្រឡោកមែនទែន ។ ពិតជាអស្ចារ្យណាស់ យុវជនអ្នកប្រឌិតក្បាច់របាំមួយដែលខ្លួនមិនដែលចេះសោះ បានត្រឹមតែឃើញក៏ធ្វើឲ្យកើតជារូបរាងពិតប្រាកដមួយបានដែលអាចបន្ទំភ្នែកទស្សនិកជនបរទេសរហូតដល់ទទួលបានជោគជ័យគួរជាទីពេញចិត្ត ។ នេះពិតជាទេពកោសល្យពីធម្មជាតិដែលខ្មែរគ្រប់រូបមានក្នុងវិស័យសិល្បៈរបស់ជាតិ និងជាកេរ្តិ៍របស់ដូនតាខ្មែរ ។ ឯរឿងល្ខោន ខ្លួនខ្ញុំក៏ពុំមែនជាអ្នកនិពន្ធ ឬក៏បានសិក្សាវិជ្ជាសម្តែងនៅវិទ្យាល័យក្នុងឱកាសមុនចូលឆ្នាំជាតិជារៀងរាល់ឆ្នាំ ។ ឥឡូវនេះ ពួកយើងអាចសម្តែងបានហើយ ។ យើងបានធ្វើការសាកល្បងបង្ហាញទស្សនីយភាពទាំងមូលឃើញថា អាចយកជាការបាន ។ ពួកយើងគ្មានប្រដាប់ប្រដារសម្រាប់សម្តែងសិល្បៈអ្វីទាំងអស់ ក្រៅពីឧបករណ៍ភ្លេងតម្រួតឲ្យខ្ចី ។ សម្លៀកបំពាក់ យើងមានតែមួយចង្កេះ ។ ដេកដើរឈរអង្គុយហូប យើងស្លៀកពាក់តែដដែលជាខោអាវដែលយើងយកជាប់តាមខ្លួនពីស្រុកយើងមក ។ មានអាវខៀវសម្រាប់អ្នកទោសខ្លះដែរ ដែលសល់ពីពេលមុន ។

ថ្ងៃណាត់សម្រាប់សម្តែងបង្ហាញពីទស្សនីយភាពសិល្បៈ

របស់ពួកយើងបានមកដល់ហើយ ។ យើងជូតទឹកសម្អាតកាយ ដោយផ្ចិតផ្ចង់ ទោះបីគ្មានសប៊ូក៏ដោយ ។ ឆាកដែលយើងរៀបទុកតាំងពីម្សិលមិញ ដោយយកតុបាយមកផ្គុំគ្នា ត្រូវបានលម្អដោយស្លឹកឈើដែលយើងសុំទៅកាប់យកមកពីក្រោមមន្ទីរឃុំឃាំងយ៉ាងកកកុញ ។ មន្ត្រីទទួលមើលការខុសត្រូវក្នុងមន្ទីរឃុំឃាំងត្រូវការកម្លាំងតម្រួតបន្ថែមទៀត ។ ពួកយើងមានចិត្តរំភើប ចំពោះភាពអធិកអធមដែលនឹកស្មានមិនដល់នេះ ព្រមទាំងលាយឡំ ដោយសេចក្តីបារម្ភចំពោះគុណភាពនៃការសម្តែងរបស់ពួកយើង ។ យើងបន់ស្រន់ក្នុងពោះចំពោះព្រលឹងដូនតាខ្មែរឲ្យមកសណ្ឋិតក្នុងខ្លួនប្រាណយើងឲ្យបានខ្លាំងក្លា ដើម្បីឲ្យការសម្តែងរបស់យើងទទួលបានជោគជ័យ នៅចំពោះមុខទស្សនិកជនសៀម ដែលមានដើមកំណើតជាខ្មែរចេះស្តាប់និងនិយាយភាសាខ្មែរ នៅលើទឹកដីខេត្តបូរីរុំនេះ ។ យើងស្រូតរូតបរិភោគបាយ និងទឹកប្រហុកត្រប់ស្រួយដូចសព្វដង ។ យើងលេបបាយស្ទើរតែពុំរួច ព្រោះឃើញមនុស្សមកអ៊ូអរដែលនាំឲ្យយើងនឹកដល់គ្រួសារ នឹកដល់បងប្អូនឯស្រុក ។ កាលពីស្រុកយើងមិនទាន់មានសង្គ្រាម យើងក៏ធ្លាប់នាំគ្នាឈូឆរទៅមើលល្ខោនដែលមកសម្តែងនៅក្នុងភូមិយើងម្តងៗដូចគ្នានេះដែរ ។

ការសម្តែងរបស់យើងចាប់ផ្តើមហើយ ។ ឆាករបស់យើងគ្មានវាំងននបិទបើកទេ ។ អ្នកសម្តែងត្រូវឡើងពីក្រោមឆាកទៅ ។ ភ្លេងរបាំត្រឡោកចាប់ផ្តើមភ្លាម នាដករសុទ្ធតែប្រុសៗស្លៀកពាក់ឯកសណ្ឋានរបស់អ្នកទោសហក់លោតចាក់ក្បាច់យ៉ាងសង្ហា ។ ត្រឡោកគោះគ្នាលាន់ឮរណ្តំតាមចង្វាក់ភ្លេង គឺពិតជាទស្សនីយភាពមួយក៏រស់រវើកបីដូចបក្សាបក្សីទាំងគូៗប្រដេញប្រចឹកគ្នាលេងជាជួរ នៅលើឆាកគួរឲ្យគយគន់មិនដាក់ភ្នែក ក្រោមពន្លឺភ្លើងអគ្គិសនីមិនសូវច្បាស់ ។ គ្រាន់តែរបាំចប់ភ្លាម សំឡេងទះដៃ និងសម្រែកជយឃោសលាន់ឮខ្ទរខ្ទារពេញរោងបាយ ។ នាដករជាអ្នកសម្តែងមានចិត្តរំភើបដល់ហូរទឹកភ្នែកដោយមិនដឹងខ្លួន ។ យើងទុកចន្លោះពេលសម្រាកប្រមាណ១៥នាទី ។

ដល់វេនល្ខោនសម័យទំនើបម្តង ។ បែបផែនរបស់ទម្រង់ល្ខោននេះ តួម្នាក់ៗឥតនិយាយស្តីទេ គ្រាន់តែមានកាយវិការ និងទឹកមុខទៅតាមសាច់រឿង ។ ឥឡូវនេះ សំឡេងខ្លុយបន្លឺយ៉ាងគ្រលួចកាត់បរិយាកាសស្ងាត់ជ្រងំនៃសាលសម្តែង ។ សំឡេងពោលឮសូរគ្រលរល្វើយៗកំពុងតែរៀបរាប់អំពីអតីតកាលដ៏រុងរឿងរបស់ប្រទេសកម្ពុជា ។ គឺជាប្រទេសដែលសម្បូរភោគផលធម្មជាតិ មានព្រែក មានស្ទឹង បឹង ទន្លេ សមុទ្រ សម្បូរត្រី មានដីសម្បូរជីជាតិ មានភ្នំ មានព្រៃ ឈើដ៏មានតម្លៃ មានរ៉ែគ្រប់ប្រភេទ ជាប្រទេសកសិកម្មផង ឧស្សាហកម្មផង ដែលជំរុញឲ្យមានពាណិជ្ជកម្មមមាញឹក ។ ប្រជាជនសម្បូរទ្រព្យធនឥតដែលខ្វះអ្វី រស់នៅសុខដុមរមនា មានសាមគ្គីរស់ ហើយអភិវឌ្ឍន៍ប្រទេសឲ្យរីកចម្រើនរុងរឿង ។ ប៉ុន្តែឥឡូវខ្មែរយកគ្នាជាសឹកសត្រូវព្រោះតែមនោគមន៍វិជ្ជាបរទេស ។ ភ្លើងសង្គ្រាមឆាបឆេះសន្ធោរសន្ធៅពេញប្រទេស ឆេះអ្វីៗទាំងអស់ ខ្មែរស្គាល់ហាយនភាពនៅពេលនេះហើយ ។ ដើម្បីរស់ខ្មែររត់ទៅពឹងពាក់ស្នាក់អាស្រ័យនៅប្រទេសជិតខាង ។ សំឡេងពោលចាប់ផ្តើមឡើង នាដករ នាដការ ដើរឡើងទៅលើឆាកដៃកាន់សម្ភារផ្សេងៗសម្រាប់ការងារប្រចាំថ្ងៃមានចប បង្គី ចង្អេរ សម្រាប់អុំអង្ករហាត់រវៃអំបោះ ដើរដង្ហែគ្នាតាមចង្វាក់ភ្លេងបទរាត្រីស្រុកខ្មែរ ។ ដើរបានមួយជុំរកកន្លែងអង្គុយធ្វើការរៀងៗខ្លួនដោយកាយវិការរស់រវើកនិងរីករាយ ។ បន្ទាប់ពីការសម្តែងនេះទៅទុកភារៈឲ្យអ្នកចម្រៀងស្រែកច្រៀងពីក្រោមឆាក ហើយឡើងមកលើឆាកនូវបទកម្សត់អំពីការព្រាត់ប្រាសនិរាសគ្នា ។ នៅចុងបញ្ចប់ឲ្យអ្នកចម្រៀងម្នាក់ទៀតឡើងច្រៀងបទមនោសញ្ចេតនាដ៏ពិរោះមួយបទទៀត ។ ពេលចម្រៀងចប់ហើយ ឲ្យតន្ត្រីករប្រគុំបទសាយ៉ូណារ៉ា នាដករទាំងអស់ឡើងលើឆាកសំពះគោរពលាភ្ញៀវ ។ រាត្រីស្រមោលសបានបញ្ចប់ក្នុងបរិយាកាសប្រកបដោយមិត្តភាព និងភាតរភាពដ៏ជ្រាលជ្រៅ ។ អនុស្សាវរីយ៍នៃជោគជ័យខាងផ្នែកសិល្បៈរបស់យើងបានដក់ជាប់ក្នុងដួងចិត្តយើងគ្រប់គ្នា ។

ស្អែកឡើង តម្រួតនាំមន្ត្រីជានារីពីរបីនាក់មកពីមន្ទីរសិល្បៈរបស់ខេត្តបូរីរុំ មកធ្វើសម្ភាសន៍ជាមួយនាដកររបាំត្រឡោក ។ គេមកកត់ត្រាក្បាច់របាំពីមួយវគ្គទៅមួយវគ្គ ។ គេឲ្យយើងធ្វើបង្ហាញ ។ យើងប្រាប់គេថា របាំនេះ គឺយើងប្រឌិតតាមការចងចាំរបស់ពួកយើង ពុំបានត្រឹមត្រូវតាមរបាំត្រឡោកពិតប្រាកដនោះទេ ។ គេចាប់អារម្មណ៍ខ្លាំងលើរបាំប្រឌិតរបស់យើងនេះ ។

មួយអាទិត្យក្រោយមក តម្រួតបាននាំដំណឹងមកឲ្យយើងថា ក្រុមទូរទស្សន៍នៅក្រុងថេប (បាងកក) ដែលជារបស់រាជវង្សចង់

ឲ្យពួកយើងទៅសម្តែងនៅសាលមហោស្រពខេត្តបូរីរាំ ហើយ គេនឹងមកថតយកទៅបញ្ចាំងឲ្យប្រជាជនសៀមបានមើលទូទាំងប្រទេស ។ ពួកយើងពុំព្រងើយកន្តើយនឹងព្រឹត្តិការណ៍ដែលនឹងមកដល់នៅពេលខាងមុខ ។ យើងខំហាត់សមម្តងហើយម្តងទៀត ជារៀងរាល់ថ្ងៃ ។

ថ្ងៃណាត់បានមកដល់ ។ គេយករថយន្តមកដឹកនាដកររបស់យើងតាំងពីរសៀល ។ យើងទៅដល់សាលមហោស្រពដ៏ធំល្វឹងល្វើយក្នុងសម្លៀកបំពាក់របស់អ្នកទោស ។ គេឲ្យយើងហាត់សមបន្តិចបន្តួចនៅខាងមុខឆាក ។ ប្រមាណម៉ោង៧ព្រលប់ កម្មវិធីមហោស្រពចាប់ផ្តើម ។ ពីដំបូង ក្រោមភ្លើងពណ៌ចម្រុះ បាំងបិទដោយវាំងននធ្វើអំពីកំណាត់ព្រែគ្រប់ពណ៌ អ្នកចម្រៀងប្រុសក៏ល្បីល្បាញមកពីក្រុងបាងកក ឡើងច្រៀងចម្រៀងមនោសញ្ចេតនាដោយសំឡេងក្រអួន ។ បទចម្រៀងទីមួយបានរស្វាត់បាត់ទៅ សំឡេងនារីតូចឆ្មារគ្រលួចបានមកអង្រួនអារម្មណ៍របស់យើងបន្តទៀត ។ បន្ទាប់មក ទើបមកដល់របាំត្រឡោក និងល្ខោនរបស់យើង ។ ជាថ្មីទៀត ជោគជ័យដ៏មហិមារបស់នាដករយើង ធ្វើឲ្យកក្រើកទីក្រុងបូរីរាំ ។ សមាជិករាជវង្សមួយអង្គឡើងប្រថាប់ ហើយទះព្រះហស្តអបអរសម្តែងការសព្វព្រះទ័យនឹងរបាំរបស់យើង ។ លោកមានបន្ទូលថា ចាំឲ្យពួកយើងទៅសម្តែងនៅក្រុងបាងកក ។ បន្ទាប់ពីរបាំ របស់យើងទៅមាននារីជាជនជាតិថៃដាំ (ជនជាតិភាគតិចលាវ) ពីរនាក់ឡើងច្រៀងបទ "សុិបហាពី" ជាខ្មែរថា "ចុកក្នុងទ្រូង" ដ៏ក្រអៅលន្លង់លន្លោច ។ គេដឹកពួកយើងឲ្យត្រឡប់មកមន្ទីរឃុំឃាំងវិញ ទាំងកម្មវិធីពុំទាន់ចប់ផងទេ ។ គេឲ្យយើងមកបរិភោគអាហារប្រចាំថ្ងៃរបស់យើងដដែល ។ នេះហើយដែលធ្វើឲ្យពួកយើងឆ្អែតចិត្តក្រៃលែង ។ ស្អែកឡើងគេយករូបថតរបស់ពួកយើង មកលក់ក្នុងមួយសន្លឹក៥បាត ឲ្យយើងទៀត ។ ពួកយើងភាគច្រើនពុំមានប្រាក់ទិញរូបថតដ៏មានន័យទាំងនោះទេ ។ មួយអាទិត្យក្រោយមកទៀត ពួកមន្ត្រីមួយក្រុមរបស់សាលាខេត្តបូរីរាំមកហៅយើងច្រើនគ្នាឲ្យទៅជាមួយពួកគេ ដើម្បីដើរឃោសនាប្រាប់ប្រជាជនសៀមអំពីអំពើសាហាវយង់ឃ្នងរបស់ពួកខ្មែរក្រហម ។ នៅពេលបន្ទាប់មកទៀត ខ្ញុំឮថារដ្ឋាភិបាលថៃព្រមព្រៀងជាមួយរដ្ឋាភិបាលក្រុងប៉េកាំង ដើម្បីឲ្យរដ្ឋាភិបាលចិន ដឹកអាវុធកាត់តាមប្រទេសថៃមកផ្គត់ផ្គង់ឲ្យកងទ័ពខ្មែរក្រហមដែលកំពុងប្រយុទ្ធល់ជាមួយកងទ័ពវៀតណាមឯព្រំដែនខ្មែរ-យៀកណាម ជាថ្នូរនឹងការឈប់ទ្រទ្រង់របស់រដ្ឋាភិបាលចិនចំពោះចលនាកុម្មុយនីស្តថៃ ។ ប្រហែលដោយហេតុនេះហើយ បានជាចលនាកុម្មុយនីស្តសៀមបាត់បង់ឥទ្ធិពលតាំងពីពេលនោះមក ។

មានព្រឹកមួយ ទាហានមួយរថយន្ត ហ្វេ.អុឹម.សេ បើកចូលមកក្នុងជំរំរបស់យើង គឺជាព្រឹត្តិការណ៍ដ៏ចម្លែកដែលពួកយើងមិនដែលបានឃើញក្នុងពេលកន្លងមក ។ មេរបស់ពួកគេចុះពីលើរថយន្ត ហើយស្រែកប្រកាសរកអ្នកស្ម័គ្រចិត្តទៅព្រំដែនខ្មែរ ដើម្បីធ្វើបន្ទាយសម្រាប់ច្បាំងជាមួយខ្មែរក្រហម ។ ខ្ញុំចេញទៅជួប ហើយនិយាយថា យើងស្ម័គ្រចិត្តទៅទាំងអស់គ្នា ។ យើងចង់ទៅជាមួយគ្នាទាំងអស់តែម្តង បើមិនបាន ដូច្នេះទេ យើងពុំអាចទៅបែកគ្នាបានទេ ។ មេទាហានម្នាក់នោះឆ្លើយថា គេពុំអាចយកទៅម្តងទាំងអស់ទេ គឺយកម្តងបួនដប់នាក់ៗ ។ ស្រាប់តែទាហាននៅលើរថយន្តចុះមកដីទាំងអស់គ្នា ហើយអូសដៃយុវជនយើងចំនួនប្រាំពីរនាក់ឡើងទៅលើរថយន្ត ហើយបើកចេញទៅ ។ ពួកយើងឆ្ងេឆ្ងា ហើយពិគ្រោះយោបល់គ្នា ដើម្បីតវ៉ាចំពោះការរំលោភសិទ្ធិរបស់ពួកយើងពីសំណាក់ទាហានសៀម ។ យើងចង់បានគ្នាយើងទាំងប្រាំពីរនាក់ដែលពួកវាចាប់មកវិញ ។ ឧបទ្ទវហេតុដែលពួកទាហានសៀមធ្វើមកលើពួកយើងជាកាយវិការដ៏កំសាក និងព្រៃផ្សៃ ព្រោះជាទង្វើឆក់កណ្តៀតមិនឲ្យពួកយើងដឹងជាមុន ។ ចាប់ពីពេលនោះមក ពួកយើងប្រុងប្រៀបពួតកម្លាំងគ្នាតទល់ជាមួយពួកវាគ្រប់ឱកាស ។ ពួកវាពុំអាចប្រព្រឹត្តមកលើពួកយើងបានស្រួលដូចលើកមុនទៀតទេ ។ ចំណែកខ្ញុំ ខ្ញុំលបលាក់សរសេរសំបុត្រជាភាសាបារាំងផ្ញើទៅស្ថានទូតបារាំងនិងផ្ញើទៅទីស្នាក់ការអង្គការសហប្រជាជាតិនៅក្រុងបាងកកដូចគ្នា ។ ខ្ញុំប្រើក្មេងម្នាក់ដែលអាចចេញពីជំរុំឃុំឃាំងបានដោយមិនឲ្យតម្រួតចាប់អារម្មណ៍ ។ ក្មេងនេះ ធ្លាប់ចេញពីជំរុំដើម្បីទៅទិញកាហ្វេ ឬវត្ថុផ្សេងៗឲ្យពួកតម្រួត ។ ខ្ញុំពុំមានប្រាក់ទិញតែមបិទសំបុត្រ ហើយក៏មិនហ៊ានសួររកប្រាក់ពីអ្នកដទៃដែរ ពីព្រោះ ខ្លាចបែកការណ៍ ។

រំលងបានមួយថ្ងៃ ព្រឹកឡើងបុគ្គលិក និងភ្នាក់ងារអន្តរជាតិមកដល់មុខជំរុំឃុំឃាំងព្រោងព្រាត ។ មានតំណាងស្ថានទូតបារាំង តំណាងកាកបាទក្រហមអន្តរជាតិ តំណាងអង្គការសិទ្ធិមនុស្សអន្តរជាតិ និងអង្គការផ្សេងៗទៀត ដែលខ្ញុំមិនចាំឈ្មោះ ។ ពួកតម្រួតប្រចាំការនៅជំរុំឃុំឃាំងមិនអនុញ្ញាតឲ្យពួកអង្គការទាំងនោះចូល

មកក្នុងជំរុំទេ ។ គេទាមទារឲ្យមានការអនុញ្ញាតពីក្រសួងមហាតថៃ (មហាផ្ទៃ) ។ ទម្រាំបានចូលមកក្នុងជំរំ បុគ្គលិក ឬភ្នាក់ងារអង្គការទាំងនោះប្រឹងស្ទុះស្ទារអស់មួយព្រឹកធំ ។ អង្គការធ្វើកំណត់ហេតុតាមសម្ភាសរបស់យើង ។ តាំងពីពេលនោះមក អង្គការអន្តរជាតិនានាចាត់គ្នីគ្នាឲ្យមកជំរំជារៀងរាល់ថ្ងៃទៅតាមវេន ដើម្បីការពារជនភៀសខ្លួនកុំឲ្យមានការចាប់បង្ខំជាថ្មីទៀត ។

បរិយាកាសនៅក្នុងជំរំឃុំឃាំងបូរីរាំមានសភាពអ៊ូអែជាងសព្វដង ព្រោះមានអង្គការអន្តរជាតិចេញចូលរាល់ថ្ងៃ មានការចែកអំណោយបន្តិចបន្តួចតាមសំណើរបស់អ្នកភៀសខ្លួន ។ ពួកយើងរក្សាស្ថានភាពប្រុងប្រយ័ត្នជាប់ជានិច្ច សម្រាប់តទល់ជាមួយកងកម្លាំងដែលអាចមកចាប់បង្ខំពួកយើងដូចថ្ងៃមុនជាយថាហេតុ ។ ក្នុងរយៈពេលនោះ មានអ្នកភៀសខ្លួនខ្មែរពីរបីនាក់ទៀតទើបត្រូវបានគេបញ្ជូនមកដល់ជំរំ ។ នៅពេលស្គាល់អ្នកភៀសខ្លួនថ្មីនោះ បានរៀបរាប់ប្រាប់ពួកយើងអំពីកលល្បិចដ៏អាក្រក់របស់កងកម្លាំងសៀម ដែលបានបោកប្រាស់ពួកគាត់ដែលនៅក្នុងជំរំឲ្យទៅកាប់ឈើនៅជិតព្រំដែនខ្មែរថា ដើម្បីធ្វើបន្ទាយសម្រាប់តស៊ូជាមួយពួកខ្មែរក្រហម ។

**(តទៅលេខក្រោយ)**

**ផា សីហា**

# ខ្សែភាពយន្តឯកសាររឿង «ក្បង់ទឹកទន្លេ»

“ក្បង់ទឹកទន្លេ” គឺជាខ្សែភាពយន្តឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលទទួលបានការគាំទ្រ និងឧបត្ថម្ភការពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។ មកដល់ពេលនេះ ខ្សែភាពយន្ត “ក្បង់ទឹកទន្លេ” ទទួលបានពានរង្វាន់លំដាប់ពិភពលោកចំនួន១៦ហើយ ។ “ក្បង់ទឹកទន្លេ” បង្ហាញនូវដំណើរជីវិតមួយដ៏វិសេសវិសាល និងមិនធ្លាប់មានពីមុនមក ដែលផ្តើមចេញពីតំបន់ជនបទ ចុងកាត់មាត់ញកព្រៃភ្នំ និងភូមិនេសាទនៅលើផ្ទៃទឹករបស់តួអង្គទាំងបី ។ ខ្សែភាពយន្តនេះបានចាក់បញ្ចាំងនៅសារមន្ទីរសិល្បៈទំនើប សហរដ្ឋអាមេរិក ចាប់ពីថ្ងៃទី១២ ដល់ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ និងប្រទេសអូទ្រីស ប៊ែលហ្ស៊ិក អាល្លឺម៉ង់ កូរ៉េខាងត្បូង អ៊ីតាលី អង់គ្លេស និងប្រទេសសិង្ហបុរី ។ ខ្សែភាពយន្តឯកសារនេះ ក៏គ្រោងនឹងដាក់បញ្ចាំងតាមសាកលវិទ្យាល័យ និងភូមិចំនួន៦០ ទូទាំងប្រទេសកម្ពុជា ដើម្បីបើកឲ្យមានការពិភាក្សាស្តីពីការផ្លាស់ប្តូរបរិស្ថាន ដើម្បីស្វែងរកដំណោះស្រាយ ។

ខ្សែភាពយន្តនេះក៏មានចាក់បញ្ចាំងជូនទស្សនារៀងរាល់ថ្ងៃសុក្រនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។

ព័ត៌មានបន្ថែមសូមទាក់ទង កញ្ញា សា ហ្វាទីលី តាមរយៈទូរស័ព្ទលេខ : ០១២ ៥១១ ៩១៨ ។

អ៊ីម៉ែល : truthfatily.s@dccam.org គេហទំព័រ : www.ariverchangescourse.com





# ដំណើរជីវិតឪពុកខ្ញុំចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥


ឪពុករបស់នារីរតន៍ គី ស្រេង

របបកម្ពុជាប្រជាធិបតេយ្យនៅចន្លោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ គឺជារបបមួយដ៏ឃោរឃៅអមនុស្សធម៌ជាទីបំផុត ។ ប្រជាជនខ្មែរជាងពីរលាននាក់ បានបាត់បង់ជីវិតដោយការធ្វើទារុណកម្ម ការបង្ខំឲ្យធ្វើការជាទម្ងន់ ការអត់ឃ្លាន ជំងឺ និងការសម្លាប់ពីសំណាក់ខ្មែរក្រហម ។ រឿងរ៉ាវទុក្ខវេទនាទាំងឡាយដែលបានកើតឡើងក្នុងរបបខ្មែរក្រហម នៅតែដិតដាមជាប់ជានិច្ចនៅក្នុងចិត្តរបស់ជនរងគ្រោះដែលរួចរស់ជីវិតពីរបបឃោរឃៅមួយនេះ ។ តួយ៉ាងដូចជាឪពុករបស់ខ្ញុំ ក៏ជាជនរងគ្រោះម្នាក់ក្នុងចំណោមជនរងគ្រោះរាប់ពាន់នាក់ផ្សេងទៀត ដែលមានវាសនារួចជីវិតពីរបបខ្មែរក្រហម ។ គាត់ធ្លាប់បានឆ្លងកាត់ និងបានឃើញផ្ទាល់ភ្នែកនូវរឿងរ៉ាវដ៏គួរឲ្យរន្ធត់ជាច្រើនដែលបានកើតឡើងក្រោមការគ្រប់គ្រងរបស់សរបបនេះ ។

ឪពុករបស់ខ្ញុំកើតនៅឆ្នាំ១៩៤៨ នៅភូមិកោះតូច ឃុំពាមជីកង ស្រុកកងមាស ខេត្តកំពង់ចាម ។ សព្វថ្ងៃនេះ គាត់បានចូលនិវត្តន៍ និងមានទីលំនៅបច្ចុប្បន្ននៅភូមិសុវណ្ណសាគរ សង្កាត់កំពង់កណ្ដាល ក្រុងកំពត ខេត្តកំពត ។ ជារឿយៗឪពុកខ្ញុំតែងតែរៀបរាប់ពីដំណើរជីវិតដែលគាត់បានឆ្លងកាត់នៅក្នុងសម័យខ្មែរក្រហម ប្រាប់កូនៗ ឲ្យបានដឹងពីទុក្ខលំបាក និងការតស៊ូដើម្បីរស់ និងត្រូវចង ចាំទុកជាមេរៀនកុំឲ្យជានប្រវត្តិសាស្ត្រនេះវិលមកជាថ្មី ។ រឿងរ៉ាវជាច្រើន ដែលគាត់លើកមកនិយាយ ប្រាប់ខ្ញុំជាកូនៗ អំពីខ្សែជីវិតរបស់គាត់ក្នុងរបបខ្មែរក្រហម ។

មុនឆ្នាំ១៩៧៥ គាត់បានមកភ្នំពេញដើម្បីបើកអាជីវកម្មជាមួយបងប្រុសជីដូនមួយ នៅមុំទឹកថ្លា លុះធ្វើបានមួយរយៈគាត់ក៏បានចូលបម្រើក្នុងជួរទ័ព លន់ នល់ ។

ល្ងាចថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៧៥ យោធាខ្មែរក្រហមវាយសន្ធាប់យ៉ាងខ្លាំងមកលើទាហាន លន់ នល់ ហើយនៅម៉ោងប្រមាណ៧យប់ ពួកប៉ារា បាននាំគ្នាដកថយពីទីតាំងខាងមុខវាលយន្តហោះពោធិ៍ចិនតុង មកដាក់ខ្សែត្រៀមនៅតាមទំនប់ទឹកថ្លានេះ ។ ទន្ទឹមនឹងការវាយសម្រុករបស់ខ្មែរក្រហម ទាហានលន់ នល់ភាគច្រើនបាក់ទ័ពរត់ចោលខ្សែត្រៀមយកតែប្រាសអាយុរៀងៗខ្លួន ។ តាមការឲ្យដឹងពីឪពុកខ្ញុំ ទាហានទាំងនោះបាក់ទឹកចិត្តដោយសារមេកើយបាននាំគ្នារត់ចោលកូនចៅ អ្នកខ្លះភៀសខ្លួនតាមឧទ្ធម្ភាគចក្រទៅប្រទេសថៃ ។ ឪពុកខ្ញុំ គឺជាទ័ពអាកាសដែលឈរជើងជាប់ព្រលានយន្តហោះពោធិ៍ចិនតុង (គាត់ឈរជើងនៅទីនោះពីឆ្នាំ១៩៧១-១៩៧៥) ។ នៅម៉ោង៥ល្ងាច កងអនុសេនាតូចរបស់ឪពុកខ្ញុំបានសម្រេចចិត្តរំសាយ ហើយវិលទៅរកគ្រួសាររៀងៗខ្លួន ។ នៅព្រឹកថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ឪពុកខ្ញុំបានធ្វើដំណើរជិះកង់ជាមួយនឹងអីវ៉ាន់មួយចំនួនឆ្ពោះទៅផ្ទះបងប្រុសរបស់គាត់នៅតាមបណ្ដោយផ្លូវកម្ពុជាក្រោម ។ នៅតាមផ្លូវធ្វើដំណើរ គាត់បានឃើញសាកសពជាទាហាន លន់ នល់ ជាច្រើនស្លាប់នៅប្របមាត់ផ្លូវ ។

នៅម៉ោងប្រហែល៩ព្រឹក ឪពុកខ្ញុំបានឃើញទាហានខាងលន់ លន់ កំពុងចរចាជាមួយយោធា ខ្មែរក្រហមដែលវាយចូលមកដល់ក្រុងភ្នំពេញ ។ មួយសន្ទុះក្រោយមក គាត់ឃើញឡានទាហានលន់ នល់ ត្រឡប់ចូលទីក្រុងវិញ ដោយបើកពីមុខឡានរបស់យោធាខ្មែរក្រហម ដែលជាសញ្ញាណនៃការទម្លាក់អាវុធចុះចាញ់ ។ ស្របពេលនោះ ក៏មានការប្រកាសពីការរំដោះបានទីក្រុងភ្នំពេញទាំងស្រុងរបស់ខ្មែរក្រហម ហើយប្រជាជនបានចេញមកស្វាគមន៍ចំពោះវត្តមាន និងជ័យជម្នះរបស់យុទ្ធមិត្តយើង ដោយក្ដីត្រេកអរ ។ ប្រជាជនម្នាក់ៗ រួមទាំងឪពុករបស់ខ្ញុំមានសេចក្ដីរីករាយខ្លាំងណាស់ ព្រោះម្នាក់ៗគិតថា ចាប់តាំងពីពេលនេះទៅ ប្រទេសរបស់យើងបានសន្តិភាព និងឈប់មានសង្គ្រាមទៀតហើយ ។

ភាពសប្បាយរីករាយ ដែលពោរពេញដោយក្តីសង្ឃឹម បានប្រែក្លាយជាភាពអស់សង្ឃឹម និងភាពភ័យខ្លាចបន្ទាប់ពីព្រឹត្តការបញ្ជាក់ពីសំណាក់យុទ្ធមិត្តយើង ឲ្យប្រជាជនទាំងអស់ចាកចេញពីផ្ទះបីថ្ងៃសិនជាបន្ទាន់ ក្រោមហេតុផលថា បោសសម្អាតខ្មាំង និងការពារប្រជាជនពីការទម្លាក់គ្រាប់បែករបស់អាមេរិកាំង ។ មិនខុសពីប្រជាជនដទៃទៀត ឪពុកខ្ញុំ និងបងប្រុស ព្រមជាមួយនឹងក្មួយ៤នាក់ទៀត ត្រូវជម្លៀសដោយបង្ខំចេញពីផ្ទះ ។ គាត់ និងសមាជិកគ្រួសារបានធ្វើដំណើរមកដល់ និងសម្រាកនៅអន្លង់ក្ងាន នៅផ្ទះមួយដែលម្ចាស់ផ្ទះបានចាកចេញទៅហើយ ។ ពេលកំពុងសម្រាក គាត់បាននឹកឃើញដល់ពេលដែលគាត់ស្តាប់វិទ្យុប៉េកាំង បានផ្សាយថា «កាលណាកងទ័ពរំដោះវ៉ៃឈ្នះរបបគ្រប់គ្រងលន់ នល់ ក្រដាសប្រាក់របស់ លន់ នល់ ត្រូវបានបញ្ចប់ឥតយកមកប្រើប្រាស់ជាផ្លូវការឡើយ» ។ ពេលនោះ ឪពុកខ្ញុំគាត់សល់ក្រដាសប្រាក់ លន់ នល់ មួយចំនួន ដោយពេលនោះ នៅចាយវាយបាននៅឡើយ គាត់ក៏លុយទាំងនោះ ដើរទិញម្ហូបសម្រាប់ជាស្បៀងធ្វើដំណើរទាំងអស់ ។ ដោយឡែកបងប្រុសរបស់គាត់ នៅតែមិនជឿនូវអ្វីដែលឪពុកខ្ញុំបានប្រាប់គាត់ទេ ហើយគាត់នៅតែរក្សាទុកលុយទាំងនោះដដែល ដោយគាត់ប្រាប់ថា ពេលទៅដល់ស្រុកកំណើតខ្លាចអត់មានប្រាក់សម្រាប់ចាយ ។

ការធ្វើដំណើរនៅពេលនោះ ពិតជាលំបាកខ្លាំងណាស់សម្រាប់ឪពុកខ្ញុំ ព្រោះគាត់ត្រូវមើលក្មួយៗដែលនៅក្មេង រួមនឹងបងប្រុសពិការទៀតផង ហើយនឹងត្រូវអូសកង់ដែលផ្ទុកអីវ៉ាន់ពេញ ។ គាត់ទាំងអស់គ្នាបានធ្វើដំណើរទៅទិសខាងជើង តាមផ្លូវព្រែកព្នៅ ។ ពេលកំពុងធ្វើដំណើរ ជាចៃដន្យ គាត់ទាំងអស់គ្នាបានជួបនឹងអ៊ីចំណាស់ម្នាក់ ស្លៀកខោចែវពណ៌ខ្មៅ ពាក់អាវខ្មៅដៃវែងកម្ពូល និងបង់កក្រមាផង បានដើរមកកាន់ឪពុកខ្ញុំហើយប្រាប់ថា «ក្មួយចាំទុកកង់ប្រវត្តិសាស្ត្រវិលហើយ ឥតត្រឡប់ក្រោយទេបើអ្នកធ្វើឲ្យស្ទះកង់ប្រវត្តិសាស្ត្រ អ្នកនោះត្រូវតែទទួលខុសត្រូវចំពោះមុខអង្គការបដិវត្តន៍» ។

បន្តដំណើរមកដល់ស្រុកពញាឮ ក្បែរស្ពានពានសេដ្ឋា អ្នកជម្លៀសទាំងអស់ត្រូវអង្គការឲ្យសម្រាកនៅទីនោះមួយយប់ ដើម្បីចាំស្រឡាងដែលនឹងមកទទួលនៅព្រឹកស្អែក ។ ស្អែកឡើងត្រូវនឹងថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៧៥ បន្ទាប់ពីហូបអាហារពេលព្រឹករួច អង្គការឲ្យអ្នកជម្លៀសទាំងអស់ឡើងលើស្រឡាងដែលចាំជាស្រេចនៅមាត់ច្រាំងដើម្បីឆ្លងទៅត្រើយខាងជើងសំដៅទៅកំពង់ចាម ។ ស្រឡាងដល់ច្រាំង អង្គការបានប្រកាសហៅប្រជាជនទាំងអស់ទៅបើករបបអង្ករ និងស្រូតធ្វើដំណើរបន្តទៀត ។ អង្គការក៏បានប្រកាសថែមទៀតថា «សូមឲ្យបងប្អូនអ្នកជម្លៀសទាំងអស់កុំសង្ឃឹមថានឹងបានត្រឡប់ក្រោយវិញអី ហើយក្រដាសប្រាក់ លន់ នល់ ដែលបងប្អូនយកមកតាមខ្លួនក៏គ្មានតម្លៃអ្វីទៀតដែរ ពីព្រោះនៅតំបន់រំដោះប្រជាជនត្រូវធ្វើការរួមជាក្រុមសាមគ្គី ចែកភោគផលគ្នារស់ ឥតមានអ្នកមាន អ្នកក្រ គឺស្មើៗគ្នា» ។ គ្មានការតវ៉ាអ្វីទាំងអស់នៅពេលនោះ គឺម្នាក់ៗស្រូតបើករបប និងរៀបចំដាំបាយហូប ដើម្បីស្រូតធ្វើដំណើរទៅមុខបន្តតាមទិសរបស់អង្គការ ។ នៅរសៀលបន្តិច ឪពុកខ្ញុំ និងសមាជិក៦ទៀត បានធ្វើដំណើរមកដល់ជើងភ្នំបាធាយ ក្នុងស្រុកជើងព្រៃ ដែលជាប់នឹងផ្លូវជាតិលេខ៦ ។ ភ្នំបាធាយ គឺជាស្នាក់ការរបស់យោធាខ្មែរក្រហមដែលបានបោះទីតាំងនៅលើភ្នំនោះ ។ ឪពុកខ្ញុំ និងអ្នក៦ទៀតបានបន្តដំណើរទៅកាន់ជើងភ្នំ ប៉ុន្តែ នៅខ្លោងទ្វារចូលទៅកាន់ជើងភ្នំ មានយោធាខ្មែរក្រហមមួយក្រុមរង់ចាំឆែកឆេរ និងសួររកប្រជាជនណាដែលជាអតីតអ្នករដ្ឋការ លន់ នល់ ទាហានប៉ូលីសជាដើម ដោយប្រាប់ថាអង្គការត្រូវយកទៅរៀនសូត្រនៅលើភ្នំ ហើយអ្នកដែលធ្លាប់ធ្វើការអ្វី អង្គការនឹងឲ្យធ្វើការនៅកន្លែងដើមវិញ ។ ពេលនោះ មនុស្សមួយចំនួនបានទៅចុះឈ្មោះតាមការប្រកាសនេះ ។ កំពុងតែរៀបចំដាំបាយហូប មានបុរសម្នាក់ដើរមកកាន់ឪពុកខ្ញុំហើយប្រាប់ថា «ពាក្យថាទៅរៀនសូត្រនេះមិនធម្មតាទេ ម្សិលមិញ ខ្ញុំឃើញអ្នកធាក់ស៊ីក្លូម្នាក់ បានទៅចុះឈ្មោះ ដោយកុហកថា គាត់ជាអតីតទាហាន លន់ នល់ ពាក់ស័ក្តិ៣ ។ ក្រោយពីអង្គការហៅយកទៅ ក៏បាត់ដំណឹងរហូត» ។ គ្រាន់តែឮដូច្នេះ ឪពុកខ្ញុំប្រញាប់ហូប និងស្រូតដំណើរទៅមុខទៀត ។ គាត់ទាំងអស់គ្នា បានធ្វើដំណើរមកដល់ផ្សារស្គន់ ដែលនៅទីនោះមានកម្មាភិបាលខ្មែរក្រហមរង់ចាំទទួលស្វាគមន៍ប្រជាជនជម្លៀស ហើយនិងបានប្រកាសថា «បងប្អូនណាមានស្រុកកំណើតនៅទីណា សូមបងប្អូនធ្វើដំណើរទៅស្រុកភូមិរបស់បងប្អូនចុះ ហើយកម្មាភិបាលនៅភូមិឃុំទាំងនោះ នៅចាំទទួលបងប្អូនជានិច្ច» ។

ក្រោយប្រកាសចប់ ឪពុកខ្ញុំបានបន្តដំណើរទៅមកខាងកើតតាមបណ្ដោយផ្លូវជាតិលេខ៧វិញ និងមកសម្រាកនៅសៀមបោយមួយយប់ នៅសាលារៀនជាមួយនឹងអ្នកជម្លៀសប្រហែល ១០នាក់ទៀត ។ មុននឹងសម្រាក កម្មាភិបាលស្រុកបានហៅប្រជាជនជម្លៀសទាំងអស់ទៅប្រជុំ ដើម្បីធ្វើការណែនាំ និងផ្សព្វផ្សាយពីមាគ៌ាដឹកនាំរបស់បក្ស លើកឡើងពីការតស៊ូវណ្ណៈប្រឆាំងចក្រពត្តិឆ្លងកាត់ឧបសគ្គនានាទម្រាំបានជ័យជម្នះ និងឈានមកដល់ថ្ងៃនេះ ។

នៅព្រឹកព្រលឹមស្រាង១ថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៧៥ អ្នកទាំងអស់គ្នា ហូបចុករួចរាល់ ទើបរៀបចំឥវ៉ាន់ធ្វើដំណើរឆ្ពោះមកបឹងត្រាវទឹកដីស្រុកកងមាស ខេត្តកំពង់ចាម ។ មិនយូរប៉ុន្មានក៏មកដល់វត្តបឹងត្រាវ ឪពុកខ្ញុំបានបន្តដំណើរទៅទិសខាងកើតទៅឃុំអង្គរ ដើម្បីជិះទូកដទៅភូមិកំណើត គឺភូមិកោះតូច ។ បន្ទាប់ពីធ្វើដំណើរយ៉ាងលំបាកតាំងពីភ្នំពេញមក ទីបំផុត ឪពុកខ្ញុំក៏ជួបជាបងប្រុសគាត់ និងក្មួយៗទាំង៤ បានជួបជុំនឹងសាច់ញាតិ និងគ្រួសារវិញនៅភូមិកោះតូចនេះ ។

ក្រោយពីគាត់បានមកដល់ភូមិកំណើត អ្នកទាំងអស់គ្នាបានចូលរួមក្នុងក្រុមសាមគ្គីបង្កបង្កើនផល គឺធ្វើការរួមតាមក្រុម មានមេក្រុម និងអនុក្រុមជាអ្នកចាត់ចែងប្រមូលផលបានចែកគ្នាតាមពលកម្ម ។ ការរស់នៅក្នុងសាមគ្គីមិនយូរប៉ុន្មាន អង្គការបានប្រមូលក្រុមសាមគ្គីក្នុងភូមិទាំងអស់ឲ្យទៅជាសហករណ៍ ហើយក្នុងមួយភូមិមានរោងបាយរួមពីរ ។ ចំពោះចានឆ្នាំងដែលជាកម្មសិទ្ធិរបស់យើងម្នាក់ៗក៏ត្រូវប្រមូលដាក់រួមក្នុងរោងបាយដែរ ។ ដោយឡែកឪពុករបស់ខ្ញុំត្រូវបញ្ចូលក្នុងកងចល័តយុវជន គឺជាកងពិសេសក្នុងភូមិ កន្លែងណាដែលស្មុគស្មាញ អង្គការបានចាត់តាំងឲ្យប្រធានកងចល័ត ដឹកនាំសមាជិកវាយសម្រុកឲ្យគ្រប់ផែនការអង្គការលើជាដាច់ខាត ។ ពុករស់នៅមូលដ្ឋានបានមួយរយៈ អង្គការចាត់តាំងឲ្យកងចល័តនេះចុះ ស្ដាប្រឡាយ លើកទំនប់ នៅភូមិសំបូរមាស និងពេលយប់ដើរចាប់កណ្ដុរ ការពារកុំឲ្យវាកាត់ស្រូវ ។ ចាប់តាំងពីក្លាយខ្លួនជាកងចល័ត គឺសម្រុកទាំងថ្ងៃទាំងយប់ ពេលទំនេរបានតែពេលហូប និងដេកប៉ុណ្ណោះ ។ នៅតាមភូមិឥតមានអ្វីជាកម្មសិទ្ធិទេ សូម្បីតែដំណាំដាំដុះនៅក្នុងបរិវេណផ្ទះក៏ជារបស់រួមដែរ ។ ម្យ៉ាងទៀតផ្ទះធំៗ ព្រះវិហារ កុដិ សាលារៀន អង្គការ ត្រូវការពេលណាគឺរុះរើពេលនោះ ។ នៅមូលដ្ឋានចាប់ពីខែមីនា ឆ្នាំ១៩៧៧ អង្គការបានរៀបចំឲ្យមានគ្រួសារគ្រប់ភូមិទូទាំងឃុំសរុប៦០គូ ។ ក្នុងនោះមាន ខ្មែរ៣០គូ រួមទាំងឪពុកម្ដាយរបស់ខ្ញុំ និង ខ្មែរឥស្លាម៣០គូ ។ ប៉ុន្តែក្រោយមក បងប្អូនខ្មែរឥស្លាម ទាំង៣០គូ បានត្រូវអង្គការយកទៅកម្ទេច ចោលអស់២៩គូ នៅសល់១គូ ដែលរត់រួចទៅជ្រកនៅបឹងក្បែរវត្តអូតាកួន ។ ទាក់ទងនឹងផែនការកម្ទេចខ្មែរអ៊ីស្លាម ឪពុកខ្ញុំរំឭកថា ថ្ងៃមួយនៅម៉ោង៧រសៀលនាឆ្នាំ១៩៧៧ មេភូមិបានចាត់តាំងពុកខ្ញុំ និងខ្មែរម្នាក់ទៀត រួមជាមួយនឹងបងប្អូនខ្មែរអ៊ីស្លាមប្រហែល៣០នាក់ យកចបកាប់ និងបង្គីទៅជីក រណ្ដៅដីនៅខាងជើងភូមិចម្ងាយ៥០០ម៉ែត្រ លុះដល់កន្លែងគោលដៅហើយ មេភូមិ មេកង មេក្រុម ព្រមទាំងអ្នកឡើងត្នោតមួយចំនួនចូលរួមក្នុងការជីករណ្ដៅនោះដែរ ។ នៅរសៀលម៉ោងប្រហែល៤ រណ្ដៅជិតរួចរាល់ មេភូមិបានប្រមូលមេកង មេក្រុម និងក្រុមឡើងត្នោតទៅប្រជុំសម្ងាត់ ចម្ងាយពីកន្លែងជីករណ្ដៅប្រហែល៣០ម៉ែត្រប៉ុណ្ណោះ ។ បន្ទាប់ពីអ្នកទាំងនោះត្រឡប់មកវិញ ក៏នាំគ្នាឈរនៅជុំវិញមាត់រណ្ដៅ ហើយមេភូមិបានស្រែកថា ឈប់ដាក់បង្គីចបទៅក្រោម ពុកខ្ញុំឮដូច្នេះ ក៏ដាក់ចបបង្គីទៅក្រោមដែរ រួចមេកង មេក្រុម និងពួកឡើងត្នោត នាំគ្នាលោតចុះរណ្ដៅចាប់ក្រុមបងប្អូនចាមដោយយកខ្សែចងដៃទៅក្រោយ ។ បន្ទាប់មកទៀត មេកងម្នាក់បានទៅចាប់បងប្រុសម្នាក់ដែលជាខ្មែរ តែគាត់កោរសក់ ទើបមេភូមិស្រែកពីលើរណ្ដៅថាខ្មែរទេ ឪពុកខ្ញុំឮដូច្នេះក៏ធូរទ្រូង ។ មេភូមិរូបនោះ ប្រាប់ពុកខ្ញុំ និងបងប្រុសម្នាក់នោះឲ្យយកចប និងបង្គីទៅភូមិ ។ ពុក និងបងប្រុសម្នាក់នោះក៏ប្រញាប់ប្រញាល់ប្រមូលចបបង្គីដើរត្រឡប់ទៅភូមិយ៉ាងលឿន សូម្បីងាកក្រោយក៏ឥតហ៊ានងាកផង ។ លុះមកដល់ភូមិ ឪពុកខ្ញុំក៏សំដៅទៅរោងបាយ ឃើញរទេះបួនប្រាំរង់ចាំដឹកប្រពន្ធ និងកូនតូចៗជាខ្មែរអ៊ីស្លាម គ្រាន់តែឃើញដូច្នេះ គាត់ក៏យល់ថា នេះជាផែនការកម្ទេចជនជាតិខ្មែរអ៊ីស្លាមទាំងអស់ ។ ក្រោយហូបបបររួចរាល់ ឪពុកខ្ញុំបានចុះទៅងូតទឹកទន្លេ ស្រាប់តែដល់កំពង់បានឃើញកងឈ្លបដេញចាប់ចាមម្នាក់ តែឥតចាប់បានទេ ព្រោះចាមនោះពូកែហែលទឹក ដោយហែលយ៉ាងលឿនឃ្លាតពីច្រាំងបាន៥០ម៉ែត្រ ក៏ស្រែកប្រាប់មកឈ្លបថា “ជាតិនេះយើងបែកគ្នាហើយ” ។ ក្រោយមក ចាមម្នាក់នោះក៏មក

លាក់ខ្លួននៅបឹងក្បែរវត្ត ។ រស់នៅទីនោះបាន៣ខែគណៈឃុំពាមជីកង ដែលជាកិរិយាគណៈស្រុកកងមាស បានលើកលែងទោសឲ្យគ្រួសារខ្មែរអ៊ីស្លាមនោះ ដោយសារប្តីប្រពន្ធទាំងពីរ មានជំនាញដែលជាប្រយោជន៍ដល់អង្គការ គឺប្តីពូកែមុជទឹកទន្លេយកគល់ឈើ និងប្រពន្ធជំនាញជួសមង-អួន-សំណាញ់សម្រាប់នេសាទ ។

មិនខុសពីកំលោះក្រមុំឯទៀត ឪពុកខ្ញុំ ក៏ត្រូវអង្គការចាត់ឲ្យមានគ្រួសារ គឺម្តាយខ្ញុំ ។ ក្រោយថ្ងៃរៀបការបានពីរអាទិត្យ អង្គការចាត់តាំងឲ្យឪពុកម្តាយខ្ញុំទៅចម្ការកៅស៊ូ នៅអូរអណ្តូង ។ ក្រោយហូបបាយថ្ងៃត្រង់រួច ឪពុកម្តាយខ្ញុំទៅដល់ផ្ទះរៀបរាប់ប្រាប់ជីដូនជីតាតែពួកគាត់ឥតនិយាយអ្វីទេ ព្រោះគាត់យល់ពីកង់ប្រវត្តិសាស្រ្តអង្គការចាត់តាំងហើយបើប្រឆាំងគឺស្លាប់ ។ នៅពេលរសៀលថ្ងៃដដែល ឪពុកម្តាយខ្ញុំបានចាកចេញពីផ្ទះកំណើតរួមជាមួយនឹងអីវ៉ាន់មួយអម្រែកទម្រាំមកដល់ភូមិសាច់សូ កន្លែងស្នាក់ការឃុំរសៀលទាប ហើយបងប្អូនតាមភូមិដទៃដែលអង្គការបញ្ជូនទៅចម្ការកៅស៊ូនោះ បានទៅអស់ហើយ ដូច្នេះអង្គការឲ្យអ្នកទាំងពីរស្នាក់នៅស្នាក់ការឃុំសិន រង់ចាំលើកក្រោយ ។ ឪពុកម្តាយខ្ញុំបានរស់នៅចម្ការកៅស៊ូនេះពីឆ្នាំ១៩៧៧ ដល់១៩៧៨ ។

ក្នុងអំឡុងខែកញ្ញាដល់វិច្ឆិកា ឆ្នាំ១៩៧៨ ទឹកជំនន់ធំជន់លិចភូមិនៅទូទាំងឃុំពាមជីកង អង្គការបានជម្លៀសសត្វពាហនៈ មកដាក់ទីទួលសុវត្ថិភាព នៅម្តុំស្ទឹងប្រយោល ក្នុងស្រុកព្រៃឈរ ។ ចំណែកពុកខ្ញុំ អង្គការប្រគល់គោឲ្យចំនួន១០ក្បាល ឲ្យមើលថែរក្សា តែអ្នកឯទៀតឥតច្រើនដូចគាត់ទេ ត្រង់នេះគឺគេចង់ពិនិត្យសមត្ថភាពរបស់ពុកខ្ញុំ ។ ពេលនេះពុកគិតថា ប្រហែលមិនរស់ទេ ប៉ុន្តែទឹកចិត្តនៅតែខំប្រឹងពុះពារគ្រប់ឧបសគ្គ បើខុសត្រូវយ៉ាងណាទៅតាមយថាកម្មចុះ ។ ក្នុងពេល៣ខែ ឪពុករបស់ខ្ញុំមើលថែគោទាំង១០ក្បាលបានយ៉ាងល្អ ។ លុះដល់ទឹកស្រកពីភូមិអស់ ពុកក៏វិលចូលមកភូមិវិញ ។

ចុងឆ្នាំ១៩៧៨ ពុកបានឮស្នូរកាំភ្លើងល្មើយៗ នៅឯទិសបូព៌ា ។ មិនយូរប៉ុន្មាន នៅខែធ្នូ ឆ្នាំ១៩៧៨ រណសិរ្សរំដោះជាតិកម្ពុជា ក៏បានវាយយកខេត្តកំពង់ចាម រួមទាំងស្រុកកងមាសដែរ ។ ពេលនោះក្នុងភូមិច្របូកច្របល់ សត្វពាហនៈរត់ប្រសេចប្រសាចពេញភូមិ មនុស្សម្នាចេញពីភូមិស្ងាត់ ចំណែកពុកម្តាយខ្ញុំមានកញ្ជើ ដែលគាត់យកមកពីភូមិកំណើតមកបានដាក់អីវ៉ាន់ និងបង្វេចខោអាវ ឆ្ពោះសំដៅទៅស្រុកសំបូរមាសដែលជាទិសដៅអង្គការថ្នាក់លើឲ្យទៅ ។ តែពេលនោះមានមិត្តភក្តិនៅភូមិកោះតូច បានសួរគាត់ថា «ឯងទៅណា? ទៅរកស្លាប់ ស្រុកកំណើតមិនទៅ ឬទៅរកងាប់? បន្ទាប់មក លោកទាំងពីរក៏រកទូកឆ្លងទៅកោះតូចដែលជាភូមិកំណើតវិញ ហើយក៏បានជួបជុំឪពុកម្តាយ បងប្អូនវិញដូចបំណង ។

បន្ទាប់ពីថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ របបកម្ពុជាប្រជាធិបតេយ្យបានដួលរលំទាំងស្រុង ។ ឪពុកម្តាយរបស់ខ្ញុំបានធ្វើដំណើរទៅកាន់ស្រុកកំណើតម្តាយខ្ញុំ ដែលនៅខេត្តកំពត និងបន្តរស់នៅទីនោះ រហូតដល់បច្ចុប្បន្ន ជាមួយនឹងបងប្អូនប្រុសស្រីរបស់ខ្ញុំចំនួនបួននាក់ ។ **ឌិន ដួងចន្ទ្រាកែវលក្ខិនារីរតន៍**

# ដំណឹងស្វែងរកប្អូនស្រី

ខ្ញុំបាទឈ្មោះ ហង់ ខេត ភេទប្រុស អាយុ៦០ឆ្នាំ បច្ចុប្បន្នរស់នៅភូមិជ្រៃ ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។ សូមប្រកាសស្វែងរក ហង់ សាម៉ូត ភេទស្រី ត្រូវជាប្អូនស្រីពៅ (បច្ចុប្បន្ន អាយុប្រហែល៥៤-៥៥ឆ្នាំ) មានស្រុកកំណើតនៅភូមិត្រពាំងអណ្តើក ឃុំបឹងស្រង៉ែ ស្រុកត្រាំកក់ ខេត្តតាកែវ បាត់ខ្លួននៅឆ្នាំ១៩៧៩ ពេលវៀតណាមចូល ។ កាលពីសម័យខ្មែរក្រហម សាម៉ូត ធ្វើជាកងនារីតំបន់ស្រុកត្រាំកក់ មានឪពុកឈ្មោះ ជ័យ ឃុន និងម្តាយ ឈឹម ណេង ។ មានបងប្អូនបង្កើត៧នាក់ (ប្រុស២ ស្រី៥នាក់) ។

បងប្អូនណាបានឮសូមទាក់ទងមេភូមិជ្រៃ ទូរស័ព្ទលេខ ០៩៧ ៣ ១៧៤ ៩៦៧ ឬ ទំនាក់ទំនងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា ផ្ទះលេខ៦៦, មហាវិថីព្រះសីហនុ, រាជធានីភ្នំពេញ ឬ តាមរយៈទូរស័ព្ទ ០២៣ ២១១ ៨៧៥ ។

***សូមអរគុណ!***

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់នៅក្នុងរបបខ្មែរក្រហម




មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ អេង កុកថាយ ទូរស័ព្ទលេខ ០១២ ៧៩៧ ៣៩៤ ឬ អ៊ីម៉ែល ៖ truthkokthay@dccam.org ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។




**សូមផ្តល់ព័ត៌មានដូចខាងក្រោមៈ**

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍ៈ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ ៖ ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍ៈ លេខទូរស័ព្ទ អាស័យដ្ឋាន) ។

**ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោមៈ**

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍ៈ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។




ដើម្បីយុត្តិធម៌និងការចងចាំ
ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយ ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ សហរដ្ឋអាមេរិក (USAID)
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម.៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 185ssssss, 2015 ◆ Funded by USAID.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.